# មាគ៌ាឆ្ពោះទៅរកយុត្តិធម៌

# សិទ្ធិទទួលបានយុត្តិធម៌ ដោយផ្ដោតលើ

# ជនក្រីក្រ ស្ត្រី និងជនជាតិភាគតិច

## ជំពូកទី១

## ក្របខ័ណ្ឌទ្រឹស្ដី និងវិធីសាស្ត្រ

ក្រសួងយុត្តិធម៌ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

២០០៥

# ជំពូក I
# ក្របខ័ណ្ឌទ្រឹស្តី និងវិធីសាស្ត្រ

ជំពូកនេះពន្យល់អំពីក្របខ័ណ្ឌទ្រឹស្តី និងវិធីសាស្ត្រទាំងឡាយ ព្រមទាំងឆ្លុះបញ្ចាំងអំពីគោលដៅ និងឧបករណ៍ជាវិធីសាស្ត្រ ដែលក្រុមការងារបានប្រើប្រាស់សម្រាប់ដំណើរការសិក្សាស្រាវជ្រាវ ចាប់តាំងពីដើមរហូតដល់ការសិក្សាត្រូវបានបញ្ចប់។

## ម ា តិ ក ា


១. ក្របខ័ណ្ឌទ្រឹស្តី........១១
១.១. ទ្រឹស្តីសិទ្ធិមនុស្ស........១១
១.២. គោលគំនិតស្តីពីសិទ្ធិទទួលបានយុត្តិធម៌........២៣
១.២.១. សិទ្ធិទទួលបានយុត្តិធម៌ដោយផ្អែកលើ "ការដោះស្រាយវិវាទជាក់ស្តែង"........២៣
១.២.២. សិទ្ធិទទួលបានយុត្តិធម៌ ដោយផ្អែកលើគោលការណ៍សិទ្ធិមនុស្ស........២៤
១.៣. ផ្អែកតាមទ្រឹស្តីច្បាប់ៈ ប្រព័ន្ធច្បាប់ឯកនិយម និងប្រព័ន្ធច្បាប់ពហុនិយម........៣៤
១.៤. ប្រព័ន្ធយុត្តិធម៌ផ្លូវការ និងក្រៅផ្លូវការ........៤១
១.៥. យន្តការដោះស្រាយវិវាទក្រៅតុលាការ (ADR)........៤៤
១.៦. ច្បាប់ប្រពៃណី និងច្បាប់ជនជាតិដើមភាគតិច........៤៧
២. អំពីការសិក្សាស្រាវជ្រាវ........៥០
២.១. ក្របខ័ណ្ឌស្ថាប័ន........៥០
២.២. មូលដ្ឋានវិធីសាស្ត្រនៃការសិក្សាផ្អែកលើគោលការណ៍សិទ្ធិមនុស្ស........៥២
២.៣. គោលដៅចម្បងនៃការសិក្សា និងលទ្ធផលរំពឹងទុក........៥៤
២.៤. វិធីសាស្ត្រប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ........៥៥
២.៥. វិធីសាស្ត្រ និងឧបករណ៍ដែលបានប្រើប្រាស់សម្រាប់ការសិក្សា........៥៩
៣. ទិន្នន័យដែលបានប្រើប្រាស់........៦៤
៣.១ ប្រតិទិននៃសកម្មភាពសិក្សាស្រាវជ្រាវ........៦៤
៣.២. ធនធានមនុស្ស........៦៥
៣.៣. សកម្មភាព និងលទ្ធផលជាចម្បងៗ........៦៨
៤. ដែនកំណត់នៃការសិក្សាស្រាវជ្រាវ........៧៣

# ១. ក្របខ័ណ្ឌទ្រឹស្តី

យើងនឹងបញ្ជាក់ឱ្យច្បាស់អំពីក្របខ័ណ្ឌទ្រឹស្តី និងវិធីសាស្ត្រទាំងឡាយដែលបានប្រើប្រាស់នៅក្នុងការសិក្សាស្រាវជ្រាវនេះ។ ដោយការសិក្សានេះធ្វើឡើងដោយផ្អែកលើគោលការណ៍សិទ្ធិមនុស្ស ទាំងលើគោលគំនិត និងវិធីសាស្ត្រ យើងនឹងពន្យល់ផងដែរអំពីគោលគំនិត ស្តីអំពីសិទ្ធិមនុស្សដែលត្រូវបានសន្មតនៅក្នុងការសិក្សានេះ។ យើងបានមើលឃើញផងដែរពីភាពចាំបាច់ក្នុងការបញ្ជាក់ឱ្យច្បាស់លាស់ អំពីគោលគំនិតស្តីពីសិទ្ធិទទួលបានយុត្តិធម៌ ដោយហេតុថាជាញឹកញាប់សិទ្ធិទទួលបានយុត្តិធម៌ ត្រូវបានគេសំដៅទៅលើតែការដោះស្រាយវិវាទតែប៉ុណ្ណោះ។ លើសពីនេះទៅទៀតមានទស្សនៈខ្វែងគំនិតគ្នាជាច្រើនទៀតដែលចាំបាច់ត្រូវតែបំភ្លឺបន្ថែម ដូចជា ភាពខុសគ្នារវាងប្រព័ន្ធច្បាប់ឯកនិយមនិងប្រព័ន្ធច្បាប់ពហុនិយម (legal monism and legal pluralism) ប្រព័ន្ធយុត្តិធម៌ផ្លូវការនិងក្រៅផ្លូវការ (formal and informal justice) យន្តការដោះស្រាយវិវាទក្រៅតុលាការនិងប្រព័ន្ធយុត្តិធម៌ផ្លូវការ (ADR and formal justice) ក៏ដូចជាច្បាប់ទំនៀមទំលាប់ និងច្បាប់ជនជាតិដើមភាគតិច (customary law and indigenous law) ជាដើម។ បន្ទាប់ពីមានការពន្យល់អំពីក្របខ័ណ្ឌទ្រឹស្តីនេះ យើងនឹងពន្យល់ផងដែរអំពីវិធីសាស្ត្រដែលទាក់ទងនឹងការប្រើប្រាស់គោលគំនិតទាំងឡាយ ដែលបានលើកឡើង។

## ១.១. ទ្រឹស្តីសិទ្ធិមនុស្ស

ការសិក្សានេះបានចាប់ផ្តើមដោយផ្អែកលើអង្គហេតុដែលថា ព្រះរាជាណាចក្រកម្ពុជាបានអនុម័តទទួលស្គាល់សិទ្ធិមនុស្សនៅក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន ហើយក៏បានផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស សំខាន់ៗផងដែរ[៣]។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ (ធ្វើវិសោធនកម្មនៅឆ្នាំ១៩៩៩) បានទទួលស្គាល់សិទ្ធិមនុស្សយ៉ាងទូលំទូលាយ ដូចមានចែងក្នុងមាត្រា៣១ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ព្រមទាំងកតិកាសញ្ញានិងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ(....)"។ រដ្ឋធម្មនុញ្ញនៃកម្ពុជាក៏បានចែងផងដែរ អំពីរបបប្រជាធិបតេយ្យសេរី ដោយមានការបែងចែកអំណាច។ ដូច្នេះ ប្រជាពលរដ្ឋខ្មែរគ្រប់រូបអាចទាមទារឱ្យមានការគោរពសិទ្ធិមនុស្ស នៅក្នុងបរិបទនៃរបបប្រជាធិបតេយ្យ។ ពេលនេះយើងនឹងនិយាយពីអ្វីជាខ្លឹមសារពិតប្រាកដនៃសិទ្ធិមនុស្ស និងមានលក្ខខណ្ឌសម្រាប់ការបកស្រាយ និងអនុវត្តសិទ្ធិទាំងនេះ ?

### និយមន័យ "សិទ្ធិមនុស្ស"

មានការពិភាក្សារបស់អ្នកសិក្សាជាច្រើនអំពីនិយមន័យនិងខ្លឹមសារនៃ"សិទ្ធិមនុស្ស"។ ដោយឡែកការសិក្សានេះមិនមានបំណងលើកមកនិយាយឡើងវិញ ពីការជជែកវែកញែករបស់អ្នកសិក្សាឱ្យវែងឆ្ងាយនោះទេ គឺគ្រាន់តែបញ្ជាក់បំភ្លឺអំពីខ្លឹមសារនៃគោលគំនិត ដែលបានយកមកប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការសិក្សានេះប៉ុណ្ណោះ។ តាមទស្សនៈទំនើបរបស់លោកខាងលិច

[៣] សូមមើលឧបសម្ព័ន្ធទី១.១. ស្តីពីក្របខ័ណ្ឌច្បាប់ស្តីពីសិទ្ធិទទួលបានយុត្តិធម៌ និងសិទ្ធិមនុស្សនៅកម្ពុជា។ សូមមើលមាត្រាច្បាប់ទាក់ទងនឹងជំពូកនេះនៅក្នុងឧបសម្ព័ន្ធ១.១។

មានចរន្តបីផ្សេងគ្នា[៤] ដែលបានព្យាយាមកំណត់និយមន័យសិទ្ធិមនុស្ស គឺៈ (១).តាមទ្រឹស្តីបែបធម្មជាតិនិយម (iusnaturalist approach) (២).តាមទ្រឹស្តីនៃការយល់ដឹងបែបវិជ្ជមាននិយម (positivist understanding) និង (៣).ទ្រឹស្តីដែលឈរលើមូលដ្ឋានប្រវត្តិសាស្ត្រ (historic account)។ តាមទ្រឹស្តីអ្នកធម្មជាតិនិយម (iusnaturalist approach) ដូចដែលបានអនុម័តដោយធម្មនុញ្ញអង្គការសហប្រជាជាតិ បានកំណត់និយមន័យសិទ្ធិមនុស្សថាជា "អ្វីដែលមាននៅជាប់" ឬ "នៅជាស្ថិតស្ថេរ" (inherent or immanent) ដោយឯកឯងជាមួយមនុស្ស។ មានន័យថា សិទ្ធិមនុស្សមានតាំងពីមុនដែលមានការទទួលស្គាល់ដោយច្បាប់ទៅទៀត។ ជំហររបស់អ្នកធម្មជាតិនិយមបានគាំទ្រ ដល់ការប្តឹងតវ៉ាខាងសីលធម៌ ដែលសមស្របអាចបង្កើតបានជាសិទ្ធិ ទោះបីជាមិនមានការទទួលស្គាល់ពីរដ្ឋក៏ដោយ។ ម្យ៉ាងទៀត ទ្រឹស្តីនៃការយល់ដឹងបែបវិជ្ជមាននិយម ប្រកាន់ជំហរថាមានតែការប្តឹងតវ៉ាខាងសីលធម៌ ដែលសមស្របទាំងឡាយណាដែលច្បាប់ទទួលស្គាល់ប៉ុណ្ណោះ (អាចជាច្បាប់ជាតិ ច្បាប់អន្តរជាតិ ឬច្បាប់ប្រពៃណី) ដែលអាចជាមូលដ្ឋាននៃសិទ្ធិមនុស្សបាន។ តាមទស្សនៈនេះ ត្រូវមានការសម្រុះសម្រួលដែលត្រូវធ្វើឡើងដោយស្ថាប័នស្របច្បាប់ទាំងឡាយ (ដូចជារដ្ឋ សហគមន៍អន្តរជាតិ) ដើម្បីផ្លាស់ប្តូរការទាមទារតាមផ្លូវសីលធម៌នោះឱ្យទៅជាសិទ្ធិ ហើយដោយសារការសម្រុះសម្រួលនេះហើយ ដែលអាចធ្វើឱ្យសិទ្ធិទាំងនោះត្រូវបានគេគោរព[៥]។ រីឯទ្រឹស្តីដែលឈរលើមូលដ្ឋានប្រវត្តិសាស្ត្រវិញ អះអាងថា "សិទ្ធិមនុស្ស គឺទស្សនៈធម្មានិយាម (ជាអ្វីដែលគួរតែកើតមាន) នៃសេចក្តីត្រូវការទាំងឡាយ ដែលត្រូវបានគេចាត់ទុកថាជាសក្តានុពលសម្រាប់ការអភិវឌ្ឍមនុស្សទាំងជាបុគ្គល ជាក្រុម និងជាក្រុមប្រជាពលរដ្ឋ[៦] "។ តាមទ្រឹស្តីនេះ សិទ្ធិមនុស្សគឺជាការទទួលស្គាល់ដោយច្បាប់ នូវអ្វីដែលជាតម្រូវការ ដើម្បីបំពេញតាម "សេចក្តីត្រូវការជាក់ស្តែង" របស់ប្រជាពលរដ្ឋ។ ពាក្យថា *សេចក្តីត្រូវការជាក់ស្តែង ឬសេចក្តីត្រូវការសង្គម* ឬ *សេចក្តីត្រូវការ* សំដៅលើគម្លាតរវាងស្ថានភាពបច្ចុប្បន្នរបស់បុគ្គល និងក្រុមទាំងឡាយ ដែលរារាំងដល់ការអភិវឌ្ឍមនុស្សរបស់ពួកគេ ជាមួយនឹងលទ្ធភាពសម្រាប់ការអភិវឌ្ឍជាលក្ខណៈបុគ្គលម្នាក់ៗ ឬជាក្រុមនៅក្នុងទេសកាលប្រវត្តិសាស្ត្រនិមួយៗ។ គម្លាតនេះត្រូវបានចាត់ទុកជា "សក្តានុពល" និងសម្រាប់យកទៅធ្វើការពិចារណាលើលក្ខខណ្ឌ ដែលអំណោយផលសម្រាប់ការអភិវឌ្ឍ។ ក្នុងន័យនេះពាក្យថា "សេចក្តីត្រូវការ" គឺរួមបញ្ចូលទាំងអ្វីៗដែលជា "សក្តានុពល" ផងដែរ។ សិទ្ធិមនុស្សត្រូវបានគេឱ្យ

---

៤ សម្រាប់ការពន្យល់អំពីចរន្តនៃអ្នកធម្មជាតិនិយម និងអ្នកវិជ្ជមាននិយម (iusnaturalist and positivist) សូមមើល ៖ Rey Pérez: José (2004): 'A Legal view on basic income". Barcelona: Universal Forum of Cultures, 2004. (Available at: http://www.etes.ucl.ac.be/BIEN/Files/Papers/2004ReyPerez2.pdf); Dworkin, Ronald (1997): *Taking Rights Seriously*. London: Duckwoth; Peces-Barba Martinez, G. (1995): *Curso de Derechos Fundamentales. Teoria General*. Madrid: Universidad Carlos III។ សម្រាប់ការពន្យល់អំពី ចរន្តដែលឈរលើមូលដ្ឋានប្រវត្តិសាស្ត្រ (historic approach) សូមមើល ៖ Baratta, Alessandro (1991): "Requisitos Mínimos para el Respeto de los Derechos Humanos en la Ley Penal", In *Justicia y Derechos Humanos*. Lima: CEAS, and (1992) "Derechos Humanos: Entre violencia estructural y violencia pena. Por la pacificación de los conflictos violentos", in: *Justicia y derechos Humanos*. Lima: CEAS; García-Mendez (1990), Emilio: *Ser niño en América Latina. De las necesidades a los derechos*. Argentina: UNICRI, Nr. 42, p. 11-26.

៥ សូមមើល ៖ Rey Pérez, 2004 "We can define rights as those justified moral claims that are recognized by the positive law and constitute a system inside the positive law (Peces-Barba, 1995). (...) When we follow the ideas of the methodological positivism, as I will do here, the step from the moral values to the institutions is not automatic. Although we can justify some moral claims, those moral claims are not rights yet. It is necessary that some positive laws include them. The mediation of institutions is needed. Moral claims can exist without being included in the law. In that case, we would have moral claims that try to be legal rights, but they are not that yet. They are incomplete rights." Rey Pérez, 2004.

៦ បកប្រែមកពី ៖ "[L]os derechos humanos son la proyección normativa, en términos de deber ser, de aquellas necesidades que son potencialidades de desarrollo de los individuos, de los grupos, de los pueblos". Baratta Alessandro (1995): "Democracia y Derechos del Niño" In Bianchi, C. (comp.): *El derecho y los chicos*. Buenos Aires: Espacio Editorial, p. 39-40. Baratta's theory connects human rights, social needs, development, and democracy.

និយមន័យថា ជាការធានាដោយច្បាប់ ដែលអាចផ្លាស់ប្តូរពី "សក្តានុពលនៃការអភិវឌ្ឍមនុស្ស" ឱ្យក្លាយទៅជា "ការអភិវឌ្ឍជាក់ស្តែង"។ យើងរកឃើញទស្សនៈវិទ្យានេះនៅក្នុង "គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍" ដែលអនុម័តដោយអង្គការសហប្រជាជាតិនៅឆ្នាំ២០០០។ គោលដៅទាំងនេះ បង្ហាញពីសក្តានុពលនៃការអភិវឌ្ឍមនុស្ស នៅក្នុងពេលបច្ចុប្បន្ននៃ ប្រវត្តិសាស្ត្រ ដែលជាសក្តានុពលសម្រាប់ពិចារណាអំពីធនធានដែលមានរបស់សកលលោក ហើយក៏ជា (ដូច្នេះ) សក្តានុពលសម្រាប់ការពិចារណាផងដែរចំពោះសមត្ថភាពរបស់សកលលោក ក្នុងការឆ្លើយតបចំពោះតម្រូវការបន្ទាន់ៗរបស់មនុស្សនៅក្នុងសង្គម[៧]។

ការសិក្សាស្រាវជ្រាវនេះបានសន្និដ្ឋានថា រាល់គំនិតនិងទស្សនៈទាំងអស់ ដែលបានរៀបរាប់មកខាងលើនេះ អាចរួមចំណែកដើម្បីឱ្យនិយមន័យពេញលេញ និងទូលំទូលាយមួយស្តីពីសិទ្ធិមនុស្ស ដូចនេះរាល់គំនិតនីមួយៗ យើងអាចចាត់ទុកថាជាការបំពេញបន្ថែមគ្នាទៅវិញទៅមក។ គំនិតនីមួយៗ បានសង្កត់ធ្ងន់អំពីចំណុចសំខាន់នៃគោលការណ៍គ្រឹះនៃសិទ្ធិមនុស្ស។ ទស្សនៈដែលឈរលើមូលដ្ឋានប្រវត្តិសាស្ត្រ បានគូសបញ្ជាក់អំពី *សេចក្តីត្រូវការរបស់សង្គម* ថាជាសក្តានុពលសម្រាប់ការអភិវឌ្ឍមនុស្ស ដែលជាប្រភពនៃខ្លឹមសារនិងទម្រង់នៃសិទ្ធិមនុស្ស។ ចំពោះទស្សនៈបែបធម្មជាតិនិយមវិញ សំដៅលើយុត្តិកម្មតាមផ្លូវសីលធម៌នៃសិទ្ធិ។ រីឯទស្សនៈបែបវិជ្ជមាននិយមវិញ គឺនិយាយអំពីការទទួលស្គាល់សិទ្ធិមនុស្សដោយច្បាប់ ហើយដែលអាចផ្លាស់ប្តូរការទាមទារតាមផ្លូវសីលធម៌ និងតម្រូវការសង្គមមួយចំនួន ឱ្យទៅជាសិទ្ធិស្របច្បាប់ ដែលអាចយកទៅអនុវត្តបាន[៨]។

និយមន័យទូលំទូលាយស្តីពីសិទ្ធិមនុស្ស

និយមន័យទូលំទូលាយនៃសិទ្ធិមនុស្ស ត្រូវបានពិចារណាទៅលើទិដ្ឋភាពឬធាតុផ្សំបី ដែលមានដូចជា: ក-មានការទទួលស្គាល់ដោយច្បាប់ (positivist approach) ខ-យុត្តិកម្មតាមផ្លូវសីលធម៌ (iusnaturalist approach) គ-តម្រូវការសង្គម (historic approach)។ សម្រាប់ការសិក្សានេះ សិទ្ធិមនុស្សគឺសំដៅលើរាល់សិទ្ធិទាំងឡាយណា ដែលទទួលស្គាល់ដោយច្បាប់ជាតិនិងអន្តរជាតិ មានន័យថាជាសិទ្ធិទាំងឡាយដែលអាចអនុវត្តបាន។ ការនេះរួមបញ្ចូលទាំងការទាមទារតាមផ្លូវសីលធម៌ដែលសង្គមទទួលស្គាល់ និងការស្វះស្វែងបំពេញនូវសេចក្តីត្រូវការរបស់សង្គម ដោយពិចារណាទៅលើសក្តានុពលនៃការអភិវឌ្ឍមនុស្សនៅគ្រប់បរិបទនៃសង្គមនៃទេសកាលប្រវត្តិសាស្ត្រនីមួយៗ។

**តារាងស្តីពីទិដ្ឋភាពនៃនិយមន័យទូលាយស្តីពីសិទ្ធិមនុស្ស**

| គោលគំនិត (Approach) | ឈរលើមូលដ្ឋានប្រវត្តិសាស្ត្រ (Historic) | បែបធម្មជាតិនិយម (Iusnaturalist) | បែបវិជ្ជមាននិយម (Positivist) |
|---|---|---|---|
| និយមន័យ សិទ្ធិមនុស្ស | សិទ្ធិមនុស្សជាទស្សនៈធម្មានិយាម (ជាអ្វីដែលគួរតែកើតមាន) នៃសេចក្តីត្រូវការសង្គម ដែលត្រូវបានគេយល់ថាជាសក្តានុពល សម្រាប់ការអភិវឌ្ឍមនុស្ស នៅក្នុងបរិបទ និងទេសកាលប្រវត្តិសាស្ត្រនិមួយៗ។ | សិទ្ធិមនុស្សរាប់បញ្ចូលទាំងការទាមទារតាមផ្លូវសីលធម៌ ដែលមានហេតុផល។ សិទ្ធិមនុស្សជាអ្វីដែលមាន នៅជាប់នឹងមនុស្សពីកំណើត តាំងពីមុនពេលមានច្បាប់ចែងអំពីវាទៅទៀត។ | សិទ្ធិមនុស្សគឺជាការទាមទារទាំងឡាយដែលទទួលស្គាល់ដោយច្បាប់ និងអាចអនុវត្តបាន។ រដ្ឋមានកាតព្វកិច្ចត្រូវគោរព និងផ្តល់នូវសិទ្ធិទាំងនេះ។ |

៧ យើងនឹងនិយាយបន្ថែមពីប្រធានបទនេះនៅខាងមុខទៀត។

៨ ជាការពិតណាស់ មានភាពចំរូងចំរាសគ្នាជាច្រើនរវាងអ្នកប្រកាន់ទ្រឹស្តីបែបធម្មជាតិនិយម និងអ្នកដែលប្រកាន់ទ្រឹស្តីបែបវិជ្ជមាននិយម លើបញ្ហាថាតើដើម្បីឱ្យសិទ្ធិមនុស្សអាចត្រូវបានគេអនុវត្តតាមផ្លូវតុលាការបាន ចាំបាច់ត្រូវតែមានការទទួលស្គាល់ជាផ្លូវការនៅក្នុងច្បាប់ឬយ៉ាងណា?។ យើងមិនចាំបាច់ខ្វាយខ្វល់អំពីការពិភាក្សាយ៉ាងចំរូងចំរាសនេះឡើយ តែទោះជាយ៉ាងណាដូចដែលបាននិយាយក្នុងអត្ថបទខាងលើ នៅកម្ពុជាបានទទួលស្គាល់នូវសិទ្ធិយ៉ាងទូលាយនៅក្នុងរដ្ឋធម្មនុញ្ញ ដូចនេះតុលាការកម្ពុជាត្រូវបានផ្តល់អំណាចដើម្បីអនុវត្តសិទ្ធិទាំងនោះ។ លើសពីនេះទៀត សិទ្ធិទាំងនេះគឺជាផ្នែកមួយនៃច្បាប់កំពូលរបស់ជាតិ។

| | | | |
|---|---|---|---|
| ធាតុផ្សំនៃសិទ្ធិមនុស្ស យោងតាមគោលគំនិតនិមួយៗ | **តម្រូវការសង្គម** មូលដ្ឋានតថភាព បង្កើតឱ្យមានមាតិកាជាខ្លឹមសារ នៃសិទ្ធិមនុស្សទៅតាមទេសកាលនីមួយៗ | **យុត្តិកម្មតាមផ្លូវសីលធម៌** មូលដ្ឋានសីលធម៌ នាំឱ្យការទាមទារនានា បានទទួលយុត្តិកម្ម | **ទទួលស្គាល់ដោយច្បាប់** មូលដ្ឋានស្ថាប័ន ដែលនាំឱ្យមានការអនុវត្តសិទ្ធិនានា |
| ការរួមចំណែកនៃគោលគំនិតនីមួយៗ ក្នុងចក្ខុវិស័យដ៏ទូលំទូលាយមួយនៃសិទ្ធិមនុស្ស | សិទ្ធិមនុស្សគួរតែខិតខំធានាបំពេញឱ្យបាននូវសេចក្តីត្រូវការសង្គម។ សិទ្ធិមនុស្សគួរតែត្រូវបានគេអនុវត្តដោយពិចារណាទៅលើលទ្ធភាពជាប្រវត្តិសាស្ត្រក្នុងការបំពេញនូវតម្រូវការសង្គមទាំងនោះ។ | សិទ្ធិមនុស្សគួរឆ្លុះបញ្ចាំង អំពីតម្លៃខាងវប្បធម៌។ យុត្តិកម្មខាងផ្លូវសីលធម៌ អាចជួយដល់ការបកស្រាយ និងទទួលស្គាល់សិទ្ធិកាន់តែច្រើនឡើង។ | ការទទួលស្គាល់ដោយច្បាប់ផ្លាស់ប្តូរការទាមទារតាម ផ្លូវសីលធម៌ និងតម្រូវការសង្គមឱ្យទៅជាសិទ្ធិ ដែលត្រូវបានគេអនុវត្ត។ ស្តង់ដា (និយាម) នៃច្បាប់ គឺជាមូលដ្ឋានជាអប្បបរមានៃការទាមទារ។ |

សិទ្ធិដែលទទួលស្គាល់ដោយច្បាប់

ការទទួលស្គាល់ដោយច្បាប់នូវសិទ្ធិមនុស្ស ជាមូលដ្ឋានដែលមិនអាចបដិសេធបាន សម្រាប់ការទាមទារទាំងឡាយដែលផ្អែកលើសិទ្ធិទាំងនោះ។ ប្រភពនៃច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស មានដូចជាច្បាប់អនុសញ្ញា ច្បាប់ទំនៀមទំលាប់អន្តរជាតិ សេចក្តីសម្រេចរបស់ស្ថាប័នដែលមានអំណាចយុត្តាធិការអន្តរជាតិ និងគោលការណ៍ទូទៅនៃសិទ្ធិមនុស្ស។ ច្បាប់អនុសញ្ញារួមមានឧបករណ៍អន្តរជាតិនានាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ដូចជាសេចក្តីប្រកាស អនុសញ្ញា សន្ធិសញ្ញា និងពិធីសារផ្សេងៗ។ ច្បាប់ទំនៀមទំលាប់អន្តរជាតិ រួមមានការអនុវត្តជាអន្តរជាតិទាំងឡាយ ដែលត្រូវបានអនុវត្តជាបន្តបន្ទាប់ក្នុងរយៈពេលយូរ ហើយក្លាយជាវិធានចាប់បង្ខំសម្រាប់មនុស្សគ្រប់រូប (*erga ommnes*) និងបន្ទាប់មកត្រូវបានគេអនុវត្តជាច្បាប់។ គោលការណ៍ទូទៅទាំងនេះនាំឱ្យមានការយល់ដឹងជាទូទៅ អំពីសិទ្ធិមនុស្សស្របទៅតាមនិយាមអន្តរជាតិ ដែលមានការវិវត្តន៍ជាបន្តបន្ទាប់មក។ ដោយព្រះរាជាណាចក្រកម្ពុជា បានប្តេជ្ញាយ៉ាងមុតមាំថានឹងគោរពតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដូចនេះកម្ពុជាមានកាតព្វកិច្ចអនុវត្តនូវសន្ធិសញ្ញាអន្តរជាតិនានា ដែលខ្លួនបានឱ្យសច្ចាប័ន ព្រមទាំងច្បាប់ទំនៀមទំលាប់អន្តរជាតិ និងនិយាមអន្តរជាតិទាំងឡាយបង្កើតឡើងដោយគោលការណ៍ទូទៅនៃសិទ្ធិមនុស្ស។

យុត្តិកម្មតាមផ្លូវសីលធម៌

យុត្តិកម្មតាមផ្លូវសីលធម៌រាប់បញ្ចូលទាំងតម្លៃវប្បធម៌ ដែលអាចមានប្រភពជាច្រើនដូចជាតម្លៃខាងសាសនា យុត្តិកម្មដែលបានកំណត់តាមភាពចាំបាច់ ឬសេចក្តីត្រូវការសង្គមជាដើម។ ទោះក្នុងករណីណាក៏ដោយ យុត្តិកម្មតាមផ្លូវសីលធម៌នៃការទាមទារមួយ បានផ្តល់ជាមូលដ្ឋានខាងសីលធម៌ សម្រាប់ការទទួលស្គាល់ដោយស្របច្បាប់នូវសិទ្ធិថ្មីៗ ការបកស្រាយក៏ដូចជាសទ្ធិដែលបានច្បាប់ទទួលស្គាល់រួចហើយដែរ។ យុត្តិកម្មនៃសិទ្ធិមនុស្ស អាចត្រូវបានគេបញ្ជាក់យ៉ាងច្បាស់តាមរយៈការសិក្សាស្រាវជ្រាវរបស់អ្នកមានវិជ្ជាជ្រៅជ្រះ (អ្នកប្រាជ្ញ) តែការគោរពអនុវត្ត និងផ្តល់នូវសិទ្ធិទាំងនេះ គឺទាមទារឱ្យមានការចូលរួមពីសំណាក់មន្ត្រីផ្តល់សេវាយុត្តិធម៌ (ចៅក្រម មេធាវី អ្នកសម្របសម្រួល អាជ្ញាកណ្តាល អាជ្ញាធរជនជាតិដើមភាគតិច ។ល។) ផង និងការចូលរួមពីសំណាក់អ្នករកសេវាយុត្តធម៌ពីប្រព័ន្ធយុត្តិធម៌ទាំងនេះផង ដើម្បីឱ្យពួកគេជឿជាក់ថាការទាមទាររបស់គេពិតជាមានការឆ្លើយតបតាមទម្រង់ណាមួយមិនខាន។ ជាទូទៅយុត្តិកម្មតាមផ្លូវសីលធម៌នៃការទាមទារ ត្រូវបានរៀនសូត្រតៗគ្នា តាមរយៈដំណើរប្រព្រឹត្តិទៅនៅក្នុងសង្គមប្រចាំថ្ងៃជាធម្មតា (មានដូចជាសាលារៀន សាសនា ការអប់រំដែលទទួលបានចាប់តាំងអំពីក្មេងៗមក ។ល។) ដែលមានបង្កប់នៅជាមួយនឹងតម្លៃសាសនា វប្បធម៌ ហើយដែលទៅពេលខ្លះឆ្លុះបញ្ចាំងនៅក្នុងបទដ្ឋាន

ច្បាប់ និងការអនុវត្តនានាផងដែរ។ "វប្បធម៌ដែលមានលក្ខណៈច្បាប់" នៅក្នុងសង្គមបញ្ជាក់យ៉ាងច្បាស់អំពីតម្លៃខាងវប្បធម៌ដែលធ្វើយុត្តិកម្មដល់ការទាមទារដោយស្របច្បាប់ ក៏ដូចជាគុណតម្លៃវាទទួលហិតនៅពីក្រោយការអនុវត្តច្បាប់ជាក់ស្តែង ហើយដែលពេលខ្លះមានភាពតានតឹងរវាងគ្នាទៅវិញ។ ដោយមានការប្រែប្រួលគុណតម្លៃខាងសីលធម៌និងវប្បធម៌ នាំឱ្យក្រុមគោលដៅផ្សេងៗអាចធ្វើយុត្តិកម្មលើការទាមទារស្របច្បាប់របស់ពួកគេរៀងៗខ្លួន ដោយផ្អែកលើមូលដ្ឋាននៃទស្សនៈផ្សេងៗពីគ្នាខាងវប្បធម៌ និងសីលធម៌។

តម្រូវការសង្គមជាកត្តាចង្អុលបង្ហាញនៃសក្តានុពលសម្រាប់ការអភិវឌ្ឍមនុស្ស

តម្រូវការសង្គម ត្រូវបានគេមើលឃើញថាជាកត្តាចង្អុលបង្ហាញនៃសក្តានុពលសម្រាប់ការអភិវឌ្ឍមនុស្ស ដោយវាជាកត្តារួមផ្សំនៃសិទ្ធិមនុស្សផង និងជាកត្តានាំឱ្យសិទ្ធិមនុស្សមានអត្ថិភាពផង ដែលកត្តាចាំបាច់ដើម្បីសម្រេចឱ្យបាននូវលក្ខខណ្ឌជាអប្បបរមា ដែលអាចទទួលយកបានសម្រាប់ការរស់នៅផង។ តាមន័យទូលាយ តម្រូវការសង្គមជាប្រភពចម្បងសម្រាប់ការយុត្តិកម្មនៃការទាមទារស្របច្បាប់ដោយឈរលើមូលដ្ឋានសិទ្ធិមនុស្ស ដូច្នេះវាក៏ជាយុត្តិកម្មដ៏ចម្បងសម្រាប់ការបកស្រាយការអនុវត្ត និងការអភិវឌ្ឍសិទ្ធិមនុស្សដែរ។ អង្គការសហប្រជាជាតិបានខិតខំប្រឹងប្រែង ក្នុងការវាស់វែងលទ្ធភាពភាពសម្រាប់អភិវឌ្ឍន៍មនុស្ស ដើម្បីបំពេញតម្រូវការសង្គមដ៏បន្ទាន់បំផុតនៅលើពិភពលោក ដែលជាលទ្ធផលគឺយើងមានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សហប្រជាជាតិ[៩]។ គោលដៅទាំងនេះអាចធ្វើទៅបាន ពីព្រោះគេបានពិចារណាអំពីធនធាន ដែលមានស្រាប់រួចហើយ។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ជាតំណាងឱ្យទស្សនៈជាធម្មានិយាម ពោលគឺជាអ្វីដែលគួរតែកើតមានដោយហេតុថាតម្រូវការសង្គមត្រូវបានគេចាត់ទុកជាកត្តាចង្អុលបង្ហាញមួយអំពីសក្តានុពលសម្រាប់ការអភិវឌ្ឍមនុស្ស។ ក្នុងន័យនេះ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍បានផ្តល់ជាមាតិកាជាខ្លឹមសារសម្រាប់សិទ្ធិសង្គម ដែលជាសិទ្ធិដ៏ចាំបាច់។ សមិទ្ធិផលនៃគោលដៅទាំងនេះ ពឹងផ្អែកទាំងស្រុងទៅលើធនធានដែលមានស្រាប់របស់សកលលោក។ ក្នុងន័យនេះ សកលភាពនៃសិទ្ធិមនុស្សត្រូវបានគេមើលឃើញថា តែពីផ្នែកខាងអ្នកមានផលប្រយោជន៍ពីសិទ្ធិនោះប៉ុណ្ណោះទេ តែគេក៏មើលឃើញផងដែរពីខាងអ្នកដែលមានកាតព្វកិច្ចធានា និងផ្តល់សិទ្ធិទាំងនោះ។ ព្រះរាជាណាចក្រកម្ពុជា បានអនុម័តទទួលយកគោលដៅអភិវឌ្ឍន៍សហស្សវត្សន៍ទាំងនេះ ព្រមទាំងបានដាក់ចេញនូវយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររួចហើយដែរនៅឆ្នាំ២០០២ ដែលរួមបញ្ចូលចំណែកដែលជាខ្លឹមសារនៃសិទ្ធិសង្គមទាំងឡាយ ដែលទទួលស្គាល់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា នាពេលបច្ចុប្បន្ននេះ[១០]។

គោលគំនិតស្តីអំពី *សេចក្តីត្រូវការសង្គម* គឺកត្តាដ៏ចាំបាច់ដើម្បីដោះស្រាយភាពប្រទាក់គ្នានៃការឱ្យនិយមន័យស្តីពី *សិទ្ធិមនុស្ស* ដោយហេតុថានិយមន័យសិទ្ធិមនុស្សច្រើន ជាគោលការណ៍ដែលមានលក្ខណៈទូលាយ និងអរូបី។ ដូចដែលបានរៀបរាប់មកខាងលើហើយថា សិទ្ធិមនុស្សត្រូវតែយកទៅអនុវត្តក្នុងស្ថានភាពជាក់ស្តែង ដូចនេះវាទាមទារឱ្យមានការបកស្រាយ។ និយមន័យ និងភាពជំពាក់ជំពិននៃគោលគំនិត ស្តីពី "សេចក្តីថ្លៃថ្នូររបស់មនុស្ស" "ការប្រព្រឹត្តិដោយយុត្តិធម៌និងមនុស្សធម៌" "ស្ថានភាពរស់នៅសមរម្យ" រួមទាំងសិទ្ធិជាក់លាក់មួយចំនួនដូចជា សិទ្ធិទទួលបានការគាំពារសុខភាព សិទ្ធិទទួលបានការអប់រំ សិទ្ធិទទួលបានលំនៅដ្ឋាន សិទ្ធិទទួលបានការងារធ្វើ ក៏ដូចជាសិទ្ធដទៃៗទៀត គឺវាអាស្រ័យលើៈ ក). បរិបទនៃវប្បធម៌សង្គមដែលសិទ្ធិទាំងនោះ ត្រូវបានគេគោរព និង ខ). លទ្ធភាពនានាដែលមានស្រាប់ សម្រាប់ការអភិវឌ្ឍមនុស្សនៅក្នុងទេសកាលណាមួយនៃប្រវត្តិសាស្ត្រ។

---

៩ គោលដៅទាំង៨ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សហប្រជាជាតិ ដែលត្រូវសម្រេចឱ្យបានមុនឆ្នាំ២០១៥ មានៈ ទី១). លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លាន ទី២). សម្រេចឱ្យបានជាសកលនូវការអប់រំមូលដ្ឋានកម្រិតបឋមសិក្សា ទី៣). លើកកម្ពស់សមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី ទី៤). កាត់បន្ថយអត្រាមរណៈភាពកុមារ ទី៥). លើកកម្ពស់សុខភាពមាតា ទី៦). ប្រយុទ្ធមេរោគអេដស៍/ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺដទៃៗទៀត ទី៧) ធានានិរន្តរភាពបរិស្ថាន និងទី៨). បង្កើតភាពជាដៃគូជាសកលសម្រាប់ការអភិវឌ្ឍ។ សូមមើលនៅគេហទំព័រ : http://www.un.org/milleniumgoals/.

១០ សូមមើលឯកសារទាំងស្រុងនៅក្នុងគេហទំព័ររបស់រាជរដ្ឋាភិបាលកម្ពុជា : http://www.cambodia.gov.kh/unisql1/egov/english/home.view.html.

ឧទាហរណ៍ ការគោរព "សិទ្ធិទទួលបានការគាំពារខាងសុខភាព" គឺអាស្រ័យលើទស្សនៈស្តីពីសុខភាព និងភាពមានជំងឺនៅក្នុងសង្គមជាក់លាក់ណាមួយ ព្រមទាំងអត្ថិភាពនៃយន្តការ ដើម្បីគាំពារសុខមាលភាពរបស់ប្រជាពលរដ្ឋ។ តាមទស្សនៈភាគច្រើននៃវប្បធម៌របស់លោកខាងលិច ទស្សនៈអំពីសុខភាពគឺជាប់ពាក់ព័ន្ធទៅនឹងសុខមាលភាពខាងរាងកាយ និងខាងផ្លូវចិត្ត។ តែដោយឡែក ទស្សនៈរបស់វប្បធម៌នៃប្រទេសនៅអាស៊ី និងឥណ្ឌា-អាមេរិកមួយចំនួនយល់ថា សុខភាពក៏អាចសំដៅលើសមតាខាងស្មារតីដែរ។ ដូច្នេះការបំពេញតាមសេចក្តីត្រូវការរបស់សង្គម ក្នុងវិស័យសុខមាលភាពនៅក្នុងសង្គមអាស៊ី ឬឥណ្ឌា-អាមេរិក អាចតម្រូវឱ្យមានការឆ្លើយតបធំទូលាយជាងនៅក្នុងសង្គមលោកខាងលិច រួមទាំងការទទួលស្គាល់ ឬការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន និងបុគ្គលម្នាក់ៗ (ដូចជាគ្រូប) ដែលពាក់ព័ន្ធនឹងការផ្តល់សេវាសុខភាពនេះក្នុងទម្រង់ដ៏ទូលំទូលាយមួយ។ ទាក់ទងនឹងលទ្ធភាពដែលមាននាបច្ចុប្បន្ន ក្នុងការឆ្លើយតបចំពោះតម្រូវការសង្គម យើងត្រូវតែពិចារណាអំពីកម្រិតនៃការអភិវឌ្ឍខាងឱសថសាស្ត្រនៅក្នុងពិភពលោក។ បើសិនជាឱសថត្រូវបានគេអភិវឌ្ឍ និងរកឃើញអាចព្យាបាលជំងឺមរណៈមួយចំនួនពីមុននោះ សិទ្ធិខាងសុខមាលភាពក៏នឹងដើរតាមការជឿនលឿន និងអភិវឌ្ឍន៍ខាងឱសថសាស្ត្រនេះដែរ។ សម្រាប់សិទ្ធិផ្សេងៗទៀតក៏ដូចគ្នានេះដែរ។ ឧទាហរណ៍ នៅក្នុងសង្គមពហុវប្បធម៌មួយ ការធានានូវសិទ្ធិទទួលបានការអប់រំតម្រូវឱ្យគោរព និងពិចារណាទៅលើវប្បធម៌ និងភាសាផ្សេងៗរបស់ក្រុមគោលដៅ។ ឬក្នុងករណីដែលមានមានអត្រាស្ត្រីមិនចេះអក្សរខ្ពស់ ចាំបាច់ត្រូវមានការផ្តល់ឱកាស និងលើកទឹកចិត្តឱ្យបានសមរម្យដើម្បីលើកកំពស់សមភាពយេនឌ័រក្នុងបរិបទនៃសិទ្ធិទទួលបានការអប់រំ។ ទ្រឹស្តីដែលឈរលើមូលដ្ឋានប្រវត្តិសាស្ត្រ បានពិចារណាលើទំនាក់ទំនងនៅក្នុងសង្គម និងការប្រែប្រួលខាងគុណតម្លៃនានា។ ការប្រែប្រួលនៃសេចក្តីត្រូវការសង្គម អាចកើតឡើងតាមរូបភាពនៃសិទ្ធិមនុស្ស ដូចនេះហើយចាំបាច់ត្រូវតែបំពេញនូវសេចក្តីត្រូវការសង្គមទាំងនោះដោយខានពុំបាន។

*សិទ្ធិ ករណីយកិច្ច និងការធានា*

ការសិក្សានេះបានសន្មតថា ទ្រឹស្តីស្តីពីសិទ្ធិមនុស្ស ក៏តម្រូវឱ្យមានគោលគំនិតស្តីពីតួនាទី និងការធានាផងដែរ[១១]។ អត្ថិភាពពិតប្រាកដនៃសិទ្ធិ ត្រូវបានបញ្ជាក់តាមអត្ថិភាពនៃតួនាទី ដែលមានសហទំនាក់ទំនងគ្នា ដើម្បីឱ្យសិទ្ធិទាំងនោះត្រូវបានធានា។ ការធានាសំដៅលើយន្តការ ដែលអាចធានាឱ្យបាននូវការគោរពសិទ្ធិទាំងនេះ។

អ្នកដែលមានផលប្រយោជន៍ពីសិទ្ធិ អាចជាបុគ្គល ឬក្រុមមនុស្ស ដូចជាកុមារ ស្ត្រី ជនជាតិភាគតិច។ល។ ក្រុមប្រជាពលរដ្ឋ ឬមនុស្សជាតិទាំងអស់។ តែមានតែលើបុគ្គលមួយចំនួន និងរដ្ឋប៉ុណ្ណោះដែលជាប់កាតព្វកិច្ច។ ជាលទ្ធផលដោយហេតុថាសិទ្ធិទាំងឡាយត្រូវបានធានាដោយរដ្ឋ ដូចនេះរដ្ឋមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការការពារ អនុវត្ត ឬផ្តល់ឡើងវិញ និងបើចាំបាច់រដ្ឋត្រូវផ្តល់សំណងជួសជុលការខូចខាត បើសិទ្ធិណាមួយត្រូវបានរំលោភ។ នៅពេលរដ្ឋមួយ ដូចជាព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់នូវរាល់ច្បាប់អន្តរជាតិ ស្តីពីសិទ្ធិមនុស្ស (តាមរយៈការឱ្យសច្ចាប័ន ឬតាមវិធីដទៃទៀត) បើសិនជាសិទ្ធិរបស់សមាជិករដ្ឋនោះណាម្នាក់ត្រូវបានគេរំលោភ បុគ្គលនោះអាចប្តឹងតវ៉ាទៅយន្តការអន្តរជាតិណាមួយ ដើម្បីសុំការការពារបាន (ដូចជាប្តឹងទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ) ជាដើម។ សម្រាប់ហេតុផលមនុស្សធម៌ នៅក្នុងស្ថានភាពជ្រុលហួសហេតុមួយចំនួន ដូចជាអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ច្បាប់ទំនៀមទំលាប់អន្តរជាតិអនុញ្ញាតឱ្យសហគមន៍អន្តរជាតិធ្វើអន្តរាគមបាន ដើម្បីជាប្រយោជន៍ក្នុងការការពារសិទ្ធិមនុស្ស ទោះបីប្រទេសដែលហេតុការណ៍នេះកើតមាននោះ ពុំបានឱ្យសច្ចាប័នចំពោះយន្តការដោះស្រាយវិវាទអន្តរជាតិនេះក៏ដោយ។

---

[១១] សូមមើល : Rey Pérez, 2004.

*ករណីយកិច្ចៈ* ករណីយកិច្ចអាចជា "ករណីយកិច្ចសកម្ម" ដែលមានន័យថាជាកាតព្វកិច្ចដើម្បីធ្វើអ្វីមួយ ឬអាចជា "ករណីយកិច្ចអកម្ម" ដែលមានន័យថាមានកាតព្វកិច្ចមិនត្រូវធ្វើអ្វីមួយ។ ជាឧទាហរណ៍ សិទ្ធិទទួលបានអ្នកប្រឹក្សាច្បាប់តម្រូវឱ្យចៅក្រមអនុញ្ញាតឱ្យចុងចំលើយអាចមានមេធាវី និងអនុញ្ញាតឱ្យមេធាវីនោះអាចបំពេញមុខងាររបស់ខ្លួនដោយស្របច្បាប់ (នេះជាកាតព្វកិច្ចអវិជ្ជមានរបស់រដ្ឋ ហើយក៏អាចជាវិជ្ជមានផងដែរបើសិនជារដ្ឋត្រូវតែផ្តល់មេធាវី)។ បន្ថែមលើនេះទៀត សិទ្ធិនេះបង្កប់នូវកាតព្វកិច្ចវិជ្ជមានចំពោះប្រជាពលរដ្ឋ និងក្រុមហ៊ុននានាដែលត្រូវបង់ពន្ធ ធ្វើដូចនេះអាចឱ្យរដ្ឋមានថវិកាសម្រាប់ជួលមេធាវី។ ឧទាហរណ៍មួយទៀត គឺសិទ្ធិក្នុងការអប់រំជាមូលដ្ឋានដែលធានាដោយរដ្ឋធម្មនុញ្ញ។ វាមានន័យថាជាកាតព្វកិច្ចវិជ្ជមានរបស់រដ្ឋផងដែរ ក្នុងការផ្តល់សាលារៀន និងផ្តល់ប្រាក់បៀវត្សរ៍សម្រាប់គ្រូបង្រៀនទាំងឡាយ។ ករណីនេះរដ្ឋនិងបុគ្គលទាំងឡាយក៏មានកាតព្វកិច្ចអវិជ្ជមានផងដែរ ដោយរដ្ឋនិងបុគ្គលទាំងឡាយនោះ មិនអាចបង្កជាឧបសគ្គនានាដែលនាំឱ្យសិស្សមិនអាចចូលរៀនបាន ដូចជាការរើសអើងប្រឆាំងសិស្សមួយចំនួន ប្រព្រឹត្តមិនសមរម្យដល់សិស្ស ឬតម្រូវឱ្យសិស្សបង់ប្រាក់ខុសច្បាប់ណាមួយឡើយ។ ក្នុងការធានានូវការគោរពសិទ្ធិអប់រំនេះ ក៏ទាមទារឱ្យមានកាតព្វកិច្ចវិជ្ជមានផងដែរចំពោះអ្នកបង់ពន្ធទាំងឡាយ ដើម្បីឱ្យរដ្ឋអាចមានថវិកាសម្រាប់ គ្រប់ដណ្តប់ក្នុងការផ្តល់សេវាកម្មអប់រំ មូលដ្ឋាននេះបាន។ ចំពោះសិទ្ធិផ្សេងៗទៀតដូចជាសិទ្ធិពលរដ្ឋ និងនយោបាយ ព្រមទាំងសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌ក៏មាន លក្ខណៈដូចសិទ្ធិអប់រំនេះដែរ។ ដូចនេះក្នុងការគោរព និងធានាដល់សិទ្ធិទាំងអស់ ទាមទារឱ្យមានកាតព្វកិច្ចវិជ្ជមានផង និងអវិជ្ជមានផង។

**តារាងពន្យល់អំពីរចនាសម្ព័ន្ធនៃកាតព្វកិច្ចនៃសិទ្ធិទទួលបានមេធាវី**

| កាតព្វកិច្ច / អ្នកមានកាតព្វកិច្ច | អវិជ្ជមាន (Abstention) | វិជ្ជមាន (Action) |
|---|---|---|
| រដ្ឋ | មិនរារាំង ឬរំខានដល់ការងាររបស់មេធាវី | - សម្របសម្រួលដល់ការងារមេធាវី ដូចជាជួយជំរុញដល់ការចូលរួមរបស់សាក្សី និងបង្ហាញនូវភស្តុតាងទាំងឡាយ។<br>- ផ្តល់មេធាវីដល់ចុងចោទ បើសិនជាចុងចោទមិនមានលទ្ធភាពបង់ប្រាក់ឱ្យមេធាវី |
| ប្រជាពលរដ្ឋ | ភាគីរដ្ឋប្បវេណី ក្នុងរឿងព្រហ្មទណ្ឌ និងករណីដទៃទៀតៈ មិនរំខានដល់ការងាររបស់មេធាវី | ប្រជាពលរដ្ឋ និងក្រុមហ៊ុននៅក្នុងប្រទេស ត្រូវបង់ពន្ធជូនរដ្ឋ ដើម្បីឱ្យរដ្ឋមានថវិកាអាចជួលមេធាវីសាធារណៈបាន។ |

**ការធានាៈ** រាល់ការធានាទាំងឡាយអាចធ្វើឡើងតាមទម្រង់ផ្សេងៗពីគ្នា។ ការធានាជាទូទៅមួយឱ្យមានការការពារសិទ្ធិមនុស្ស ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញគឺសិទ្ធិទទួលបានយុត្តិធម៌។ កង្វះខាតយន្តការជាក់លាក់ដើម្បីការពារសិទ្ធិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ មិនមែនមានន័យថារដ្ឋអាចគេចផុតពីកាតព្វកិច្ច ក្នុងការការពារសិទ្ធិទាំងនោះឡើយ។ ចៅក្រមមានកាតព្វកិច្ចការពារសិទ្ធិទាំងឡាយ ដែលធានាដោយរដ្ឋធម្មនុញ្ញ ពីព្រោះរដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលរបស់ប្រទេស ទោះបីសិទ្ធិនោះមិនត្រូវបានគេចែងបន្ថែមនៅក្នុងច្បាប់បន្ទាប់បន្សំផ្សេងទៀតក្តី ឬទោះជាគ្មាននីតិវិធីច្បាស់លាស់ ក្នុងការប្តឹងនៅពេលសិទ្ធិទាំងនោះត្រូវបានគេរំលោភក្តី។ ក្នុងករណីដែលពុំមានច្បាប់ឬបទបញ្ញត្តិជាក់លាក់ចែងនោះ ចៅក្រមត្រូវតែបកស្រាយសិទ្ធិនោះដោយស្របទៅនឹងការតាំងចិត្តរបស់កម្ពុជា ក្នុងការគោរពច្បាប់អន្តរជាតិ តាមរយៈការឱ្យសច្ចាប័នលើឧបករណ៍ស្តីពីសិទ្ធិមនុស្សនានា។ បើពុំដូចនោះទេ ការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការអនុវត្តឱ្យបាននូវច្បាប់អន្តរជាតិទាំងនោះក្លាយទៅជាការតាំងចិត្តដោយគ្មានន័យអ្វីទាំងអស់។

នៅប្រទេសមួយចំនួន គេមានយន្តការជាក់លាក់សម្រាប់ការពារសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញ។ ឧទាហរណ៍ : ក).˝សិទ្ធិមិនត្រូវបានឃុំខ្លួនហួសកាលកំណត់នៃច្បាប់ - *habeas corpus*˝ ដើម្បីការពារដល់បូរណភាពខាងរូបកាយនិងសេរីភាពបុគ្គល [១២] ខ).អធិបញ្ញារបស់តុលាការប្រឆាំងនឹងវិធានការរដ្ឋបាល ដែលគំរាមកំហែងដល់សិទ្ធិទាំងឡាយ ដែលធានាដោយរដ្ឋធម្មនុញ្ញ ដោយអះអាងថាសិទ្ធិទាំងនោះខុសពីបូរណភាពខាងរូបកាយ និងសេរីភាពបុគ្គល (ដូចជាការប្រជុំគ្នា ការសំដែងមតិ ការបង្កើតជាសមាគម សិទ្ធិសង្គមនានា។ល។ គ).គោលការណ៍ស្តីពីទិន្នន័យសុំនៅក្រៅឃុំ (habeas data) ដើម្បីការពារដល់ទិន្នន័យរបស់បុគ្គល ឃ).ប្តឹងប្រឆាំងពីភាពមិនស្របធម្មនុញ្ញរបស់ច្បាប់ ឬបទបញ្ញតិណាមួយដែលផ្ទុយពីច្បាប់ធម្មនុញ្ញ។ មានស្ថាប័នជាក់លាក់ខ្លះ ជាស្ថាប័នជំនាញដែលទទួលបន្ទុក រាល់ការពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់ ដើម្បីការពារសិទ្ធិ ដូចជាតុលាការធម្មនុញ្ញជាដើម ហើយក្រៅពីនេះក៏នៅមានស្ថាប័នផ្សេងទៀត ដូចជា អំប៊ុដស៊ីម៉ែន (Ombudsman) ជាដើម តែជាធម្មតាស្ថាប័នខាងក្រោយនេះ ពុំមានអំណាចយុត្តាធិការឡើយ [១៣] ។

នៅព្រះរាជាណាចក្រកម្ពុជា ពុំមានស្ថាប័នជំនាញណាមួយ ដែលទទួលបន្ទុកក្នុងការការពារសិទ្ធិទាំងឡាយ ដែលមានចែងនៅក្នុងធម្មនុញ្ញក្រៅពីតុលាការឡើយ ។ ដូចនេះតួនាទីរបស់ចៅក្រម គឺមានសារៈសំខាន់ណាស់ក្នុងការការពារសិទ្ធិទាំងនេះ [១៤] ។

គោលការណ៍នានាក្នុងការបកស្រាយ អនុវត្តន៍ និងអភិវឌ្ឍន៍នៃសិទ្ធិមនុស្ស

**គោលការណ៍ ˝ភាពជឿនលឿនជាលំដាប់˝ នៃសិទ្ធិមនុស្ស**

˝ភាពជឿនលឿនជាលំដាប់ - Progressiveness˝ ត្រូវបានគេចាត់ទុកថាជាលក្ខណៈមួយនៃសិទ្ធិមនុស្ស និងជាលទ្ធផលមួយនៃច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស[១៥]។ ដោយសេចក្តីត្រូវការសង្គមមានការប្រែប្រួល ដូចនេះតម្រូវការនានាដើម្បីឱ្យការការពារសិទ្ធិមនុស្សឱ្យមានប្រសិទ្ធិភាព ក៏មានការប្រែប្រួលផងដែរ។ ទំហំ និងយន្តការនានា ដែលបានប្រើប្រាស់ដើម្បីជាប្រយោជន៍ដល់ការការពារសិទ្ធិ តែងមានបន្តរីកចំឡើង១ជាប្រចាំ។ ការនេះមានជាប់ពាក់ព័ន្ធយ៉ាងច្រើនជាមួយនឹងការទទួលស្គាល់ការបកស្រាយ និងការអនុវត្តនូវសិទ្ធិទាំងនោះ។ ក្នុងការបកស្រាយតាមគោលការណ៍ ˝ភាពជឿនលឿនជាលំដាប់˝ មានន័យថា បើសិនជាមានការខ្វែងគំនិតគ្នារវាងចៅក្រម ឬអាជ្ញាធរនានាទាក់ទិននឹងការបកស្រាយនូវសិទ្ធិជាក់លាក់ណាមួយនោះ ការបកស្រាយណាដែលទទួលស្គាល់សិទ្ធិ ឬផលប្រយោជន៍ច្រើនជាងដល់រូបវ័ន្តបុគ្គល ត្រូវមានអានុភាពលើការបកស្រាយ ដែលកម្រិតសិទ្ធិ និងផលប្រយោជន៍ទាំងនេះ។ ជាឧទាហរណ៍ បើសិនជាការកំណត់អំពីសិទ្ធិដែលមានចែងនៅក្នុងច្បាប់ជាតិ មានលក្ខណៈចង្អៀត តែរដ្ឋនោះបានឱ្យសច្ចាប័នលើអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិមនុស្សដែលមានន័យទូលាយជាង ឬការបកស្រាយទូលាយជាងនោះ ការបកស្រាយដូចមានចែងនៅក្នុងច្បាប់អន្តរជាតិ នឹងមានអនុភាពជាងក្នុងការអនុវត្ត។ គ្មានបទបញ្ញត្តិដែលមានឋានានុក្រមទាបជាង (ច្បាប់ ក្រឹត្យ អនុក្រឹត្យ) ឬបញ្ញត្តិដទៃទៀតណា ដែលចេញដោយអាជ្ញាធរណាមួយអាចកម្រិត ឬបន្ថយសិទ្ធិរបស់ពលរដ្ឋបានឡើយ។ តែបើសិនជាករណីនេះកើតមាននោះ រាល់ការកម្រិតនូវសិទ្ធិ ឬការចែងអំពីសិទ្ធិដែលមានលក្ខណៈចង្អៀតនោះត្រូវចាត់ទុកជាមោឃៈ។ តាមគោលគំនិតនេះ គឺថាគ្រប់មនុស្សទាំងអស់ទោះជាបុគ្គលក្តី ឬក្រុមក្តីគួរទទួលបាននូវផលប្រយោជន៍ពីការតាំងចិត្តដ៏ខ្លាំងបំផុតរបស់រដ្ឋក្នុងការគោរពសិទ្ធិមនុស្ស បើពុំដូចនោះទេ រាល់ការប្តេជ្ញាចិត្តរបស់រដ្ឋមួយថាគោរពសិទ្ធិមនុស្សនោះ នឹងក្លាយជាការប្តេជ្ញាចិត្តដោយគ្មានន័យអ្វីទាំងអស់។ ន័យមួយផ្សេងទៀតនៃ ˝ភាពជឿនលឿនជាលំដាប់ឬការអនុវត្ត

[១២] នៅពេលជនដែលត្រូវគេចោទប្រកាន់ ឬសាច់ញាតិរបស់ជននោះដាក់ពាក្យសុំឱ្យនៅក្រៅឃុំ ទៅចៅក្រមណាមួយហើយ អាជ្ញាធរមានសមត្ថកិច្ចនេះមានរកាតព្វកិច្ចត្រូវធ្វើការចុះត្រួតពិនិត្យជាបន្ទាន់ ឬក្នុងរយៈពេល ២៤ ម៉ោងយ៉ាងយូរ ដល់កន្លែងឃុំខ្លួន ហើយបើសិនជារកឃើញថា ការចាប់ខ្លួននេះគឺធ្វើឡើងដោយមិនត្រឹមត្រូវនោះ ចៅក្រមត្រូវបញ្ជាឱ្យដោះលែងជននោះ ឱ្យនៅក្រៅឃុំភ្លាម ។ ហើយចៅក្រមអាចបន្តស៊ើបអង្កេតទៅទៀតបាន។

[១៣] សូមចំណាំថា ក៏មានគណៈកម្មការសិទ្ធិមនុស្សអំប៊ុដម៉ែន មួយចំនួនដែលមានអំណាចយុត្តាធិការ ដូចជានៅប្រទេសកាណាដាជាដើម ។

[១៤] សូមមើលរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣១ និង ៣៩ នៅក្នុងឧបសម្ព័ន្ធទី ១។

[១៥] Defensoría del Pueblo de Venezuela: *"El principio de progresividad"* (Available at: http://www.defensoria.gov.ve/lista.asp?sec=140403).

ជាបណ្តើរៗ" គឺពេលខ្លះត្រូវបានគេប្រើប្រាស់ដោយសំដៅលើការអនុវត្តសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌។ ការអនុវត្តនេះតម្រូវឱ្យរដ្ឋាភិបាលចាត់វិធានការជាវិជ្ជមានជាបណ្តើរៗ និងជាជំហានៗ ដើម្បីឈានទៅដល់គោលដៅ។ ជាលទ្ធផល រដ្ឋាភិបាលមិនអាចមិនគោរពសិទ្ធិមនុស្ស ដោយការមិនធ្វើសកម្មភាពអ្វីទាំងអស់ ឬចាត់វិធានការតាមសង្កត់នោះឡើយ [១៦]។

គោលការណ៍ "និយាមអន្តរជាតិអប្បបរមា"

ការសិក្សានេះបានសន្មតថា និយាមសិទ្ធិមនុស្សអន្តរជាតិជាអប្បបរមា ផ្តល់នូវក្របខ័ណ្ឌអប្បបរមាសម្រាប់ការបកស្រាយសិទ្ធិមនុស្ស ប៉ុន្តែនិយាមទៅក្នុងបរិបទនៃសង្គមនីមួយៗ ចាំបាច់ត្រូវពិចារណាពីសេចក្តីត្រូវការរបស់សង្គម និងការទាមទារតាមផ្លូវសីលធម៌ ដើម្បីឱ្យដឹងថា តើសិទ្ធិទាំងនោះអាចត្រូវបានគេអនុវត្តយ៉ាងដូចម្តេច នៅក្នុងកាលៈទេសៈនីមួយៗ។

គោលការណ៍ "ឆ្លើយតបជាអតិបរមាចំពោះសេចក្តីត្រូវការសង្គម"

សិទ្ធិគួរតែត្រូវបានគេបកស្រាយ និងអនុវត្តដើម្បីឆ្លើយតបឱ្យបានជាអតិបរមា ចំពោះសេចក្តីត្រូវការសង្គម សម្រាប់ការអភិវឌ្ឍមនុស្ស។ ហើយត្រូវយកចិត្តទុកដាក់ផងដែរ អំពីស្ថានភាពជាក់លាក់របស់ក្រុមគោលដៅមួយចំនួន ឬចំពោះបរិបទនៃសង្គម ដែលត្រូវអនុវត្តសិទ្ធិទាំងនោះ ដូចជាបរិបទនៃតម្លៃវប្បធម៌ ភាសារបស់មូលដ្ឋាន យេនឌ័រ និងបញ្ហាជាតិពន្ធុផងដែរ។ ការពិចារណាអំពីសេចក្តីត្រូវការរបស់សង្គម និងបរិបទនៃវប្បធម៌ ក្នុងទេសកាលនៃការអនុវត្តសិទ្ធិមនុស្សទាំងនោះ មិនគួរត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាលដើម្បីធ្វើជាលេស សម្រាប់កាត់បន្ថយនិយាមសិទ្ធិមនុស្ស ដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិឡើយ តែត្រូវប្រើប្រាស់វាជាលក្ខខណ្ឌ សម្រាប់ការអនុវត្តតាមរូបភាពមួយដែលកាន់តែប្រសើរឡើង។ ការអនុវត្តនូវរាល់សិទ្ធិទាំងឡាយ បង្ហាញពីប្រសិទ្ធិភាពនៃច្បាប់ និងភាពខ្លាំងខាងតម្លៃសីលធម៌ និងធម្មានុរូបរបស់ខ្លួន។ តែទោះជាយ៉ាងណាគោលដៅចម្បងរបស់វាគឺធានាឱ្យបាននូវការឆ្លើយតបយ៉ាងពេញលេញ ចំពោះសេចក្តីត្រូវការរបស់សង្គម។

ការយកចិត្តទុកដាក់ចំពោះតម្លៃវប្បធម៌របស់មូលដ្ឋាន និងសេចក្តីត្រូវការសង្គម ធ្វើឱ្យយើងអាចចៀសវាងនូវរាល់ការរិះគន់ថា សិទ្ធិមនុស្សជាអ្វីមួយដែលចំឡែកសម្រាប់ប្រជាពលរដ្ឋ និងជាសម្ពាធពីខាងក្រៅ ដែលធ្វើដោយប្រទេសលោកខាងលិច ដែលមានឥទ្ធិពលទៅលើប្រទេសកំពុងអភិវឌ្ឍន៍ ដូចនៅទ្វីបអាហ្វ្រិក អាស៊ី និងអាមេរិកឡាទីនជាដើម។ ជាការពិតណាស់ថា ឧបករណ៍ស្តីពីសិទ្ធិមនុស្សនានា ត្រូវបានអនុម័តដោយយោងទៅតាមប្រពៃណីនៃច្បាប់របស់លោកខាងលិចមួយចំនួន និងការរិះគន់ទាំងនោះអាចជាការត្រឹមត្រូវ បើសិនជាសិទ្ធិមនុស្សត្រូវបានគ្រាន់តែបកស្រាយទៅតាមនិយាមវប្បធម៌ និងសេចក្តីត្រូវការរបស់សង្គមនៃប្រទេសលោកខាងលិចទេនោះ។ ទោះជាយ៉ាងនេះក្តី បើសិនជាសិទ្ធិមនុស្ស ត្រូវបានអនុម័តដោយប្រទេសកំពុងអភិវឌ្ឍន៍នានា តាមតម្រូវការរបស់ប្រជាពលរដ្ឋសម្រាប់អនុវត្តលទ្ធិប្រជាធិបតេយ្យ ហើយត្រូវគេឱ្យនិយមន័យ និងបកស្រាយដោយពិចារណាទៅលើសេចក្តីត្រូវការសង្គម វប្បធម៌ និងលក្ខខណ្ឌផ្សេងៗទៀតរបស់សង្គម ដែលចាំបាច់ត្រូវអនុវត្តនោះ វាមិនត្រូវបានចាត់ទុកថាជាអ្វីមួយ ដែលសម្ពាធពីខាងក្រៅឡើយ។

---

១៦ គោលការណ៍នេះ មានពន្យល់នៅក្នុងសេចក្តីប្រកាសគីតូ *(Quito Declaration)* ស្តីពីការអនុវត្ត និងធ្វើឱ្យជាក់ស្តែង នូវសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ នៅប្រទេសអាមេរិកឡាទីន និងនៅ Caribbean (Quito, July 24, 1998): ២៩ "លើសពីនេះទៀត រដ្ឋមានកាតព្វកិច្ចដូចតទៅ: កាតព្វកិច្ចក្នុងការផ្តល់សិទ្ធិជាបណ្តើរៗ និងទប់ស្កាត់កុំឱ្យមានការដើរថយក្រោយ ក្នុងការគោរពសិទ្ធិមនុស្ស : រដ្ឋមានកាតព្វកិច្ចចាត់វិធានការ ដើម្បីធានាឱ្យមានប្រសិទ្ធិភាពពេញលេញ នៃការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌។ ដូច្នេះរាល់ការមិនធ្វើសកម្មភាព និងការពន្យារពេលក្នុងការចាត់វិធានការដោយគ្មានហេតុផលសមរម្យ ឬពន្យារពេលក្នុងការចាត់វិធានការណាមួយដែលដើរថយក្រោយក្នុងការគោរពសិទ្ធិទាំងនេះ គឺផ្ទុយពីគោលការណ៍អនុវត្តន៍ឱ្យបានប្រសើរឡើងជាបណ្តើរៗ។ រដ្ឋទាំងឡាយមិនត្រូវបានគេអនុញ្ញាតឱ្យអនុវត្តគោលនយោបាយដើរថយក្រោយក្នុងការគោរពសិទ្ធិមនុស្ស ដែលអាចប៉ះពាល់ ឬជារនាំងក្នុងការអនុវត្តនូវរាល់សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ឡើយ ..."
(សូមមើលបន្ថែមនៅ : http://cesr.org/filestore2/download/592) ។

ធម្មានុរូបភាពនៃសិទ្ធិមនុស្សនៅក្នុងប្រទេសមួយ វាទាក់ទិននឹងលទ្ធភាពដែលប្រជាពលរដ្ឋរកឃើញថា សិទ្ធិមនុស្សពិតជាបានឆ្លើយតបចំពោះសេចក្តីត្រូវការក្នុងសង្គមនោះ។ មានប្រជាពលរដ្ឋជាច្រើន រួមទាំងមន្ត្រីសាធារណៈមួយចំនួនផងមិនបានដឹងថាអ្វីជាសិទ្ធិមនុស្សទេ។ ទោះជាយ៉ាងនេះក្តី ចាំបាច់គួរកត់សំគាល់ថាការគោរពសិទ្ធិមនុស្ស គឺដើម្បីបំពេញរាល់សេចក្តីត្រូវការនៅក្នុងសង្គម ដូចនេះវាតម្រូវឱ្យមានការពិភាក្សាអន្តរវប្បធម៌តាមទេសកាលនីមួយៗ ទាក់ទងនឹងការបកស្រាយ និងអនុវត្តសិទ្ធិទាំងនោះ។ ជាការចាំបាច់ណាស់ដែលរដ្ឋ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលត្រូវខិតខំប្រឹងប្រែងដើម្បីជំរុញឱ្យប្រជាពលរដ្ឋទាំងអស់យល់ដឹង និងជាម្ចាស់លើសិទ្ធិមនុស្ស ក៏ដូចជាយល់ដឹងពីការទទួលខុសត្រូវរបស់ខ្លួន ក្នុងកាតព្វកិច្ចនានាដែលពាក់ព័ន្ធនឹងសិទ្ធិទាំងនោះ។ ការដែលប្រជាពលរដ្ឋជាម្ចាស់នៃសិទ្ធិទាំងនោះ ត្រូវតែផ្អែកទៅលើការយល់ដឹងថាសិទ្ធិមនុស្សជាការឆ្លើយតបមួយចំពោះតម្លៃវប្បធម៌ ការទាមទារខាងសីលធម៌ និងសេចក្តីត្រូវការសង្គមរបស់ពួកគេ។

> ព្រះរាជាណាចក្រកម្ពុជាកំពុងប្រឈមនឹងការអភិវឌ្ឍនៃកិច្ចពិភាក្សាអន្តរវប្បធម៌រវាងក្រុមមនុស្សផ្សេងៗ ដែលមាននៅកម្ពុជា ដើម្បីធ្វើឱ្យកាន់តែជាក់ស្តែងឡើងនូវមូលដ្ឋានវប្បធម៌ និងសីលធម៌នៃសិទ្ធិមនុស្ស ដោយពិចារណាទៅលើប្រពៃណីវប្បធម៌ សាសនា និងជាតិពន្ធុផ្សេងៗដែលមាននៅក្នុងប្រទេស។ ការដែលធ្វើដូចនេះ ប្រជាពលរដ្ឋអាចចូលរួមនិងលើកឡើងនូវសេចក្តីត្រូវការរបស់ពួកគេ ដោយគោរពតាមសិទ្ធិមនុស្ស។

គោលការណ៍សម្របតាមស្ថានភាពមូលដ្ឋាន ដោយមិនភ្លេចគោលការណ៍នៃសេចក្តីថ្លៃថ្នូរស្មើៗគ្នា

គោលគំនិតជាគន្លឹះស្តីពីសិទ្ធិមនុស្ស គឺថាមនុស្សគ្រប់រូបនិងគ្រប់ក្រុមនៃជាតិពន្ធុ មានសេចក្តីថ្លៃថ្នូរស្មើៗគ្នា។ គោលការណ៍នេះអាចត្រូវគេមើលឃើញថា ជាអ្វីមួយដែលមានទំនាស់ជាមួយគោលគំនិតខាងវប្បធម៌ និងការសម្របតាមស្ថានភាពមូលដ្ឋានស្តីពីសិទ្ធិមនុស្ស បើសិនជានៅថ្នាក់មូលដ្ឋាន មានការបែងចែកឋានៈសង្គមដោយផ្អែកលើតម្លៃវប្បធម៌ ឬសាសនា ដែលនាំឱ្យមានសិទ្ធិអាទិភាព និងកាតព្វកិច្ចក្នុងចំណោមបុគ្គលនិងក្រុមមនុស្ស ក្នុងលក្ខណៈមួយដែលបង្កឱ្យមានការរើសអើង ឬប្រកាន់ពូជសាសន៍ (ដូចជាកើតមាននៅក្នុងចំណោមស្ត្រី កុមារ និងក្រុមអ្នកដែលគេមិនអើពើ ។ល។)។ វាជាការមួយចាំបាច់គួរកត់សំគាល់ថា ការគោរពគោលការណ៍សមភាពនៃសេចក្តីថ្លៃថ្នូររបស់មនុស្ស គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំនៃគម្រោងសិទ្ធិមនុស្សទាំងមូល។ ការសម្របតាមស្ថានភាពមូលដ្ឋាននៃសិទ្ធិមនុស្ស អាចនាំឱ្យគោលការណ៍នេះត្រូវបានគេគោរពកាន់តែប្រសើរជាជាងការធ្វើឱ្យគ្រោះថ្នាក់ដល់គោលការណ៍នេះ។ នេះជាការប្រឈមរបស់សង្គមនីមួយៗ ដែលបានអនុម័តសិទ្ធិមនុស្សឱ្យទៅជាច្បាប់របស់ខ្លួន ដើម្បីរកឱ្យឃើញថា តើត្រូវចាក់គ្រឹះជាមូលដ្ឋាននូវគោលគំនិត ស្តីពីសេចក្តីថ្លៃថ្នូររបស់មនុស្សនៅក្នុងឫសគល់នៃវប្បធម៌ និងសេចក្តីត្រូវការសង្គមរបស់ខ្លួនដោយរបៀបណា។

ជាការពិតណាស់ថា គោលគំនិតនៃ "សិទ្ធិបុគ្គល" កើតមានឡើងជាមួយនឹងរដ្ឋទំនើបពោលគឺនីតិរដ្ឋ និងការបែងចែកអំណាចដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ ស្ថាប័នទាំងនោះ ព្រមទាំងលំដាប់នៃច្បាប់បានជួយ សម្រួលឱ្យអនុលោមទៅតាមកិច្ចការពារខាងស្ថាប័នសម្រាប់ការគោរពសិទ្ធិមនុស្ស[១៧]។ គោលគំនិតដែលថា មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នានិងជាសិទ្ធិមានពីកំណើតដូចៗគ្នា ដោយមិនគិតពីលក្ខខណ្ឌសង្គមឡើយ ហើយជាយថាហេតុ វាអាចជំនះលើគំនិតដែលមានមុនសម័យទំនើបដែលបែងចែកមុខងារនិងតួនាទីដោយផ្អែកលើឋានៈសង្គម។ គោលគំនិតនេះ គឺជាអ្វីមួយដែលធ្វើឱ្យមានភាពខុសគ្នារវាង "សង្គមនៃសិទ្ធិ" ជាមួយនឹង "សង្គមនៃឋានៈ"។ សម្រាប់សង្គមនៃសិទ្ធិជនគ្រប់ៗរូបត្រូវបានគេចាត់ទុកថាជាប្រធាននៃសិទ្ធិ ដូចនេះ

[១៧] គ្រាន់តែគំនិតនៃ "រដ្ឋធម្មនុញ្ញ" គឺកំណត់អំពីការបែងចែកអំណាច និងការគោរពសិទ្ធិបុគ្គល ព្រមទាំងការធានាទាំងឡាយ ។ សូមមើល : សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សនិងពលរដ្ឋ (Declaration of the Rights of Man and of the Citizen (France, 1789) ដោយបានចែងថា "សង្គមដែលគ្មានការត្រួតពិនិត្យពីច្បាប់ និងគ្មានការបែងចែកអំណាច នោះមានន័យថា សង្គមនោះគ្មានរដ្ឋធម្មនុញ្ញឡើយ" (សូមមើលអត្ថបទទាំងស្រុងជាភាសាអង់គ្លេសនៅឯ: http://www.[illegible]) ។

គ្រប់បុគ្គលទាំងអស់ អាចទាមទារនូវសិទ្ធិទាំងនោះបាន។ សម្រាប់សង្គមនៃឋានៈវិញ ប្រជាពលរដ្ឋមិនមានសិទ្ធិដែលកើតមានពីកំណើតឡើយ តែគេបែរជាមានតួនាទី មុខងារ និងបុព្វសិទ្ធិទាក់ទងនឹងឋានៈសង្គមរបស់គេទៅវិញ[១៨]។ ដូច្នេះបើសិនជាអ្នកណាម្នាក់មានឋានៈសង្គមខ្ពស់ នោះគេមានបុព្វសិទ្ធិលើបុគ្គលទាំងឡាយ ដែលមានឋានៈសង្គមទាបជាងខ្លួន។ ស្ត្រីមានតួនាទីនិងបុព្វសិទ្ធិមួយចំនួនចំពោះបុរស កុមារចំពោះចាស់ទុំ និងករណីផ្សេងៗទៀត។ នៅក្នុងសង្គមនៃសិទ្ធិ គឺជនគ្រប់រូបត្រូវបានគេចាត់ទុកថាជាប្រធាននៃសិទ្ធិ និងមានសេចក្តីថ្លៃថ្នូរដូចៗគ្នា ដោយសមភាពនៅចំពោះមុខច្បាប់ ដោយមិនប្រកាន់លើភេទ ឋានៈសង្គម ពូជសាសន៍ ភាសា ឬដើមកំណើតឡើយ។ ដូចនេះជនគ្រប់រូប មានសិទ្ធិសេរីភាពពេញលេញ ដូចដែលបានទទួលស្គាល់ដោយច្បាប់ ហើយពួកគេមានសិទ្ធិប្តឹងទាមទារដើម្បីឱ្យមានការការពារពីច្បាប់ នៅពេលដែលសិទ្ធិណាមួយត្រូវបានគេរំលោភ។ ស្ថាប័នប្រជាធិបតេយ្យ នានាមាននាទីធានាការគោរពនូវរាល់សិទ្ធិទាំងនេះ។

គោលការណ៍នៃសេចក្តីថ្លៃថ្នូរដោយសមភាពរបស់មនុស្ស តម្រូវឱ្យមានដំណោះស្រាយសមរម្យមួយ សម្រាប់ភាពខុសៗគ្នានៅក្នុងសង្គម ដែលជាហេតុនាំឱ្យមានឱកាស និងការឱ្យតម្លៃមិនស្មើភាពគ្នាក្នុងចំណោមជនគ្រប់រូប និងក្នុងក្រុមមនុស្សទាំងឡាយ។ នេះជាអ្វីមួយដែលតែងតែកើតមាននៅគ្រប់សង្គម ទោះបីជាសង្គមបែបទំនើបរបស់លោកខាងលិច ដែលគ្រប់គ្រងដោយសេដ្ឋកិច្ចទីផ្សារក្តី នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានប្រពៃណីវប្បធម៌ផ្សេងគ្នា ឬមិនដូចលោកខាងលិចក្តី។

នៅព្រះរាជាណាចក្រកម្ពុជា មានបញ្ហាសង្គមជាច្រើន ដែលទាមទារឱ្យមានដំណោះស្រាយសមរម្យ ដើម្បីធានាឱ្យបាននូវសមភាពរបស់ជនគ្រប់រូប ឬក្រុមទាំងឡាយ ជាពិសេសនៅក្នុងចំណោមក្រុមជនទន់ខ្សោយនានា។ បើសិនជាពុំមានសមភាពជាអប្បបរមានៅក្នុងសង្គមទេនោះ ទោះបីមានជាស្ថាប័នប្រជាធិបតេយ្យក្តី មានប្រព័ន្ធយុត្តិធម៌ក្តី ក៏មិនអាចធានាដល់ការគោរពសិទ្ធិមនុស្សបានឡើយ។ ដូចជានៅប្រទេសអាស៊ានផ្សេងៗទៀតដែរ ប្រពៃណីវប្បធម៌របស់ប្រទេសកម្ពុជា នាំឱ្យមានការឱ្យតម្លៃ និងបុព្វសិទ្ធិមួយចំនួនចំពោះចាស់ទុំ ព្រះសង្ឃ និងបុគ្គលដែលមានអំណាចដទៃៗទៀត ដែលត្រូវបានគេចាត់ទុកថាមានកិត្តិយស ហើយមានប្រាជ្ញា។ ត្រឡប់មកវិញ ក្រុមទាំងនេះបានផ្តល់មកវិញនូវយោបល់ល្អៗ សេវា ឬការការពារនានា ទៅតាមការបណ្តាញបរិបាលកិច្ច និងតាមគោលការណ៍ឋានានុក្រមនៅក្នុងសង្គមរបស់គេ។ ករណីដូចគ្នានេះដែរ គោលការណ៍បរិបាលកិច្ច និងឋានានុក្រមសង្គម (patronage and hierarchical principles) អាចបញ្ជាក់អំពីចរិតលក្ខណៈជាប្រវត្តិសាស្ត្ររវាងរដ្ឋាភិបាល និងអ្នកដែលស្ថិតនៅក្រោមបង្គាប់[១៩]។ សូម្បីតែទំនាក់ទំនងក្នុងគ្រួសារ ក៏ធ្លាប់មានគោលក្នុងគោលការណ៍ឋានានុក្រមប្រហាក់ប្រហែលគ្នានេះដែរ។ ភាសាខ្មែរ ក៏ឆ្លុះបញ្ចាំងអំពីទំនាក់ទំនង និងភាពខុសគ្នានៃឋានៈសង្គមនៅក្នុងចំណោមអ្នកនិយាយដែលមកពីប្រភព ឬឋានៈផ្សេងៗរបស់សង្គមដែរ។ នៅក្នុងរបប ប៉ុល ពត រាល់ការគោរពចំពោះចាស់ទុំ ព្រះសង្ឃ និងរចនាសម្ព័ន្ធរបស់សង្គមជាប្រវត្តិសាស្ត្រ ត្រូវបានលុបបំបាត់ចោលទាំងស្រុង ដោយបង្កើតជំនួសវិញនូវរបបមួយដែលប្រជាពលរដ្ឋទាំងអស់មានភាពស្មើគ្នានៅក្នុងសង្គម។ ទ្រព្យសម្បត្តិដែលជាប្រភពសំខាន់សម្រាប់កំណត់ពីស្ថានភាពសេដ្ឋកិច្ច ក៏ត្រូវបានបំផ្លាញផងដែរ ហើយប្រជាពលរដ្ឋគ្រប់រូប ត្រូវបានជម្លៀសឱ្យទៅធ្វើការនៅឯជនបទ។ តែរបបនេះមិនបានលុបបំបាត់ចោលនូវរចនាសម្ព័ន្ធនៃឋានានុក្រមនៃអំណាចនយោបាយឡើយ ហើយតាមពិត ទាំងរបប ប៉ុល ពត ក្តី និងរបបមុននោះក្តី មិនបានផ្អែកលើគោលការណ៍សមភាពនៃសិទ្ធិមនុស្សអ្វីទាំងអស់។ បន្ទាប់ពីរបប ប៉ុល ពត ដួលរលំ សង្គ្រាមស៊ីវិលនៅតែបន្ត ហើយប្រទេសកម្ពុជាបានទទួលរងការឈឺចាប់ពីការផ្លាស់ប្តូរជាច្រើន។ នៅក្នុងបរិបទនៃកង្វះក្របខ័ណ្ឌច្បាប់ និងភាពច្របូកច្របល់ខាងស្ថាប័ន រចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ច និងនយោបាយថ្មីៗបានកើតឡើង។ ប្រជាពលរដ្ឋ

១៨ Clavero, Bartolomé (2001): "Freedom's law and oeconomical status: The Euroamerican constitutional moment in the 18th century", in *Quaderni Fiorentini per la Storia del Pensiero Giuridico Moderno* No 30 (2001) T. I, p. 81-135.

១៩ ក្នុងចំណោមនោះមាន : Mabbet, Ian and David Chandler (1995): *The Khmers. The Peoples of South-East Asia and the Pacific.* Cambridge: Blackwell Publishers.

ក្រីក្រខ្លះបានសំដែងនូវការព្រួយបារម្ភរបស់ខ្លួន អំពីការហូរចូលអ្នកមានថ្មីៗ (*nouveaux riche*) ដែលហូរចូលមកជាមួយឡាន ទំនើបៗ និងអ្នកទាំងឡាយដែលទិញ ឬចាប់យកដីធ្លីរបស់ពួកគេដោយមានការគាំទ្រពីខាងក្រោយដោយមន្ត្រីសាធារណៈ ឬយោធាដែលមានអំណាច[២០]។ ប្រព័ន្ធថ្មីៗនៃបរិបាលកិច្ចតាមឋានានុក្រមត្រូវបានគេបង្កើត។ ការគោរពចាស់ទុំនិងអ្នក ដែលមានកិត្តិយស មើលទៅហាក់ដូចជាត្រូវបានគេផ្លាស់ប្តូរឱ្យទៅជាធិនិការធិបតេយ្យ (របបដែលគ្រប់គ្រងដោយ អ្នកមាន) ថ្មីមួយ ដែលមិនបានផ្តល់គតិបណ្ឌិតជាប្រពៃណី ឬយោបល់ណាមួយឡើយ តែនៅតែផ្តល់ការការពារ និងមានឥទ្ធិពល ដើម្បីទទួលផលប្រយោជន៍ពីសាធារណៈ ដែលច្បាប់ចែងថាជារបស់ជនគ្រប់រូប[២១]។ តាមមនោគមវិជ្ជា ស្តីពីប្រពៃណីគោរព ចាស់ទុំដែលមានកេរ្តិ៍ឈ្មោះ វិសមភាពខាងៗសេដ្ឋកិច្ចដែលកើតមានថ្មីៗនេះ មិនត្រូវបានគេមើលឃើញឡើយ។ នេះជាការ ប្រឈមមួយដ៏ធំរបស់ប្រទេសថា តើត្រូវធ្វើដូចម្តេចដើម្បីធានាឱ្យមានការគោរពសិទ្ធិមនុស្ស ដោយអាចទទួលយកបាន ដោយសមភាពសម្រាប់ជនគ្រប់រូប ក្នុងបរិបទនៃការរីកដុះដាលនៃអំពើពុករលួយ និងបរិបាលកិច្ច។

ភាពស្មើគ្នាគឺជាតម្រូវការមួយដ៏ចាំបាច់របស់ប្រជាពលរដ្ឋទាំងឡាយ ហើយជាមូលដ្ឋានសម្រាប់របបប្រជាធិបតេយ្យ។ បើពុំដូច្នោះទេ ស្ថាប័នទាំងឡាយមិនអាចធានាបាននូវភាពមិនលំអៀង និងយុត្តិធម៌បានឡើយ។ ឧទាហរណ៍ បើសិនជាមានចៅក្រម ណាម្នាក់ និយាយដោយគោរពជាមួយភាគីម្ខាងនៃវិវាទ តែបែរជានិយាយដោយគ្មានការគោរពចំពោះភាគីម្ខាងទៀតនោះ តើធ្វើដូចម្តេចធានាថា ចៅក្រមនោះអាចផ្តល់យុត្តិធម៌ជូនភាគីបាន បើសូម្បីតែអាការៈខាងក្រៅ សំដែងពីភាពមិនស្មើភាពទៅ ហើយនោះ។ ការផ្តល់នូវការធានាកម្រិតអប្បបរមា នូវឱកាសស្មើភាពគ្នា និងការទទួលបានយុត្តិធម៌ មិនត្រឹមតែជាកាតព្វកិច្ច របស់រដ្ឋដែលតម្រូវដោយច្បាប់ប៉ុណ្ណោះទេ តែវាក៏ជាសេចក្តីត្រូវការខាងនយោបាយផងដែរ ដើម្បីការពារកុំឱ្យមាន អំពើហិង្សាឬការបះបោរណាមួយ។ វប្បធម៌ជាប្រពៃណី ដូចជាការគោរពចាស់ទុំ និងជនដែលមានកិត្តិយស មិនត្រូវទុកទៅ ប្រើដើម្បីធ្វើជាលេស បិទបាំងនូវរចនាសម្ព័ន្ធសេដ្ឋកិច្ចមិនស្មើភាពបែបថ្មីណាមួយ និងដើម្បីគេចវេសពីដំណើរកសាងប្រជាធិបតេយ្យ ដ៏ចាំបាច់របស់ប្រទេសមួយនោះដែរ។

**ចំណុចប្រសព្វគ្នារវាងសិទ្ធិបុគ្គល និងសិទ្ធិមនុស្សជាក្រុម**

ក្នុងការអនុវត្តជាក់ស្តែង គម្លាតនៃយេនឌ័រ ស្ថានភាពសេដ្ឋកិច្ច ប្រភពដើមនៃពូជសាសន៍ ភាសា។ល។ អាចជាមូលហេតុ ដែលនាំឱ្យមានភាពមិនស្មើគ្នា រវាងបុគ្គលនិងមនុស្សជាក្រុម ដែលផ្ទុយពីគោលការណ៍សមភាព នៅក្នុងសង្គម។ ដូច្នេះការ អភិវឌ្ឍនៃទ្រឹស្តីសេរីភាពនៃសិទ្ធិមនុស្សបានវិវត្តន៍ឡើង ដើម្បីទទួលស្គាល់សិទ្ធិជាក់លាក់របស់ក្រុមជនទន់ខ្សោយដែលងាយ រងគ្រោះ ដើម្បីធានាឱ្យមានសមភាពទាំងសិទ្ធិបុគ្គល ទាំងសិទ្ធិមនុស្សជាក្រុម ព្រមទាំងកុំឱ្យមានការរើសអើងតាម

---

២០ មានអ្នកចូលរួមក្នុងសិក្ខាសាលាខ្លះ និងអ្នកដែលក្រុមការងារបានសម្ភាសមួយចំនួនបានលើកឡើងពីការបារម្ភយ៉ាងខ្លាំងចំពោះបញ្ហាវិវាទដីធ្លីដោយហេតុថា មានអ្នកមានៗជាច្រើនបានប្រមូលយកដី ដើម្បីទុកលក់យកប្រាក់ចំណេញទៅពេលក្រោយផ្លូវត្រូវបានសាងសង់រួច។ ការធ្វើអាជីវកម្មរកប្រាក់ចំណេញ ដោយការទិញដីទុកសម្រាប់លក់នេះ កើតមានជាច្រើនដោយហេតុផលកង្វះនៃក្របខណ្ឌច្បាប់ និងការអនុវត្តច្បាប់ភូមិបាលគ្មានប្រសិទ្ធិភាព។ ស្ថានភាពនេះ បង្កឱ្យមានបាតុភាពដ៏គ្រោះថ្នាក់ចំពោះសង្គម។ ជាឧទាហរណ៍ មានអ្នកខ្លះសុខចិត្តបង់លុយមួយចំនួនឱ្យទៅក្រុមអ្នកមាន ដើម្បីឱ្យខ្លួនអាចចូលជាផ្នែកមួយ នៃប្រព័ន្ធបរិបាលកិច្ច ដោយសង្ឃឹមថាធ្វើដូច្នោះអាចឱ្យពួកគេទទួលបានផលប្រយោជន៍កម្រិតណាមួយជាយថាហេតុ។ មានអ្នកខ្លះទៀត បានលើកឡើងអំពី អំណាចផ្តាច់ការរយៈពេលយូរអង្វែងនៃអតីតកាល ដែលអាចជាគ្រោះថ្នាក់យ៉ាងខ្លាំងចំពោះស្ថេរភាពនយោបាយរបស់សង្គម "នៅក្នុងរបប ប៉ុល ពត យើងទាំងអស់គ្នាក្រយ៉ាងខ្លាំង តែយើងទាំងអស់គ្នាស្មើភាពគ្នានៅក្នុងសង្គម។ ពុំមានអ្នកមានលុយច្រើនហូរហៀរដូចនៅបច្ចុប្បន្នកាលនេះឡើយ"។ ហើយជាពិសេសក្នុងចំណោមយុវជនខ្លះព្យាយាមប្រព្រឹត្តិបទល្មើសផ្សេងៗដើម្បីទទួលអ្វីដែលសង្គមមិនអាចផ្តល់ឱ្យពួកគេបាន។

២១ ជាឧទាហរណ៍ មានអ្នកចូលរួមក្នុងសិក្ខាសាលាខ្លះ ក៏ដូចជាអ្នកដែលក្រុមការងារបានសម្ភាសជាមួយ បានត្អូញត្អែរថា គ្រប់ការធ្វើអាជីវកម្មទាំងឡាយណា ដែលតម្រូវឱ្យមានការអនុញ្ញាតពីស្ថាប័នរដ្ឋ ទោះបីជាការរកស៊ីតូចតាចក៏ដោយ ចាំបាច់ត្រូវតែមានការគាំទ្រពីក្រោយខ្នង ដោយអ្នកមានឋានៈខ្ពស់ ឬយោធាជាដើម ។ បើពុំនោះទេ នគរបាល និងមន្ត្រីនៅជាន់ទាបៗ នឹងទៅទារលុយមិនចេះចប់ឡើយ ដើម្បីឱ្យអាជីវកម្មនោះអាចដំណើរការទៅបាន។

ទម្រង់ណាមួយឡើយ។ សិទ្ធិជាក់លាក់របស់ក្រុមជនទន់ខ្សោយទាំងនេះ ត្រូវបានគេចែងបញ្ចូលទៅក្នុងអនុសញ្ញា និងសិទ្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិស្ត្រី សិទ្ធិកុមារ សិទ្ធិជនជាតិភាគតិច និងសិទ្ធិរបស់ជនជាតិដើមភាគតិចនានារួចហើយ[២២]។ សិទ្ធិជាក្រុមត្រូវបានគេយល់ថា ជាកត្តាមួយក្នុងការធានាមួយចំនួនចំពោះក្រុមមនុស្សខុសៗគ្នា រួមទាំងនាំឱ្យមានការគោរព និងធ្វើឱ្យជាក់ស្តែងនូវសិទ្ធិរបស់បុគ្គលនីមួយៗ។

ក្នុងករណីសង្គមពហុវប្បធម៌ ដែលមានភាសាផ្លូវការនិងវប្បធម៌តែមួយ ដែលជារបស់ក្រុមជាតិពន្ធុដែលមានសមាជិកច្រើនលើសគេនោះ បុគ្គលដែលជាសមាជិកនៃក្រុមជាតិពន្ធុច្រើននោះ នឹងមានផលប្រយោជន៍ច្រើន តែដោយឡែកបុគ្គលដែលនៅក្រុមផ្សេងៗទៀតដែលជាក្រុមភាគតិចនោះ បែរជាមិនអាចទទួលនូវសេរីភាព និងសមភាព ដូចអ្វីដែលបុគ្គលដែលជាសមាជិកនៃក្រុមភាគច្រើនមានឡើយ។ ដូច្នេះទើបនាំឱ្យមានអ្នកនិពន្ធដើម្បីសេរីភាពខ្លះ ចាប់ផ្តើមនិយាយអំពី "យុត្តិធម៌តាមវប្បធម៌ជាតិពន្ធុ (ethnocultural Justice)" ដែលសំដៅលើសមភាពជាអប្បបរមា ដែលត្រូវតែមានសម្រាប់ក្រុមជាតិពន្ធុភាគតិចនានានៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីធានានូវអត្តសញ្ញាណ និងមានឱកាសដោយស្មើភាពរបស់ពួកគេ[២៣]។

## ១.២. គោលគំនិតស្តីពីសិទ្ធិទទួលបានយុត្តិធម៌

### ១.២.១. សិទ្ធិទទួលបានយុត្តិធម៌ដោយផ្តោតលើ "ការដោះស្រាយវិវាទជាក់ស្តែង"

គោលគំនិតជាទូទៅមួយស្តីពីសិទ្ធិទទួលបានយុត្តិធម៌ គឺជាសិទ្ធិទទួលបាននូវយន្តការមួយប្រកបដោយប្រសិទ្ធិភាព និងយុត្តិធម៌សម្រាប់ "ដោះស្រាយវិវាទឬទំនាស់" ដែលវិវាទទាំងនោះ ភាគច្រើនជាទំនាស់ផលប្រយោជន៍រវាងភាគី [២៤]។ ការរៀបចំគម្រោងសិក្សា និងគោលនយោបាយស្តីពីសិទ្ធិទទួលបានយុត្តិធម៌ ដែលពឹងផ្អែកទាំងស្រុងទៅលើគោលគំនិតនេះ គឺវាជាប់ពាក់ព័ន្ធជាមួយនឹងវិវាទ និងទំនាស់ជាចម្បងៗរវាងបុគ្គលនានា (រួមទាំងវិវាទរវាងជនក្រីក្រនិងភាគីអ្នកមានអំណាច) និងយន្តការផ្សេងៗ ដែលប្រជាពលរដ្ឋប្រើប្រាស់ដើម្បីដោះស្រាយវិវាទប្រកបដោយប្រសិទ្ធិភាពបំផុត ក្នុងការឆ្លើយតបចំពោះរាល់វិវាទដែលកើតមាននៅក្នុងសង្គម។ ទោះជាយ៉ាងនេះក្តី ស្ថានភាពមួយចំនួនដូចជាអំពើពុករលួយ ការឃុំខ្លួនដោយខុសច្បាប់ ឬកង្វះខាតនូវការគោរពសិទ្ធិសង្គម មិនត្រូវបានលេចចេញជាផ្នែកមួយនៃតម្រូវការយុត្តិធម៌ក្នុងសង្គម តាមគោលការណ៍

---

២២ សូមមើលឧបសម្ព័ន្ធទី ១.១. ស្តីពីក្របខ័ណ្ឌច្បាប់ស្តីពីសិទ្ធិទទួលបានយុត្តិធម៌ និង សិទ្ធិមនុស្សនៅកម្ពុជា។

២៣ សូមមើល : Kymlicka, Will (2001): *Politics In the vernacular. Nationalism, multiculturalism and citizenship*. Part II, Chapter 4: "Human rights and ethnocultural Justice" (p. 69-90).

២៤ ជាឧទាហរណ៍នៃគោលគំនិតនេះ គឺត្រូវបានគេយកមកប្រើនៅក្នុងគម្រោងសិក្សាមួយរបស់ធនាគារពិភពលោកនៅកម្ពុជា ក្នុងវិស័យសិទ្ធិទទួលបានយុត្តិធម៌តាមរយៈយន្តការមួយដែលប្រកបដោយតម្លាភាពត្រឹមត្រូវ និងចំណាយតិចដើម្បីដោះស្រាយវិវាទ។ ដូចនេះ "កម្មវិធីយុត្តិធម៌សម្រាប់ជនក្រីក្រនឹងធ្វើការសិក្សាពីគ្រប់ប្រព័ន្ធនិងយន្តការដោះស្រាយវិវាទដែលមាន ថាតើប្រព័ន្ធនីមួយៗមានប្រសិទ្ធិភាពកម្រិតណា និងហេតុអ្វីបានជាមានប្រសិទ្ធិភាព...។ល។" គោលបំណងនៃកម្មវិធីនេះ គឺដើម្បីកែលំអនូវរបៀបវារៈកំណែទម្រង់ ដែលកំណត់អំពីសកម្មភាពជាក់លាក់នានា និងកែលំអការដោះស្រាយវិវាទដែលជាប់ពាក់ព័ន្ធនឹងជនក្រីក្រ ដើម្បីឱ្យដំណោះស្រាយទាំងនោះ ត្រូវបានធ្វើឡើងដោយយុត្តិធម៌ និងប្រកបដោយសមភាព"។ សូមមើល World Bank Cambodia: *Justice for the Poor Program. Concept Note*. Phnom Penh: World Bank, May 2005 (p. 1-2). និយមន័យមួយទៀត ដែលស្រដៀងគ្នានេះផងដែរ (តែស្ថិតក្នុងក្របខ័ណ្ឌទូលាយជាង) ត្រូវបានកំណត់ដោយកម្មវិធីថ្នាក់តំបន់របស់អង្គការ UNDP ស្តីពីសិទ្ធិទទួលបានយុត្តិធម៌: "អ្វីទៅជាសិទ្ធិទទួលបានយុត្តិធម៌? ប្រជាពលរដ្ឋត្រូវការឱ្យមានការដោះស្រាយដើម្បីការពារខ្លួន ក្នុងករណីដែលមានការបង្កអន្តរាយដែលបណ្តាលមកពីអ្នកដទៃ នៅពេលដែលខ្លួនពាក់ព័ន្ធក្នុងវិវាទនានា។ ការដោះស្រាយគឺជាវិធានការជួសជុលមហន្តរាយនេះ ដូចជាតាមរយៈសំណងការខូចខាត ឬ ការសងនូវអ្វីដែលបានខាតបង់ ឬខូចខាត...។ល។ អង្គការ UNDP បានកំណត់និយមន័យសិទ្ធិទទួលបានយុត្តិធម៌ថា "ជាលទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការស្វែងរក និងទទួលបានការដោះស្រាយតាមរយៈស្ថាប័នយុត្តិធម៌ផ្លូវការ និងក្រៅផ្លូវការ ដោយស្របតាមនិយាមសិទ្ធិមនុស្ស"។ សូមមើល : United Nations Development Programme: *Programming for Justice Access for All. The Access to Justice Practitioner's Guide*. UNDP Asia Pacific Rights and Justice Initiative, April 2005 (p. 4). (*Hereinafter* UNDP Asia Pacific, 2005).

នេះឡើយ ព្រោះថាស្ថានភាពទាំងនោះមិនបានឆ្លុះបញ្ចាំងអំពីវិវាទជាក់ស្តែងរវាងបុគ្គលឡើយ តែអាចថាជាផ្នែកមួយនៃបរាជ័យរបស់រដ្ឋចំពោះប្រជាពលរដ្ឋរបស់ខ្លួនទៅវិញ។ អំពើពុករលួយដែលកើតមានជារៀងរាល់ថ្ងៃក្នុងការផ្តល់សេវាសាធារណៈគឺជាឧទាហរណ៍មួយយ៉ាងច្បាស់លាស់ ដែលបញ្ជាក់ពីការរងទុក្ខរបស់ប្រជាពលរដ្ឋពីបញ្ហានេះ ប៉ុន្តែពុំមានបណ្តឹងផ្លូវការណាមួយធ្វើឡើងប្រឆាំងនឹងអំពើទាំងនោះទេ ដោយប្រជាពលរដ្ឋពុំមានទំនុកចិត្តឬក៏សង្ឃឹមថាស្ថាប័នដែលមានស្រាប់បច្ចុប្បន្ននេះ អាចជួយ "ដោះស្រាយ" បញ្ហានេះជូនពួកគេបាន។ កង្វះនូវការគោរពសិទ្ធិសង្គមនានាដូចជា សិទ្ធិក្នុងការទទួលបានការអប់រំជាមូលដ្ឋាន សិទ្ធិខាងសុខាភិបាល ។ល។ (បណ្តាលមកពីអំពើពុករលួយ ឬខ្វះខាតនូវកាខិតខំរបស់រដ្ឋក្នុងការធានានូវសិទ្ធិទាំងនោះ) ក៏ត្រូវបានប្រជាពលរដ្ឋមើលឃើញថាជា "ស្ថានភាពអយុត្តិធម៌" ឬ "បញ្ហា" ឬជាកម្មវាសនាដែលកើតចេញពីភាពក្រីក្រ តែពួកគេមិនបានចាត់ទុកថាជា "ការរំលោភលើសិទ្ធិ" ដែលពួកគេអាចទាមទារសំណងខាងផ្លូវច្បាប់ ដោយប្តឹងតវ៉ាទៅស្ថាប័នមានសមត្ថកិច្ចណាមួយឡើយ លើកលែងតែការរំលោភសិទ្ធិនោះមានលក្ខណៈធ្ងន់ធ្ងរហួសហេតុ[២៥]។ ជាទូទៅ ករណីទាំងនេះកម្រក្លាយជា "រឿងក្តី" ណាស់ ដោយហេតុថាភាគីដែលរងការប៉ះពាល់កម្រប្តឹងណាស់ ដូចនេះ "រាល់ការដោះស្រាយវិវាទ" មិនបានចាត់ទុកថាស្ថានភាពនេះជាផ្នែកមួយនៃតម្រូវការយុត្តិធម៌ក្នុងសង្គមនៃសិទ្ធិទទួលបានយុត្តិធម៌ឡើយ។ ដោយហេតុនេះ គោលគំនិតនេះមិនបានផ្តល់អាទិភាពចំពោះអនុសាសន៍ទាំងឡាយ ដែលទាក់ទិននឹងរបៀបក្នុងការស្វែងរកយុត្តិធម៌ នៅពេលមានការរំលោភអំណាច អំពើពុករលួយ ឬនៅពេលមានកង្វះខាតក្នុងការធានាដល់សិទ្ធិសង្គមឡើយ[២៦] ។

### ១.២.២. សិទ្ធិទទួលបានយុត្តិធម៌ ដោយផ្អែកលើគោលការណ៍សិទ្ធិមនុស្ស

តាមគោលការណ៍សិទ្ធិមនុស្ស សិទ្ធិទទួលលបានយុត្តិធម៌មានន័យធំទូលាយជាងគោលគំនិត ដែលផ្តោតសំខាន់តែទៅលើ "ការដោះស្រាយវិវាទដែលកើតមាន" ហើយវាពាក់ព័ន្ធនឹងកត្តាជាច្រើន។

- ទីមួយ សិទ្ធិទទួលបានយុត្តិធម៌ត្រូវបានគេឱ្យនិយមន័យថាជាសិទ្ធិ។ ទស្សនាទាននេះគឺវាបញ្ចូលទាំងគោលគំនិតស្តីពីកាតព្វកិច្ច និងការធានាផងដែរ។
- ទីពីរ សិទ្ធិទទួលបានយុត្តិធម៌ ត្រូវបានគេមើលឃើញថាជាការឆ្លើយតបចំពោះតម្រូវការរបស់សង្គមយ៉ាងធំធេង ពោលគឺមិនត្រឹមតែសំដៅលើដំណោះស្រាយវិវាទ ដែលកើតមានជាក់ស្តែងរវាងភាគីប៉ុណ្ណោះទេ វាក៏គ្របដណ្តប់ផងដែរចំពោះការការពារសិទ្ធិមនុស្ស និងត្រួតពិនិត្យការរំលោភអំណាចទាំងឡាយ ចំពោះការប្តឹងទាមទារជាសក្តានុពល ក៏ដូចជាជាវិវាទជាក់ស្តែងរវាងប្រជាពលរដ្ឋជាមួយនឹងរដ្ឋ។

---

២៥ មានអត្ថបទកាសែតក្នុងស្រុកមួយបានចុះផ្សាយពីករណីមួយទាក់ទិននឹងការធ្វេសប្រហែសយ៉ាងខ្លាំងរបស់គ្រូពេទ្យ ដែលនាំឱ្យអ្នកជំងឺម្នាក់ស្លាប់ដោយសារការធ្វេសប្រហែសនេះ។ សាច់ញាតិរបស់ជនរងគ្រោះបានអះអាងថា ដោយសារតែជនរងគ្រោះ និងគ្រួសារពុំមានថវិកាគ្រប់សម្រាប់បង់ប្រាក់ឈ្នួលក្រោមតុ ហើយពួកគេជាអ្នកក្រមិនដឹងថាត្រូវប្តឹងទៅអ្នកណា។

២៦ មានការសិក្សាស្រាវជ្រាវជាច្រើននៅកម្ពុជា ដែលបានចេញជារបាយការណ៍ និងខ្លះកំពុងសិក្សានៅឡើយ ដោយផ្តោតសំខាន់លើ "គោលការណ៍ដោះស្រាយវិវាទ" ជាពិសេសនៅថ្នាក់មូលដ្ឋាន។ រាល់ការសិក្សាទាំងនោះ គេតែងតែបញ្ចូលនូវសំណួរមួយចំនួនដើម្បីកំណត់អំពីវិវាទ ឬទំនាស់ផ្សេងៗ និងពីរបៀបដោះស្រាយបញ្ហាទាំងនោះ។ ការសិក្សាទាំងនោះ មិនបានពិចារណាអំពីតម្រូវការយុត្តិធម៌ក្នុងសង្គមទាំងឡាយ ដែលប្រជាពលរដ្ឋមិនបានប្តឹងទៅស្ថាប័នណាមួយ ដូចជាអំពើពុករលួយ និងការរំលោភសិទ្ធិបុគ្គល និងសិទ្ធិសង្គម។ សូមមើល : Hughes, Caroline: *An investigation of conflict management in Cambodian villages. A review of the literature with suggestions for future research.* Phnom Penh: Centre for Peace and Development and Cambodia Development Resource Institute, 2001; Luco, Fabienne: *Between a tiger and a crocodile. Management of local conflicts in Cambodia. An anthropological approach to traditional and new practices.* UNESCO: Phnom Penh, 2002; Ninh Kim and Roger Henke: *Commune Councils in Cambodia: A national survey on their functions and performance, with a special focus on conflict resolution.* Phnom Penh: The Asia Foundation in collaboration with the Center for Advanced Study, May 2005; Diprose Rachel, Payton Deeks and Sovothikar Invong: *Dispute Resolution and Commune Councils in Cambodia: A study of conflict and best practices for peace.* Phnom Penh: USAID and The Asia Foundation (draft Sept. 2005).

- ទីបី គោលការណ៍សិទ្ធិមនុស្ស បានយកចិត្តទុកដាក់សំខាន់ទៅលើតម្រូវការយុត្តិធម៌ជាក់ស្តែងនានា (ពោលគឺករណីដែលភាគីបានប្តឹងទៅអាជ្ញាធររួចហើយ) ព្រមទាំងតម្រូវការយុត្តិធម៌ជាសក្តានុពលផងដែរ។ តម្រូវការយុត្តិធម៌ជាសក្តានុពលអាចឆ្លុះបញ្ចាំងពីការយល់ដឹងអំពីសិទ្ធិ ក៏ដូចជាការខ្វះខាតនូវយន្តការនានា ដើម្បីឱ្យប្រជាពលរដ្ឋប្តឹងទាមទារនូវសេចក្តីត្រូវការទាំងនោះ។
- ទីបួន គោលការណ៍សិទ្ធិមនុស្ស យកចិត្តទុកដាក់ផងដែរចំពោះភ្នាក់ងារនានា និងយន្តការទាំងឡាយ ដែលកំពុងផ្តល់សេវាកម្មយុត្តិធម៌ជូនប្រជាពលរដ្ឋ ក៏ដូចជាដំណើរការនិងលទ្ធផលនៃការផ្តល់សេវាយុត្តិធម៌ទាំងនោះ ដើម្បីធានាឱ្យបានថាការផ្តល់សេវានេះ ពិតជាឆ្លើយតបនឹងតម្រូវការយុត្តិធម៌ក្នុងសង្គម និងស្របតាមនិយាមសិទ្ធិមនុស្សមែន។
- ទីប្រាំ គោលការណ៍សិទ្ធិមនុស្សនេះជាភស្តុតាងនៃទំនាក់ទំនងរវាងសិទ្ធិទទួលបានយុត្តិធម៌ និងតម្រូវការនៃស្ថាប័នប្រជាធិបតេយ្យ និងការអនុវត្តដើម្បីធានានូវការគោរពសិទ្ធិមនុស្ស។
- ទីប្រាំមួយ សិទ្ធិទទួលបានយុត្តិធម៌ តាមគោលការណ៍សិទ្ធិមនុស្សដើរតួយ៉ាងសំខាន់ ក្នុងការវិភាគអំពីស្ថានការណ៍ជាក់ស្តែងរបស់សង្គម និងអាចផ្តល់នូវទ្រឹស្តីនិងឧបករណ៍ជាវិធីសាស្ត្រ សម្រាប់ការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍគោលនយោបាយផងដែរ។

## សិទ្ធិទទួលបានយុត្តិធម៌: និយមន័យ និងខ្លឹមសារ

សិទ្ធិទទួលបានយុត្តិធម៌ ត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងឧបករណ៍អន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស[២៧]។ គោលគំនិតដែលថាសិទ្ធិទទួលបានយុត្តិធម៌ គឺជាសិទ្ធិជាកត្តាមួយដ៏មានសារៈសំខាន់។ មានន័យថាប្រជាពលរដ្ឋមានសិទ្ធិប្តឹងទាមទារកយុត្តិធម៌។ ប្រជាពលរដ្ឋមិនមាន និងមិនគួរមានកាតព្វកិច្ចទៅសុំសេវាយុត្តិធម៌ដោយមានការបង់ប្រាក់ក្រោមតុឡើយ[២៨]។ បន្ថែមលើនេះទៀត ដោយសិទ្ធិទាំងនេះត្រូវបានការពារជាអន្តរជាតិ ព្រោះរដ្ឋមានកាតព្វកិច្ចជាអន្តរជាតិក្នុងការការពារ និងធានានូវសិទ្ធិទាំងនោះ ដូចនេះនៅពេលប្រជាពលរដ្ឋមិនអាចរកយុត្តិធម៌នៅក្នុងប្រទេសរបស់ខ្លួនបាន ពួកគេអាចប្រើប្រាស់យន្តការអន្តរជាតិ ដើម្បីទាមទារនូវការធានា និងផ្តល់នូវសិទ្ធិទាំងនោះ។

និយមន័យ "*សិទ្ធិទទួលបានយុត្តិធម៌*" ក្នុងន័យប្រតិបត្តិអាចជា:

លទ្ធភាពរបស់បុគ្គលម្នាក់ក្នុងការស្វែងរក និងទទួលបាននូវការឆ្លើយតបមួយប្រកបដោយប្រសិទ្ធិភាព និងយុត្តិធម៌ ដើម្បីដោះស្រាយវិវាទ ការពារសិទ្ធិ និងត្រួតពិនិត្យការរំលោភអំណាច តាមរយៈយន្តការមួយប្រកបដោយតម្លាភាព គណនេយ្យភាព និងមានតម្លៃសមរម្យ"។ យន្តការនេះ ត្រូវតែមានលក្ខណៈឆ្លើយតបទៅនឹងតម្រូវការសង្គម និងយកចិត្តទុកដាក់ចំពោះបញ្ហាយេនឌ័រ ភាសា និងវប្បធម៌។

---

២៧ សូមមើលឧបសម្ព័ន្ធទី ១.១. ស្តីពីក្របខ័ណ្ឌច្បាប់ស្តីពីសិទ្ធិទទួលបានយុត្តិធម៌ និង សិទ្ធិមនុស្សនៅកម្ពុជា។

២៨ ទស្សនាទានដែលថា សិទ្ធិទទួលបានយុត្តិធម៌ គឺជាសិទ្ធិ ជាការមួយសំខាន់ណាស់នៅក្នុងបរិបទនៃសង្គម នៅពេលដែលសេវាសាធារណៈត្រូវបានគេមើលឃើញថាជា "ក្តីអនុគ្រោះ" ដែលតម្រូវឱ្យពលរដ្ឋបង់ប្រាក់ក្រោមតុខុសច្បាប់ ជាថ្នូរនឹងសេវាទាំងនោះ។ ក្នុងចំណោមយន្តការផ្តល់សេវាកម្មយុត្តិធម៌ តុលាការត្រូវបានគេរកឃើញថាជាស្ថាប័នដែលពុករលួយជាងគេ នេះបើ យោងតាមអ្វីដែលប្រជាពលរដ្ឋបានលើកឡើង។ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) បានបោះពុម្ពឯកសារជាច្រើនទាក់ទិននឹងអំពើពុករលួយនៅក្នុងសេវាសាធារណៈ។ ឯកសារទាំងនោះមានដូចជា: CSD (1998): *National Survey on Public Attitudes Towards Corruption*. Phnom Penh: CSD. This research was followed by "The Impact of and Attitudes Towards Corruption, November 2003 – April 2005", also published by CSD (2005): and available at: http://www.bigpond.com.kh/users/csd/cs.htm.

តារាងសង្ខេបពីខ្លឹមសារ និងលក្ខណៈនៃសិទ្ធិទទួលបានយុត្តិធម៌

| | |
|---|---|
| ខ្លឹមសារនៃសិទ្ធិ | ១. ដោះស្រាយវិវាទ<br>២. ការពារសិទ្ធិ<br>៣. ត្រួតពិនិត្យការរំលោភអំណាច |
| លក្ខណៈនៃសេវាកម្មយុត្តិធម៌ | • អាចរកបាន : នៅជិតប្រជាពលរដ្ឋ ចំណាយតិច យល់ពីវប្បធម៌ និងភាសា<br>• យុត្តិធម៌ (ត្រឹមត្រូវ)<br>• ប្រសិទ្ធិភាព<br>• ឆ្លើយតបចំពោះសេចក្ដីត្រូវការសង្គម<br>• យកចិត្តទុកដាក់ចំពោះបញ្ហាខាងវប្បធម៌ ភាសា ជាតិពន្ធុ និងយេនឌ័រ<br>• ប្រជាធិបតេយ្យ : នីតិវិធីមានតម្លាភាព និងគោរពតាមនីតិវិធីច្បាប់<br>• ដោយសន្តិភាព: រាល់ការប្រើកម្លាំង និងការបង្ខំត្រូវធ្វើឡើងដោយស្របតាមច្បាប់ និងបទបញ្ញត្តិនានា ហើយប្រើតែក្នុងជំរើសចុងក្រោយប៉ុណ្ណោះ<br>• មានគណនេយ្យភាព : ត្រូវមានការត្រួតពិនិត្យមើលរាល់សកម្មភាពរបស់អាជ្ញាធរ និងវិធានការជាក់លាក់នានា |

ខ្លឹមសារនៃសិទ្ធិទទួលបានយុត្តិធម៌ ការពារសិទ្ធិមនុស្ស និងត្រួតពិនិត្យការរំលោភអំណាច នៅក្នុងនីតិរដ្ឋ

គោលគំនិតទីមួយនៃសិទ្ធិទទួលបានយុត្តិធម៌ តាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ គឺសំដៅលើសិទ្ធិក្នុងការទទួលបាននូវការដោះស្រាយដ៏មានប្រសិទ្ធិភាព ចំពោះរាល់ការរំលោភសិទ្ធិនានា ហើយការដោះស្រាយនេះត្រូវស្របទៅនឹងអ្វីដែលធានាដោយរដ្ឋធម្មនុញ្ញ និងឧបករណ៍អន្តរជាតិស្ដីពីសិទ្ធិមនុស្ស។ សិទ្ធិទទួលបានយុត្តិធម៌សម្រាប់ការពារសិទ្ធិនានា ត្រូវបានចាត់ទុកជាពិតជាសំខាន់ណាស់សម្រាប់រាល់គោលគំនិតស្ដីពីសិទ្ធិមនុស្ស។ ការទទួលស្គាល់សិទ្ធិទាំងឡាយ តម្រូវឱ្យមានការធានាការពារយ៉ាងមានប្រសិទ្ធិភាពចំពោះសិទ្ធិទាំងនោះ នៅពេលដែលមានការរំលោភ។ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ដែលអនុម័តនៅឆ្នាំ១៩៤៨ (មាត្រា៨) ចែងថា: "ជនគ្រប់រូបមានសិទ្ធិទទួលបាននូវដំណោះស្រាយដ៏មានប្រសិទ្ធិភាព ដោយសាលាជំរះក្ដីជាតិដែលមានសមត្ថភាព ចំពោះរាល់អំពើទាំងឡាយណាដែលរំលោភលើសិទ្ធិជាមូលដ្ឋានរបស់គេ ដែលបានធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់" កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)[២៩] ដែលអនុម័តដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៦៦ និងចុះហត្ថលេខាដោយកម្ពុជានៅឆ្នាំ១៩៩២ មានការកំណត់អំពីសិទ្ធិនេះកាន់តែទូលាយថែមទៀត រួមទាំងមានការការពារនូវរាល់សិទ្ធិទាំងឡាយ ដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិទៀតផង គឺមិនត្រឹមតែរដ្ឋធម្មនុញ្ញ ឬច្បាប់ជាតិប៉ុណ្ណោះទេ។ កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែងនូវរាល់ការរំលោភបំពានលើសិទ្ធិទាំងនេះ ទោះបីរំលោភដោយបុគ្គលឯកជនក្ដី ឬអាជ្ញាធរសាធារណៈក្ដី ព្រមទាំងចែងផងដែរអំពីការធានាអនុវត្តនូវដំណោះស្រាយ ដែលបានធ្វើឡើងដោយតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃៗទៀត (មាត្រា ៣): ដោយចែងថា "រដ្ឋជាភាគីនៃកតិកាសញ្ញានេះមានភារកិច្ចៈ ក.ត្រូវធានាថា ត្រូវមានដំណោះស្រាយដ៏មានប្រសិទ្ធិភាពមួយ សម្រាប់ជនណាម្នាក់ក៏ដោយ ដែលសិទ្ធិឬសេរីភាពរបស់គេដែលបានទទួលស្គាល់ក្នុងកតិកាសញ្ញានេះត្រូវបានរំលោភបំពាន ទោះបីជាការរំលោភនេះបានប្រព្រឹត្តិដោយភ្នាក់ងារដែលបំពេញបេសកកម្មជាផ្លូវការក៏ដោយ។ ... គ. ធានាថាអាជ្ញាធរមានសមត្ថកិច្ចត្រូវតែអនុវត្តនូវដំណោះស្រាយនោះ ក្រោយពីមានការសម្រេចរួចហើយ។"

---

២៩ សូមមើលអត្ថបទពេញនៅ : http://www.ohchr.org/english/law/ccpr.htm

អត្ថិភាពនៃប្រព័ន្ធធានាដល់ការគោរពសិទ្ធិនិងសេរីភាព គឺជាគោលគំនិតដែលជាប់ដោយផ្ទាល់ជាមួយគោលការណ៍បែងចែកអំណាច។ នៅក្នុងសង្គមប្រជាធិបតេយ្យ រដ្ឋធម្មនុញ្ញតែងចែងពីការបែងចែកអំណាច និងប្រព័ន្ធតុល្យភាពអំណាច ដើម្បីការពារនិងត្រួតពិនិត្យការរំលោភអំណាច។ បើសិនជាមានអាជ្ញាធរណាមួយ ឬបុគ្គលណាម្នាក់ដែលបំពេញមុខងារជាផ្លូវការ ទាញយកផលប្រយោជន៍ពីមុខងាររបស់ខ្លួននោះ មានន័យថាគេរំលោភច្បាប់ ហើយករណីនេះរដ្ឋធម្មនុញ្ញចាត់ទុកជាការរំលោភអំណាច។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ (វិសោធនកម្មឆ្នាំ១៩៩៩) បានកំណត់អំពីមុខងាររបស់តុលាការក្នុងការត្រួតពិនិត្យមើលសកម្មភាពរបស់រដ្ឋ ឬស្ថាប័នណាមួយ ដែលរំលោភលើគោលការណ៍នីតិរដ្ឋ (មាត្រា ៣៩) : ដោយចែងថា "ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជូសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជូសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ។"

សិទ្ធិដែលត្រូវគេរំលោភអាចជាសិទ្ធិបុគ្គលឬជាសិទ្ធិសមូហភាព ដែលក្នុងនោះអាចជាសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌ជាដើម។

មានសេរីភាពពេញលេញ: ច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្សការពារគ្រប់បុគ្គលទាំងអស់ ប្រឆាំងនឹងការរំលោភលើសិទ្ធិសេរីភាពតាមគ្រប់រូបភាព។ ឧទាហរណ៍ បើសិនជានគរបាល ឬមន្ត្រីតំណាងឱ្យអង្គការនីតិប្រតិបត្តិណាម្នាក់ រំលោភអំណាចដូចជាការចាប់ខ្លួនដោយខុសច្បាប់ ការវាយធ្វើទារុណកម្ម ឬការរំខាន ឬរំលាយការជួបជុំប្រមូលផ្តុំនានា នោះតុលាការមានកាតព្វកិច្ចត្រួតពិនិត្យការប្រើអំណាចហួសកំណត់នោះ ហើយនិងធានាឬផ្តល់នូវសិទ្ធិសេរីភាពដែលត្រូវបានគេរំលោភនោះវិញ។ ជាជំហានដំបូង កាតព្វកិច្ចរបស់រដ្ឋ (តួនាទីរបស់រដ្ឋាភិបាល) ទាក់ទិនជាចម្បងនឹងភាពមិនរំខាន និងបង្ការកុំឱ្យមានការរារាំងសេរីភាពដោយខុសច្បាប់។ ធ្វើដូច្នោះ បុគ្គលគ្រប់រូបអាចអនុវត្តនូវសិទ្ធិសេរីភាពរបស់ខ្លួនពេញលេញ។ ប៉ុន្តែបើសិនជាមានការធ្វើអន្តរាគមន៍ពីនគរបាល ដែលរារាំងដល់សេរីភាពរបស់បុគ្គលដោយខុសច្បាប់នោះ រដ្ឋមានកាតព្វកិច្ចធ្វើអន្តរាគមន៍តាមរយៈស្ថាប័នមួយទៀត ជាពិសេសតុលាការ ដើម្បីត្រួតពិនិត្យការរំលោភអំណាចនេះ។

**គោរពនីតិវិធីច្បាប់:** ការគោរពនីតិវិធីច្បាប់ មានកំណត់អំពីសិទ្ធិផ្សេងៗ និងធានាដល់ការការពារបុគ្គល នៅក្នុងករណីដែលពួកគេប្រឈមនឹងចំណាត់ការក្តីព្រហ្មទណ្ឌ ដូចជាគោលការណ៍សច្ចធារណ៍នៃនិរទោស (សន្មតថាគ្មានទោស) សិទ្ធិទទួលបានមេធាវី សិទ្ធិទទួលបានអ្នកបកប្រែបើចាំបាច់ សិទ្ធិទទួលបានការជំនុំជំរះដោយទាន់ពេលនៅចំពោះមុខចៅក្រម (មាត្រា ៩.៣ នៃ ICCPR) សិទ្ធិឱ្យតុលាការត្រួតពិនិត្យលើរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសាធារណៈ សិទ្ធិទទួលបានសំណងខូចខាតសម្រាប់ ការ-ចាប់ខ្លួនដោយខុសច្បាប់ (មាត្រា ៩.៥ នៃ ICCPR) និងសិទ្ធិដទៃៗទៀត។ ក្នុងករណីនេះ រដ្ឋមានកាតព្វកិច្ចធ្វើអន្តរាគមន៍ដើម្បីធានាឱ្យមានអ្នកការពារក្តីសាធារណៈ (មេធាវី) ធានាឱ្យចៅក្រមត្រួតពិនិត្យលើការបំពេញមុខងាររបស់នគរបាល ធានាឱ្យមានលក្ខខណ្ឌសមរម្យសម្រាប់ពន្ធនាគារ ធានាឱ្យមានការយកចិត្តទុកដាក់ពិសេសសម្រាប់ជនរងគ្រោះដោយ បទល្មើសដូចដែលមានចែងនៅក្នុងសេចក្តីប្រកាស ស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋាន សម្រាប់ជនរងគ្រោះនៃបទព្រហ្មទណ្ឌ ឬការរំលោភអំណាច (១៩៨៥)។ល។ សេចក្តីសង្ខេបនៃសិទ្ធិទាំងនោះ ត្រូវបានចែងនៅក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម ឬអង្គការនៅក្នុងសង្គមដើម្បីលើកស្ទួយនិងការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋានដែលបានទទួលស្គាល់ជាសាកល (១៩៩៨) ដែលមាត្រា ៩.២ ចែងថា "ជាអវិសាន្ត ជនគ្រប់រូបទាំងឡាយណា ដែលសិទ្ធិឬសេរីភាពរបស់ខ្លួនត្រូវបានរំលោភបំពាន មានសិទ្ធិធ្វើការប្តឹងតវ៉ាដោយខ្លួនឯង ឬតាមរយៈតំណាងដែលអនុញ្ញាតតាមផ្លូវច្បាប់ និងឱ្យការប្តឹងតវ៉ានោះត្រូវបានពិនិត្យឱ្យទាន់ពេលវេលា នៅក្នុងសវនាការជាសាធារណៈ ដោយស្ថាប័នតុលាការដែលឯករាជ្យ មិនលំអៀង និងមានសមត្ថភាព ឬអាជ្ញាធរណាមួយដែលបានបង្កើតឡើងដោយច្បាប់ ព្រមទាំងទទួលសេចក្តីសម្រេចពីអាជ្ញាធរនោះ

ដោយបានផ្តល់នូវដំណោះស្រាយស្របតាមច្បាប់ រួមមានការសងសំណងត្រឹមត្រូវតាមច្បាប់ ប្រសិនជាមានការរំលោភបំពានលើសិទ្ធិ និងសេរីភាពរបស់បុគ្គលនោះពិតប្រាកដមែន ព្រមទាំងអនុវត្តការសម្រេចនោះដោយថាហេតុ ដោយគ្មានការពន្យារពេលខុសពីនីតិវិធីច្បាប់ឡើយ។"

ប្រតិបត្តិសិទ្ធិសង្គមយ៉ាងពេញលេញៈ ក្រៅពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ រដ្ឋធម្មនុញ្ញនិងច្បាប់អន្តរជាតិក៏បានធានាផងដែរនូវសិទ្ធិសង្គម។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ អនុម័ត នៅឆ្នាំ១៩៦៦ (ICESR)[៣០] និងឱ្យសច្ចាប័នដោយកម្ពុជានៅឆ្នាំ១៩៩២ ផងដែរនោះ បានចែងរួមបញ្ចូលទាំងសិទ្ធិខាងការងារ លក្ខខណ្ឌរស់នៅដោយសមរម្យ សិទ្ធិលំនៅដ្ឋាន សិទ្ធិទទួលបាននូវការគាំពារសុខភាព ការធានារបស់សង្គម សិទ្ធិអប់រំ និងសិទ្ធិទទួលបានអាហារគ្រប់គ្រាន់ ព្រមទាំងសិទ្ធិផ្សេងៗ។ រដ្ឋជាភាគីទាំងអស់ បានឯកភាពជាមួយគ្នាទៅវិញទៅមកថា នឹងអនុវត្តជាបណ្តើរៗនូវសិទ្ធិទាំងនេះ ដើម្បីសម្រេចឱ្យបាននូវស្តង់ដាសិទ្ធិមនុស្សជាអប្បបរមា។ មានយន្តការដោះស្រាយវិវាទអន្តរជាតិមួយ ក្នុងការត្រួតពិនិត្យមើលការអនុវត្តរបស់ប្រទេសនីមួយៗ ដោយតម្រូវឱ្យមានសេចក្តីរាយការណ៍អំពីភាពជឿនលឿននៃការគោរពសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់ខ្លួន។ បើសិនជាមានការរើសអើងនិងការបំបិទសិទ្ធិសេរីភាពរបស់បុគ្គល ឬក្រុមណាមួយនោះ ករណីនេះជាការរំលោភលើសិទ្ធិយ៉ាងច្បាស់។ សិទ្ធិទទួលបានយុត្តិធម៌មិនមានគោលដៅលុបបំបាត់ចោលឱ្យអស់នូវរនាំង និងឧបសគ្គទាំងឡាយក្នុងការអនុវត្តនូវសិទ្ធិទាំងនោះ។ ទោះបីជាមានការពិភាក្សាយ៉ាងវែងអំពីកម្រិតនៃការអនុវត្តជាអប្បបរ មាននូវសិទ្ធិទាំងនេះក្តី តែវាច្បាស់ណាស់ថាទោះបីជាបុគ្គលក្តី ឬក្រុមក្តីសុទ្ធតែមានសិទ្ធិទទួលបាននូវយុត្តិធម៌ ដោយត្រូវបញ្ឈប់នូវការរើសអើង អំពើពុករលួយ ឬសកម្មភាពផ្សេងៗទៀត ដែលជារនាំងដល់ការអនុវត្តនូវសិទ្ធិទាំងនេះ។ នៅលើឆាកអន្តរជាតិក៏មានសម្ពាធកាន់តែខ្លាំងឡើងផងដែរ ពោលគឺការកើនឡើងនៃយុត្តិសាស្ត្រជាអន្តរជាតិ ដែលតម្រូវឱ្យរដ្ឋនីមួយៗចាំបាច់ត្រូវតែចាប់យកនូវជំហានជាវិជ្ជមានណាមួយ ក្នុងការអនុវត្តនូវសិទ្ធិទាំងនេះ ដើម្បីធានាឱ្យបាននូវការអនុវត្តជាបណ្តើរៗនូវសិទ្ធិទាំងនេះ។ ដូចនេះ បុគ្គលអាចទាមទាររកយុត្តិធម៌ បើសិនជាសិទ្ធិណាមួយក្នុងចំណោមសិទ្ធិទាំងនេះ ត្រូវបានគេរំលោកតាមរយៈវិធានការ ឬសកម្មភាពរដ្ឋបាលជាក់លាក់ណាមួយរបស់អាជ្ញាធរ ឬនៅពេលដែលមានភាពអកម្ម ឬ "ដើរថយក្រោយ"។ ដូចគ្នានេះផងដែរ អាចនិយាយបានសម្រាប់សិទ្ធិជាក់លាក់មួយចំនួនទៀតរបស់ស្ត្រី កុមារ ជនជាតិភាគតិច និងជនជាតិដើមភាគតិច។

ដំណោះស្រាយវិវាទសម្រាប់ជាប្រយោជន៍ដល់សន្តិភាពសង្គម

តាមច្បាប់អន្តរជាតិ សន្តិភាពមិនមែនគ្រាន់តែសំដៅលើការបញ្ចប់នៃភាពប្រទូស្តរាយ ឬនៅពេលដែលទំនាស់ត្រូវបានបញ្ចប់នោះទេ តែវាជាអ្វីមួយដែលចេញមកពីការទទួលស្គាល់នូវសិទ្ធិទាំងឡាយ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានគាំទ្រចំពោះគោលការណ៍នេះនៅក្នុងសេចក្តីពិចារណារបស់ខ្លួនថា: "(.......) យោលទៅតាមគោលការណ៍នានា ដែលបានប្រកាសនៅក្នុងធម្មនុញ្ញសហប្រជាជាតិ ទទួលស្គាល់នូវសេចក្តីថ្លៃថ្នូរពីកំណើត ព្រមទាំងសិទ្ធិស្មើគ្នា និងមិនអាចផ្ទេរបាននៃសមាជិកទាំងអស់នៃគ្រួសារមនុស្សជាតិថាជាមូលដ្ឋានគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពនៅលើពិភពលោក (....) "។

លទ្ធផលនៃគោលការណ៍នេះដើរតួយ៉ាងសំខាន់ ពីព្រោះសន្តិភាពសង្គមត្រូវតែដាក់គ្រឹះ នៅលើការទទួលស្គាល់នូវសេចក្តីថ្លៃថ្នូរនិងសិទ្ធិទាំងឡាយ។ ពេលខ្លះនៅក្នុងដំណោះស្រាយនៃវិវាទសម្រាប់ជាប្រយោជន៍ ដល់សន្តិភាពសង្គម អាចនាំឱ្យភាគីជាអ្នកលះបង់នូវសិទ្ធិរបស់ខ្លួន។ ទោះបីជាមានការប្តឹងតវ៉ាដោយមានមូលដ្ឋានរឹងមាំនៅក្នុងសង្គម ដើម្បីទាមទារនូវសិទ្ធិ

[៣០] សូមមើលអត្ថបទពេញនៅ: http://www.ohchr.org/english/law/cescr.htm.

ស្របច្បាប់មួយចំនួន ដែលមិនអាចរំលោភបានដាច់ខាតក្តី តែអាជ្ញាធរមួយចំនួននៅតែបារម្ភខ្លាំង តែទៅលើការរក្សានូវ "សន្តិភាពសង្គម" ជាជាងយកចិត្តទុកដាក់សំខាន់ក្នុងការធានាការគោរពសិទ្ធិរបស់ភាគី។ អាចនិយាយដូចគ្នានេះដែរសម្រាប់អ្នកសម្រុះសម្រួល និងអ្នកផ្សះផ្សា ឬអ្នកប្រតិបត្តិ ដែលដើរតួរក្នុងការដោះស្រាយវិវាទ ដែលពួកអ្នកទាំងនោះយកចិត្តទុកដាក់សំខាន់តែទៅលើការដោះស្រាយបញ្ចប់ទំនាស់រវាងគូភាគី ជាជាងធានានិងផ្តល់សិទ្ធិដល់គូភាគីពាក់ព័ន្ធ ជាពិសេសបើសិនជាភាគីទាំងនោះជាអ្នកទន់ខ្សោយ និងងាយរងគ្រោះ។ ការសិក្សានេះបានសន្មតថា ការយកគោលការណ៍សិទ្ធិមនុស្ស ជាគោលក្នុងការដោះស្រាយវិវាទ មានន័យថានៅពេលមានសន្តិភាពសង្គមពិតជាលក្ខណៈល្អរបស់សង្គម ដែលមិនអាចប្រកែកបាននោះ ការថែរក្សាសន្តិភាពសង្គមឱ្យបាន ត្រូវតែពិចារណាលើការការពារសិទ្ធិមនុស្សចាំបាច់។ យើងអាចនិយាយបានម្យ៉ាងទៀតថា សិទ្ធិមនុស្សគឺជាគោលបំណងធំបំផុតក្នុងការដោះស្រាយវិវាទ ពីព្រោះថាការដែលដាក់សិទ្ធិមនុស្សជាគោលសំខាន់នោះ វាជាមូលដ្ឋានគ្រឹះដ៏រឹងមាំតែមួយគត់ សម្រាប់សន្តិភាពសង្គមប្រកបដោយចីរភាព។ នៅពេលដែលចាំបាច់ ត្រូវធ្វើសម្បទានឱ្យគ្នាដើម្បីឈានដល់ដំណោះស្រាយនៅក្នុងទំនាស់ចូទ្ធរនោះ ការធ្វើសម្បទាននេះ គួរតែធ្វើឡើងត្រឹមតែកម្រិតផលប្រយោជន៍របស់ភាគី ជាជាងទៅលើសិទ្ធិរបស់ភាគី។

ជាសង្ខេប សិទ្ធិទទួលបានយុត្តិធម៌ទាមទារឱ្យមានការការពារសិទ្ធិមនុស្ស ត្រួតពិនិត្យការរំលោភអំណាច និងការដោះស្រាយវិវាទ ដោយយកការគោរពសិទ្ធិមនុស្សជាគោល។ ឥឡូវនេះ ដើម្បីធានានូវសិទ្ធិទទួលបានយុត្តិធម៌នៅក្នុងសង្គមជាក់លាក់មួយ ដំបូងចាំបាច់ត្រូវវិភាគ និងយល់អំពីសេចក្តីត្រូវការរបស់សង្គម ដែលជាតម្រូវការយុត្តិធម៌នៅក្នុងសង្គម [៣១]។

**ការស្ថាបនាតម្រូវការយុត្តិធម៌នៅក្នុងសង្គមៈ** តម្រូវការយុត្តិធម៌ក្នុងសង្គមរួមមានតម្រូវការយុត្តិធម៌ជា *សក្តានុពល* និងតម្រូវការយុត្តិធម៌*ជាក់ស្តែង* [៣២]។

តម្រូវការយុត្តិធម៌ជាសក្តានុពល

តម្រូវការយុត្តិធម៌ *ជាសក្តានុពល* ឬ *ដែលអាចកើតមាន* ជាអ្វីដែលមាននៅក្នុងសេចក្តីត្រូវការរបស់សង្គម ឬ ជាបញ្ហា ឬវិវាទនានារបស់សង្គម ដែលត្រូវមានដំណោះស្រាយសមរម្យ តែមិនទាន់មានភាគីណាមួយប្តឹងទៅជនទីបីណាមួយ ដើម្បីរកដំណោះស្រាយឡើយ។ តម្រូវការយុត្តិធម៌*ជាសក្តានុពល* ឬ *ដែលនៅអាចកើតមាន* អាចត្រូវបានគេឱ្យនិយមន័យដោយផ្អែកលើទស្សនាទានខាង "សត្យានុម័ត" (objective perspective) ឬ ដោយផ្អែកលើមូលដ្ឋាននៃកត្តាបុគ្គលឬអត្តនោម័ត (subjective approach)។

១. និយមន័យផ្អែកទស្សនាទាន "សត្យានុម័ត" (objective perspective) ទាញចេញមកពីច្បាប់ផ្សេងៗ ឬច្បាប់ទំនៀមទំលាប់។ ច្បាប់កំណត់អំពីវិធានសិទ្ធិ និងកាតព្វកិច្ចនានា រួមទាំងនីតិវិធី និងលក្ខខណ្ឌច្បាប់ដទៃៗទៀត ដែលកំណត់ក្របខ័ណ្ឌនូវអ្វីដែលអាចហៅថា "ព្រឹត្តិការណ៍ ឬករណីដែលអាចជារឿងក្តីបាន" ពោលគឺព្រឹត្តិការណ៍ណាដែលអាចឱ្យភាគីប្តឹងដើម្បីរកដំណោះស្រាយ នៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ចជាក់លាក់ណាមួយ។

---

[៣១] សូមមើលបន្ថែមនៅក្នុងជំពូក ២

[៣២] ពាក្យថា "តម្រូវការជាសក្តានុពល" និង "តម្រូវការជាក់ស្តែង" ដកស្រង់ចេញពីគោលការណ៍ក្នុងន័យសេដ្ឋកិច្ច ដែលយើងយកវាមកអនុវត្តក្នុងវិស័យនៃការផ្តល់សេវាកម្មយុត្តិធម៌នេះផងដែរ។

២. ផ្អែកលើមូលដ្ឋាននៃកត្តាបុគ្គលឬអត្តនោម័ត (subjective approach)វិញ គឺសំដៅលើការយល់ឃើញរបស់ប្រជាពលរដ្ឋ ថាតើព្រឹត្តិការណ៍អ្វីខ្លះដែលត្រូវបានពួកគេចាត់ទុកថាជាករណី ដែលសមស្របអាចប្ដឹងរកយុត្តិធម៌ទៅភាគីទីបីណាមួយបាន ដោយផ្អែកលើតម្លៃខាងសីលធម៌ និងវប្បធម៌ជាច្បាប់របស់ពួកគេ។

**ទស្សនទានអំពីសេចក្ដីត្រូវការបញ្ហា និងវិវាទនៅក្នុងសង្គមៈ** សេចក្ដីត្រូវការរបស់សង្គម គឺជាអ្វីដែលជាប្រយោជន៍ខាងសម្ភារៈនិងវប្បធម៌ ដែលប្រជាពលរដ្ឋ (ទាំងបុគ្គល ក្រុម និងប្រជាពលរដ្ឋទាំងអស់) យល់ឃើញថា វាចាំបាច់សម្រាប់ការអភិវឌ្ឍមនុស្ស។ ការយល់ឃើញរបស់សង្គមអំពីសេចក្ដីត្រូវការ គឺអាស្រ័យលើលក្ខខណ្ឌសេដ្ឋកិច្ចសង្គមជាទូទៅ ក្របខ័ណ្ឌច្បាប់ និងនយោបាយ និងក្រមនៃវប្បធម៌។ សេចក្ដីត្រូវការសង្គមមិនមែនគ្រាន់តែជាកត្តា "សត្យានុម័ត" ប៉ុណ្ណោះទេ តែវាជាផ្នែកមួយនៃការកកើតឡើងខាងសង្គម និងវប្បធម៌នៃសេចក្ដីពិតរបស់សង្គម[៣៣]។ ដូច្នេះសេចក្ដីត្រូវការសង្គម អាចប្រែប្រួលតាមទេសកាលនៃប្រវត្តិសាស្ត្រតាមវប្បធម៌ និងក្រុមផ្សេងៗ[៣៤]។ បញ្ហានិងវិវាទទាំងឡាយនៅក្នុងសង្គម អាចមានការប៉ះពាល់ដល់ការបំពេញតម្រូវការរបស់សង្គម និងគុណតម្លៃខាងវប្បធម៌។ ជាធម្មតាបញ្ហាសង្គមមានពាក់ព័ន្ធជាមួយនឹងលក្ខខណ្ឌនៃការរស់នៅរយៈពេលវែងនិងជារចនាសម្ព័ន្ធ។ មួយផ្នែកនៃបញ្ហាសង្គមកើតចេញ ឬជាផ្នែកមួយនៃបរិយាកាស ដែលក្នុងនោះវិវាទនានាអាចកើតមាន ដោយទំនាក់ទំនងអន្តរបុគ្គល។ វិវាទនិងទំនាស់ផ្សេងៗ គឺជាផ្នែកមួយនៃជីវិតក្នុងសង្គម និងអាចជះឥទ្ធិពលដល់ប្រយោជន៍ ឬសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋក្នុងសង្គម។ គុណតម្លៃខាងវប្បធម៌ និងវិធានច្បាប់ គឺជាមូលដ្ឋានដើម្បីកំណត់ថាតើការប៉ះទង្គិចគ្នាជាក់លាក់ណាមួយទៅលើសេចក្ដីត្រូវការរបស់សង្គម ដែលនាំឱ្យមានជាករណីដែលអាចប្ដឹងទាមទារ រកយុត្តិធម៌ ឬហៅថាព្រឹត្តិការណ៍ ដែលអាចជារឿងក្ដីបានដែរឬយ៉ាងណា។

**និយមន័យនៃសេចក្ដីត្រូវ ឬវិវាទនៅក្នុងសង្គម ថាជាព្រឹត្តិការណ៍អាចជារឿងក្ដីបានៈ** ដូចដែលបានបញ្ជាក់មកពីខាងលើហើយថា *ព្រឹត្តិការណ៍ដែលអាចជារឿងក្ដីបាន* គឺជាវិវាទបញ្ហា និងការរំលោភសិទ្ធិនានា ដែលអាចប្ដឹងទៅជនទីបីណាមួយដើម្បីដោះស្រាយបាន។ យោងតាមទស្សនៈដោយផ្អែកលើគោលការណ៍ច្បាប់ *ព្រឹត្តិការណ៍ដែលអាចជារឿងក្ដីបាន* គឺជាករណីដែលអាចជួសជុលឱ្យល្អឡើងវិញបាន ដោយការសម្រេចសេចក្ដីពីតុលាការស្របតាមច្បាប់។ ការសិក្សានេះ មិនបានកំណត់អំពីព្រំដែនថាតើ *ព្រឹត្តិការណ៍ដែលអាចជារឿងក្ដីបាន*នោះជាព្រឹត្តិការណ៍ដែលធ្ងន់ធ្ងរឬតូចតាចកម្រិតណាឡើយ ដែលអ្នកអាចរកឃើញអំពីប្រភពរបស់វានៅក្នុងទ្រឹស្ដី ច្បាប់ដែលត្រូវបានគេសន្មតទុកជាមុននៃប្រព័ន្ធច្បាប់ឯកនិយម[៣៥]។ ការសិក្សានេះប្រើប្រាស់និយមន័យទូលាយ ទាញចេញអំពីសង្គមវិទ្យានៃច្បាប់ និងការសិក្សាអំពីមនុស្ស (នរវិទ្យា) ដើម្បីស្វែងយល់ឱ្យ

---

៣៣ សូមមើល : Berger, Peter and Thomas Luckmann (1991): *The Social Construction of Reality: Treatise in the Sociology of Knowledge.* Penguin Books.

៣៤ ជាឧទាហរណ៍ ភាពក្រីក្រ ឬអំពើហិង្សាក្នុងគ្រួសារ អាចត្រូវបានគេកំណត់ថាជាព្រឹត្តិការណ៍ដែលចៀសមិនផុត និងជាផ្នែកមួយនៃវាសនារបស់មនុស្ស ដែលប៉ះពាល់ដល់សិទ្ធិមនុស្ស និងជាករណីដែលអាចកែតម្រូវបាន។

៣៥ ប្រព័ន្ធច្បាប់ទោលត្រូវបានលើកមកពិភាក្សា និងប្រៀបធៀបជាមួយនឹងប្រព័ន្ធច្បាប់ពហុនិយម (ជាទស្សនាទានខាងទ្រឹស្ដីនៃការសិក្សានេះ) នៅក្នុងផ្នែកទាំងបួនខាងក្រោមនេះ។ តាមទស្សនាទានខាងផ្លូវច្បាប់ *ព្រឹត្តិការណ៍ដែលអាចជារឿងក្ដីបាន* ជាករណីជាក់លាក់ដែលអាចកែតម្រូវឱ្យល្អវិញបាន តាមរយៈការកាត់សេចក្ដីរបស់តុលាការ។ ព្រឹត្តិការណ៍នេះ ត្រូវតែមានចែងនៅក្នុងច្បាប់ ដើម្បីឱ្យព្រឹត្តិការណ៍នេះអាចក្លាយជា "រឿងក្ដី" បាន (អាចជារឿងក្ដីរដ្ឋប្បវេណី ឬអាចជារឿងក្ដីព្រហ្មទណ្ឌ)។ ច្បាប់ក៏មានចែងច្បាស់អំពីនីតិវិធីឬវិធាននានា រួមទាំងអាជ្ញាធរដែលមានសមត្ថកិច្ចដោះស្រាយលើករណីជាក់លាក់នានា។ ជនទីបីអាចដោះស្រាយវិវាទបានអាចជាចៅក្រម ហើយប្រើនីតិវិធីកាត់សេចក្ដី។ សម្រាប់ករណីរដ្ឋប្បវេណី ចៅក្រមបង្ហាញនូវអំណះអំណាងថាតើមានការរំលោភសិទ្ធិមែនឬយ៉ាងណា (ឬមានការរំលោភលើកូនទីរបស់ខ្លួនឬយ៉ាងណា) ហើយកាត់សេចក្ដីសម្រាប់គូភាគី ថាតើភាគីខាងណាជាអ្នកឈ្នះ។ តែសម្រាប់ករណីព្រហ្មទណ្ឌវិញ ចៅក្រមសម្រេចថាតើជនណាមួយដែលមានទោស ឬគ្មានទោស ដោយផ្អែកលើមូលដ្ឋានច្បាប់។ អំណាចក្នុងការកាត់សេចក្ដីហៅថាអំណាចយុត្តាធិការ និងជាអំណាចដែលឯករាជ្យអំពីអំណាចនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីធានានូវឯករាជ្យភាព និងការត្រួតពិនិត្យតុល្យភាពអំណាចនៅក្នុងប្រព័ន្ធប្រជាធិបតេយ្យ។

បានកាន់តែច្បាស់ អំពីសេចក្តីត្រូវការសង្គមទាំងឡាយ [៣៦]។ ទំហំនៃការសិក្សានេះរួមបញ្ចូលទាំងព្រឹត្តការណ៍នានា ដែលចែងដោយច្បាប់ផ្លូវការរបស់រដ្ឋថាជា "រឿងក្តី" និងអាចត្រូវភាគីប្តឹងទៅតុលាការដើម្បីដោះស្រាយ និងរួមបញ្ចូលផងដែរ នូវករណីទាំងឡាយដែលបុគ្គលឬក្រុមនានាយល់ថា អាចប្តឹងទៅយន្តការណាមួយ ដើម្បីដោះស្រាយបានដោយផ្អែកលើមូលដ្ឋាននៃច្បាប់ទំនៀមទំលាប់ វិធានរបស់ជនជាតិដើមភាគតិច ឬតម្លៃច្បាប់មិនផ្លូវការនិងការអនុវត្តនានា។ យន្តការដោះស្រាយទាំងនេះ អាចប្រើប្រាស់វិធីដោះស្រាយ ដោយផ្អែកលើការសម្រុះសម្រួលផលប្រយោជន៍របស់គូភាគី សមធម៌ និងការសម្រេចសេចក្តី ដោយស្របទៅតាមវិធានសិទ្ធិ និងកាតព្វកិច្ចនានា។ ការយល់ឃើញ ឬការទទួលស្គាល់លើបញ្ហា និងវិវាទ ថាជា *រឿងក្តី* ដោយប្រជាពលរដ្ឋដែលរងការប៉ះពាល់ គឺអាស្រ័យទៅលើតម្លៃជាវប្បធម៌ និងសីលធម៌ ការយល់ដឹងពីច្បាប់ និងការយល់ដឹងពីសិទ្ធិរបស់ពួកគេ (អាស្រ័យលើច្បាប់ផ្លូវការ ឬច្បាប់ទំនៀមទំលាប់) រួមទាំងការរំពឹងទុក (ទំនុកចិត្ត) របស់ពួកគេ ថាតើស្ថាប័នដែលដោះស្រាយនោះ អាចដោះស្រាយវិវាទជូនពួកគេ ដោយយុត្តិធម៌ និងត្រឹមត្រូវដែរឬយ៉ាងណា។

ផ្អែកលើគោលការណ៍សិទ្ធិមនុស្ស ការសិក្សានេះចាត់ទុក *ព្រឹត្តិការណ៍ដែលអាចជារឿងក្តីបាន* ថាជាករណី ដែលប្រជាពលរដ្ឋអាចប្តឹងបាននៅពេលពួកគេដឹងពីសិទ្ធិរបស់គេ។ បើសិនជាប្រជាពលរដ្ឋមិនប្តឹងនោះ ករណីទាំងនេះនៅតែជាតម្រូវការយុត្តិធម៌ជាសក្តានុពលដដែល។

តម្រូវការយុត្តិធម៌ជាក់ស្តែង

តម្រូវការយុត្តិធម៌ជាក់ស្តែង រួមមានរឿងក្តីទាំងឡាយដែលបានប្តឹងដោយប្រជាពលរដ្ឋ ទៅកាន់ភ្នាក់ងារផ្សេងៗ (បុគ្គល ឬស្ថាប័ន) ដើម្បីធ្វើការដោះស្រាយ។ បើសិនជាប្រៀបធៀបរវាងតម្រូវការយុត្តិធម៌ជាក់ស្តែង និងតម្រូវការយុត្តិធម៌ជាសក្តានុពល ការសិក្សានេះនឹងពិចារណាអំពីប្រភេទផ្សេងៗនៃបញ្ហា ឬករណីដែលអាចជារឿងក្តីបាន និងករណីវិវាទនានាដែលត្រូវបានភាគីប្តឹងទៅភាគីទីបីណាមួយរួចហើយ។

ជនគ្រប់រូបអាចធ្វើឱ្យតម្រូវការយុត្តិធម៌របស់ខ្លួន ក្លាយជាជាក់ស្តែងបានដោយប្តឹងនូវបញ្ហា ឬករណីដែលអាចជារឿងក្តីបាននោះ ទៅភាគីទីបី ដោយអាស្រ័យលើ : ក-កត្តាទូទៅ ឬសត្យានុម័ត និង ខ-កត្តាបុគ្គល ឬអត្តនោម័ត។

កត្តាទូទៅ ឬសត្យានុម័តដែលធ្វើឱ្យប្រជាពលរដ្ឋអាចប្រែក្លាយតម្រូវការយុត្តិធម៌ទាំងនោះ ជាតម្រូវការយុត្តិធម៌ជាក់ស្តែងមានដូចខាងក្រោមនេះ :

១- ក្របខ័ណ្ឌច្បាប់: អត្ថិភាពនៃបទបញ្ញត្តិច្បាប់ ឬវិធានទំនៀមទម្លាប់ដែលកំណត់បញ្ហា ឬ វិវាទបែបនោះថាជា *រឿងក្តី* ក៏ដូចជាចែងពីយន្តការ និងនីតិវិធីក្នុងការដោះស្រាយ *រឿងក្តីទាំងនោះ*។

២- ក្របខ័ណ្ឌស្ថាប័ន: អត្ថិភាពនៃស្ថាប័នដែលមានស្រាប់ (បុគ្គល ឬស្ថាប័ន) ហើយអាចឱ្យប្រជាពលរដ្ឋអាចទៅរកដើម្បីប្តឹងតវ៉ាពីករណី ឬបញ្ហាដែលអាចជារឿងក្តីបាន។

៣- វប្បធម៌ផ្នែកច្បាប់: អត្ថិភាពនៃចំណេះដឹងពីច្បាប់ជាទូទៅ អាចជួយឱ្យប្រជាពលរដ្ឋមានមូលដ្ឋានច្បាប់ក្នុងការប្តឹងតវ៉ា និងការអនុវត្តទាំងឡាយរបស់អ្នកផ្តល់សេវាយុត្តិធម៌ និងអ្នកប្រើប្រាស់សេវាយុត្តិធម៌អាចអនុញ្ញាតឱ្យប្រព័ន្ធច្បាប់ដោះស្រាយករណីឬបញ្ហា ដែលអាចជារឿងក្តីបាន។

---

[៣៦] តាមទស្សនៈច្បាប់សង្គមវិទ្យា ព្រឹត្តិការណ៍អាចជារឿងក្តីបានជាអ្វីមួយដែលកើតឡើងដោយមាន ឬមិនមានចែងនៅក្នុងច្បាប់ តែប្រជាពលរដ្ឋយល់ថាជាករណីដែលពួកគេអាចប្តឹងទៅភាគីទីបីណាមួយបាន។ ភាគីទីបីនេះអាចជាបុគ្គលមួយរូប ឬច្រើនរូប ហើយអាចត្រូវបានឬមិនបានតែងតាំងដោយច្បាប់ តែភាគីទីបីនេះជាអ្នកដែលភាគីទុកចិត្ត និងជឿថាអាចដោះស្រាយជូនពួកគេបាន។ ភាគីទីបីអាចដោះស្រាយ ឬសម្រុះសម្រួលព្រឹត្តិការណ៍នោះ (បញ្ហាវិវាទ ឬជាទំនាស់) ដោយជួយឱ្យភាគីឯកភាព ព្រមព្រៀង ឬកាត់សេចក្តីដោយស្របតាមនីតិវិធីច្បាប់ គោលការណ៍សមភាព តម្លៃវប្បធម៌ និងសាសនា តាមការអនុវត្តកន្លងមកជាធម្មតា ឬតាមលក្ខខណ្ឌតម្រូវដោយភាគីជាដើម។

កត្តាបុគ្គលពឹងផ្អែកទៅលើលក្ខខណ្ឌច្បាស់លាស់របស់ដើមបណ្តឹង ដូចជា :

១. ការយល់ដឹងពីច្បាប់និងសិទ្ធិ (ចំណេះដឹងជាក់លាក់ពីវិធាន សិទ្ធិ នីតិវិធី ស្ថាប័ន និងការអនុវត្តច្បាប់)

២. លក្ខខណ្ឌផ្នែកសេដ្ឋកិច្ច និងសម្ភារៈ (ពេលវេលា ធនធានហិរញ្ញវត្ថុ...ល។)

៣. ការគាំទ្រផ្លូវចិត្ត សម្ព័ន្ធភាពនៃសង្គមនិងនយោបាយ តម្លៃបុគ្គលនិងគោលបំណង។ល។

តារាង: មូលហេតុនៃការកកើតតម្រូវការយុត្តិធម៌ក្នុងសង្គម




### ដំណើរការ លទ្ធផល និងយន្តការ

តាមគោលការណ៍សិទ្ធិមនុស្ស សិទ្ធិទទួលបានយុត្តិធម៌រាប់បញ្ចូលទាំងអត្ថិភាពនិយាមជាអប្បបរមា ទាក់ទងនឹងដំណើរការ និងលទ្ធផលនៃការផ្តល់សេវាកម្មយុត្តិធម៌[៣៧]។ ដូច្នេះការដោះស្រាយវិវាទ គឺត្រូវតែផ្អែកលើកត្តាទាំងនេះ។ ផ្អែកលើគោលសិទ្ធិមនុស្ស ពិតជាមិនមានការផ្តល់យុត្តិធម៌ដល់ប្រជាពលរដ្ឋឡើយ បើសិនជាការដោះស្រាយវិវាទធ្វើឡើងដោយរំលោភលើសិទ្ធិមនុស្ស ឬបើសិនជាអ្នកផ្តល់សេវាយុត្តិធម៌នេះ មិនមានឯករាជ្យភាពពីអំណាចដទៃទៀត (ដូចជា សេដ្ឋកិច្ច យោធា និងនយោបាយជាដើម) ឬបើសិនជាប្រព័ន្ធផ្តល់សេវាយុត្តិធម៌នោះ មិនមានសមត្ថភាពទប់ស្កាត់កុំឱ្យមានការប្រើអំណាចពីអ្នកមានអំណាចជាង ដោយគៀបសង្កត់ទៅលើភាគីក្រីក្រ ឬទន់ខ្សោយ ពីបុរសទៅលើស្ត្រី ពីក្រុមជាតិពន្ធុភាគច្រើនទៅលើក្រុមភាគតិច ។

៣៧ ការសិក្សានេះបានចែករំលែកទ្រឹស្តីទស្សនៈនេះជាមួយកម្មវិធីរបស់អង្គការ UNDP ថ្នាក់តំបន់ផងដែរ (UNDP Asia Pacific, 2005, p. 3.)

យោងតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ សិទ្ធិទទួលបានយុត្តិធម៌មានដូចជា [៣៨] :

- សិទ្ធិប្រើប្រាស់សេវាសាធារណៈដោយពុំមានការរើសអើង
- សិទ្ធិដើម្បីប្តឹងតវ៉ា
- សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយអាជ្ញាធរមានសមត្ថកិច្ចដែលឯករាជ្យ និងមិនលំអៀង
- សិទ្ធិទទួលបានការសម្រេចសេចក្តីដោយមិនពន្យារពេល
- សិទ្ធិទទួលបានការដោះស្រាយដោយប្រសិទ្ធិភាព
- សិទ្ធិក្នុងការអនុវត្តនូវរាល់សេចក្តីសម្រេចទាំងឡាយ

លក្ខខណ្ឌតម្រូវខាងស្ថាប័ន ៖

សិទ្ធិទទួលបានយុត្តិធម៌ដោយផ្អែកលើគោលការណ៍សិទ្ធិមនុស្ស ពិចារណាទៅលើទម្រង់នៃសង្គម និងរដ្ឋដែលផ្តល់សេវាកម្មយុត្តិធម៌ទាំងនេះ ។ លក្ខខណ្ឌតម្រូវខាងស្ថាប័ននៃសិទ្ធិទទួលបានយុត្តិធម៌មានៈ ប្រព័ន្ធនយោបាយប្រជាធិបតេយ្យ អភិបាលកិច្ចល្អ មានសេរីភាពក៏ដូចជាសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌ផងដែរ។ វាមិនអាចមានយុត្តិធម៌ទេ បើសិនជាពុំមានយន្តការក្នុងសង្គម ដើម្បីត្រួតពិនិត្យការរំលោភអំណាច ឬពុំមានប្រព័ន្ធត្រួតពិនិត្យតុល្យភាពអំណាច។ ក្នុងន័យនេះ សិទ្ធិទទួលបានយុត្តិធម៌ជាប់ ពាក់ព័ន្ធជាមួយក្របខ័ណ្ឌធំទូលាយនៃគោលដៅរបស់សង្គម ដូចជាប្រជាធិបតេយ្យភាវូបនីយកម្ម តម្លាភាព និងការកាត់បន្ថយ ភាពក្រីក្រ រួមទាំងសមធម៌សង្គម យេនឌ័រ និងជាតិពន្ធុផងដែរ។

ការផ្តល់សេវាកម្មយុត្តិធម៌

អ្នកដែលមានសិទ្ធិទទួលបានយុត្តិធម៌ គឺជាបុគ្គលគ្រប់រូបនិងគ្រប់ក្រុម។ រដ្ឋគឺជាភាគីដែលមានកាតព្វកិច្ចគោរពសិទ្ធិមនុស្ស តាមរយៈការបំពេញតួនាទីសហសម្ព័ន្ធរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី តម្រូវការយុត្តិធម៌ក្នុងសង្គម អាចត្រូវបានបំពេញដោយយន្តការផ្តល់សេវាយុត្តិធម៌ផ្សេងៗ។ អ្នកផ្តល់សេវាយុត្តិធម៌ទាំងនេះអាចមានដូចជា : បុគ្គលណាម្នាក់ ស្ថាប័ននានា និងអង្គការទោះជាសាធារណៈ ឬឯកជនក្តី ហើយអាចនៅថ្នាក់មូលដ្ឋាន ឬថ្នាក់ជាតិ ដែលមានយុត្តាធិការដូចជាតុលាការ យន្តការដោះស្រាយវិវាទក្រៅតុលាការ យន្តការដោះស្រាយវិវាទនៅមូលដ្ឋាន អាជ្ញាធរជនជាតិដើមភាគតិច។ល។ សម្រាប់ច្បាប់អន្តរជាតិ យន្តការដោះស្រាយវិវាទទាំងនេះ អាចធ្វើអន្តរាគមន៍ទោះបីក្នុងរឿងក្តីរដ្ឋប្បវេណីក្តី ព្រហ្មទណ្ឌក្តី ឱ្យតែយន្តការ ទាំងនេះមានគោលបំណងការពារនូវសិទ្ធិឱ្យប្រសើរឡើង។

ជាប្រពៃណី ឧបករណ៍សិទ្ធិមនុស្សអន្តរជាតិផ្តោតសំខាន់ទៅលើតុលាការ ដោយហេតុថាតុលាការជាស្ថាប័នគោលមួយក្នុងការផ្តល់សេវាយុត្តិធម៌ ជាពិសេសក្នុងករណីព្រហ្មទណ្ឌ។ តាមការអភិវឌ្ឍក្រោយៗមក ឧបករណ៍ជាច្រើនបានចែងអំពីយន្តការផ្សេងៗដែលផ្តល់សេវាយុត្តិធម៌ រួមទាំងការដោះស្រាយសម្រាប់ជនរងគ្រោះផង។ ឧទាហរណ៍មួយដូចមានចែងនៅក្នុងសេចក្តីប្រកាស ស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានសម្រាប់ជនរងគ្រោះនៃបទព្រហ្មទណ្ឌឬការរំលោភអំណាច (១៩៨៥) មាត្រា ៧ ចែងថា : "ក្នុងករណីសមស្រប ត្រូវប្រើប្រាស់យន្តការមិនផ្លូវការសម្រាប់ការដោះស្រាយទំនាស់ រួមមានការសម្របសម្រួលអាជ្ញាកណ្តាល ព្រមទាំងយុត្តិធម៌បែបប្រពៃណី ឬទំនៀមទំលាប់របស់ជនជាតិ ដើមភាគតិច ដើម្បីសម្រួលដល់ការរួបរួមគ្នា និងស្វែងរកដំណោះស្រាយ ឱ្យជនរងគ្រោះ"។ អនុសញ្ញាលេខ ១៦៩ របស់អង្គការពលកម្មអន្តរជាតិ ស្តីពីជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធនៅក្នុងប្រទេសឯករាជ្យ ទទួលស្គាល់សមត្ថកិច្ចរបស់អាជ្ញាធរជនជាតិដើមភាគតិចសម្រាប់ដោះស្រាយវិវាទ រួមទាំងការដោះស្រាយបញ្ហាព្រហ្មទណ្ឌ ដែលកើតមាននៅក្នុងសហគមន៍ជនជាតិដើមភាគតិច[៣៩] (មាត្រា ៨ និង ៩)។

---

[៣៨] សូមមើលឧបសម្ព័ន្ធទី១ : មាតិកាក្របខ័ណ្ឌច្បាប់ជាច្រើន

[៣៩] សូមមើលឧបសម្ព័ន្ធទី១ : អត្ថបទច្បាប់ទាំងនេះ

ការទទួលខុសត្រូវចុងក្រោយរបស់រដ្ឋ ហើយក្រោយមកគឺយន្តការអន្តរជាតិ គឺដើម្បីធានាថាតម្រូវការយុត្តិធម៌ក្នុងសង្គមត្រូវបានគេឆ្លើយតបតាមរយៈការគោរពសិទ្ធិមនុស្សយ៉ាងទូលំទូលាយ ដោយពិចារណាពីនិយាមជាអប្បបរមាសេចក្តីត្រូវការរបស់សង្គម និងវប្បធម៌នៅក្នុងសង្គមនីមួយៗ។ បើសិនជាសិទ្ធិទទួលបានយុត្តិធម៌ មិនត្រូវបានគេផ្តល់ឱ្យនៅក្នុងប្រទេសទេនោះ ប្រជាពលរដ្ឋអាចប្តឹងទាមទារទៅភ្នាក់ងារអន្តរជាតិ ដូចជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ឬស្ថាប័នដទៃទៀតដែលរដ្ឋរបស់ខ្លួនជាសមាជិក។

តារាងស្តីពីការផ្តល់សេវាកម្មយុត្តិធម៌

| | |
|---|---|
| សេវាកម្មយុត្តិធម៌អាចទទួលបានតាមរយៈ | • តុលាការ<br>• យន្តការដោះស្រាយវិវាទក្រៅតុលាការ (ការផ្សះផ្សា ការសម្រុះសម្រួល និងអាជ្ញាកណ្តាល)<br>• យុត្តិធម៌តាមប្រពៃណី<br>• ច្បាប់ជនជាតិដើមភាគតិច និងរបៀបដោះស្រាយវិវាទរបស់គេ<br>• យន្តការក្រៅផ្លូវការដទៃៗទៀតសម្រាប់ដោះស្រាយវិវាទ |
| តួនាទីរបស់រដ្ឋ | ការសម្របសម្រួលធានាការគោរពសិទ្ធិមនុស្ស |

ការស្រាវជ្រាវអំពីសិទ្ធិទទួលបានយុត្តិធម៌

គោលការណ៍សិទ្ធិមនុស្ស ក៏បញ្ចូលផងក្នុងវិស័យការសិក្សាស្រាវជ្រាវ និងការកែលំអគោលនយោបាយ។ ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងក្នុងគោលបំណងកែលំអគោលនយោបាយ ដោយផ្អែកលើមូលដ្ឋាននៃនិយមន័យសិទ្ធិមនុស្ស ពោលគឺសិទ្ធិទទួលបានយុត្តិធម៌ ដោយមិនកំណត់ការសិក្សាត្រឹមតែករណីវិវាទដែលកើតមានជាក់ស្តែង របៀបដោះស្រាយវិវាទទាំងនោះ ឬធ្វើយ៉ាងណាទើបការដោះស្រាយវិវាទទាំងនោះ មានប្រសិទ្ធិភាពប៉ុណ្ណោះទេ។ ប៉ុន្តែការសិក្សាស្រាវជ្រាវនេះ គួរតែបញ្ចូលការសិក្សាអំពីប្រភពនៃការរំលោភសិទ្ធិ និងការរំលោភអំណាច និងតម្រូវយុត្តិធម៌ក្នុងសង្គមផ្សេងៗទៀត ដែលប្រជាពលរដ្ឋមិនបានប្តឹងតវ៉ា ដោយហេតុថាពួកគេខ្វះការយល់ដឹង ឬគ្មានទំនុកចិត្តនៅក្នុងប្រព័ន្ធច្បាប់។ ការសិក្សានៅក្នុងវិស័យនេះ ត្រូវតែពិចារណាផងដែរ ថាតើតម្រូវការយុត្តិធម៌នៅក្នុងសង្គមមួយចំនួន ដែលស្ថិតនៅជាអាថ៌កំបាំង គួរត្រូវឆ្លើយតបដោយរបៀបណា ហើយរកវិធីដើម្បីបង្កើតឱ្យមានយន្តការដ៏មានប្រសិទ្ធិភាពនានា ដើម្បីអនុវត្តនូវសិទ្ធិទាំងនោះ និងដើម្បីត្រួតពិនិត្យការរំលោភ អំណាច[៤០]។

## ១.៣. ផ្នែកតាមទ្រឹស្តីច្បាប់ៈ ប្រព័ន្ធច្បាប់ឯកនិយម និងប្រព័ន្ធច្បាប់ពហុនិយម

គោលគំនិតនៃ "ច្បាប់" អាចយល់បានពីទស្សនាទាននៃ "ប្រព័ន្ធច្បាប់ឯកនិយម" ឬ "ប្រព័ន្ធច្បាប់ពហុនិយម"។

ប្រព័ន្ធច្បាប់ឯកនិយម

ប្រព័ន្ធច្បាប់ឯកនិយម គឺជាទ្រឹស្តីដែលកំណត់ថា "រដ្ឋមួយ" មាន "ច្បាប់មួយ"។ ប្រព័ន្ធច្បាប់ឯកនិយម គឺជាទ្រឹស្តីដែលអាចប្រតិបត្តិតាមរូបភាពជាបទបញ្ញត្តិ ឬជាការពិពណ៌នា។ យោងតាមទ្រឹស្តីពិពណ៌នាមានន័យថា ពុំមាន "ច្បាប់" ដទៃណាទៀតនៅក្នុងតំបន់ភូមិសាស្ត្រជាក់លាក់មួយ ក្រៅពីច្បាប់ដែលបង្កើតឡើងដោយរដ្ឋឡើយ។ រីឯតាមទ្រឹស្តីជាបទបញ្ញត្តិវិញមានន័យថា មិនត្រូវមានប្រព័ន្ធច្បាប់ផ្សេងទៀត នៅក្នុងតំបន់ភូមិសាស្ត្រណាមួយរបស់រដ្ឋឡើយ ព្រោះនៅក្នុងរដ្ឋមួយត្រូវមានប្រព័ន្ធច្បាប់តែមួយប៉ុណ្ណោះ។

៤០ យើងនឹងពន្យល់បន្ថែមអំពីប្រធានបទនេះនៅក្នុងផ្នែក "វិធីសាស្ត្រនៃការស្រាវជ្រាវ"

ប្រព័ន្ធច្បាប់ឯកនិយមប្រកាន់ថា មានតែរដ្ឋប៉ុណ្ណោះជាអ្នកបង្កើត "ច្បាប់" ហើយរដ្ឋមានអំណាចផ្ដាច់មុខ ក្នុងការប្រើប្រាស់ការបង្ខំឱ្យអនុវត្ត (ការប្រើប្រាស់កម្លាំងដោយស្របច្បាប់)។ ផ្ទុយមកវិញ រដ្ឋត្រូវតែស្ថិតនៅក្រោមការបញ្ញត្តិរបស់ច្បាប់ផងដែរ។ ច្បាប់ត្រូវបានគេឱ្យនិយមន័យថាជាប្រព័ន្ធនៃវិធានដែលបង្កើតឡើង ដោយរដ្ឋតាមរយៈអំណាចរបស់ខ្លួនដោយស្របតាមបទបញ្ញត្តិជាក់លាក់នានា និងត្រូវអនុវត្តដោយស្ថាប័នផ្សេងៗ ផ្អែកលើមូលដ្ឋាននីតិវិធីច្បាប់ទាំងឡាយ។ អំណាចនីតិបញ្ញត្តិ ជាស្ថាប័នផ្ដាច់មុខទទួលមុខងារជាអ្នកអនុម័តច្បាប់ទូទៅ ដែលមានជាប់កាតព្វកិច្ចសម្រាប់ជនគ្រប់រូប។ តុលាការទទួលមុខងារផ្ដាច់មុខក្នុងការបកស្រាយច្បាប់ និងកាត់សេចក្ដីនូវវិវាទដែលកើតមាន។ ឯនីតិប្រតិបត្តិវិញមានអំណាចផ្ដាច់មុខក្នុងការអនុវត្តច្បាប់ ព្រមទាំងត្រួតពិនិត្យនូវរាល់សណ្ដាប់ធ្នាប់សាធារណៈ[៤១]។ បុគ្គលគ្រប់ៗរូបនៅក្នុងសង្គមអាចចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀងរវាងគ្នាដោយសេរី។ កិច្ចសន្យាទាំងនេះមានតម្លៃជាច្បាប់សម្រាប់ភាគី។ តែសម្រាប់ប្រព័ន្ធច្បាប់ឯកនិយម គ្មានបុគ្គល ឬក្រុមណាមួយក្រៅពីរដ្ឋ អាចបង្កើតឱ្យមានវិធាន ឬច្បាប់ចាប់បង្ខំសម្រាប់អ្នកដទៃបានឡើយ។ យោងតាមទ្រឹស្ដីសេរីនិយមបែបប្រពៃណីស្ដីពីរដ្ឋ គឺមានតែរដ្ឋប៉ុណ្ណោះ ដែលមានអំណាចក្នុងការបង្កើតឱ្យមានវិធានចាប់បង្ខំនានាសម្រាប់ប្រជាពលរដ្ឋទាំងអស់ ហើយអាចប្រើប្រាស់នូវការប្រើកម្លាំងដោយបង្ខំ ចំពោះពលរដ្ឋបានដើម្បីជាប្រយោជន៍ក្នុងការការពារសេរីភាពរបស់ប្រជាពលរដ្ឋរបស់ខ្លួន។

យើងអាចសង្កេតឃើញថា ដើមកំណើតនៃប្រព័ន្ធច្បាប់ឯកនិយមកើតចេញពីគំនិតពីរ។ គំនិតទីមួយគឺថាមានតែរដ្ឋទេដែលអាចទាមទារឱ្យប្រើប្រាស់កម្លាំង ដោយស្របច្បាប់នៅក្នុងទេសកាលណាមួយនៃប្រវត្តិសាស្ត្រ ដែលជាការប្រមូលផ្ដុំអំណាចនយោបាយដោយរដ្ឋទំនើបរបស់លោកខាងលិច ទៅលើក្រុមពួកសក្តិភូមិដែលធ្លាប់ប្រើប្រាស់កម្លាំងបង្ខំ នៅក្នុងដែនដីរបស់ពួកគេ។ តាមទ្រឹស្ដីនយោបាយសេរី ការមានអំណាចប្រើកម្លាំងដោយផ្ដាច់មុខរបស់រដ្ឋ ត្រូវបានធ្វើយុត្តិកម្មដោយសំអាងថា នេះជាវិធីមួយដែលរដ្ឋអាចការពារសិទ្ធិរបស់ប្រជាពលរដ្ឋ [៤២]។ រីឯគំនិតមួយផ្សេងទៀត ដែលជាមូលដ្ឋានគ្រឹះនៃទ្រឹស្ដីសេរីតាមប្រពៃណីរបស់រដ្ឋផងដែរនោះ គឺគោលការណ៍ការបែងចែកអំណាច [៤៣]។

ប្រភពមួយផ្សេងទៀតស្ដីពីប្រព័ន្ធច្បាប់ឯកនិយមនេះ គឺទ្រឹស្ដីវិជ្ជមាននិយមនៃច្បាប់ (legal positivism) ដែលមានប្រជាប្រិយភាពក្នុងកំឡុងពេលសតវត្សរ៍ទី ២០។ តាមទ្រឹស្ដីវិជ្ជមាននិយមនៃច្បាប់ ច្បាប់គ្រាន់តែជាវិធានឯកទេស ដែលធានា

---

៤១ នៅប្រទេសជាច្រើន ស្ថាប័នធម្មនុញ្ញឯករាជ្យផ្សេងទៀតក៏អាចមានអំណាចទាំងនេះខ្លះដែរ ស្ថាប័នទាំងនោះអាចជា អុំប៊ុដសម៉ែន ក្រុមប្រឹក្សាធម្មនុញ្ញ តុលាការធម្មនុញ្ញ គណៈកម្មាធិការបោះឆ្នោត ។ល។

៤២ ទស្សនៈវិទូ Thomas Hobbes ជាបិតានៃទស្សនៈវិជ្ជាសេរី ការពារគោលគំនិតដែលថាមានតែរដ្ឋប៉ុណ្ណោះដែលមានសិទ្ធិអំណាចផ្ដាច់មុខក្នុងការប្រើប្រាស់កម្លាំងដោយស្របច្បាប់ ក្នុងន័យធានាឱ្យមានសន្តិភាពក្នុងចំណោមប្រជាពលរដ្ឋ តាមរយៈការអនុវត្តច្បាប់។ បើសិនជាពុំមានច្បាប់ដែលធានាដោយការបង្ខំឱ្យអនុវត្តដោយរដ្ឋ នោះបុគ្គលនីមួយៗអាចព្យាយាមធ្វើអ្វីៗតាមទំនើងចិត្ត ដើម្បីបំពេញសេចក្ដីត្រូវការរបស់ខ្លួន ដោយមិនខ្វល់អំពីអ្នកដទៃឡើយ ដែលជាលទ្ធផលនាំឱ្យមានអសន្តិសុខសម្រាប់ជីវិត និងទ្រព្យសម្បត្តិ។ នេះជាគំនិតដែលថា "គ្រប់មនុស្សទាំងអស់គឺជាសត្វចចក ចំពោះមនុស្សម្នាក់ទៀត" នៅក្នុងរដ្ឋបែបធម្មជាតិ។ សូមមើល ៖ Hobbes, Thomas (1651): *Leviathan, or the matter, forme and power of a common-wealth ecclesiasticall and civill*. London: Penguin Books, reimp. 1985.

៤៣ បើសិនជារដ្ឋប្រមូលនូវអំណាចផ្ដាច់មុខ ក្នុងការប្រើប្រាស់កម្លាំងដោយស្របច្បាប់ កម្លាំងដែលប្រើដោយរដ្ឋនោះ ត្រូវតែមិនមែនជាការធ្វើឡើងដោយបង្ខំនិងរំលោភចំពោះជីវិត និងសន្តិសុខ ឬសិទ្ធិមនុស្សឡើយ។ នៅក្នុងទ្រឹស្ដីតាមបែបសេរីនិយម ការការពារសិទ្ធិទាំងនោះគឺជាមូលហេតុដែលនាំឱ្យមានរដ្ឋ។ ដូចនេះ ការបែងចែកអំណាចនៅក្នុងរដ្ឋគឺជាការមួយចាំបាច់ណាស់ ដើម្បីបង្កើតប្រព័ន្ធត្រួតពិនិត្យតុល្យភាពអំណាច ក្នុងចំណោមអំណាចរបស់រដ្ឋ ដើម្បីធានាឱ្យបានថា រាល់ការប្រើកម្លាំងដោយបង្ខំ គឺពិតជាធ្វើឡើងដោយស្របច្បាប់។ តុលាការមានបន្ទុកក្នុងការត្រួតពិនិត្យការប្រើប្រាស់កម្លាំងដោយអំណាចប្រតិបត្តិ។ ទ្រឹស្ដីស្ដីពីការបែងចែកអំណាច ជាគំនិតរបស់លោក Montesquieu ។ សូមមើល ៖ Montesquieu, Charles-Louis (1748): The Spirit of the Laws, translated by Thomas Nugent, revised by J. V. Prichard based on an public domain edition published in 1914 by G. Bell & Sons, Ltd., London.

ដោយការបង្ខំ ហើយវិធានទាំងនេះខុសអំពីសីលធម៌ និងសាសនា [៤៤]។ រដ្ឋជាអ្នកមានអំណាចផ្តាច់មុខ ក្នុងការប្រើប្រាស់កម្លាំងដោយបង្ខំ។ តាមទស្សនៈរបស់លោកកែលសិន (Kelsen) ប្រព័ន្ធទាំងអស់ គឺពឹងផ្អែកសំខាន់តែទៅលើការអនុវត្តដោយបង្ខំដោយស្ថាប័ជាក់លាក់របស់រដ្ឋ ស្របតាមនីតិវិធីទាំងឡាយ ដែលមានចែងក្នុងច្បាប់ [៤៥] ។

ដោយប្រព័ន្ធច្បាប់ឯកនិយមកំណត់ថា ច្បាប់ជាវិធានដែលបង្កើតឡើងដោយរដ្ឋ ដូចនេះធម្មនិយម ឬវិធាននៃការប្រព្រឹត្តិទៅរបស់សង្គម ដែលមិនត្រូវបានបង្កើតឡើងដោយរដ្ឋ ត្រូវបានហៅថាជា "ប្រពៃណី"។ ប្រពៃណីកើតចេញពីបទដ្ឋាននានារបស់សង្គម ដែលត្រូវបានអនុវត្តជាដដែលៗក្នុងរយៈពេលដ៏វែង ហើយក្រោយមកប្រជាពលរដ្ឋ ចាប់ផ្តើមធ្វើតាមវិធានទាំងនោះដោយចាត់ទុកថាវាជាកាតព្វកិច្ចដែលគេត្រូវធ្វើ។ ច្បាប់កំណត់ស្ថានភាពផ្លូវច្បាប់របស់ប្រពៃណី ដោយទទួលស្គាល់ភាពស្របច្បាប់សម្រាប់ករណីខ្លះ នៅពេលដែលប្រពៃណីនេះជួយបំពេញបន្ថែមទៅលើច្បាប់របស់រដ្ឋ ដរាបណាប្រពៃណីនេះមិនត្រូវផ្ទុយអំពីច្បាប់របស់រដ្ឋឡើយ ។ ច្បាប់របស់រដ្ឋមិនបានទទួលស្គាល់ប្រពៃណីទាំងឡាយណា ដែលផ្ទុយច្បាប់ឡើយ ។

**ព្រំដែន (Limits)៖** ផ្អែកតាមទ្រឹស្តីនៃការពិពណ៌នា ប្រព័ន្ធច្បាប់ឯកនិយមមានការប្រឈមយ៉ាងខ្លាំង ចំពោះស្ថានភាពដែលមានប្រព័ន្ធច្បាប់ច្រើន នៅក្នុងតំបន់ភូមិសាស្ត្រតែមួយ ដោយសារមានការប្រែប្រួលអាណានិគមនិយម និងវត្តមានរបស់ក្រុមជនជាតិដើមភាគតិចនៅក្នុងប្រវត្តិសាស្ត្រ ។ល។

ផ្អែកតាមទ្រឹស្តីជាបទបញ្ញត្តិអំណះអំណាងរបស់វា គឺជាទ្រឹស្តីសេរីតាមបែបទំនើប ។ រដ្ឋមានសិទ្ធិផ្តាច់មុខងក្នុងការបង្កើតច្បាប់ និងការប្រើប្រាស់កម្លាំងដោយស្របច្បាប់ សម្រាប់ជាប្រយោជន៍ក្នុងការការពារសិទ្ធិ និងសេរីភាព។ តាមពិតចាំបាច់ត្រូវមានរៀបចំឱ្យមានសណ្តាប់ធ្នាប់សង្គម និងបង្កាការរំលោភដោយសារការប្រើកម្លាំងរបស់ឯកជន ដោយខ្វះខាតការត្រួតពិនិត្យដែលច្បាប់បានផ្តល់ឱ្យ។ ទោះជាយ៉ាងនេះក្តី បើសិនជាជាក់ស្តែងមានប្រព័ន្ធច្បាប់ ឬការអនុវត្តផ្សេងៗពីគ្នានៅជាមួយគ្នា ហើយរដ្ឋមិនទទួលស្គាល់វិធានប្រពៃណី ឬវិធានរបស់ជនជាតិដើមភាគតិច ដែលក្រុមមួយចំនួនអនុវត្តនិងគោរពនោះ ជាលទ្ធផលអាចនាំឱ្យក្រុមអ្នកដែលអនុវត្ត និងរស់នៅក្រោមវិធានមិនផ្លូវការទាំងនោះ ត្រូវនៅក្រៅការគាំពារពីរដ្ឋ (ឧទាហរណ៍ ការរៀបអាពាហ៍ពិពាហ៍របស់ពួកគេ ប្រពន្ធ័គ្រប់គ្រងដីធ្លីពួកគេ និងការប្រតិបត្តិផ្សេងៗទៀតមិនត្រូវបានទទួលស្គាល់ឡើយ) ហើយស្របពេលជាមួយគ្នានេះ ក្រុមមនុស្សដែលរស់នៅក្រោមច្បាប់ប្រពៃណីទាំងនោះ មិនអាចមានឱកាសទទួលយកសេវានានាពីស្ថាប័នរដ្ឋឡើយ។ យោងតាមអង្គហេតុនេះ ការប្រកាន់ជំហរឱ្យមានប្រព័ន្ធច្បាប់ឯកនិយម នៅក្នុងបរិបទដែលមានប្រព័ន្ធច្បាប់ច្រើននៅក្នុងរដ្ឋតែមួយនោះ អាចមានក្លាយជាស្ថានភាពរំលោភសិទ្ធិមនុស្ស ជាជាងការការពារសិទ្ធិសេរីភាពជូនពលរដ្ឋ ។

---

[៤៤] ទ្រឹស្តីវិជ្ជមាននិយមនៃច្បាប់ (Legal positivism) បែងចែកនូវបទដ្ឋាននានាដោយយោងទៅតាមប្រភព និងចរិតរបស់វា។ ចំពោះលោក Kelsen ជាបិតានៃទ្រឹស្តីវិជ្ជមាននិយមនៃច្បាប់ លើកឡើងថាពបលបទដ្ឋាន (វិធាន "នូវអ្វីដែលគួរកើត") អាចជាសាសនា សីលធម៌ ឬជាច្បាប់ ។ល។ ជាចុងក្រោយភាពខុសគ្នាគឺអាស្រ័យលើការប្រើប្រាស់កម្លាំងបង្ខំ ដោយអនុលោមតាមបទដ្ឋានច្បាប់។ បទដ្ឋានខាងសាសនាត្រូវបានធានា ដោយសារការបំភ័យនៅក្នុងជាតិក្រោយៗទៀត (ដូចជាស្ថានសួគ៌ និងស្ថាននរកជាដើម) ដូចនេះមនុស្សខ្លះអាចគោរពតាមការបង្រៀនសាសនាទាំងនោះ ហើយអ្នកខ្លះក៏មិនគោរពតាមដែរ ។ បទដ្ឋានខាងសីលធម៌ត្រូវ បានធានាដោយសម្ពាធរបស់សង្គម។ សម្ពាធរបស់សង្គមអាចកាន់តែខ្លាំងឡើងៗ ហើយកើតឡើង ឬអាចអត់។ ប៉ុន្តែបទដ្ឋាននីត្យានុកូល "ច្បាប់" ត្រូវបានធានាដោយការប្រើកម្លាំងបង្ខំ។ សូមមើល : Kelsen, Hans (1967): *Pure Theory of Law*, (Knight trans.), UC Berkeley press.

[៤៥] ការបង្ខិតបង្ខំ ត្រូវបានគេហៅផងដែរថា "ហិង្សាដោយស្របច្បាប់"។ ច្បាប់តម្រូវឱ្យ ១. មានសុពលភាព (បទដ្ឋាននានា គួរតែផ្អែកលើមូលដ្ឋានច្បាប់ដែលខ្ពស់ជាង ឬរដ្ឋធម្មនុញ្ញ) ២. មានការទទួលស្គាល់ដោយពលរដ្ឋ (ត្រូវបានទទួលស្គាល់ជាទូទៅ ដោយពលរដ្ឋ) ៣. មានប្រសិទ្ធិភាព (អាចអនុវត្តបាន) និង ៤.ទទួលស្គាល់ជាអន្តរជាតិ ។ សូមមើល : Kelsen (ob. cit).

ប្រព័ន្ធច្បាប់ពហុនិយម

ប្រព័ន្ធច្បាប់ពហុនិយម គឺជាទ្រឹស្តីដែលអនុញ្ញាតឱ្យមាន "ប្រព័ន្ធច្បាប់" ច្រើនជាងមួយនៅក្នុងតំបន់ភូមិសាស្ត្រ តែមួយ និងជាទូទៅមានការសិក្សានិងកែលំអនូវរាល់មធ្យោបាយ ដើម្បីចែង និងទប់ស្កាត់នូវរាល់ទំនាស់រវាងច្បាប់ទាំងនោះ[៤៦] ។ ប្រព័ន្ធច្បាប់ពហុនិយម ក៏មានវិសាលភាពខាងការពិពណ៌នា និងការដាក់បញ្ញត្តិដែរ ។

ទ្រឹស្តីពហុនិយមនៃច្បាប់ តម្រូវឱ្យមានការឱ្យនិយមន័យ "ច្បាប់" ដែលអាចប្រើដើម្បីកំណត់ និងប្រៀបធៀប ប្រព័ន្ធច្បាប់ផ្សេងៗគ្នា នៅក្នុងតំបន់ភូមិសាស្ត្រតែមួយ។ អ្នកដែលការពារប្រព័ន្ធច្បាប់ពហុនិយម ដែលភាគច្រើនជាអ្នកសិក្សាពីនរវិទ្យា បាននិយមន័យច្បាប់ជាច្រើន។ ជាអប្បបរមា "ច្បាប់" មាន: ១). វិធាននានា ២). អាជ្ញាធរ និង ៣). នីតិវិធីដើម្បីប្រើប្រាស់សម្រាប់ ក)- ធ្វើនិយ័តកម្មជីវិតក្នុងសង្គម ខ)- រៀបចំសណ្តាប់ធ្នាប់សាធារណៈ គ)- ដោះស្រាយវិវាទ និង ឃ)-ផ្លាស់ប្តូរវិធាននានា។ ប្រព័ន្ធនៃធម្មនិយម អាជ្ញាធរ និងនីតិវិធីត្រូវតែមានប្រសិទ្ធិភាព ក្នុងកម្រិតណាមួយ (ដូចជាយ៉ាងម៉ឺងម៉ាត់ និងអនុវត្តបាន) និងស្របច្បាប់ (ដោយពិចារណាអំពីភាពចាំបាច់របស់អ្នកប្រើប្រាស់) ដើម្បីរាប់ថាជាច្បាប់ត្រឹមត្រូវ។ បទបញ្ញត្តិអាចដាច់ដោយឡែកពីគ្នា ឬមានការលាយឡំជាមួយសាសនា សីលធម៌ និងវិធាននានារបស់សង្គម ឧទាហរណ៍ក្នុងករណីដែល វិធាននោះផ្អែកលើគោលការណ៍សាសនា តម្លៃខាងសីលធម៌ វិធានជាប្រពៃណី និងបទបញ្ញត្តិនានាដែលបង្កើតឡើងដោយក្រុមឬការព្រមព្រៀងណាមួយ។ ការអនុវត្តអាចធ្វើឡើងដោយយន្តការ និងអាជ្ញាធរនានា ដែលមិនចាំបាច់ថាត្រូវតែជាស្ថាប័នឯកទេសឡើយ (យន្តការទាំងនេះ អាចជាអាជ្ញាធរនយោបាយនិងសាសនា ហើយអាចជាបុគ្គលណាម្នាក់ ឬជាក្រុមក៏បាន) ។ វិធានទាំងឡាយអាចត្រូវបានបង្កើត ឬកែប្រែឡើងវិញនៅក្នុងបរិបទ និងដោយភ្នាក់ងារផ្សេងៗគ្នា។ យោង-តាមការឱ្យនិយមន័យ "ច្បាប់" នេះ ទោះបីជាគ្មានរដ្ឋក៏អាចមានច្បាប់បានដែរ ឬនៅក្នុងតំបន់ភូមិសាស្ត្រតែមួយអាចមាន ប្រព័ន្ធច្បាប់ច្រើន។

ប្រព័ន្ធច្បាប់ពហុនិយម ត្រូវបានបង្កើតឡើងនៅក្នុងស្ថានភាពជាច្រើន[៤៧] ។ ទីមួយស្ថានភាពអាណានិគម ដែលរដ្ឋាភិបាលអាណានិគមបង្កើតបទបញ្ញត្តិថ្មីៗនៅក្នុងទឹកដី ដែលធ្លាប់គ្រប់គ្រងដោយអាជ្ញាធរ បទបញ្ញត្តិ និងនីតិវិធីពីមុនៗរួចហើយនោះ។ ដូចនេះវិស័យខ្លះនៃការរស់នៅ និងនៅតំបន់មួយចំនួននៅតែបន្តអនុវត្ត ប្រព័ន្ធច្បាប់ចាស់ដែលធ្លាប់មានកន្លងមក។ ប្រព័ន្ធច្បាប់ពហុនិយម អាចមានអត្ថិភាពផងដែរ ក្នុងបរិបទនៃសង្គ្រាម ការធ្វើបដិវត្តន៍ និងការធ្វើទំនើបកម្មដ៏ឆាប់រហ័ស ដែលនាំឱ្យមានប្រព័ន្ធច្បាប់ចាស់និងច្បាប់ថ្មី មានអត្ថិភាពក្នុងពេលជាមួយគ្នា ក្នុងរយៈពេលណាមួយនោះ។ ប្រព័ន្ធច្បាប់ពហុនិយមអាចកើតមានផងដែរ នៅកន្លែងដែលមានជនជាតិដើមភាគតិច ឬក្រុមជាតិពន្ធុនានារស់នៅស្របពេលជាមួយប្រជាពលរដ្ឋភាគច្រើន ដែលជាអ្នកកំណត់ឱ្យមាន "ប្រព័ន្ធច្បាប់ជាតិ"។ អត្ថិភាពនៃប្រព័ន្ធច្បាប់ផ្សេងៗនៅពេលជាមួយគ្នា នៅក្នុងតំបន់ភូមិសាស្ត្រណាមួយ អាចបង្កឱ្យមានទំនាស់លើអន្តរនិត្យានុកូលភាព។

ឫសគល់ប្រវត្តិសាស្ត្រ: នៅប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅអាស៊ី អាហ្វ្រិក និងអាមេរិកឡាទីន ធ្លាប់ និងកំពុងមានដំណើរការនៃ "លំនាំចូលនូវច្បាប់" របស់ប្រទេសលោកខាងលិចមួយចំនួន ទាំងអង្គភាព និងស្ថាប័នច្បាប់ ដែលក្រោយមកបានក្លាយជា "ច្បាប់ជាតិ" និង "ផ្លូវការ"។ ករណីភាគច្រើនស្ថាប័នច្បាប់បែបលោកខាងលិចអនុវត្តមានប្រសិទ្ធិភាព តែនៅតំបន់

៤៦ Santos, Boaventura de Sousa (1995): *Towards a New Common Sense: Law, Science and Politics in the Paradigmatic Transition.* Nueva York: Rutledge; (1991): *Estado, Derecho y Luchas Sociales.* Bogotá: ILSA (p. 63-72); (1987): "Law: A Map of Misreading: Toward a Postmodern Conception of Law", en *Journal of Law and Society* 14. See also: Griffiths, John (1986): *What is Legal Pluralism?, in: Journal of Legal Pluralism and Unofficial Law* No. 24: 1-56; Gluckman, Max (1955) *The Judicial Process among the Barotse of Northern Rhodesia.* Manchester. Merry, Sally (1988): "Legal Pluralism". Law and society review, Vol. 22, p. 869-96.

៤៧ Santos, Boaventura de Sousa (1994): "Entrevista", en *Desfaciendo Entuertos* N° 3-4 (pp. 27-31).

មួយចំនួនដែលមានការរីកចំរើនប៉ុណ្ណោះ ដូចជានៅទីក្រុង ឬទីប្រជុំជនជាដើម។ តែនៅឯជនបទដាច់ស្រយាលវិញ ប្រជាពលរដ្ឋនៅតែបន្តអនុវត្ត និងគ្រប់គ្រងការរស់នៅប្រចាំថ្ងៃរបស់ពួកគេតាមបែបប្រពៃណី (ដូចជាការរៀបអាពាហ៍ពិពាហ៍ ការគ្រប់គ្រងកេរ្តិ៍មរតក និងការគ្រប់គ្រងដីធ្លី។ល។) ព្រមទាំងដោះស្រាយវិវាទដោយយោងទៅតាមទំនៀមទំលាប់ប្រពៃណី ឬវប្បធម៌របស់ពួកគេ។ នៅក្នុងកាលៈទេសៈទាំងនេះ ត្រូវមានដំណើរការសម្របសម្រួលរវាង "ប្រព័ន្ធច្បាប់ជាតិ" និងច្បាប់ដែលអនុវត្តនៅតាមមូលដ្ឋាន។ ស្ថានភាពនេះ អាចបង្កឱ្យមានទំនាស់អន្តរនិត្យានុកូលភាព នៅពេលដែលប្រព័ន្ធច្បាប់ទាំងនេះ អនុវត្តទៅមិនចុះសំរុងនឹងគ្នា។ ជាធម្មតាប្រព័ន្ធច្បាប់ទំនើប ផ្អែកលើមូលដ្ឋាននៃស្ថាប័នបែបលោកខាងលិច មិនត្រូវបានគេអនុវត្តដោយមានប្រសិទ្ធិភាពខ្ពស់ឡើយ ដោយប្រព័ន្ធនេះតម្រូវឱ្យមានអ្នកប្រតិបត្តិការដែលមានជំនាញច្បាស់លាស់ (ចៅក្រម ព្រះរាជអាជ្ញា។ល។) ក៏ដូចជាធនធានផ្សេងៗទៀតដើម្បីអាចអនុវត្ត បាននៅតំបន់ដាច់ស្រយាលនៃប្រទេស។ បន្ថែមលើនេះទៀតប្រព័ន្ធច្បាប់ថ្មីជាអ្នករំកិលទំពោះរាល់វប្បធម៌នៃច្បាប់មួយ ដែលផ្សេងពីអ្វីដែលមាននៅមូលដ្ឋាន គឺគេជាអ្នកធ្វើនិយ័តកម្មលើផ្នែកសំខាន់ៗមួយចំនួន (ដូចជាការរៀបអាពាហ៍ពិពាហ៍ និងការគ្រប់គ្រងមរតកជាដើម) តាមវិធីដែលខុសអំពីអ្វីដែលប្រជាពលរដ្ឋធ្លាប់មានកន្លងមក។ គេក៏ដោះស្រាយចំពោះបទល្មើសព្រហ្មទណ្ឌ ដែលកើតមានដោយខុសប្លែកអំពីអ្វីដែលជាទំលាប់របស់មូលដ្ឋានផងដែរ។ តាមក្រមច្បាប់បែបលោកខាងលិច ក៏មានចែងផងដែរអំពីស្ថាប័នផ្សេងៗសម្រាប់ត្រួតពិនិត្យសង្គម ដូចជាតុលាការ មេធាវី ព្រះរាជអាជ្ញា។ល។ ដូច្នេះនៅតាមជនបទដាច់ស្រយាល ប្រជាពលរដ្ឋមានបំណងអភិរក្សនូវការអនុវត្តច្បាប់ និងទំនៀមទំលាប់របស់ពួកគេ ដែលមានលក្ខណៈខុសប្លែកអំពីប្រព័ន្ធច្បាប់របស់ជាតិ និងបន្តឱ្យអាជ្ញាធរមូលដ្ឋានដើរតួនាទីដោះស្រាយវិវាទប្រចាំថ្ងៃ ស្របទៅតាមវប្បធម៌ និងទំលាប់របស់មូលដ្ឋានដដែល។

បាតុភូតនៃអត្ថិភាពស្របគ្នានៃច្បាប់ផ្លូវការតាមបែបលោកខាងលិចនេះ "ទោះជាប្រព័ន្ធច្បាប់ស៊ីវិល (ប្រព័ន្ធបារាំង) ឬប្រព័ន្ធច្បាប់ឥតសរសេរ (common law - ដែលមានឥទ្ធិពលពីច្បាប់អង់គ្លេស) ក្តី" និងបទបញ្ញត្តិនៃទំនៀមទំលាប់ក្រៅផ្លូវការ (ថ្នាក់មូលដ្ឋាន) គឺជាករណីសមញ្ញសម្រាប់ប្រទេសនៅអាស៊ីនិងអាហ្វ្រិក ដោយសារតែការធ្វើអាណានិគមរបស់ប្រទេសនៅអឺរ៉ុប និងនៅអាមេរិកឡាទីន បន្ទាប់ពីទទួលបានឯករាជ្យភាពនៅសតវត្សរ៍ទី១៩ រៀងមក[៤៨]។ គ្រប់ប្រទេសទាំងអស់ដែលប្រកាន់យកប្រព័ន្ធច្បាប់ស៊ីវិល សុទ្ធតែធ្លាប់នៅក្រោមអាណានិគមបារាំងកាលពីសតវត្សរ៍ទី១៩ ដូចជានៅប្រទេសកម្ពុជា ជាដើម ដែលអនុម័តយកក្រមណាប៉ូលេអុង និងប្រព័ន្ធច្បាប់ឯកនិយម។ ដូច្នេះពួកគេបដិសេធទាំងស្រុង នូវអ្វីដែលជាប្រព័ន្ធច្បាប់ពហុនិយម។ ប្រព័ន្ធច្បាប់ឯកនិយមសុទ្ធតែទទួលយកដោយមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដែលអនុម័តនៅក្រោមប្រព័ន្ធច្បាប់ស៊ីវិលទំនើប។ ការនេះនាំឱ្យមានគោលគំនិតពីរ គឺគំនិតស្តីពីរដ្ឋ (Nation-state) និងអត្តសញ្ញាណនៃរដ្ឋជាមួយនឹងច្បាប់ (identity of the State with law)។ រដ្ឋធម្មនុញ្ញនៃរដ្ឋទាំងនេះបានចែង និងអនុញ្ញាតឱ្យមានប្រព័ន្ធច្បាប់តែមួយភាសាផ្លូវការមួយ និងមានវប្បធម៌គ្របដណ្តប់រួមមួយនៅក្នុងប្រទេស។ មានន័យថាមានតែរដ្ឋទេ ដែលមានអំណាចធ្វើច្បាប់ និងអនុញ្ញាតឱ្យប្រើកម្លាំងដោយបង្ខំបាន ហើយប្រជាពលរដ្ឋទាំងអស់ត្រូវតែស្ថិតនៅក្រោមអាជ្ញាធរតែមួយ ច្បាប់តែមួយ និងនីតិវិធីតែមួយដូចដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ បន្ទាប់ពីអនុម័តយកតាមប្រព័ន្ធច្បាប់នេះ នៅក្នុងប្រទេសនានានៅអាស៊ី និងអាហ្វ្រិក នៅក្នុងសតវត្សរ៍ទី១៩មក ការបែងចែករវាងច្បាប់ផ្លូវការ និងតថភាពរបស់សង្គមបានលេចជារូបរាងឡើង។

---

[៤៨] រដ្ឋទាំងឡាយដែលធ្លាប់នៅក្រោមអាណានិគមរបស់អង់គ្លេសនៅសតវត្សរ៍ទី១៩ អាចបញ្ចូលនូវប្រព័ន្ធច្បាប់មូលដ្ឋាន ជាមួយបញ្ញត្តិច្បាប់លោកខាងលិចបានតាមរូបភាពនៃ "វិធានមិនផ្ទាល់" ដូចអ្វីដែលប្រទេសអេស្ប៉ាញបានធ្វើក្នុងអំឡុងអាណានិគមលើប្រទេសនានានៅអាមេរិកឡាទីន (សតវត្សរ៍ទី ១៦-១៨)។ តាមទម្រង់នេះអាជ្ញាធរជាតិដើមភាគតិច ក៏ដូចជាវិធាននិងរបៀបដោះស្រាយវិវាទទាំងឡាយត្រូវបានគេអនុញ្ញាត និងទទួលស្គាល់ តែត្រូវដាក់ជារបោបនៃអាជ្ញាធរ វិធាន និងនីតិវិធីទាំងឡាយរបស់រដ្ឋាភិបាលអាណានិគម។ នេះជាករណីដែលយើងអាចហៅថា "តុលាការប្រពៃណី" នៅក្នុងប្រទេសមួយចំនួននៅអាហ្វ្រិក ដឹកនាំដោយអាជ្ញាធរក្រុមកុលសម្ព័ន្ធ ឬជនជាតិដើមភាគតិច ក្រុមក្លាន (clan or tribal authorities)។ នៅប្រទេសដែលនៅក្រោមអាណានិគមរបស់អង់គ្លេសវិញ ប្រព័ន្ធច្បាប់ពហុនិយមត្រូវបានអនុញ្ញាតដោយមានកម្រិត ដូចនេះ ប្រព័ន្ធច្បាប់ជាតិកំណើតអាចអនុញ្ញាតិឱ្យប្រើប្រាស់ដើម្បីដោះស្រាយវិវាទផ្សេងៗ ព្រមទាំងការដាក់ទោសទណ្ឌផងដែរ។ អ្វីដែលជាប្រព័ន្ធថ្មីស្រឡាងនោះ គឺឥទ្ធិពលនៃប្រព័ន្ធច្បាប់ស៊ីវិល។

នៅតំបន់ជនបទដាច់ស្រយាល ស្ថាប័នច្បាប់នៅមូលដ្ឋាន នៅតែបន្តអនុវត្ត ដូចជាការរៀបការតាមប្រពៃណី និងដំណើរការសម្រុះសម្រួលក្នុងការដោះស្រាយវិវាទនានាជាដើម ប៉ុន្តែច្បាប់ផ្លូវការមិនអើពើ ឬថែមទាំងមិនអនុញ្ញាតទៀតផង។ ប្រទេសមួយចំនួននៅអាមេរិកឡាទីន ការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលបានធ្វើកាលពីទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទី២០ បានព្យាយាមធ្វើកំណែទម្រង់ ដោយពិចារណានិងយកចិត្តទុកដាក់ចំពោះស្ថានភាពនេះ និងលុបបំបាត់នូវគម្លាតរវាងច្បាប់ផ្លូវការ និងការអនុវត្តនៅមូលដ្ឋាន។ ជាឧទាហរណ៍ ប្រទេសនៅអាស៊ីនិងអាមេរិកឡាទីនមួយចំនួន នៅមានយន្តការដោះស្រាយវិវាទនៅមូលដ្ឋាន ក៏ដូចជាការអាពាហ៍ពិពាហ៍តាមប្រពៃណី ហើយត្រូវបានទទួលស្គាល់ដោយច្បាប់ផ្លូវការ ដោយចាត់ទុកថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

នៅពេលដែលជនជាតិដើមភាគតិចអភិរក្សនូវអាជ្ញាធរ វិធានជាប្រពៃណី ក៏ដូចជាយន្តការ និងនីតិវិធីផ្សេងៗសម្រាប់ដោះស្រាយវិវាទរបស់ពួកគេ នោះយើងនឹងមានអ្វីមួយដែលហៅថា "ច្បាប់ទំនៀមទំលាប់របស់ជនជាតិដើមភាគតិច" ឬច្បាប់ជនជាតិដើមភាគតិច។ បើសិនជាច្បាប់ជនជាតិដើមភាគតិច មិនត្រូវបានគេទទួលស្គាល់ថាមានលក្ខណៈធម្មនុរូបភាព និងជាប្រភពនៃច្បាប់ទេ នោះប្រព័ន្ធច្បាប់ជាតិនឹងត្រូវបានគេដាក់ឱ្យអនុវត្តសម្រាប់ប្រជាពលរដ្ឋដែលជាជនជាតិដើមភាគតិចនោះ ដែលអាចឱ្យមានអំពើហិង្សាកម្រិតផ្សេងៗគ្នា ដោយអាស្រ័យទៅលើកម្រិតនៃប្រតិកម្មរបស់ជនជាតិដើមភាគតិច ប្រឆាំងនឹងប្រព័ន្ធច្បាប់ផ្លូវការ។ តាមប្រវត្តិសាស្ត្រ មាន "រដ្ឋ" ជាច្រើនដែលធ្លាប់មាននយោបាយបំផ្លាញចោលទាំងស្រុង ការដាក់ឱ្យនៅជាមួយគ្នាដោយមិនគិតពីជាតិពន្ធុ ឬការធ្វើសមាហរណកម្មដើម្បីអនុវត្ត "ប្រព័ន្ធច្បាប់ជាតិ" ដោយបង្ខំចំពោះជនជាតិដើមភាគតិចនៅក្រោមមនោគមន៍វិជ្ជានៃអធិបតេយ្យជាតិ និងបូរណភាពទឹកដី។ នៅពីរទសវត្សរ៍កន្លងទៅ មានការអភិវឌ្ឍយ៉ាងសំខាន់ខាងច្បាប់អន្តរជាតិទាក់ទិននឹងជនជាតិដើមភាគតិច។ នៅឆ្នាំ១៩៨៩ អង្គការពលកម្មអន្តរជាតិបានអនុម័តអនុសញ្ញាលេខ ១៦៩ ស្តីពីជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធនៅក្នុងប្រទេសឯករាជ្យ ដែលអនុសញ្ញានេះបានហាមប្រាមមិនឱ្យរដ្ឋជាសមាជិកធ្វើសមាហរណកម្ម ឬការបញ្ចូលក្រុមជាតិពន្ធុឱ្យចូលគ្នាឡើយ ព្រមទាំងទទួលស្គាល់សមត្ថភាពរបស់ជនជាតិដើមភាគតិចក្នុងការអភិរក្សនិងអភិវឌ្ឍសង្គម វប្បធម៌ សេដ្ឋកិច្ច និងនយោបាយរបស់ពួកគេ ក៏ដូចជាច្បាប់ប្រពៃណីនិងអាជ្ញាធរ វិធាន និងរបៀបនៃការដោះស្រាយវិវាទ និងការដាក់ទោសដល់ជនដែលប្រព្រឹត្តិបទល្មើស នៅក្នុងរង្វង់សមាជិកសហគមន៍របស់គេថែមទៀតផង។ នេះជាទម្រង់មួយនៃ "ពហុនិយម នៃច្បាប់នៅក្នុងប្រទេសមួយ" និងស្ថិតនៅក្រោមក្របខ័ណ្ឌរួម នៃសិទ្ធិមនុស្ស។ យោងតាមគោលនយោបាយ ពហុនិយមនិងពហុវប្បធម៌ មានរដ្ឋជាច្រើននៅពេលបច្ចុប្បន្ននេះ ទទួលស្គាល់ច្បាប់ជនជាតិដើមភាគតិច អាជ្ញាធរ និងនីតិវិធីដោះស្រាយវិវាទ ព្រមទាំងព្យាយាមសម្របសម្រួលឱ្យច្បាប់ជនជាតិដើមភាគតិច នៅស្របជាមួយនឹងច្បាប់ជាតិ ប្រកបដោយសន្តិភាព និងតាមបែបប្រជាធិបតេយ្យ[៤៩]។

**គោលនយោបាយទាក់ទិននឹងស្ថានភាពជាក់ស្តែងនៃប្រព័ន្ធច្បាប់ពហុនិយម:** ការដែលអនុញ្ញាតឱ្យមានអត្ថិភាពនៃប្រព័ន្ធច្បាប់ពហុនិយមតាមជាក់ស្តែង (តាមព្រឹត្តិហេតុ) មិនមែនមានន័យថា មានការទទួលស្គាល់ខាងនយោបាយឱ្យមានដូច្នេះឡើយ ពោលគឺមានជំរើសជាច្រើនដូចជា :

ក. **គោលនយោបាយហាមឃាត់:** ទោះបីជាតាមទ្រឹស្តី អាចមានលទ្ធភាពក្នុងការបង្កើតឱ្យមានប្រព័ន្ធច្បាប់ពហុនិយមក៏ដោយក្តី រដ្ឋអាចនៅតែមិនទទួលស្គាល់ការអនុវត្តច្បាប់ប្រពៃណី និងច្បាប់ជនជាតិដើមភាគតិច។ រដ្ឋអាចប្រើប្រាស់កម្លាំងដើម្បីបង្ខំឱ្យជនជាតិដើមភាគតិច ឬក្រុមទាំងឡាយណាដែលមានវិធានច្បាប់ប្រពៃណីរបស់ខ្លួន ឱ្យគោរពទៅ

---

[៤៩] ជាឧទាហរណ៍ រដ្ឋធម្មនុញ្ញជាច្រើននៅអាមេរិកឡាទីន បានទទួលស្គាល់អំណាចយុត្តាធិការរបស់អាជ្ញាធរជនជាតិដើមភាគតិច ដើម្បីដោះស្រាយវិវាទនានាដោយស្របទៅតាមច្បាប់ប្រពៃណី និងនីតិវិធីរបស់ពួកគេ។ សូមមើល : Yrigoyen Fajardo, Raquel (2004): "Legal Pluralism, Indigenous Law and the Special Jurisdiction in the Andean Countries", en *Beyond Law, Informal Justice and Legal Pluralism in the Global South Vol. 10*, Issue # 27, 2004. (Available at http://www.ilsa.org.co/biblioteca/bl27/bl27.htm).

តាមច្បាប់ផ្លូវការរបស់រដ្ឋ ភាសាផ្លូវការ និងវប្បធម៌រួមផងដែរ។ ជាលទ្ធផល សមាជិកនៃក្រុមជនជាតិដើមភាគតិច និងក្រុមជាតិពន្ធុភាគតិចមួយចំនួនទៀត មិនអាចទទួលបានសេរីភាពនិងសិទ្ធិដូចប្រជាពលរដ្ឋ ដែលជាសមាជិកភាគច្រើននៅក្នុងប្រទេសឡើយ។ បើសិនជាពុំមានការការពារដី អត្តសញ្ញាណវប្បធម៌ និង អាជ្ញាធររបស់ពួកគេទេ ជនជាតិដើមភាគតិចទាំងនោះ អាចមានអារម្មណ៍ថាត្រូវបានគេបោះបង់ចោល ដោយដាក់ពួកគេឱ្យនៅក្រៅរដ្ឋ និងមានឱកាសដើម្បីមានជីវិតរស់នៅសមរម្យតិចជាងជនជាតិភាគច្រើន។

ខ. **គោលនយោបាយសមាហរណកម្ម:** មានតែរដ្ឋទេដែលអាចសម្រេចពង្រីកការទទួលស្គាល់ចំពោះជនជាតិដើមភាគតិច ឬវិធានជាប្រពៃណីនានា ដើម្បីធ្វើសមាហរណកម្មជនជាតិដើមភាគតិច ឬក្រុមមនុស្សផ្សេងទៀត ដែលរស់នៅក្រោមវិធានក្រៅផ្លូវការរបស់ខ្លួនជាបណ្តើរៗ ដើម្បីបញ្ជ្រាបនូវវប្បធម៌ទាំងនោះ។

គ. **គោលនយោបាយពហុនិយមៈ** ដោយមានវត្តមាននៃប្រព័ន្ធច្បាប់ក្រៅផ្លូវការជាច្រើននៅក្នុងតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ (ដូចជាមានច្បាប់ផ្លូវការរបស់រដ្ឋ និងច្បាប់ជនជាតិដើមភាគតិច) ជាមួយគ្នាដូចនេះ រដ្ឋគួរលើកស្ទួយឱ្យមានការពិភាក្សាអន្តរវប្បធម៌ សម្រាប់ជាប្រយោជន៍ដល់ការទទួលស្គាល់ច្បាប់ជនជាតិដើមភាគតិច (អាជ្ញាធរ វិធាននានា នីតិវិធីសម្រាប់ដោះស្រាយវិវាទ) និងត្រូវមានការយន្តការប្រជាធិបតេយ្យមួយ សម្រាប់សម្របសម្រួលរវាងប្រព័ន្ធផ្សេងៗ។ ធ្វើដូច្នេះជនជាតិដើមភាគតិចអាចចាត់ទុកខ្លួនឯងថា ជាផ្នែកមួយនៃរដ្ឋពហុនិយម ដោយពួកគេមានសិទ្ធិរក្សានិងអភិវឌ្ឍន៍អត្តសញ្ញាណវប្បធម៌របស់ពួកគេ ប៉ុន្តែពួកគេក៏មានកាតព្វកិច្ច ក្នុងការចូលរួមនៅក្នុងសង្គមជាតិ និងគោរពក្របខ័ណ្ឌនៃសិទ្ធិមនុស្សផងដែរ។

**តារាងប្រៀបធៀបប្រព័ន្ធច្បាប់ទោល និងប្រព័ន្ធច្បាប់ពហុ**

| | ប្រព័ន្ធច្បាប់ឯកនិយម | ប្រព័ន្ធច្បាប់ពហុនិយម |
|---|---|---|
| ក្របខ័ណ្ឌទ្រឹស្តី (ជាការពិពណ៌នា) | មានច្បាប់ ឬប្រព័ន្ធច្បាប់តែមួយនៅក្នុងរដ្ឋមួយ។ ច្បាប់គឺជាប្រព័ន្ធនៃៈ<br>ក. "វិធានច្បាប់" ដែលមានការបែងចែកច្បាស់លាស់ (ខុសប្លែកអំពីសីលធម៌ និងសាសនា)<br>ខ. បង្កើតឡើងដោយរដ្ឋ<br>គ. អនុវត្តដោយភ្នាក់ងាររបស់រដ្ឋ ស្របតាមនីតិវិធីច្បាប់ | មានប្រព័ន្ធច្បាប់ច្រើននៅក្នុងតំបន់ភូមិសាស្ត្រជាក់លាក់មួយ។ ច្បាប់គឺជាប្រព័ន្ធនៃ :<br>ក. វិធាន ឬវិន័យទាំងឡាយ (អាចបែងចែកច្បាស់លាស់ ឬអត់)<br>ខ. អាជ្ញាធរ (ជាបុគ្គល ឬជាក្រុម)<br>គ. នីតិវិធីទាំងឡាយ គ្រប់គ្រងជីវិតប្រចាំថ្ងៃក្នុងសង្គម ដោះស្រាយវិវាទ និង រៀបចំសណ្តាប់ធ្នាប់សង្គម មានប្រសិទ្ធិភាព និងមានទំនុកចិត្តពីសមាជិកម្ចាស់ឆ្នោតរបស់ខ្លួន។ |
| បច្ច័យខាង នយោបាយ (ជាបញ្ញត្តិ) | មានតែវិធានរបស់រដ្ឋមួយគត់ដែលអាចអនុវត្តបាន<br>- វិធានដទៃៗទៀត គឺជា "ប្រពៃណី" និងមានកម្រិត<br>- វិធានដែលផ្ទុយពីវិធានរបស់រដ្ឋ ត្រូវចាត់ទុកថាខុសច្បាប់ និងត្រូវហាមឃាត់ជាដាច់ខាត | មានជំរើសជាច្រើន ដូចជាៈ<br>ក. គោលនយោបាយបញ្ចូលគ្នាៈ លុបបំបាត់ប្រព័ន្ធច្បាប់ពហុនិយម ទោះជាត្រូវធ្វើឡើងដោយប្រើកម្លាំងក្តី<br>ខ. គោលនយោបាយសមាហរណកម្មៈ ទទួលស្គាល់លើផ្នែកខ្លះ ដើម្បីបញ្ចូលជាបណ្តើរៗ<br>គ. គោលនយោបាយពហុនិយមៈ ទទួលស្គាល់ដោយប្រជាធិបតេយ្យ នៅក្នុងរដ្ឋពហុនិយម និងក្របខ័ណ្ឌរួមនៃសិទ្ធិមនុស្ស។ |

## ១.៤. ប្រព័ន្ធយុត្តិធម៌ផ្លូវការ និងក្រៅផ្លូវការ

ជាញឹកញាប់ពាក្យ "ក្រៅផ្លូវការ មិនផ្លូវការ ឬមិនមែនរបស់រដ្ឋ" ត្រូវបានគេប្រើប្រាស់ជាសទិសន័យ។ នៅក្នុងផែនការជាយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា បានប្រើប្រាស់ពាក្យ "យន្តការដោះស្រាយវិវាទក្រៅតុលាការ" ដែលមានន័យសំដៅលើយន្តការនានាដូចជា: ក). យន្តការដែលបង្កើតឡើង និងគ្រប់គ្រងដោយច្បាប់ហើយជាយន្តការមួយរបស់រដ្ឋ ពោលគឺគណៈកម្មការសុរិយោដី ខ). យន្តការដែលបង្កើតឡើង និងគ្រប់គ្រងដោយច្បាប់តែឯករាជ្យ ពោលគឺក្រុមប្រឹក្សាអាជ្ញាកណ្ដាលដោះស្រាយវិវាទការងារ គ). ការដោះស្រាយវិវាទតាមបែបប្រពៃណី និង ឃ). យន្តការដោះស្រាយវិវាទនៅថ្នាក់មូលដ្ឋាន។ ការសិក្សាដទៃៗទៀតសន្មតថា "យន្តការដោះស្រាយវិវាទក្រៅតុលាការ គឺសំដៅលើរាល់យន្តការទាំងអស់ ដែលដោះស្រាយវិវាទ លើកលែងតែតុលាការ" រួមទាំងការដោះស្រាយតាមច្បាប់ប្រពៃណី[៥០]។ អង្គការ UNDP ប្រចាំតំបន់ ដែលបានសិក្សាលើសិទ្ធិទទួលបានយុត្តិធម៌នេះផងដែរ បានកំណត់ថា "ប្រព័ន្ធយុត្តិធម៌មិនផ្លូវការ" គឺរាប់បញ្ចូលទាំងយន្តការដោះស្រាយវិវាទក្រៅតុលាការ និងប្រព័ន្ធយុត្តិធម៌ប្រពៃណីនិងជនជាតិដើមភាគតិច[៥១]ផងដែរ។ ជាចុងក្រោយមានការសិក្សាមួយផ្សេងទៀត ដែលប្រើពាក្យ "ប្រព័ន្ធយុត្តិធម៌មិនមែនរបស់រដ្ឋ" ដោយសំដៅលើ "ប្រព័ន្ធដោះស្រាយវិវាទតាមបែបប្រពៃណី ទំនៀមទំលាប់ សាសនា និងដែលមិនផ្លូវការទាំងអស់[៥២]"។ លក្ខណៈរួមនៃយន្តការដោះស្រាយវិវាទ ដូចបានរៀបរាប់ដោយប្រើពាក្យខុសៗគ្នាទាំងនេះ គឺថាយន្តការទាំងនេះ ត្រូវបានប្រើប្រាស់ និងអភិវឌ្ឍដោយមានទិសដៅផ្ទុយពីប្រព័ន្ធយុត្តិធម៌ផ្លូវការរបស់រដ្ឋ និងប្រព័ន្ធយុត្តិធម៌តាមបែបលោកខាងលិច។ ករណីនេះត្រូវបានពន្យល់កាន់តែច្បាស់ តាមរយៈការពិភាក្សាខាងលើស្ដីពីប្រព័ន្ធច្បាប់ឯកនិយម និងប្រព័ន្ធច្បាប់ពហុនិយមនៅក្នុងរដ្ឋមួយ ។

ពាក្យថា "ផ្លូវការ" និង "ក្រៅផ្លូវការ" មានប្រភពមកពីសង្គមវិទ្យានៃច្បាប់ និងគោលគំនិតនៃច្បាប់ ដែលគ្រប់គ្រងសង្គម។ មានទស្សនៈពីរដែលមានជំហរផ្ទុយគ្នា :

ក. កាលណានិយាយអំពីការត្រួតពិនិត្យ "ផ្លូវការ" គឺសំដៅលើការត្រួតពិនិត្យសង្គម ដែលធ្វើឡើងដោយរដ្ឋ ស្របតាមបញ្ញត្តិច្បាប់ ហើយអនុវត្តដោយភ្នាក់ងារឬស្ថាប័នជាក់លាក់ណាមួយ និងធ្វើដោយស្របតាមនីតិវិធី ដូចមានចែងក្នុងច្បាប់ និង

ខ. "ការរីកសាយភាយ" នៃការត្រួតពិនិត្យសង្គម ដែលធ្វើឡើងដោយភ្នាក់ងារសង្គមនានា (បុគ្គលនានា អង្គការសង្គម ស្ថាប័នឯកជន) ដែលមានយន្តការផ្សេងៗ រួមទាំងប្រតិកម្មសយម្ភូត ដែលត្រូវបានគេចាត់ទុកថា ជាការត្រួតពិនិត្យ "មិនផ្លូវការ"។

---

៥០ The South African Law Commission (established by the South African Law Commission Act 19 of 1973): *Alternative Dispute Resolution.* Issue paper 8. Pretoria: South African Law Commission, 1996 (available at http://wwwserver.law.wits.ac.za/salc/issue/ip8.html#a)%20What%20is%20ADR).

៥១ UNDP (2005): *Programming for Justice: Access for All.* The Access to Justice Practitioner's Guide. Bangkok: UNDP Asia Pacific Rights and Justice Initiative. (Available at: http://regionalcentrebangkok.undp.or.th/practices/governance/a2j/).

៥២ "នៅលើពិភពលោកមានប្រទេសជាច្រើន មានស្ថាប័នឯករាជ្យពីរដ្ឋមួយក្នុងការដោះស្រាយវិវាទ និងផ្ដល់សន្តិសុខដល់សង្គម។ តមុខងារទាំងនេះអាចបំពេញដោយ ប្រព័ន្ធផ្សេងៗដូចជា ប្រព័ន្ធទំនៀមទំលាប់ ប្រពៃណី សាសនា និងប្រព័ន្ធក្រៅផ្លូវការដទៃទៀត។ វាជាគោលនយោបាយរបស់នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ (DFID) ដែលទទួលស្គាល់ប្រព័ន្ធនេះថាមានប្រសិទ្ធិភាពជាងសម្រាប់ជនក្រីក្រ ជាងស្ថាប័នរដ្ឋនានា ហើយគួរតែបញ្ចូលនូវប្រព័ន្ធទាំងនេះជាយុទ្ធសាស្ត្រ តាមវិស័យដែលសមស្រប។ ទោះជាយ៉ាងនេះក្តី DFID ទទួលស្គាល់ថា ស្ថាប័នទាំងនេះប្រហែលជាបន្ថែមកម្លាំងអាជ្ញាធរមូលដ្ឋាន ដែលអាចនាំឱ្យមានភាពអយុត្តិធម៌ និងរំលោភលើសិទ្ធិមនុស្សសម្រាប់បរិបទខ្លះ " ដូច្នេះរាល់ការគាំទ្រទាំងឡាយ ដល់ប្រព័ន្ធមិនផ្លូវការត្រូវតែយកចិត្តទុកដាក់លើបញ្ហាសមធម៌ និងលទ្ធភាពដែលទទួលបាននូវយុត្តិធម៌។ សូមមើល : Governance Resource Centre Exchange United Kingdom: *Non-state justice and security systems*, available at: http://www.grc-exchange.org/g_themes/ssaj_non-state.html.

ប្រព័ន្ធយុត្តិធម៌ផ្លូវការ ដែលជាផ្នែកមួយនៃការត្រួតពិនិត្យផ្លូវការរបស់សង្គម រួមមានតុលាការ នគរបាល អយ្យការ ។ល។ ស្ថាប័នទាំងនេះត្រូវតែគោរពតាមបទបញ្ញត្តិផ្លូវការនានា ដែលបង្កើតឡើងដោយច្បាប់។ ការត្រួតពិនិត្យ “មិនផ្លូវការ” បានចង្អុលបង្ហាញឱ្យឃើញថាប្រព័ន្ធយុត្តិធម៌ផ្លូវការ ត្រូវបានបង្កើតឡើងដោយច្បាប់ ដូចនេះវាត្រូវចាត់ទុកថាស្របច្បាប់ ដែលនៅ ពេលនោះ “ការត្រួតពិនិត្យមិនផ្លូវការ” មិនត្រូវបានគេចាត់ទុកថាស្របច្បាប់ទេ ដូចនេះវិធានរបស់ខ្លួនមិនមានកម្លាំងចាប់បង្ខំដូចច្បាប់ឡើយ។ យោងតាមទស្សនៈទាំងនេះ មានការសិក្សាស្រាវជ្រាវខ្លះ[៩៣] ចាត់ទុក “ប្រព័ន្ធយុត្តិធម៌មិនផ្លូវការ” ជាយន្តការដោះស្រាយវិវាទទាំងអស់ ក្រៅពីតុលាការ រួមទាំងយន្តការដោះស្រាយវិវាទក្រៅតុលាការ និងប្រព័ន្ធយុត្តិធម៌របស់ជនជាតិដើមភាគតិចផង។ តែការបញ្ជាក់អំពីចរិកលក្ខណៈតាមរបៀបនេះ ជាការមួយដែលមានលក្ខណៈសាមញ្ញពេក។

នៅប្រទេសមួយចំនួន ប្រភេទនៃយន្តការដោះស្រាយវិវាទក្រៅតុលាការផ្សេងៗត្រូវបានទទួលស្គាល់ ដោយច្បាប់ក្នុងទម្រង់ភ្នាក់ងារជាសាធារណៈ ឯកជន ឬជាស្ថាប័នសង្គម។ ដូច្នេះ យន្តការទាំងនេះត្រូវបានកំណត់ដោយច្បាប់ និងត្រូវធ្វើទៅតាមនីតិវិធីនានាដែលមានចែងនៅក្នុងច្បាប់។ ក្នុងន័យនេះយើងមិនអាចនិយាយបានថា យន្តការទាំងនោះជាយន្តការ “មិនផ្លូវការ” ពីព្រោះច្បាប់បានចែងកំណត់អំពីយន្តការទាំងនោះរួចហើយ។ ករណីប្រព័ន្ធយុត្តិធម៌របស់ជនជាតិដើមភាគតិចក៏ដូចគ្នានេះដែរ។

> នៅព្រះរាជាណាចក្រកម្ពុជា គណៈកម្មការសុរិយោដី និងក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទការងារ គឺជាយន្តការដោះស្រាយវិវាទក្រៅតុលាការ ដែលមានច្បាប់ចែងកំណត់។ គណៈកម្មការសុរិយោដីគឺជាផ្នែកមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រីឯក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទការងារ គឺជាស្ថាប័នឯករាជ្យ។ ច្បាប់ភូមិបាល (ឆ្នាំ ២០០១) ទទួលស្គាល់សមត្ថកិច្ចរបស់អាជ្ញាធរប្រពៃណីរបស់ជនជាតិដើមភាគតិច ក្នុងការគ្រប់គ្រងដីរួមរបស់សហគមន៍ជនជាតិដើមភាគតិច ស្របតាមវិធានជាប្រពៃណី និងដំណើរការដោះស្រាយវិវាទរបស់ពួកគេ។ ដូច្នេះ យន្តការដោះស្រាយវិវាទក្រៅតុលាការខ្លះ ក៏ដូចជាវិធាននានារបស់ជនជាតិដើមភាគតិច មិនគួរត្រូវបានគេហៅថា “ក្រៅផ្លូវការ” ឡើយសម្រាប់បរិបទនៃកម្ពុជា។

យោងតាមទស្សនៈវិស័យនៃប្រព័ន្ធច្បាប់ពហុនិយម ប្រព័ន្ធដោះស្រាយវិវាទមិនមែនរបស់រដ្ឋមួយចំនួន ដូចជា ច្បាប់ជនជាតិដើមភាគតិច និងប្រព័ន្ធផ្សេងៗទៀតនៃច្បាប់ទំនៀមទម្លាប់ ក្លាយជា “ច្បាប់ ” បន្ទាប់ពីឆ្លងកាត់នីតិវិធីផ្ទៃក្នុងសហគមន៍ ដូចអ្វីដែលលោក Bohannan ហៅថា “ការយល់ព្រមទ្វេដង” : ទីមួយ យល់ព្រមថាជាវិធាននៃសង្គម និងបន្ទាប់មកថាជាវិធានច្បាប់សម្រាប់ពួកគេ[៩៤]។ ដូច្នេះយន្តការទាំងនេះវាមិនមែន “មិនផ្លូវការ” ទេ ក្នុងន័យថាវាជាប្រតិកម្មដោយឯកឯង របស់ប្រជាពលរដ្ឋដោយគ្មានទម្រង់បែបបទផ្លូវការ ឬពុំមានស្ថាប័នដែលបង្កើតឡើងដោយច្បាប់ឡើយ។ ប្រព័ន្ធរបស់ជនជាតិដើមភាគតិចគេមានអាជ្ញាធរ វិធាននិងនីតិវិធីផ្ទាល់ខ្លួនរបស់គេ។ ដូចនេះយន្តការទាំងនេះ ជាយន្តការដែលមានទម្រង់ជាក់លាក់ច្បាស់លាស់។

ប៉ុន្តែទោះបីតាមគោលការណ៍ប្រព័ន្ធច្បាប់ឯកនិយម វិធានជាប្រពៃណីរបស់ជនជាតិដើមភាគតិច មិនមែនជាអ្វីមួយដែលហៅថា “ក្រៅផ្លូវការ” ទៀតទេ ដោយហេតុថាមានការទទួលស្គាល់ជាផ្លូវការ និងពីច្បាប់ទោះបីជាជាក់ស្តែង នីតិវិធីដែលប្រើប្រាស់តាមប្រព័ន្ធនេះ មានលក្ខណៈខុសពីនីតិវិធីរបស់តុលាការក៏ដោយ។ ប្រទេសនៅអាមេរិកឡាទីនមួយចំនួន ទទួលស្គាល់នៅក្នុងរដ្ឋធម្មនុញ្ញនូវអំណាចយុត្តាធិការដោះស្រាយវិវាទរបស់ជនជាតិដើមភាគតិច។ ដូច្នេះ “អំណាចយុត្តាធិការរបស់ជនជាតិដើមភាគតិច” មិនមែនក្រៅផ្លូវការទៀតឡើយ ក្នុងន័យនេះ វាមានការទទួលស្គាល់ពីច្បាប់ និងជាផ្លូវការ។

---

៩៣ ដូចជាអង្គការ UNDP Asia Pacific 2005.

៩៤ Bohannan, Paul (1964): “La antropología y la ley”, en *Antropología una nueva visión*. Cali: Editorial Nosma.

សម្រាប់ការសិក្សានេះ ពាក្យថា "ក្រៅផ្លូវការ" គឺយើងសំដៅលើប្រតិកម្មសយម្ភូត ឬយន្តការដែលមិនមានអង្គការចាត់តាំងជាក់លាក់ និងជាប់លាប់ក្នុងការត្រួតពិនិត្យសង្គម ហើយមិនស្ថិតនៅក្នុងក្របខ័ណ្ឌនៃច្បាប់។ ក្នុងន័យនេះការអនុវត្តរបស់នគរបាល ឬក្រឡាបញ្ជីក្នុងការដោះស្រាយវិវាទ ដែលកើតមាននៅក្រៅដែនសមត្ថកិច្ចដែលបង្កើតឡើងដោយច្បាប់ គឺជា "ការអនុវត្តក្រៅផ្លូវការ"។ ចំពោះករណីយន្តការដោះស្រាយវិវាទក្រៅតុលាការ អាចនិយាយបានថាមានការអនុវត្តក្រៅក្របខ័ណ្ឌរបស់ខ្លួនដូចគ្នានេះដែរ។

**តារាងទស្សនាទានស្តីពី "ផ្លូវការ និងក្រៅផ្លូវការ"**

| | **ផ្លូវការ** | **ក្រៅផ្លូវការ** |
|---|---|---|
| **ភ្នាក់ងារ** | ស្ថាប័នរដ្ឋ : តុលាការ នគរបាល ។ល។ | តួអង្គសង្គមផ្សេងៗទៀត : អ្នកជិតខាង អង្គការនានា ស្ថាប័នឯកជន ។ល។ |
| **វិធាន** | ច្បាប់សរសេរ | សង្គម សីលធម៌ តម្លៃសង្គម |
| **នីតិវិធី** | នីតិវិធីជាក់លាក់ បង្កើតដោយច្បាប់ | សម្ពាធសង្គម ពាក្យចចាមអារាម យន្តការផ្សព្វផ្សាយនៃការត្រួតពិនិត្យសង្គមនានា |
| **ចែងច្បាស់** | "ស្របច្បាប់" ឬ ទទួលស្គាល់ដោយច្បាប់ | ច្បាប់មិនទទួលស្គាល់ជាអាជ្ញាធរស្របច្បាប់ និងអាចខុសច្បាប់ |
| | "ច្បាប់" ឬប្រព័ន្ធច្បាប់ "ចែងជាទម្រង់" | យន្តការ "មិនផ្លូវការ" មិនអាចជា "ច្បាប់" |
| **ឧទាហរណ៍** | ប្រព័ន្ធព្រហ្មទណ្ឌ | អង្គការឃ្លាំមើលនៅមូលដ្ឋានដើម្បីត្រួតពិនិត្យបទល្មើស |
| ករណីភាន់ច្រលំ និងបញ្ហាផ្សេងៗ | - "ការបំពេញមុខងាររបស់នគរបាលក្រៅក្របខ័ណ្ឌច្បាប់" : ស្ថាប័នផ្លូវការ តែមានការអនុវត្តក្រៅផ្លូវការ។<br>- យន្តការដោះស្រាយវិវាទក្រៅតុលាការ អនុវត្តខុសអំពីប្រព័ន្ធយុត្តិធម៌ផ្លូវការ តែយន្តការដោះស្រាយវិវាទក្រៅតុលាការ មានការទទួលស្គាល់ដោយច្បាប់។ | ច្បាប់ជនជាតិដើមភាគតិច :<br>- វិធានរបស់ជនជាតិដើមភាគតិចដែលបានអនុម័តសម្រាប់សហគមន៍របស់ខ្លួន ទូវចំណាត់ការមួយ ដែលមានលក្ខណៈជាផ្លូវការ។ ដូច្នេះ វាមិនមែនជា "ក្រៅផ្លូវការ" ។<br>- មានច្បាប់ខ្លះទទួលស្គាល់វិធានប្រពៃណីជនជាតិដើមភាគតិច ( ច្បាប់ភូមិបាលកម្ពុជា ឆ្នាំ ២០០១ )<br>- អនុសញ្ញាលេខ ១៦៩ របស់អង្គការពលកម្មអន្តរជាតិ និងរដ្ឋធម្មនុញ្ញរបស់ប្រទេសនៅអាមេរិកឡាទីនមួយចំនួនទទួលស្គាល់ "ប្រព័ន្ធច្បាប់ពហុនិយម" ដែលជនជាតិដើមភាគតិចមានអំណាចយុត្តាធិការស្របច្បាប់។ អំណាចយុត្តាធិការ ទាំងនេះមិនមែនជាអ្វីមួយដែលហៅថា "ក្រៅផ្លូវការ" ទេ។ |

បញ្ហាខ្វែងគំនិតគ្នារវាង "ផ្លូវការ និងក្រៅផ្លូវការ"

ជាសង្ខេបការខ្វែងគំនិតនេះគាំទ្រដល់ក្របខ័ណ្ឌឯកនិយម។ ឧទាហរណ៍ គំនិតដែលថាមានតែរដ្ឋប៉ុណ្ណោះ ដែលធ្វើច្បាប់សម្រាប់រដ្ឋ រីឯភ្នាក់ងារ "សង្គម" ផ្សេងៗទៀតជាអ្នកបង្កើតការត្រួតពិនិត្យ "សង្គម" ឬ "មិនផ្លូវការ" មិនមែនបង្កើតច្បាប់ឡើយ។ ពាក្យថា "ក្រៅផ្លូវការ" គ្របដណ្តប់លើស្ថានភាពយ៉ាងទូលំទូលាយ រួមទាំងយន្តការដោះស្រាយវិវាទក្រៅតុលាការ និងច្បាប់ប្រពៃណីបុរាណៗ និងច្បាប់ជនជាតិដើមភាគតិចផងដែរ។ ច្បាប់ជនជាតិដើមភាគតិចអាចត្រូវបានគេចាត់ទុកថា "ក្រៅផ្លូវការ" តាមគោលការណ៍ប្រព័ន្ធច្បាប់ឯកនិយម តែចំពោះទស្សនៈនៃប្រព័ន្ធច្បាប់ពហុនិយមវិញយល់ថាមិនមែន "ក្រៅផ្លូវការ" ឡើយ។ ប៉ុន្តែទោះតាមទ្រឹស្តីប្រព័ន្ធច្បាប់ឯកនិយមក្តី វិធានទាំងឡាយរបស់ជនជាតិដើមភាគតិច និងយន្តការដោះស្រាយវិវាទក្រៅតុលាការ មិនអាចចាត់ទុកថា "ក្រៅផ្លូវការ" ទេ បើសិនជាមានច្បាប់ទទួលស្គាល់ និងមានចែងនៅក្នុងច្បាប់ហើយនោះ។

ដូចនេះ ចំនុចសំខាន់គួរកត់សំគាល់មួយគឺថា នៅក្នុងការសិក្សានេះ ពាក្យថា "ប្រព័ន្ធយុត្តិធម៌ផ្លូវការ" សំដៅលើប្រព័ន្ធដែលផ្តល់សេវាកម្មយុត្តិធម៌ "ជាផ្លូវការ" ដោយមានមូលដ្ឋានច្បាប់របស់រដ្ឋ ហើយប្រតិបត្តិដោយស្ថាប័នរដ្ឋនិងគោរពទៅតាមនីតិវិធីច្បាប់ជាក់លាក់។ ពាក្យនេះ មិនមែនមានន័យថា មានតែរដ្ឋមួយគត់ដែលជា ប្រភពនៃច្បាប់នោះទេ។ ការប្រើប្រាស់ពាក្យនេះមិនបានដកចេញនូវរាល់ច្បាប់ជនជាតិដើមភាគតិច និងប្រពៃណីឡើយ។ តែសម្រាប់ការសិក្សាស្រាវជ្រាវនេះ ពាក្យថា "មិនផ្លូវការ" គឺសំដៅលើយន្តការត្រួតពិនិត្យសង្គមទាំងឡាយណា ដែលពុំមានច្បាប់ចែង និងរាល់សកម្មភាពរបស់ស្ថាប័ននានាដែលអនុវត្តក្រៅក្របខ័ណ្ឌច្បាប់។ ជាឧទាហរណ៍ ការអនុវត្តរបស់នគរបាលលើសពីតួនាទីស្របច្បាប់របស់ខ្លួនគឺជាសកម្មភាព "ក្រៅផ្លូវការ" តែសម្រាប់គណៈកម្មការសុរិយោដី និងច្បាប់ជនជាតិដើមភាគតិច មិនមែន "ក្រៅផ្លូវការ" ទេ ដោយហេតុថាស្ថាប័នទាំងនេះគោរពទៅតាមវិធានស្របច្បាប់របស់ពួកគេ។

## ១.៥. យន្តការដោះស្រាយវិវាទក្រៅតុលាការ (ADR)

យន្តការដោះស្រាយវិវាទក្រៅតុលាការ បានលេចឡើងដោយសារហេតុផលនៃភាពទន់ខ្សោយ និងបំពេញភាពខ្វះខាតរបស់ប្រព័ន្ធដោះស្រាយវិវាទផ្លូវការ ដែលបង្កើតឡើងដោយច្បាប់និងអនុវត្តតាមផ្លូវតុលាការ។ ជាក់ស្តែងណាស់ថា "ច្បាប់" និង "ប្រព័ន្ធយុត្តិធម៌ផ្លូវការ" ជារបស់រដ្ឋ។ ដូចនេះរាល់យន្តការដោះស្រាយវិវាទដទៃៗទៀត ដែលមិនមែនជាតុលាការ ត្រូវបានគេចាត់ទុកថាជា "យន្តការក្រៅតុលាការ" [៥៥]។ យន្តការដោះស្រាយវិវាទក្រៅតុលាការ រួមមាន: ការចរចា ការសម្រុះសម្រួល (សន្ធានកម្ម) ការផ្សះផ្សា និងអាជ្ញាកណ្តាល។

តាមទ្រឹស្តីច្បាប់ អំណាចយុត្តាធិការរាប់បញ្ចូលទាំង : ក). អំណាចក្នុងការស៊ើបអង្កេត អញ្ជើញសាក្សីពាក់ព័ន្ធ (*Notio*) ខ). អំណាចក្នុងការសម្រេច (*Iudicium*) និង គ). អំណាចក្នុងការអនុវត្តសេចក្តីសម្រេច (*coertio*). [៥៦] ។ ផ្ទុយទៅវិញ យន្តការដោះស្រាយវិវាទក្រៅតុលាការ ក៏ត្រូវបានគេយល់ផងដែរថា :

- សំដៅលើប្រព័ន្ធដោះស្រាយវិវាទនៅខាងក្រៅតុលាការ។ ភ្នាក់ងារដែលទទួលបន្ទុកដោះស្រាយវិវាទនោះមិនមែនជាតុលាការទេ តែជាជនទីបីណាម្នាក់ ដែលអាចជាអ្នកសម្រុះសម្រួល អ្នកផ្សះផ្សា ឬ ជាអាជ្ញាកណ្តាល។
- នីតិវិធីដែលបានប្រើប្រាស់ គឺមានលក្ខណៈសាមញ្ញជាងនីតិវិធីតាមផ្លូវតុលាការ មានការយល់ព្រមដោយផ្ទាល់មាត់និងជួបទល់មុខគ្នារវាងគូភាគី មានដំណោះស្រាយដោយការចរចាគ្នា ដោយមានការយល់យោគគ្នាទៅវិញទៅមករវាងផលប្រយោជន៍របស់ភាគី។

---

៥៥ យន្តការដោះស្រាយវិវាទក្រៅតុលាការគឺរាប់បញ្ចូលទាំងរាល់យន្តការដោះស្រាយវិវាទទាំងឡាយដើម្បីចៀសវាងនូវអំពើហិង្សា។

៥៦ Carlos, Eduardo B. (1963): Voice *Jurisdicción*. In: *Enciclopedia Juridica Omeba*. Buenos Aires: Editorial Bibliográfica Argentina, Tomo XVII, p538.

- បញ្ហាវិវាទ ជាករណីដែលគូភាគីអាចចរចារ និងសុខចិត្តធ្វើសម្បទានឱ្យគ្នា។ យន្តការដោះស្រាយវិវាទក្រៅតុលាការមិនអាចដោះស្រាយវិវាទពាក់ព័ន្ធនឹងសណ្តាប់ធ្នាប់សាធារណៈ (ដូចជាបទល្មើសព្រហ្មទណ្ឌ និងករណីលែងលះ) បានឡើយ។
- មិនអាចអនុវត្តនូវអំណាចយុត្តាធិការ ដូចជាបង្ខំឱ្យភាគី និងសាក្សីត្រូវតែបង្ហាញខ្លួន ស៊ើបអង្កេត ឬអនុវត្តសេចក្តីសម្រេចបានឡើយ។
- មិនអាចសម្រេចលើការធានា ឬផ្តល់សិទ្ធិ (លើកលែងតែអាជ្ញាកណ្តាលដែលធ្វើសេចក្តីសម្រេច)។
- មិនអាចបង្ខំឱ្យភាគីត្រូវតែអនុវត្តសេចក្តីសម្រេច ឬកិច្ចព្រមព្រៀងរបស់ភាគីបានឡើយ។ ការអនុវត្តគឺពឹងផ្អែកទាំងស្រុងទៅលើឆន្ទៈរបស់គូភាគី។

យន្តការដោះស្រាយវិវាទក្រៅតុលាការត្រូវបានគេចាត់ទុកថា ជាប្រភេទយន្តការដោះស្រាយវិវាទដោយការសម្រុះសម្រួល តែមិនរាប់បញ្ចូលអាជ្ញាកណ្តាលទេ ដោយអាជ្ញាកណ្តាលវាមានលក្ខណៈប្រហាក់ប្រហែលទៅនឹងតុលាការដែរ ព្រោះមានជនទីបីអាចកាត់សេចក្តីលើវិវាទបានក្នុងការដោះស្រាយ។ រីឯយន្តការដោះស្រាយវិវាទក្រៅតុលាការវិញ គឺដោះស្រាយវិវាទដោយអាស្រ័យលើការចរចាគ្នារវាងគូភាគីនៃវិវាទ ដោយគ្មានជនទីបីណាមួយកាត់សេចក្តីជំនួសគេឡើយ។ ម្យ៉ាងទៀត ការកាត់សេចក្តីគឺមានន័យថាមានអាជ្ញាធរមួយ ដែលមិនមែនជាភាគីវិវាទ ជាអ្នកធ្វើការសម្រេចសេចក្តីនូវរាល់បណ្តឹង ដែលប្តឹងសុំឱ្យខ្លួនដោះស្រាយ។ ប្រព័ន្ធយុត្តិធម៌ផ្លូវការ ចៅក្រមជាអ្នកកាត់សេចក្តីលើវិវាទដោយផ្អែកលើច្បាប់ ហើយប្រព័ន្ធនេះមានអំណាចយុត្តិធិការ តែយន្តការដោះស្រាយវិវាទក្រៅតុលាការ ពុំមានអំណាចនេះឡើយ។ ធ្វើដូចនេះ ប្រព័ន្ធតុលាការអាចគួរតែត្រូវបានគួបផ្សំជាមួយយន្តការដោះស្រាយវិវាទក្រៅតុលាការ តាមរូបភាពបំពេញគ្នាទៅវិញទៅមក។ យន្តការទាំងនេះអាចមាន ឬពុំមានចែងទទួលស្គាល់ដោយច្បាប់ ហើយនិងអាចធ្វើឡើងដោយភ្នាក់ងាររបស់រដ្ឋ ឬឯកជន។ ការសិក្សាស្រាវជ្រាវខ្លះ បានប្រើពាក្យ "មិនផ្លូវការ" ដោយឱ្យមានន័យស្មើនឹងយន្តការដោះស្រាយវិវាទក្រៅតុលាការ តែ "មិនផ្លូវការ" អាចបង្កប់នូវអត្ថន័យថាពុំមានច្បាប់ចែង និងយន្តការដោះស្រាយវិវាទអាចមានច្បាប់ចែង[៥៧]។

ការសម្រុះសម្រួល ការផ្សះផ្សា និងអាជ្ញាកណ្តាល ពឹងផ្អែកលើអន្តរាគមន៍របស់ជនទីបី។ ភាពខុសគ្នារវាងយន្តការទាំងនេះគឺវាអាស្រ័យលើកម្រិតនៃអន្តរាគមន៍របស់ជនទីបី។ ការសម្រុះសម្រួលមានកម្រិតអន្តរាគមន៍ តិចបំផុតពីជនទីបី (អ្នកសម្រុះសម្រួល) ដែលករណីនេះជនទីបីព្យាយាមជួយគូភាគីវិវាទ ឱ្យដោះស្រាយបញ្ហាដោយយោងតែទៅលើសំណូមពរ របស់គូភាគីផ្ទាល់ ហើយជនទីបីមិនលើកយោបល់ឬសំណូមពរណាមួយជូនដល់ភាគីឡើយ។ ជំហានបន្ទាប់គឺការផ្សះផ្សា ដែលករណីនេះជនទីបីអាចលើកជាសំណូមពរផ្សេងៗសម្រាប់គូភាគីវិវាទ និងសម្របសម្រួលឱ្យភាគីឈានដល់ដំណោះស្រាយណាមួយ។ រីឯចុងក្រោយគឺអាជ្ញាកណ្តាល ដែលមានជនទីបីជាអ្នកកាត់សេចក្តីជូនភាគីវិវាទ បន្ទាប់ពីបានស្តាប់អំណះអំណាងរបស់គូភាគីទាំងសងខាងហើយ។ សូមបញ្ជាក់ថាមានការពិភាក្សាគ្នាយ៉ាងច្រើនអំពីការកំណត់កម្រិតនៃអន្តរាគមន៍របស់ជនទីបី ដើម្បីសម្រេចថាតើការអន្តរាគមន៍ជនទីបីកម្រិតណាជាការសម្រុះសម្រួល និងកម្រិតណាជាការផ្សះផ្សា។ សម្រាប់ការសិក្សាស្រាវជ្រាវនេះ យើងបានសម្រេចយកការកំណត់ និងប្រភេទនៃការចូលរួមរបស់ជនទីបី ដូចខាងក្រោមនេះ :

[៥៧] ខាងក្រោមនេះ មានការពន្យល់ពីភាពខុសគ្នារវាង យន្តការដោះស្រាយវិវាទក្រៅតុលាការ និងច្បាប់ជនជាតិដើមភាគតិច

ភាពងស្តីពីទម្រង់ផ្សេងៗនៃយន្តការដោះស្រាយវិវាទក្រៅតុលាការ - ADR

| | ការចរចារ | ការសម្រុះសម្រួល (សន្ធានកម្ម) | ការផ្សះផ្សា | អាជ្ញាកណ្តាល (មជ្ឈត្តវិនិច្ឆ័យ) |
|---|---|---|---|---|
| **ភាគីពាក់ព័ន្ធ** | ភាគីក្នុងជម្លោះ | ភាគីក្នុងជម្លោះ + អ្នកផ្សះផ្សា | ភាគីក្នុងជម្លោះ + អ្នកសម្រុះសម្រួល | ភាគីក្នុងជម្លោះ + មជ្ឈត្តករ |
| **តួនាទីរបស់ភាគីយជន** | ភាគីម្នាក់ឯងដោះស្រាយវិវាទខ្លួនឯង | អ្នកផ្សះផ្សាព្យាយាមរកដំណោះស្រាយដោយពិចារណាលើអត្ថប្រយោជន៍របស់ភាគី។ ភាគីធ្វើសំណើ និងសម្រេចដំណោះស្រាយ | អ្នកសម្រុះសម្រួលធ្វើសំណើទៅភាគី ដើម្បីដោះស្រាយជម្លោះ។ ភាគីសម្រេចចុងក្រោយដោយទទួលជំនួយពីអ្នកសម្រុះសម្រួល។ | មជ្ឈត្តករផ្តល់ដំណោះស្រាយចំពោះរឿងក្តី។ ភាគីត្រូវគោរពតាមដំណោះស្រាយនោះ។ |
| **ការចាប់ផ្តើមដំណើរការ** | ស្ម័គ្រចិត្ត | ស្ម័គ្រចិត្ត | ស្ម័គ្រចិត្ត | ស្ម័គ្រចិត្ត (ឬតម្រូវដោយច្បាប់ ឬកិច្ចព្រមព្រៀងមុន) |
| **លទ្ធផល** | អាស្រ័យលើភាគី | អាស្រ័យលើសេចក្តីសម្រេចរបស់ភាគី | អ្នកសម្រុះសម្រួលស្នើដំណោះស្រាយ ប៉ុន្តែអាស្រ័យការយល់ព្រមរបស់ភាគី | អាស្រ័យលើការសម្រេចរបស់មជ្ឈត្តករ។ |
| **ការប្រតិបត្តិលទ្ធផល** | ការព្រមព្រៀងដូចជាកិច្ចសន្យាមួយ ប៉ុន្តែបើភាគីមួយមិនអនុវត្តតាមកិច្ចព្រមការព្រមព្រៀង ភាគីម្ខាងទៀតប្តឹងទៅតុលាការ។ | ការព្រមព្រៀងដូចជាកិច្ចសន្យាមួយ ប៉ុន្តែបើភាគីមួយមិនអនុវត្តតាមកិច្ចព្រម ការព្រមព្រៀង ភាគីម្ខាងទៀតប្តឹងទៅតុលាការ។ | ការព្រមព្រៀងដូចជាកិច្ចសន្យាមួយ ប៉ុន្តែបើភាគីមួយមិនអនុវត្តតាមកិច្ចព្រមការព្រមព្រៀង ភាគីម្ខាងទៀតប្តឹងទៅតុលាការ។ | លទ្ធផលនៃមជ្ឈត្តវិនិច្ឆ័យអាចត្រូវអនុវត្តតាមរយៈតុលាការ ឬមធ្យោបាយផ្សេងទៀត។ |

បញ្ហាៈ ដូចករណីកន្លងមកនេះដែរ ពាក្យថា "យន្តការដោះស្រាយវិវាទក្រៅតុលាការ" អាចរាប់បញ្ចូលទាំងយន្តការជាក់ស្តែងនានា ដូចជាយន្តការដែលបង្កើតឡើងដោយច្បាប់សម្រាប់ដោះស្រាយវិវាទ យន្តការសង្គម និងច្បាប់ប្រពៃណី និងច្បាប់របស់ជនជាតិដើមភាគតិច។ ការដែលធ្វើឱ្យសាមញ្ញជ្រុលហួសបែបនេះ អាចនាំឱ្យមានការយល់ច្រលំច្រើន។ ដូច្នេះជាថ្មីម្តងទៀត គឺចាំបាច់ត្រូវតែមានការប្រុងប្រយ័ត្ន។ ការប្រើប្រាស់ពាក្យ "យន្តការដោះស្រាយវិវាទក្រៅតុលាការ" នៅក្នុងការសិក្សានេះ មិនមែនបដិសេធទ្រឹស្តីពហុនិយមនៃច្បាប់ទេ ដែលមានន័យថាអ្វីៗទាំងអស់ដែលមិនមែនជាផ្នែកមួយនៃប្រព័ន្ធយុត្តិធម៌ផ្លូវការរបស់រដ្ឋ ត្រូវបានចាត់ទុកថាជាទម្រង់មួយឬផ្សេងទៀតនៃយន្តការដោះស្រាយវិវាទក្រៅតុលាការនោះទេ។ ច្បាប់ប្រពៃណី ឬ ច្បាប់ជនជាតិដើមភាគតិច អាចមានយន្តការដើម្បីដោះស្រាយវិវាទ ដែលអាចចាត់ទុកថាជា "យន្តការក្រៅតុលាការ" ដើម្បីដោះស្រាយបញ្ហាផ្សេងៗ ប៉ុន្តែមិនមែនមានមានន័យថា វាជាប្រភេទនៃយន្តការដោះស្រាយវិវាទក្រៅតុលាការនោះទេ។

## ១.៦. ច្បាប់ប្រពៃណី និងច្បាប់ជនជាតិដើមភាគតិច

### ច្បាប់ជនជាតិដើមភាគតិច

ការប្រើប្រាស់ពាក្យនេះក្នុងការសិក្សានេះ គឺទាញចេញមកពីទ្រឹស្តីពហុនិយមនៃច្បាប់។ ច្បាប់ជនជាតិដើមភាគតិចត្រូវបានគេសន្មតតាមនិយមន័យទូលាយ ដូចដែលបានលើកឡើងក្នុងការសិក្សាអំពីមនុស្ស (នរវិទ្យា) និងអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិលេខ ១៦៩ ស្តីពីជនជាតិដើមភាគតិចនិងក្រុមកុលសម្ព័ន្ធ នៅក្នុងប្រទេសឯករាជ្យមួយ ដែលសំដៅលើប្រព័ន្ធនៃវិធានគោលការណ៍ តម្លៃ នីតិវិធីសាស្ត្រ និងរបៀបនៃការត្រួតពិនិត្យករណីព្រហ្មទណ្ឌ ដែលត្រូវបានអនុវត្តដោយជនជាតិដើមភាគតិចសម្រាប់ការរស់នៅក្នុងសង្គមរបស់ពួកគេ ដូចជាគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងដោះស្រាយរាល់វិវាទនិងបញ្ហាដែលពួកគេប្រឈមផង។ វិធានទាំងនេះត្រូវបានគេអនុវត្តតាមវិធីផ្សេងៗ ហើយនិងត្រូវចាត់ទុកជាធម្មានុរូប (ល្អ និងចាំបាច់សម្រាប់ពួកគេ)។ វិធានទាំងនេះត្រូវបានកើតឡើង ឬបង្កើតឡើងវិញ និងផ្លាស់ប្តូរតាមរយៈប្រភពនានាដែលពួកគេចាត់ទុកជាធម្មានុរូប ឬចាំបាច់។ ក្នុងតថភាពនៃទ្រឹស្តីពហុនិយមនៃច្បាប់ ជាធម្មតាជនជាតិដើមភាគតិចតែងស្ថិតនៅក្នុងស្ថានភាពមួយដែលងាយរងគ្រោះ ដូចនេះពួកគេត្រូវធ្វើតាមសម្ពាធពីផ្នែកខាងក្រៅ ឬពួកគេព្យាយាមសម្របប្រព័ន្ធរបស់ពួកគេឱ្យស្របទៅតាមប្រព័ន្ធរបស់រដ្ឋ (ឧទាហរណ៍ ពួកគេអាចកំណត់ព្រំដែននៃប្រភេទ ឬកម្រិតរឿងក្តីដែលពួកគេត្រូវដោះស្រាយដោយខ្លួនឯង)។

ជាគោលគំនិតច្បាប់ ជនជាតិដើមភាគតិចមានសមត្ថភាពខាងផ្លូវច្បាប់ជាងយន្តការដោះស្រាយវិវាទក្រៅតុលាការ។ ទី១ ច្បាប់ជនជាតិដើមភាគតិច មានអាជ្ញាធរស្របច្បាប់ដើម្បី ក). ធ្វើនិយ័តកម្ម (ដាក់កម្រិត) លើការរស់នៅក្នុងសង្គមដោយផ្អែកលើច្បាប់ប្រពៃណី (ឧទាហរណ៍ វិធានពាក់ព័ន្ធនឹងការប្រើប្រាស់ដីរួម) ខ). គ្រប់គ្រង និង គ). ដោះស្រាយវិវាទ។ ទី២ ច្បាប់ប្រពៃណីអាចប្រើប្រាស់រាល់ការប៉ិនប្រសព្វ ឬជំនាញផ្សេងៗ ដើម្បីដោះស្រាយវិវាទ រួមទាំងការសម្រេចសេចក្តីលើករណីមួយចំនួនដែលយន្តការដោះស្រាយវិវាទក្រៅតុលាការមិនអាចធ្វើបាន ដូចជាករណីព្រហ្មទណ្ឌ និងការត្រួតពិនិត្យសណ្តាប់ធ្នាប់សាធារណៈនៅក្នុងសហគមន៍ជនជាតិដើមភាគតិចជាដើម។ យន្តការដោះស្រាយវិវាទក្រៅតុលាការមិនមានសមត្ថភាពផ្លូវច្បាប់ ដើម្បីធ្វើការស៊ើបអង្កេត អញ្ជើញសាក្សី និងបង្ខំឱ្យភាគីអនុវត្តសេចក្តីសម្រេចឡើយ តែច្បាប់ជនជាតិដើមភាគតិចមានសមត្ថភាពទាំងនេះ។ ក្នុងការអនុវត្តជាក់ស្តែង អាជ្ញាធរប្រពៃណីរបស់ជនជាតិដើមភាគតិចអាចស៊ើបអង្កេត កាត់សេចក្តី និងអនុវត្តនូវរាល់សេចក្តីសម្រេចនានា។ ក្នុងន័យនេះ ពួកគេអនុវត្តនូវអំណាចយុត្តាធិការតាមព្រឹត្តិហេតុ។

នៅប្រទេសមួយចំនួន ច្បាប់ជនជាតិដើមភាគតិច ត្រូវបានគេទទួលស្គាល់ដោយស្របច្បាប់ ដូចនេះវាមិនមែនជាអ្វីមួយដែលហៅថា "មិនផ្លូវការ" ឡើយ។

### ច្បាប់ប្រពៃណី

ពាក្យនេះមានប្រភពមកពីច្បាប់រ៉ូម៉ាំង (Roman law)។ វាសំដៅលើបណ្តុំនៃទំនៀមទំលាប់ វិធានការប្រើប្រាស់ និងការអនុវត្តន៍ដដែលៗ ដោយក្រុមមនុស្សជាក់លាក់ណាមួយ ក្នុងរយៈពេលយូរកម្រិតណាមួយ ដែលពួកគេអាចចាត់ទុកថាជាវិធានជាប់កាតព្វកិច្ច ដែលគ្រប់គ្នាត្រូវតែគោរពតាម (*consuetudo veterata*) ។ ប្រភពនៃទំលាប់ ឬវិធានអាចត្រូវបាត់បង់ក្នុងពេលណាមួយ ប៉ុន្តែប្រព័ន្ធនោះនៅតែត្រូវបានគេអនុវត្ត ពីព្រោះមនុស្សនៅក្រុមនោះនៅបន្តអនុវត្តជាប្រចាំ និងបង្កើតឡើងជាវិធានដោយប្រកាន់ខ្ជាប់និងយោងតាមការអនុវត្តទាំងនោះ។ គោលគំនិតនេះត្រូវបានផ្ទុយគ្នានឹងប្រព័ន្ធច្បាប់សរសេរ ដែលបង្កើតឡើងដោយរដ្ឋអំណាចកណ្តាល។ តាមប្រព័ន្ធច្បាប់ឥតសរសេរ "common law" ត្រូវបានគេចាត់ទុកថាជា "ច្បាប់ប្រពៃណី" ផងដែរ ដោយវាមានប្រភពមកពីរាល់សេចក្តីសម្រេចរបស់តុលាការ។ ទោះជាយ៉ាងនេះក្តី ពាក្យនេះត្រូវបានគេប្រើជាញឹកញាប់

សំដៅលើប្រព័ន្ធច្បាប់សម្រាប់មុខតំណែងខាងនយោបាយនៅក្រោមបង្គាប់ ។ ពីព្រោះច្បាប់រ៉ូម៉ាំង ធ្លាប់ជាច្បាប់ចក្រពត្តិនិយម (ច្បាប់អធិរាជ) គោលគំនិតនេះត្រូវបានគេបង្កើតឡើង ដើម្បីដាក់ឈ្មោះប្រព័ន្ធច្បាប់សម្រាប់គ្រប់គ្រងប្រជាពលរដ្ឋ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចក្រភពរ៉ូម។ ចក្រភពរ៉ូមបានប្រើវិធានមិនផ្ទាល់ និងអនុញ្ញាតឱ្យមានប្រព័ន្ធច្បាប់នៅក្រោមបង្គាប់ ដើម្បីគ្រប់គ្រងក្នុងជីវភាពប្រចាំថ្ងៃ តែមិនចាំបាច់សួរទៅអាជ្ញាធរ ថ្នាក់កំពូលនៅក្រុងរ៉ូមឡើយ។ នៅក្នុងស្ថានភាពនៃទ្រឹស្តីពហុនិយមនៃច្បាប់ ដែលចាប់ផ្តើមដោយការតាមសង្កត់ពីអាណានិគម ការធ្វើបដិវត្តន៍ សង្គ្រាម ឬការធ្វើទំនើបកម្មដ៏ឆាប់រហ័សជាទូទៅ ប្រព័ន្ធច្បាប់ថ្នាក់កំពូល បាត់បង់អានុភាពរបស់ខ្លួនក្នុងការគ្រប់គ្រងលើទឹកដីដោយព្រឹត្តហេតុ និងផ្តល់អំណាចឱ្យថ្នាក់ក្រោម ដោយមិនចាំបាច់មានការធ្វើច្បាប់ពីថ្នាក់កំពូលក្នុង។ ជាលទ្ធផល ប្រព័ន្ធច្បាប់សម្រាប់ថ្នាក់ក្រោម នៅតែមានក្នុងទម្រង់ជាធម្មនិយម ឬការអនុវត្តដាច់ដោយឡែកពីគេ មានលក្ខណៈជាអាជ្ញាធរមូលដ្ឋាន ហើយដែនអនុវត្តយុត្តាធិការក៏ត្រូវថយចុះផងដែរ។ វិធានទាំនេះមានការប្រែប្រួលតាមការអនុវត្ត ដូចនេះវាមានលក្ខណៈទន់ភ្លន់អាចបត់បែនបាន ប៉ុន្តែវិសាលភាពនៃច្បាប់ប្រពៃណីនេះ គឺត្រូវបានគេដាក់លក្ខខណ្ឌទៅតាមទំនាក់ទំនងរបស់វាជាមួយនឹងរដ្ឋ។ ក្នុងន័យនេះ កង្វះខាតនូវភ្នាក់ងាររបស់រដ្ឋអាចជាហេតុផលនាំឱ្យមានការពង្រីក និងការបន្តមាននូវច្បាប់ប្រពៃណី។

**តារាងសង្ខេបអំពីគោលគំនិតស្តីពីមុខងារទាំងឡាយនៃច្បាប់របស់រដ្ឋ**

| មុខងារ | ច្បាប់រដ្ឋ (ផ្លូវការ) | ច្បាប់ជនជាតិដើមភាគតិច | ច្បាប់ប្រពៃណី | ADR | ក្រៅផ្លូវការ |
|---|---|---|---|---|---|
| **សមត្ថភាពក្នុងការធ្វើនិយ័តកម្មលើការរស់នៅក្នុងសង្គម** | **និតិបញ្ញត្តិ :** បង្កើតឱ្យមានវិធានទូទៅសម្រាប់គ្រប់គ្នា | ចែងពីការរស់នៅក្នុងសហគមន៍ ឬរបស់ក្រុមមនុស្សណាមួយ | គ្រប់គ្រងការអនុវត្តមួយចំនួន ដូចជាការរៀបការតាមប្រពៃណី | គ្មាន | -ប្រតិកម្មដោយឯកឯង<br>-ក្រៅច្បាប់ផ្លូវការ<br>-នៅក្រៅបទបញ្ញត្តិរបស់ខ្លួន |
| **សមត្ថភាពដើម្បីត្រួតពិនិត្យសណ្តាប់ធ្នាប់សាធារណៈ និងការគ្រប់គ្រង** | **នីតិប្រតិបត្តិ :** ត្រួតពិនិត្យសណ្តាប់ធ្នាប់ និងគ្រប់គ្រង | អាជ្ញាធរ : នៅថ្នាក់សហគមន៍ | នៅថ្នាក់មូលដ្ឋាន | គ្មាន | -ក្រុមប្រដាប់អាវុធ ឬ<br>-ការប្រព្រឹត្តិនៅក្រៅច្បាប់ |
| **សមត្ថភាពដើម្បីដោះស្រាយវិវាទ** | **តុលាការ-អំណាចយុត្តាធិការ :**<br>១. ស៊ើបអង្កេត (*Notlo*)<br>២. សម្រេចសមត្ថភាពកាត់សេចក្តី (*Iudicium*)<br>៣. អនុវត្ត (*coertlo*) | ១. ស៊ើបអង្កេត<br>២. សម្រេច : សមត្ថភាពកាត់សេចក្តី<br>៣. អនុវត្ត (មានអន្តរាគមន៍ពីរដ្ឋ) | សមត្ថភាពមានកម្រិត មានការជួយពីរដ្ឋ | ១. មានកម្រិតសម្រាប់ការស៊ើបអង្កេត<br>២. មិនមានសិទ្ធិកាត់សេចក្តី (លើកលែងតែអាជ្ញាកណ្តាល)<br>៣. គ្មានសមត្ថភាពអនុវត្ត | ដោះស្រាយវិវាទក្រៅក្របខ័ណ្ឌច្បាប់ |

| | | | |
|---|---|---|---|
| គណៈកម្មការអាហ្វ្រិកខាងត្បូង (South African Commission) | ផ្លូវការ (Formal) | យន្តការដោះស្រាយវិវាទក្រៅតុលាការ – ADR | |
| អង្គការ UNDP សម្រាប់អាស៊ីប៉ាស៊ីហ្វិច (UNDP Asia Pacific ) | ផ្លូវការ (Formal) | ក្រៅផ្លូវការ (Informal) | |
| ចក្រភពអង់គ្លេស (UK) | ផ្លូវការ (Formal) | មិនមែនរបស់រដ្ឋ (NON-STATE) | |
| សេចក្តីសន្និដ្ឋានក្រោមប្រព័ន្ធច្បាប់ឯកនិយម (legal monism) | នៅក្រោមច្បាប់ និងសិទ្ធិមនុស្ស | - នៅថ្នាក់ក្រោមតាមនយោបាយ<br>- ពុំមានច្បាប់ទទួលស្គាល់<br>- នៅក្រៅវិធាន<br>- នៅក្រៅសិទ្ធិមនុស្ស<br>- គួរតែ "នៅខាងក្រោមប្រព័ន្ធផ្លូវការ" | |
| អំណះអំណាងក្រោមប្រព័ន្ធច្បាប់ពហុនិយម (legal pluralism) | - **គោលការណ៍ពហុនិយមសម្រាប់សេវាយុត្តិធម៌**<br>- គ្រប់ប្រព័ន្ធគួរគោរពតាមគោលការណ៍សិទ្ធិមនុស្ស ដោយយកចិត្តទុកដាក់លើវប្បធម៌ ភាសា និងយេនឌ័រ<br>- គ្រប់ប្រព័ន្ធត្រូវមានគណនេយ្យភាព និងការទទួលស្គាល់ សម្រាប់ប្រជាពលរដ្ឋ<br>- គ្រប់ប្រព័ន្ធគួរតែឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ នៅគ្រប់ថ្នាក់ គ្រប់ទីកន្លែង និងគ្រប់សមត្ថកិច្ច | | - **ផ្លូវការៈ** ការងាររបស់នគរបាល ឬស្ថាប័នផ្សេងទៀតគួរត្រូវបានត្រួតពិនិត្យ<br>- ទប់ស្កាត់កុំឱ្យមានប្រតិកម្មដោយហិង្សា |

# ២. អំពីការសិក្សាស្រាវជ្រាវ

## ២.១. ក្របខ័ណ្ឌស្ថាប័ន

នៅឆ្នាំ ២០០៣ គណៈរដ្ឋមន្ត្រីបានអនុម័តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (LJRS) ដែលរៀបចំដោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ គោលបំណងសំខាន់គឺដើម្បីផ្តល់នូវ "យុត្តិធម៌សម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់គ្នា"។ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ គឺជាផ្នែកមួយនៃដំណើរការកំណែទម្រង់ដ៏ធំទូលាយ ដែលសំដៅកាត់បន្ថយភាពក្រីក្រ និងពង្រឹងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ គោលបំណងពីរនៃការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ គឺ : (១) "ការបំពេញក្របខ័ណ្ឌច្បាប់ ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍឆាប់រហ័សប្រកបដោយចីរភាព និងដើម្បីលើកតំកើងនិងការពារសិទ្ធិ ហើយ (២) ការពង្រឹងស្ថាប័ន ដើម្បីធានាយុត្តិធម៌ដែលមានតម្លាភាព និងសមធម៌ដល់ទាំងអស់គ្នា"[៥៨]។ ដំណើរការនេះត្រូវបានធ្វើឡើងដោយមានលក្ខណៈទូលំទូលាយ និងមានការចូលរួម ព្រមទាំងមានការជួយគាំទ្រ និងសហប្រតិបត្តិការពីសហគមន៍អន្តរជាតិ។

យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ បានកំណត់គោលដៅយុទ្ធសាស្ត្រចំនួន ៧ ដើម្បីឈានទៅដល់គោលបំណងខាងលើ។ យុទ្ធសាស្ត្រមួយក្នុងចំណោមនោះ គឺ "ដាក់ឱ្យអនុវត្តនូវយន្តការដោះស្រាយវិវាទក្រៅតុលាការ" ដោយពិចារណាអំពីការលំបាករបស់ប្រជាពលរដ្ឋក្នុងការទទួលបានយុត្តិធម៌តាមតុលាការ។ នៅក្នុងខែធ្នូ ឆ្នាំ២០០៣ អ្នកចូលរួមក្នុង "សិក្ខាសាលាថ្នាក់ជាតិស្តីពីការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌" ដែលរៀបចំឡើងដោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (CLJR) និងក្រុមការងារបច្ចេកទេសច្បាប់ និងតុលាការ (LJTWG) បានលើកអនុសាសន៍ថា : ពង្រឹងក្របខ័ណ្ឌច្បាប់ កែលំអគុណភាព និងសិទ្ធិទទួលបានសេវាកម្មច្បាប់និងតុលាការ ពង្រឹងស្ថាប័នផ្នែកច្បាប់និងយុត្តិធម៌ និងដាក់ឱ្យអនុវត្តនូវយន្តការ ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ/ការយល់ដឹងអំពីច្បាប់។ ដើម្បីសម្រេចឱ្យបាននូវគោលដៅនេះ ផែនការសកម្មភាព ជាអាទិភាពរយៈពេលខ្លី (២០០៤-២០០៥) ត្រូវបានគេបង្កើតឡើងជាប្រយោជន៍ "ក្នុងការសិក្សាកែលំអ និងពង្រឹងយន្តការ ដោះស្រាយវិវាទក្រៅតុលាការ និងតាមប្រពៃណី" (សកម្មភាពទី ៦.២.១)។ ជាការឆ្លើយតបអង្គការ UNDP បានជំនះនូវរាល់ឧបសគ្គទាំងឡាយ ដើម្បីដាក់ឱ្យដំណើរការនូវគម្រោងសិក្សាស្រាវជ្រាវនេះ "ការប្រទាក់ក្រឡាគ្នារវាងប្រព័ន្ធយុត្តិធម៌ផ្លូវការ និងក្រៅផ្លូវការនៅកម្ពុជា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ" ដោយមានការសម្របសម្រួលជាមួយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងក្រសួងយុត្តិធម៌។ ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើការកែប្រែមួយចំនួន ហើយបានក្លាយ ជាការសិក្សានាពេលបច្ចុប្បន្ន។

---

[៥៨] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌: *កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (អនុម័តដោយគណៈរដ្ឋមន្ត្រី នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣).* កម្ពុជា: រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៣។ (ចាប់ពីពេលនេះតទៅត្រូវសរសេរ: LJRS)។ នៅក្នុងឧបសម្ព័ន្ធទី២នៃឯកសារនេះបានដកស្រង់ពី ជំពូកទី៤ ផ្នែក ៤.៤: ពង្រឹងស្ថាប័ន និងលើកកម្ពស់អភិបាលកិច្ច និង ៤.៤.១: កំណែទម្រង់វិស័យច្បាប់ នៃ "យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ" ត្រង់ទំព័រ ២៥-២៧។

មូលដ្ឋានគ្រឹះខាងស្ថាប័នសម្រាប់គម្រោងសិក្សាស្រាវជ្រាវនេះ

| ចំណងជើង | ខ្លឹមសារ/មូលដ្ឋានគ្រឹះរបស់ស្ថាប័នសម្រាប់គម្រោងសិក្សាស្រាវជ្រាវ |
|---|---|
| ១. "យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ" (NPRS) ឆ្នាំ ២០០២ | កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាវិស័យមួយ ក្នុងចំណោមវិស័យទាំងបួននៃការធ្វើកំណែទម្រង់ ដែលទាមទារឱ្យមានការពង្រឹងស្ថាប័ន និងកែលំអអភិបាលកិច្ច ក្នុងការរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។ គោលបំណងនៃកំណែទម្រង់ប្រព័ន្ធយុត្តិធម៌គឺ:<br>(i)- បំពេញនូវក្របខ័ណ្ឌច្បាប់ដើម្បី ការអភិវឌ្ឍឆាប់រហ័ស និងប្រកបដោយចីរភាព ហើយនិងលើកតម្កើង និងការពារសិទ្ធិ និង<br>(ii)- ពង្រឹងស្ថាប័នតុលាការដើម្បី ធានាយុត្តិធម៌ដែលមានតម្លាភាព និងសមធម៌ដល់ទាំងអស់គ្នា ដំណើរការនេះ "មានលក្ខណៈទូលំទូលាយ និង ប្រកបដោយការចូលរួម [៥៩] " |
| ២. យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ LRS សេចក្តីព្រាងរៀបចំដោយ CLJR និងអនុម័តដោយគណៈរដ្ឋមន្ត្រីនៅថ្ងៃទី២០ មិថុនា ២០០៣ | ទិសដៅជាយុទ្ធសាស្ត្រ ទាំង៧ នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌គឺ:<br>១. ពង្រឹងការការពារសិទ្ធិ និងសេរីភាពរបស់បុគ្គល<br>២. ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់<br>៣. ផ្តល់លទ្ធភាពឱ្យទទួលបានព័ត៌មានអំពីច្បាប់ និងយុត្តិធម៌កាន់តែប្រសើរឡើង<br>៤. ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃដំណើរការច្បាប់ និងសេវាកម្មដែលពាក់ព័ន្ធ<br>៥. ពង្រឹងសេវាកម្មយុត្តិធម៌ គឺអំណាចតុលាការ និងសេវាកម្មផ្នែកអយ្យការ<br>៦. បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ<br>៧. ពង្រឹងស្ថាប័នវិស័យយុត្តិធម៌ ឱ្យបំពេញអាណត្តិរបស់ខ្លួនបានសម្រេច |
| ៣. ផែនការ សកម្មភាព ទាញចេញ ពី LRS សម្រាប់ អាទិភាពរយៈពេលខ្លី (២០០៤-២០០៥) | សកម្មភាពជាអាទិភាពរយៈពេលខ្លី (២០០៤-២០០៥)<br>កំណត់យន្តការនានាសម្រាប់ដោះស្រាយវិវាទតូចតាចតាមរយៈការផ្សះផ្សា<br>សកម្មភាព ទី ៦.២.១."ស៊ើបអង្កេត កសាង និងពង្រឹងយន្តការដោះស្រាយវិវាទក្រៅតុលាការ និងតាមប្រពៃណី" |
| ៤. "សិក្ខាសាលាជាតិស្តីពីការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌" រៀបចំឡើងដោយ CLJR និង LJTWG នៅភ្នំពេញ ទី៩ ខែធ្នូ ឆ្នាំ ២០០៣ [៦០] | សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ដែលលើកឡើងដោយក្រុមពិភាក្សា ទាក់ទងនឹងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងបង្កើនការយល់ដឹងអំពីច្បាប់ ដែលបានពិភាក្សានៅក្នុងសិក្ខាសាលមាន: មានប្រព័ន្ធពីរ ទាក់ទងនឹងយន្តការដោះស្រាយវិវាទក្រៅតុលាការ (គណៈកម្មការសុរិយោដី និងក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ) ដែលចាំបាច់ត្រូវតែកែលំអបន្តទៀត ហើយនិងគួរបង្កើតឱ្យមានយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដទៃទៀត។<br>កំណត់តួនាទីរបស់តុលាការឱ្យបានច្បាស់ ទាក់ទងទៅនឹងដំណោះស្រាយរបស់គណៈកម្មការសុរិយោដី។<br>ចាំបាច់ត្រូវធ្វើការសិក្សាស្រាវជ្រាវ រួមទាំងការស្ទង់មតិ អំពីប្រព័ន្ធ ADR ដែលមានស្រាប់នាពេលបច្ចុប្បន្ននៅក្នុងសហគមន៍។ អង្គការ UNDP ត្រៀមខ្លួនដើម្បីគាំទ្រខាងហិរញ្ញវត្ថុចំពោះការសិក្សាបែបនេះ ។<br>ផ្សព្វផ្សាយដល់សាធារណៈឱ្យមានការយល់ដឹងត្រូវតែជាសកម្មភាពជាអាទិភាព (.......)[៦១] ។ |

៥៩ យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, LRS ,ក្នុងឧបសម្ព័ន្ធ២: NPRS ឆ្នាំ ២០០៣ ទំព័រ ២៥-២៧។

៦០ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌: *សិក្ខាសាលាថ្នាក់ជាតិ ស្តីអំពីការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់* និងប្រព័ន្ធយុត្តិធម៌។ *ដំណើរការសិក្ខាសាលា*។ ភ្នំពេញ រាជរដ្ឋាភិបាលកម្ពុជា, CLJR និង LJTWG, ខែធ្នូ ឆ្នាំ ២០០៣ (ចាប់ពីពេល នេះតទៅត្រូវហៅថា: សិក្ខាសាលាថ្នាក់ជាតិស្តីអំពីយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ឆ្នាំ ២០០៣) ទំព័រទី ២។

៦១ សិក្ខាសាលាថ្នាក់ជាតិ ស្តីអំពី យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ , ឆ្នាំ ២០០៣ ទំព័រ ៣៨។

## ២.២ មូលដ្ឋានវិធីសាស្ត្រនៃការសិក្សាផ្អែកលើគោលការណ៍សិទ្ធិមនុស្ស

វិធីសាស្ត្រផ្អែកលើគោលការណ៍សិទ្ធិមនុស្ស ដើម្បីទទួលបានយុត្តិធម៌មានការជាប់ពាក់ព័ន្ធ និងបង្កប់នូវការពិពណ៌នាផង និងអ្វីដែលមានចែងជាបទបញ្ញត្តិផង។

នៅក្នុងបរិបទនៃការពិពណ៌នា តម្រូវឱ្យអ្នកសិក្សាស្រាវជ្រាវ ត្រូវតែពិនិត្យមើលពីសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ដើម្បីរៀបរាប់ពិពណ៌នាអំពីតម្រូវការយុត្តិធម៌ នៅក្នុងសង្គមឱ្យកាន់តែប្រសើរ។ ដូចបានបញ្ជាក់រួចមកហើយថា ដោយហេតុផលនៃកង្វះនូវការយល់ដឹងអំពីសិទ្ធិ និងទំនុកចិត្តនៅក្នុងប្រព័ន្ធច្បាប់ នាំឱ្យតម្រូវការយុត្តិធម៌នៅក្នុងសង្គមមួយចំនួន មិនត្រូវបានគេប្តឹងទាមទារ ឬតវ៉ាចំពោះអាជ្ញាធរមានសមត្ថកិច្ចណាមួយឡើយ។ ទោះជាយ៉ាងនេះក្តី តម្រូវការយុត្តិធម៌ទាំងនេះ គឺជាផ្នែកមួយនៃតម្រូវការយុត្តិធម៌នៅក្នុងសង្គម ទោះជាវាស្ថិតនៅក្នុងភាពជាអាថ៌កំបាំងក៏ដោយ។ ដូចនេះ ចាំបាច់ត្រូវធ្វើការវិភាគឱ្យហួសពីអ្វីដែលជា "បញ្ហា" ដើម្បីឱ្យដឹងនិងយល់ច្បាស់ថា តើអ្វីទៅដែលប្រជាពលរដ្ឋប្រឈមជាក់ស្តែង។ បើសិនជាការសិក្សាស្រាវជ្រាវគ្រាន់តែសិក្សាទៅលើ "វិវាទ" ឬ "ទំនាស់" និងវិភាគតែពីការដោះស្រាយវិវាទ ឬទំនាស់ទេនោះ ការសិក្សានេះនឹងគ្របដណ្តប់ត្រឹមតែតម្រូវការសង្គម ដែលត្រូវបានប្រជាពលរដ្ឋប្តឹងតវ៉ារួចហើយតែប៉ុណ្ណោះ។ ហើយវាបន្សល់ទុកនូវស្ថានភាព ដែលមិនដែលបានដោះស្រាយផ្សេងៗទៀត ទាក់ទិននឹងការរំលោភអំណាច (ដូចជាអំពើពុករលួយ) ឬ ការរំលោភលើសិទ្ធិនានាឱ្យនៅបន្តកើតមាន ហើយប្រជាពលរដ្ឋរងទុក្ខដោយការរំលោភទាំងនោះ តែពួកគេពុំជឿថាអាចជាមូលដ្ឋានក្នុងការប្តឹងតវ៉ាបាន។

ដោយហេតុថាក្រុមគោលដៅមិនប្រាកដជាដឹងអំពីសិទ្ធិរបស់ពួកគេឡើយ ដូច្នេះដំណើរការសិក្សាស្រាវជ្រាវ ត្រូវតែធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយក្រុមទាំងនេះ (interactive process)។ ផ្នែកខ្លះនៃការសិក្សាស្រាវជ្រាវត្រូវតែធ្វើឡើងដើម្បីផ្តល់ព័ត៌មានដល់ក្រុមគោលដៅទាំងនេះ អំពីសិទ្ធិរបស់ពួកគេដើម្បី ឱ្យពួកគេដែលជាអ្នកចូលរួមក្នុងការសិក្សានេះ យល់អំពីសេចក្តីត្រូវការដែលទាក់ទងនឹងសិទ្ធិរបស់ខ្លួន។ និយាយដោយខ្លី ក្រុមគោលដៅទាំងនេះត្រូវមានលទ្ធភាពបង្ហាញនូវសេចក្តីត្រូវការរបស់ខ្លួនថាជាសិទ្ធិ ដើម្បីឱ្យអង្គការ UNDP អាចវាស់ និងវាយតម្លៃឱ្យបានត្រឹមត្រូវពីសមត្ថភាពនៃការផ្តល់សេវាកម្មយុត្តិធម៌ ដែលឆ្លើយតបទៅនឹងតម្រូវការយុត្តិធម៌ក្នុងសង្គមទាំងនោះ។ ការពិគ្រោះយោបល់ និងការចូលរួមគឺជាស្នូលនៃវិធីសាស្ត្រ ក្នុងការសិក្សាស្រាវជ្រាវនេះ ដែលមានគោលបំណងធ្វើការប៉ាន់ប្រមាណពី *តម្រូវការរបស់សង្គម* របស់ក្រុមគោលដៅ ដោយឱ្យក្រុមទាំងនោះជាអ្នកកំណត់អំពីតម្រូវការនេះ។ ជាការមួយមានតម្លៃណាស់ ដោយហេតុថាសិទ្ធិក្នុងការចូលរួមនេះ ត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាស្រាប់រួចហើយ។

ផ្អែកលើគោលការណ៍សិទ្ធិមនុស្ស ចាំបាច់ត្រូវតែវាយតម្លៃដោយបានដិតដល់ ថាតើយន្តការផ្តល់សេវាកម្មយុត្តិធម៌ទាំងឡាយអាចមានសមត្ថភាព ក្នុងការផ្តល់យុត្តិធម៌ដើម្បីជំនះលើឥទ្ធិពលអំណាចដោយព្រឹត្តិហេតុរបស់ភាគី (ដូចជា កត្តាសេដ្ឋកិច្ច នយោបាយ យោធា យេនឌ័រ ជាតិសាសន៍។ល។) បានដែរឬទេ និងដោយរបៀបណា ហើយថាតើយន្តការដំណើរការដោះស្រាយ និងលទ្ធផលនៃការដោះស្រាយវិវាទទាំងនេះ បានគោរពសិទ្ធិមនុស្សដោយយកចិត្តទុកដាក់សំខាន់លើសិទ្ធិជាក់លាក់របស់ក្រុមអ្នកទន់ខ្សោយ (អ្នកជាប់ពន្ធនាគារ ស្ត្រី កុមារ ជនជាតិដើមភាគតិច និងជនជាតិភាគតិច។ល។) ដែរឬយ៉ាងណា។ ដូច្នេះចាំបាច់ត្រូវតែធ្វើការវាយតម្លៃថាតើយន្តការផ្តល់សេវាកម្មយុត្តិធម៌ទាំងនេះ បានយកចិត្តទុកដាក់ចំពោះបញ្ហាទាក់ទិននឹងយេនឌ័រ ក្រុមជនជាតិភាគតិច និងភាសាដែរឬទេ។ ដូចនេះការវាយតម្លៃចំពោះយន្តការផ្តល់សេវាកម្មយុត្តិធម៌ ត្រូវបញ្ចូលផងដែរនូវការសិក្សាបញ្ហាជាក់លាក់មួយចំនួនដូចជា: ថាតើសិទ្ធិក្នុងការប្រើប្រាស់ភាសារបស់ជនជាតិភាគតិច ត្រូវបានគេគោរពពេញលេញ ឬទេ នៅពេលដែលក្រុមនេះប្រឈមនឹងចំណាត់ការក្តីតាមផ្លូវច្បាប់ ហើយថាតើវិធានរបស់ជនជាតិដើមភាគតិច ទាក់ទងនឹងការគ្រប់គ្រងដីរួមត្រូវបានគេគោរពដែរឬយ៉ាងណា ក្នុងការអនុវត្តជាក់ស្តែង។

ដោយឡែកនៅក្នុងបរិបទនៃការសន្ទត ដែលមានចែងជាបទបញ្ញត្តិ តាមគោលការណ៍សិទ្ធិមនុស្សតម្រូវ ឱ្យមានការពិគ្រោះយោបល់ជាមួយក្រុមគោលដៅ ដើម្បីប្រមូលយកនូវរាល់អនុសាសន៍ពីក្រុមទាំងនោះ ។ ការពិគ្រោះយោបល់នេះអាចធ្វើឡើង យ៉ាងហោចណាស់ក្នុងគោលដៅបី: ទីមួយ ក្នុងការពិគ្រោះយោបល់ជាការចាំបាច់ ដើម្បីរៀបចំគោលនយោបាយដែលមានបំណងបង្កើន និងផ្តល់អំណាចដល់បុគ្គលគ្រប់រូបនៃក្រុមគោលដៅ ទាំងជាលក្ខណៈបុគ្គល ក៏ដូចជាជាក្រុមដែរ (ជាពិសេសសម្រាប់ក្រុមទាំងឡាយណា ដែលកម្រនឹងទទួលបាននូវសេវាកម្មយុត្តិធម៌)។ ធ្វើដូចនេះ អាចឱ្យបុគ្គលឬក្រុមនោះអាចប្តឹងតវ៉ាទាមទារសិទ្ធិរបស់ពួកគេ ព្រមទាំងអាចចូលរួមក្នុងដំណើរការកំណែទម្រង់សិទ្ធិ ទទួលបានយុត្តិធម៌ផង។ ប្រជាពលរដ្ឋដឹងអំពីសេចក្តីត្រូវការរបស់ខ្លួន ប៉ុន្តែពួកគេក៏ត្រូវការដឹងអំពីសិទ្ធិ និងច្បាប់ផងដែរ ដើម្បីឱ្យពួកគេអាចធ្វើឱ្យសេចក្តីត្រូវការក្នុងសង្គមរបស់ពួកគេក្លាយជាសិទ្ធិមនុស្ស ដើម្បីឱ្យគេអាចប្តឹងតវ៉ាទាមទារសិទ្ធិ ព្រមទាំងទាមទារឱ្យរដ្ឋឆ្លើយតប និងបំពេញនូវរាល់កាតព្វកិច្ចរបស់ខ្លួនចំពោះប្រជាពលរដ្ឋ។ ទីពីរ ចាំបាច់ត្រូវមានការពិគ្រោះយោបល់ដើម្បីកែលំអការផ្តល់សេវាកម្មយុត្តិធម៌ដែល: ១). អាចឆ្លើយតបចំពោះសេចក្តីត្រូវការរបស់សង្គមកាន់តែប្រសើរ ២). មានប្រសិទ្ធិភាព ៣). ការពារទល់នឹងរាល់សម្ពាធ និងឥទ្ធិពលរបស់ភាគីអ្នកមានអំណាច ទៅលើភាគីទន់ខ្សោយ និង ៤). គោរពសិទ្ធិមនុស្ស ជាពិសេសទាក់ទិននឹងស្ត្រី កុមារ ជនជាតិដើមភាគតិច និងជនជាតិភាគតិច។ ទីបី ចាំបាច់ត្រូវមានការពិគ្រោះយោបល់ដើម្បីពង្រឹងនូវតម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាកម្មយុត្តិធម៌ និងទប់ស្កាត់អំពើពុករលួយ។ ដោយតម្រូវការក្នុងសង្គមមានការប្រែប្រួល និងបញ្ហាសិទ្ធិបានក្លាយកាន់តែធំទូលាយឡើងនោះ ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាមូលដ្ឋានគ្រឹះក្នុងការកំណត់ពីតម្រូវការយុត្តិធម៌នៅក្នុងសង្គម។

**តារាងស្តីពីការបញ្ចូលគោលការណ៍សិទ្ធិមនុស្សនៅក្នុងការសិក្សាស្តីពីសិទ្ធិទទួលបានយុត្តិធម៌**

| **ការសន្ទនានា<br>នៅក្នុងវិធីសាស្ត្រ** | **ជាការពិពណ៌នា<br>វិភាគ:** | **ចែងជាបទបញ្ញត្តិ<br>កែលំអ:** |
|---|---|---|
| • **ក្រុមគោលដៅ** : ដឹងពីសេចក្តីត្រូវការ មានតម្លៃខាងសីលធម៌ និងការអនុវត្តស្របច្បាប់<br>• **សិទ្ធិមនុស្ស** : ត្រូវតែផ្តល់ដល់ក្រុមគោលដៅ<br>• **ពិគ្រោះយោបល់** និងការចូលរួម ជាការចាំបាច់<br>• **សង្កេតមើលឧបករណ៍** ផ្សេង១ទៀត ដោយប្រៀបធៀប ព័ត៌មានបានមកពីប្រភពដទៃ | • **តម្រូវការយុត្តិធម៌ក្នុងសង្គម** : ផ្អែកលើសេចក្តីត្រូវការ<br>• **ការផ្តល់សេវាកម្មយុត្តិធម៌** : សមត្ថភាពក្នុងការឆ្លើយតបចំពោះតម្រូវការយុត្តិធម៌ក្នុងសង្គម ឱ្យបានពេញលេញ<br>• **គោរពនិយាមសិទ្ធិមនុស្ស** ក្នុងដំណើរការក្តី និងលទ្ធផល<br>• **សមធម៌** : សមត្ថភាពនៃយន្តការផ្តល់សេវាកម្មយុត្តិធម៌ ដើម្បីពុះពារលើរាល់ឥទ្ធិពលនៃអំណាច របស់គូភាគី | • **បង្កើនការយល់ដឹង និងអំណាចដល់ក្រុមគោលដៅ:**<br>ក. បង្កើនការយល់ដឹងពីសិទ្ធិនិងច្បាប់ ដើម្បីឱ្យពួកគេអាចយល់ថាតម្រូវការសង្គមរបស់ពួកគេ គឺជាសិទ្ធិស្របច្បាប់របស់ពួកគេ។<br>ខ. កសាងសមត្ថភាពជូនដល់ក្រុមគោលដៅ ដើម្បីឱ្យក្រុមគោលដៅអាចប្តឹងតវ៉ាបាន<br>គ. កសាងសមត្ថភាពជូនដល់យន្តការផ្តល់ និងពង្រឹងភាពជាអ្នកដឹកនាំសម្រាប់កំណែទម្រង់ច្បាប់<br>• **ការផ្តល់សេវាកម្មយុត្តិធម៌ដោយ:**<br>ក. យុត្តិធម៌ មានប្រសិទ្ធិភាព និងមានតម្លាភាព និងងាយរកបានដោយប្រជាពលរដ្ឋ<br>ខ. ឆ្លើយតបចំពោះតម្រូវការសង្គមកាន់តែប្រសើរ<br>គ. គោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិរបស់ក្រុមជនទន់ខ្សោយ<br>ឃ. ជំនះលើការប្រើអំណាចរបស់គូភាគីវិវាទ<br>• **គណនេយ្យភាព:** ត្រួតពិនិត្យការរំលោភ អំណាច និងអំពើពុករលួយ ក្នុងការផ្តល់ សេវាកម្មយុត្តិធម៌ |

## ២.៣. គោលដៅចម្បងនៃការសិក្សា និងលទ្ធផលរំពឹងទុក

នៅក្នុងដំណើរការរៀបចំគម្រោងនេះ អង្គការ UNDP បានឃើញពីភាពចាំបាច់ នៃការជ្រើសរើសយកការសិក្សាស្រាវជ្រាវដែលមានលក្ខណៈទូលំទូលាយ ជាជាងគ្រាន់តែសិក្សាទៅលើអ្វីដែលហៅថា យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងគោលបំណងដើម្បីឱ្យមានការយល់ដឹងកាន់តែប្រសើរឡើង អំពីស្ថានភាពសិទ្ធិទទួលបានយុត្តិធម៌។ ហេតុដូច្នេះ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងដោយមានគោលដៅទូលំទូលាយជាងអ្វីដែលគិតទុកជាមុន ប៉ុន្តែដោយផ្តោតសំខាន់ទៅលើក្រុមគោលដៅច្បាស់លាស់។ លើសពីនេះ ដោយពិចារណាអំពីគោលការណ៍ ក្នុងការចូលរួមនៅក្នុងកំណែទម្រង់ប្រកបដោយប្រជាធិបតេយ្យ គម្រោងត្រូវបានរៀបចំឡើងជាការ "ស្រាវជ្រាវដោយមានការចូលរួម" ដើម្បីផ្តល់អំណាចឱ្យប្រជាពលរដ្ឋ ក្នុងការចូលរួមក្នុងដំណើរការកំណែទម្រង់។ ការចូលរួម និងការពិគ្រោះយោបល់ ត្រូវបានចាត់ទុកជាស្នូលនៃការសិក្សានេះ។ តាមមធ្យោបាយនេះ គម្រោងត្រូវបានកែប្រែឱ្យទៅជាគម្រោង "ស្រាវជ្រាវដោយមានការចូលរួម (research-action) ស្តីពី "សិទ្ធិទទួលបានយុត្តិធម៌ ដោយផ្តោតសំខាន់លើអ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច" ដោយមានគោលដៅ និងលទ្ធផលរំពឹងទុកដូចខាងក្រោម។

លទ្ធផលរំពឹងទុកចម្បង១:

ក. ក្រុមគោលដៅត្រូវបានយល់ដឹង និងត្រូវបានផ្តល់សិទ្ធិអំណាចកាន់តែប្រសើរជាងមុន ដើម្បីចូលរួមក្នុងដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌។

ខ. ទាញបាននូវទិដ្ឋភាពរួមអំពីបញ្ហាចម្បងៗក្នុងសង្គម រួមទាំងតម្រូវការយុត្តិធម៌របស់សង្គម ជាពិសេសសម្រាប់អ្នកដែលងាយបាត់បង់អត្ថប្រយោជន៍ជាងគេដូចជា ស្ត្រី និងជនជាតិដើមភាគតិច ក៏ដូចជាយន្តការផ្សេងៗដែលប្រជាពលរដ្ឋប្រើ ដើម្បីទទួលបានយុត្តិធម៌ដែលខ្លួនត្រូវការ។

គ. ការវាយតម្លៃទូទៅលើការផ្តល់សេវាកម្មយុត្តិធម៌ រួមទាំងតុលាការ នគរបាល អាជ្ញាធររដ្ឋាភិបាល យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) គណៈកម្មការសុរិយោដី (CCo) និងក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ (LACo) ព្រមទាំងយន្តការដោះស្រាយវិវាទនៅសហគមន៍ ដោយពិចារណាលើច្បាប់ទំនៀមទម្លាប់ ដែលអនុវត្តដោយសហគមន៍ជនជាតិដើមភាគតិច

ឃ. អនុសាសន៍ដើម្បីធ្វើការកែលំអគោលនយោបាយ អំពីសិទ្ធទទួលបានយុត្តិធម៌ ជាពិសេសទាក់ទងនឹងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងប្រព័ន្ធយុត្តិធម៌នៅសហគមន៍ (CSJ)

ង. អនុសាសន៍ផ្សេងៗទៀត សម្រាប់អ្នកធ្វើគោលនយោបាយ និងអ្នកផ្តល់ជំនួយ។

**តារាងទី ១១. តារាងស្តីពីគោលបំណងសំខាន់ៗនៃការសិក្សាស្រាវជ្រាវ**

| គោលបំណងទូទៅ | គោលបំណងជាក់លាក់ | លទ្ធផល |
|---|---|---|
| ១. សិក្សាស្រាវជ្រាវ និងវិភាគអំពីតម្រូវការយុត្តិធម៌របស់សង្គម និងវាយតម្លៃពីការផ្តល់សេវាយុត្តិធម៌ | រៀបចំប្លង់គម្រោង និងអនុវត្តការសិក្សាស្រាវជ្រាវដើម្បីឱ្យយល់កាន់តែច្បាស់អំពី:<br>១. បញ្ហានិងវិវាទចម្បងៗ ដែលនាំឱ្យមានតម្រូវការយុត្តិធម៌ សម្រាប់សង្គម ជាពិសេសសម្រាប់អ្នកក្រីក្រ ស្ត្រី និងសហគមន៍ជនជាតិដើមភាគតិច។<br>២. ការផ្តល់សេវាយុត្តិធម៌: "ផែនទី" នៃប្រព័ន្ធ និងយន្តការដោះស្រាយវិវាទផ្សេងៗ ដែលប្រជាពលរដ្ឋអាចទទួលយកបាន និងប្រើប្រាស់ ជាពិសេសសម្រាប់អ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច ។<br>៣. វាយតម្លៃអំពីឥទ្ធិពលនៃ ADR និង CSJ<br>៤. អន្តរកម្ម និងភាពតានតឹងគ្នារវាងប្រព័ន្ធផ្សេងៗ | ១. ទាញបាននូវទិដ្ឋភាពរួមអំពីបញ្ហាតម្រូវការយុត្តិធម៌របស់សង្គម និងការផ្តល់សេវាយុត្តិធម៌ ព្រមទាំងមើលឃើញពីប្រព័ន្ធផ្សេងៗ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងការទទួលបានយុត្តិធម៌ និងវិភាគអំពីភាពប្រទាក់ក្រឡាគ្នារវាងប្រព័ន្ធទាំងនោះ |

| | | |
|---|---|---|
| ២. ផ្តល់ព័ត៌មានដល់ក្រុមគោលដៅដើម្បីឱ្យពួកគាត់ដឹងថាគាត់មានអំណាច និងលើកទឹកចិត្តឱ្យមានការចូលរួម | ផ្តល់ឱ្យក្រុមគោលដៅនូវ :<br>១. ព័ត៌មានទាក់ទងនឹង : (ក) ដំណើរការកំណែទម្រង់ (ខ) សិទ្ធិទទួលបាននូវយុត្តិធម៌ (គ) សិទ្ធិក្នុងការចូលរួម និង (ឃ) សិទ្ធិពិសេសរបស់ស្ត្រី និងជនជាតិដើមភាគតិច ។<br>២. ព័ត៌មានស្តីអំពីស្ថាប័ន និងច្បាប់ ស្តីពីប្រព័ន្ធតុលាការ យុត្តិធម៌សហគមន៍ និងយន្តការក្រៅប្រព័ន្ធតុលាការ<br>៣. ប្រៀបធៀបបទពិសោធន៍ | ២. ក្រុមគោលដៅត្រូវបានយល់ដឹង និងត្រូវបានពិគ្រោះ នៅក្នុងដំណើរការកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ |
| ៣. លើកអនុសាសន៍ជូនដល់អ្នកធ្វើគោលនយោបាយក្នុងវិស័យយុត្តិធម៌ ដោយអាស្រ័យលើការពិគ្រោះយោបល់ | យោងតាមលទ្ធផលពិគ្រោះយោបល់ជាមួយក្រុមគោលដៅ បានលើកឡើងនូវសំណូមទាក់ទងនឹង:<br>១. កំណែទម្រង់ច្បាប់ និងពង្រឹងស្ថាប័នដើម្បី ក) -ពង្រឹង និងរៀបចំស្ថាប័នយុត្តិធម៌មូលដ្ឋាន ខ) -កែលំអយន្តការដោះស្រាយវិវាទក្រៅតុលាការ គ) -កែលំអយុត្តិធម៌ផ្លូវការ ដើម្បីឆ្លើយតបឱ្យកាន់តែប្រសើរឡើងចំពោះសេចក្តីត្រូវការរបស់ជនក្រីក្រ ស្ត្រី និងក្រុមជនជាតិដើមភាគតិច ឃ) -ទទួលស្គាល់ច្បាប់ជនជាតិដើមភាគតិច ង) -បង្កើតឱ្យមានយន្តការមួយ ដើម្បីសម្របសម្រួលសេវាយុត្តិធម៌ផ្សេងៗគ្នា (ប្រព័ន្ធនៃការផ្តល់សេវាយុត្តិធម៌របស់ជាតិ)<br>២. ផ្តល់អំណាចដល់ជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច តាមរយៈកម្មវិធីយល់ដឹងពីសិទ្ធិ<br>៣. ពង្រឹងសមត្ថភាពដល់មន្ត្រីដែលជាអ្នកផ្តល់សេវាយុត្តិធម៌ | ៣. អនុសាសន៍ ដើម្បីកែលំអគោលនយោបាយអំពីសិទ្ធិទទួលបានយុត្តិធម៌ រួមទាំងកម្មវិធីកំណែទម្រង់ច្បាប់ ការពង្រឹងស្ថាប័ន និងការយល់ដឹងពីសិទ្ធិ |

## ២.៤. វិធីសាស្ត្រប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ

ការសិក្សាគ្របដណ្តប់យ៉ាងទូលំទូលាយៈ រាប់ចាប់ពីតម្រូវការយុត្តិធម៌របស់សង្គម រហូតដល់ការផ្តល់សេវាយុត្តិធម៌

ការសិក្សាស្រាវជ្រាវនេះ បានផ្តើមសាកសួរប្រជាពលរដ្ឋអំពីបញ្ហា និងវិវាទចម្បងៗដែលពួកគេជួបប្រទះជាទូទៅ ។ ប៉ុន្តែក្នុងចំណោមបញ្ហាឬវិវាទទាំងនោះ មានតែបញ្ហាមួយចំនួនប៉ុណ្ណោះដែលត្រូវបានប្រជាពលរដ្ឋយល់ថាជា "រឿងក្តី" គឺសំដៅលើករណីដែលអាចប្តឹងទៅជនទីបី ឬភ្នាក់ងារណាមួយដើម្បីដោះស្រាយតាមវិធីណាមួយ ។ ទីបំផុតមានបញ្ហាតែមួយចំនួនតូចប៉ុណ្ណោះ ដែលត្រូវបានដាក់ទៅភ្នាក់ងារ ឬជនទីបីណាមួយដើម្បីដោះស្រាយ ។ នេះមានន័យថាបញ្ហាឬវិវាទធ្ងន់ធ្ងរមួយចំនួនមិនត្រូវបានគេប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចឡើយ ដោយសារខ្វះការយល់ដឹងពីសិទ្ធិ ឬពុំមានទំនុកចិត្តចំពោះប្រព័ន្ធយុត្តិធម៌ផ្លូវការ ក៏ដូចជាមានការលំបាកនិងឧបសគ្គទាំងឡាយក្នុងការ ទទួលយកយុត្តិធម៌តាមផ្លូវតុលាការ ដោយសារត្រូវចំណាយខ្ពស់ពេក ។ សូមចងចាំថា ការសិក្សាស្រាវជ្រាវនេះ ផ្តោតសំខាន់លើថា តើតម្រូវការយុត្តិធម៌នៅក្នុងសង្គម ត្រូវបានស្តែងចេញយ៉ាងដូចម្តេច ហើយតើវារួមមានអ្វីខ្លះ?

ដើម្បីអាចយល់ពីតម្រូវការយុត្តិធម៌ក្នុងសង្គម ការសិក្សាស្រាវជ្រាវនេះក៏ធ្វើការវិភាគផងដែរពីយន្តការផ្សេងៗ ដែលប្រជាពលរដ្ឋប្រើប្រាស់ដើម្បីដោះស្រាយបញ្ហារបស់ពួកគេ និងវិភាគពីយន្តការទាំងនេះថាតើវាបានឆ្លើយតប ឬមិនបានឆ្លើយតបទៅនឹងបញ្ហាឬវិវាទទាំងនោះ ។ យន្តការទាំងនេះអាចបង្កើតឡើងដោយច្បាប់ ឬមិនបានបង្កើតឡើងដោយច្បាប់ អាចជាផ្លូវការ

ឬក្រៅផ្លូវការ ឬក៏ចំរុះគ្នា។ការសិក្សានេះ រួមបញ្ចូលទាំងការវិភាគលើក្របខ័ណ្ឌ ច្បាប់ ការអនុវត្តរបស់ស្ថាប័ន ការយល់ដឹងពីច្បាប់ និងការអនុវត្តរបស់ភ្នាក់ងារ ឬស្ថាប័ននានាដែលបច្ចុប្បន្នកំពុងផ្តល់សេវាយុត្តិធម៌ តាមរយៈការផ្សះផ្សា ការសម្រុះសម្រួល ឬតាមទម្រង់ផ្សេងៗទៀតនៃការដោះស្រាយ។ ការសិក្សាស្រាវជ្រាវនេះបញ្ចូលនូវការវាយតម្លៃ ដែលធ្វើឡើងដោយក្រុមគោលដៅ ចំពោះការផ្តល់សេវាយុត្តិធម៌ និងសំណូមពររបស់ពួកគេដើម្បីកែលំអសិទ្ធិទទួលបានយុត្តិធម៌។ ជារួមការស្រាវជ្រាវនេះបានព្យាយាមគ្របដណ្តប់លើតម្រូវការ និងការផ្តល់សេវាយុត្តិធម៌ ព្រមទាំងលើកអនុសាសន៍ដើម្បីកែលំអសិទ្ធិទទួលបានយុត្តិធម៌ផងដែរ។

បទពិសោធន៍ទទួលបាន:

ក. ការសិក្សានេះគាំទ្រចំពោះសារៈសំខាន់ នៃការចាប់ផ្តើមចេញពីតម្រូវការក្នុងសង្គមរបស់ប្រជាពលរដ្ឋ ដើម្បីឈានទៅវាយតម្លៃការផ្តល់សេវាយុត្តិធម៌។ ការសិក្សាភាគច្រើនបំផុត គ្រាន់តែផ្តោតសំខាន់ លើការដោះស្រាយវិវាទដោយស្ថាប័នជាក់លាក់មួយចំនួន ដែលកើតមានរវាងប្រជាពលរដ្ឋប៉ុណ្ណោះ ដោយមិនពិចារណាពីតម្រូវការយុត្តិធម៌ក្នុងសង្គម ដែលមិនត្រូវបានគេដោះស្រាយឡើយ (ដូចជា ការរំលោភសិទ្ធិ អំពើពុករលួយ និងការរំលោភអំណាចជាដើម)។ ប្រហែលនេះជាការសិក្សាតែមួយគត់ ដែលមិនត្រឹមតែសិក្សាការដោះស្រាយវិវាទរវាងប្រជាពលរដ្ឋទេ តែត្រូវបានគ្របដណ្តប់លើតម្រូវការយុត្តិធម៌ក្នុងសង្គមផ្សេងៗទៀតផងដែរ។

ខ. ការសិក្សានេះ ក៏អះអាងគាំទ្រដល់ភាពចាំបាច់ក្នុងការពិចារណាអំពីយន្តការដោះស្រាយវិវាទផ្សេងៗ ទាក់ទិននឹងសិទ្ធិទទួលបានយុត្តិធម៌ ដើម្បីអោយយល់បានច្បាស់អំពីស្ថានភាពទូទៅនៃរាល់យន្តការដែលមានស្រាប់។

គ. ចាំបាច់ត្រូវសិក្សាពីនគរបាលផងដែរ ដោយហេតុថានគរបាលក៏ជាតួអង្គមួយដ៏សំខាន់ ក្នុងការដោះស្រាយវិវាទ។

ការសិក្សាមានលក្ខណៈទូលំទូលាយ ប៉ុន្តែផ្តោតសំខាន់ទៅលើអ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច

ការសិក្សានេះ មានគោលបំណងដើម្បីផ្តល់នូវទិដ្ឋភាពរួមមួយ នៃបញ្ហាសំខាន់ៗទាក់ទងនឹងសិទ្ធិទទួលបានយុត្តិធម៌ភាគច្រើននៅតំបន់ជនបទ ដោយផ្តោតជាសំខាន់លើថ្នាក់មូលដ្ឋាន។ ការសិក្សានេះបានផ្តោតសំខាន់ពីបញ្ហាទាំងឡាយ ដែលប្រឈមដោយក្រុមអ្នកងាយបាត់បង់អត្ថប្រយោជន៍ច្រើនជាងគេនៅកម្ពុជា។ ការសិក្សានេះព្យាយាមរកឱ្យឃើញនូវប្រព័ន្ធ និងយន្តការយុត្តិធម៌ដែលមានស្រាប់នៅពេលបច្ចុប្បន្ននៅកម្ពុជា ហើយនិងដើម្បីឱ្យដឹងថាតើយន្តការ និងប្រព័ន្ធទាំងនេះឆ្លើយតបទៅនឹងតម្រូវការសិទ្ធិទទួលបានយុត្តិធម៌របស់សង្គមបានកម្រិតណា។ ពីព្រោះវិធីសាស្ត្រស្រាវជ្រាវបានក្តោបលើរឿងរ៉ាវទូលំទូលាយ ជាជាងការវិភាគស៊ីជម្រៅលើបញ្ហានីមួយៗ ។

ទោះបីជាការសិក្សាស្រាវជ្រាវនេះមានលក្ខណៈទូលំទូលាយក្តី តែវាបានផ្តោតសំខាន់លើសេចក្តីត្រូវការរបស់អ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច។ ភាគច្រើននៃប្រជាពលរដ្ឋកម្ពុជាទាំងអស់រស់នៅតំបន់ជនបទ (៨៤%) ប៉ុន្តែពួកគេទទួលបានប្រាក់ចំណូលត្រឹមតែ ១/៣ នៃចំណូលជាតិប៉ុណ្ណោះ[៦២]។ អ្នកទាំងនោះ ភាគច្រើនជាអ្នកក្រីក្រ ហើយយ៉ាងហោចណាស់មាន ១/៣ រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ។ ស្ត្រីមានចំនួនប្រហែល ៥២%នៃប្រជាពលរដ្ឋទាំងអស់ ហើយនៅក្នុងភាគរយមួយដែលគួរឱ្យកត់សំគាល់ ដែលពួកគេទាំងនោះទទួលរងនូវការរើសអើងផ្លូវភេទ និងអំពើហិង្សាជារៀងរាល់ថ្ងៃ។ ជនជាតិដើមភាគតិចនៅកម្ពុជាមានតិចតួចធៀបនឹងចំនួនប្រជាពលរដ្ឋទាំងអស់ (ប្រហែល ១-២%) ប៉ុន្តែពួកគេជាប្រជាពលរដ្ឋភាគច្រើន ដែលរស់នៅក្នុងខេត្ត

៦២ ប្រជាពលរដ្ឋប្រមាណជា ៨៤.៣% រស់នៅជនបទ (តាមស្ថិតិជំរឿនដោយវិទ្យាស្ថានជាតិស្ថិតិ) ឬឯកម្លាំងពលកម្មក្នុងវិស័យកសិកម្ម គឺមានប្រហែលជា៧៥% ហើយកសិកម្មចូលរួមចំណែកក្នុងផលទុនសរុបក្នុងស្រុក, ផ.ស.ស (GDP) ចំនួន ៣៥ % គឺប្រហែលជា ១/៣ នៃ ផ.ស.ស (ការប៉ាន់ស្មាននៅ ឆ្នាំ ២០០៣) រដ្ឋាភិបាល ស.រ.អ: The World Factbook, Cambodia, គេហទំព័រ : http://www.cia.gov/cia/publications/factbook/geos/cb.html (ថ្ងៃខែមើលគេហទំព័រ: ទី២៥ ខែមេសា ឆ្នាំ ២០០៥)។

មួយចំនួន(ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី)។ សូម្បីតែនៅក្នុងខេត្តដែលពួកគេជាប្រជាពលរដ្ឋភាគច្រើនបែបនេះក្តី ជនជាតិដើមភាគតិចបានទទួលរងនូវការគំរាមកំហែងយ៉ាងខ្លាំងដល់អត្ថិភាពរបស់ពួកគេជាប្រជាពលរដ្ឋ ដោយសារការបាត់បង់មធ្យោបាយខាងសម្ភារៈ និងវប្បធម៌សម្រាប់ការរស់នៅ និងកង្វះខាតនូវការគោរពអត្តសញ្ញាណ នៃភាសានិងវប្បធម៌របស់ពួកគេ។ ការសិក្សាស្រាវជ្រាវនេះបានយកចិត្តទុកដាក់ទៅលើលក្ខខណ្ឌសង្គម-សេដ្ឋកិច្ច យេនឌ័រ និងវប្បធម៌នៃក្រុមដែលបាត់បង់អត្ថប្រយោជន៍នៅកម្ពុជា។ មានមនុស្សជាច្រើនទៀត ដែលកំពុងប្រឈមមុខនឹងគ្រោះថ្នាក់ ហើយដែលគួរតែត្រូវបានយកចិត្តទុកដាក់ ដូចជាកុមារ ជនចាស់ជរា អ្នកជាប់ពន្ធនាគារ ជនល្មើសជាអនីតិជន និងជនភៀសខ្លួនជាដើម។ ប៉ុន្តែការសិក្សានេះ មិនអាចគ្របដណ្តប់ទៅលើគ្រប់ក្រុមមនុស្សទាំងនោះទេ។

បទពិសោធន៍ទទួលបានៈ

ក. ការសិក្សានេះបានអះអាង និងគាំទ្របន្ថែមពីសារៈសំខាន់ក្នុងការឆ្លើយតប ចំពោះសេចក្តីត្រូវការរបស់ក្រុមគោលដៅជាក់លាក់មួយចំនួន : ជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច។

ខ. ចាំបាច់ត្រូវធ្វើការសិក្សាឱ្យបានស៊ីជម្រៅអំពីច្បាប់ជនជាតិដើមភាគតិច ក៏ដូចជាវិវាទដែលកើតមានទៅតាមទីប្រជុំជន (ឧទាហរណ៍ វិវាទទាក់ទងនឹងលំនៅដ្ឋាន គ្រោះថ្នាក់ចរាចរ និងការសម្រុះសម្រួល ឬចំណាត់ការរបស់នគរបាលពេលទទួលបណ្តឹង) និងបញ្ហាពាក់ព័ន្ធនឹងយុវជន (ដូចជា ដំណើរការដោះស្រាយពេលមានវិវាទទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ បងតូចបងធំ អំពើហិង្សានៅមូលដ្ឋាន និងករណីព្រហ្មទណ្ឌជាដើម)។

ផ្តោតសំខាន់ទៅលើបញ្ហា និងសំណូមពរនាពេលបច្ចុប្បន្ន
**(Synchronic methodology not diachronic)**

ដោយសារតែពេលវេលាមានកម្រិតសម្រាប់ការសិក្សានេះ វិធីសាស្ត្រដែលបានប្រើបានផ្តោតសំខាន់ទៅលើបញ្ហា និងសំណូមពរដែលមាននៅពេលបច្ចុប្បន្ននេះ។ ឬអាចនិយាយម្យ៉ាងទៀតថា ការសិក្សានេះគឺមានលក្ខណៈ បច្ចុប្បន្នភាពជាជាងអតីតភាព។ ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា និងសេចក្តីយោងនានាទៅលើយន្តការនានា ដែលមានពីអតីតកាលសម្រាប់ការដោះស្រាយវិវាទ បានរួមចំណែកយ៉ាងសំខាន់សម្រាប់គម្រោងស្រាវជ្រាវនេះ ប៉ុន្តែវាមិនមែនជាកម្មវត្ថុនៃការសិក្សានេះទេ។ ការសិក្សាស្រាវជ្រាវនេះ មិនបានវិភាគពីយន្តការដោះស្រាយវិវាទ ដែលមានពីអតីតកាល ហើយដែលពុំមានប្រើតទៅទៀតនៅពេលបច្ចុប្បន្ននេះទេ។ រឿងនេះគឺជាកម្មវត្ថុនៃការសិក្សាផ្សេង១ទៀត[៦៣] ហើយវាតម្រូវឱ្យប្រើពេលច្រើនជាងនេះ។

ការសិក្សាស្រាវជ្រាវដោយមានការចូលរួម **(research-action approach)**

វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវនេះ គឺផ្អែកលើគោលការណ៍សិទ្ធិមនុស្ស។ យើងបានចាប់យកវិធីសាស្ត្រសិក្សាស្រាវជ្រាវដោយមានការចូលរួម (Research-Action) មកប្រើប្រាស់ ពីព្រោះគោលដៅមួយក្នុងចំណោមគោលដៅជាច្រើននៃគម្រោងនេះគឺដើម្បីផ្តល់អំណាចដល់ក្រុមគោលដៅ ក្នុងគោលបំណងដើម្បីលើកជម្កើងការចូលរួមរបស់ពួកគេក្នុងដំណើរការកំណែទម្រង់។ យើងក៏បានបញ្ចូលនូវឧបករណ៍មួយចំនួន នៅក្នុងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ដើម្បីធានានូវការចូលរួម និងពិគ្រោះយោបល់ឱ្យមានផុសផុល។ ការចូលរួមនិងពិគ្រោះយោបល់ទាំងនេះ ត្រូវបានធ្វើឡើងតាមរយៈសិក្ខាសាលា និងកិច្ចសម្ភាសន៍នានា។ ការចូលរួមអាចធ្វើឱ្យការធ្វើកំណែទម្រង់ឆ្លើយតបទៅនឹងតម្រូវការរបស់សង្គម ដូចជាខាងភាសា

---

៦៣ សូមមើល : Luco, Fabienne: *Between a tiger and a crocodile. Management of local conflicts in Cambodia. An anthropological approach to traditional and new practices.* Phnom Penh: UNESCO, 2002; Hughes, Caroline: *An investigation of conflict management in Cambodian villages. A review of the literature with suggestions for future research.* Phnom Pennh: Centre for Peace and Development, Cambodia Development Resource Institute, 2001.

និងវប្បធម៌ សម្រាប់ប្រជាពលរដ្ឋទាំងអស់។ ឧបករណ៍ទាំងនេះ អាចអនុញ្ញាតឱ្យប្រជាពលរដ្ឋកម្ពុជាអនុវត្តនូវសិទ្ធិចូលរួមក្នុងដំណើរការកែទម្រង់ប្រព័ន្ធយុត្តិធម៌របស់ពួកគេ ដូចដែលបានធានាដោយរដ្ឋធម្មនុញ្ញ មាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញថា *"ប្រជាពលរដ្ឋ ខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ សេចក្តីស្នើ ទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ ពីអង្គការរដ្ឋ។"*

តាមរយៈសិក្ខាសាលាទាំងនេះ វាអាចផ្តល់ឱកាសឱ្យយើងអាចស្វែងយល់ច្បាស់លាស់អំពីឫសគល់នៃបញ្ហាដដែល ពិភាក្សា និងលើកសំណូមពរកែលំអ។ ឧបករណ៍ខ្លះត្រូវបានប្រើប្រាស់ដើម្បី "ប្រមូលព័ត៌មាន" ទាក់ទងនឹងប្រធានបទនៃបញ្ហាចម្បងៗរបស់ពួកគេ (តម្រូវការយុត្តិធម៌ក្នុងសង្គម) និងដំណើរការនៃប្រព័ន្ធដោះស្រាយវិវាទផ្សេងៗពីគ្នា (ការផ្គត់ផ្គង់ សេវាយុត្តិធម៌)។ ឧបករណ៍ដទៃទៀតត្រូវបានបង្កើតឡើងដើម្បី "ផ្តល់ព័ត៌មាន" ដល់អ្នកចូលរួមអំពីសិទ្ធិពួកគេទាក់ទងទៅនឹងសិទ្ធិទទួលបានយុត្តិធម៌ និងអំពីដំណើរការកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នាពេលបច្ចុប្បន្ន។ ជាចុងក្រោយ ឧបករណ៍ខ្លះបានផ្តល់នូវឱកាសសម្រាប់ជជែកពិភាក្សា និងធ្វើសំណូមពរ។ ការយល់ដឹងរបស់ប្រជាពលរដ្ឋពីសិទ្ធិ ក៏ដូចជាការយល់ដឹងពីព្រឹត្តិការណ៍ជាតិ គឺជាឧបករណ៍សំខាន់ដែលអាចឱ្យប្រជាពលរដ្ឋ និងអង្គការនៅថ្នាក់មូលដ្ឋានចូលរួមកាន់តែមានប្រសិទ្ធិភាពនៅក្នុងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បច្ចុប្បន្ន។ ការធ្វើដូចនេះ កំណែទម្រង់បច្ចុប្បន្ននឹងឆ្លើយតបកាន់តែប្រសើរ ទៅនឹងសេចក្តីត្រូវការសង្គមរបស់ប្រជាពលរដ្ឋកម្ពុជា។

ការសិក្សានេះ បានពិគ្រោះយោបល់យ៉ាងផុសផុលជាមួយនឹងក្រុមគោលដៅមួយចំនួនដូចជា: ប្រជាពលរដ្ឋនៅជនបទ ស្ត្រី និងជនជាតិដើមភាគតិច។ លើសពីនេះ យើងបានពិគ្រោះយោបល់ជាមួយមន្ត្រី និងអតិថិជន (ភាគីវិវាទ) ដែលធ្លាប់ប្រើប្រាស់យន្តការដោះស្រាយវិវាទ ក្រៅប្រព័ន្ធតុលាការ (គណៈកម្មការសុរិយោដី និងក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ) មេភូមិ និងសមាជិកក្រុមប្រឹក្សាឃុំ នគរបាល និងចៅក្រម ព្រមទាំងចាស់ទុំនៅក្នុងសហគមន៍ជនជាតិដើមភាគតិច អង្គការក្រៅរដ្ឋាភិបាល ទីភ្នាក់ងារអន្តរជាតិ និងអ្នកពាក់ព័ន្ធនឹងកំណែទម្រង់ផងដែរ។

ដំណើរការនៃការរៀបចំអនុវត្ត ត្រួតពិនិត្យ សរសេររបាយការណ៍ និងធ្វើសុពលភាពនៃការសិក្សាស្រាវជ្រាវ នេះត្រូវបានធ្វើឡើងដោយមានការចូលរួម។ សមាជិកនៃស្ថាប័នដៃគូនៃការសិក្សាស្រាវជ្រាវនេះ (ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្រសួងយុត្តិធម៌ និងអង្គការ UNDP ប្រចាំនៅកម្ពុជា) ក៏ដូចជាអ្នកពាក់ព័ន្ធផ្សេងទៀត បានមានឱកាសចូលរួមចំណែក និងរៀនសូត្រតាមរយៈដំណើរការនេះ។

បទពិសោធន៍ទទួលបាន:

ជាដំបូង សិក្ខាសាលានៅថ្នាក់មូលដ្ឋានគួរត្រូវធ្វើឡើង សម្រាប់ក្រុមគោលដៅប្រហាក់ប្រហែលគ្នាដូចជា ស្ត្រី ជនជាតិដើមភាគតិច ជនជាតិភាគតិច។ល។ តែសម្រាប់ជនជាតិដើមភាគតិច និងជនជាតិភាគតិច ការរៀបចំសិក្ខាសាលាបែបនេះគួរត្រូវធ្វើឡើងជាភាសារបស់ពួកគេ។ បន្ទាប់មកសិក្ខាសាលាអាចធ្វើឡើងដោយមានការចូលរួមចំរុះគ្នា រួមទាំងវត្តមានរបស់អាជ្ញាធរដែនដីនៅមូលដ្ឋាន និងជាបន្តបន្ទាប់អាចរៀបចំឱ្យមានសិក្ខាសាលាថ្នាក់តំបន់ ឬថ្នាក់ជាតិ។ លើសពីនេះក៏ចាំបាច់ផងដែរក្នុងការរៀបចំឱ្យមានសិក្ខាសាលានៅថ្នាក់ជាតិសម្រាប់តែស្ត្រី ឬជនជាតិដើមភាគតិច ហើយបន្ទាប់មកជាមួយអ្នកពាក់ព័ន្ធនានា។ ដើម្បីឱ្យ "ការចូលរួម" មានន័យ គឺតម្រូវឱ្យមានការបង្កើនសមត្ថភាព និងផ្តល់អំណាចដល់ក្រុមជនដែលងាយរងគ្រោះបំផុតជាមុនសិន។

ការសិក្សានេះផ្អែកលើព័ត៌មានទិន្នន័យ និងផ្អែកលើការសិក្សាវិភាគ

ការសិក្សានេះផ្អែកលើព័ត៌មានទិន្នន័យ និងផ្អែកលើការសិក្សាវិភាគ រួមទាំងការចុះស្រាវជ្រាវដល់មូលដ្ឋាន (ទស្សនកិច្ចសិក្សា) និងសិក្សាវិភាគលើករណីជាក់ស្តែងមួយចំនួនផងដែរ។ ដោយពេលវេលាមានកម្រិតសម្រាប់ការស្រាវជ្រាវនេះ វាមិនបានក្លាយជាការស្រាវជ្រាវ ដែលមានលក្ខណៈជាជាតិពន្ធុសាស្ត្រទេ។ តែទោះយ៉ាងណាក្តី ការសិក្សានេះបានទទួលនូវព័ត៌មាន និងទិន្នន័យសំខាន់ៗពីមូលដ្ឋាន និងស្ថាប័ននានា។ របាយការណ៍នេះយោងយ៉ាងខ្លាំង ទៅលើព័ត៌មានទាំងនោះ។ ដំណើរការពិគ្រោះយោបល់ និងការប្រមូលឯកសារសរសេរ អាចធ្វើទៅបានដោយសារកិច្ចសហការនៃស្ថាប័នរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន ម្ចាស់ជំនួយអន្តរជាតិ មជ្ឈមណ្ឌល ឬអង្គការនានាដែលធ្វើការទាក់ទងនឹងការស៊ើបអង្កេត អ្នកសិក្សានានា អ្នកចូលរួមក្នុងសិក្ខាសាលា និងអ្នកផ្តល់បទសម្ភាសន៍។

## ២.៥. វិធីសាស្ត្រ និងឧបករណ៍ដែលបានប្រើប្រាស់សម្រាប់ការសិក្សា

ការស្រាវជ្រាវនេះរួមបញ្ចូលទាំងវិធីសាស្ត្រផ្សេងៗទៀតដូចខាងក្រោម :

ការសិក្សាវិភាគលើឯកសារដែលមានស្រាប់

យើងបានប្រមូល និងវិភាគឯកសារដែលមានពាក់ព័ន្ធនឹងប្រធានបទនៃការសិក្សានេះ។ ឯកសារនេះរួមមានៈ ច្បាប់ ការសិក្សាស្រាវជ្រាវនានា របាយការណ៍ស្ថិតិផ្លូវការ ការស្ទង់មតិ ដំណើរការសិក្ខាសាលា និងគម្រោងនានា។ យើងបានអានសៀវភៅ ទស្សនាវដ្តី ឯកសារ និងរបាយការណ៍ផ្សេងៗទៀត ដែលជាសេចក្តីព្រាង ឬជាឯកសារមិនទាន់បោះពុម្ពជាផ្លូវការ (grey-literature) ហើយនិងឯកសារអេឡិចត្រូនិច ជាច្រើនទៀត (digital information) ។

ការស្ទង់មតិ

ការស្ទង់មតិត្រូវបានធ្វើឡើងជាផ្នែកមួយនៃការស្រាវជ្រាវនៅថ្នាក់មូលដ្ឋាន ដោយយកចិត្តទុកដាក់សំខាន់ទៅលើក្រុមគោលដៅចំនួន ៥: ១- តួអង្គប្រតិបត្តិក្នុងប្រព័ន្ធយុត្តិធម៌ផ្លូវការ ដូចជាចៅក្រម មេធាវី និងនគរបាល ២- អាជ្ញាធរមូលដ្ឋាន ដូចជាមេភូមិ និងសមាជិកក្រុមប្រឹក្សាឃុំ ៣- មន្ត្រីទទួលបន្ទុកដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងអតិថិជន (គណៈកម្មការស៊ីវិលយោជិ និងក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ) ៤- ស្ត្រី និង ៥- ជនជាតិដើមភាគតិច។ ការស្ទង់មតិនេះត្រូវបានធ្វើឡើងនៅក្នុងខេត្តចំនួន ៤ គឺ: កំពង់ឆ្នាំង កំពង់ស្ពឺ មណ្ឌលគិរី និងសៀមរាប។ ក្រុមហ៊ុន Indochina Research Ltd. (IRL) បានទទួលបេសកកម្មពី អង្គការ UNDP ក្នុងការធ្វើកិច្ចការនេះ។ IRL បានរៀបចំបញ្ជីសំណួរចំនួន៥ ជាភាសាខ្មែរនិងអង់គ្លេស។ អ្នកសម្ភាសន៍និយាយភាសាខ្មែរដើរប្រមូលព័ត៌មានពីមូលដ្ឋាន។ បន្ទាប់មកត្រូវបានបកប្រែ និងចងក្រងរៀបចំជាភាសាអង់គ្លេស តាមរយៈប្រព័ន្ធទិន្នន័យ (web-data)។ របាយការណ៍ចុងក្រោយមានជាភាសាអង់គ្លេស និងភាសាខ្មែរ។ យោងតាមប្រធានបទនៃបញ្ហាលទ្ធផលនេះ មានអត្ថប្រយោជន៍សម្រាប់បង្ហាញ ដើម្បីផ្ទៀងផ្ទាត់នឹងព័ត៌មានដែលទទួលបានពីប្រភព និងវិធីផ្សេងទៀត។ ការអង្កេតនេះបានផ្តល់បទពិសោធន៍ ដែលត្រូវរៀនសូត្រជាច្រើន។

បទពិសោធន៍ទទួលបានៈ

ក. ការចាប់ផ្តើមសិក្សាស្រាវជ្រាវនេះបានចង្អុលបង្ហាញ និងផ្អែកលើគោលគំនិត "ប្រព័ន្ធយុត្តិធម៌ផ្លូវការ និងក្រៅផ្លូវការ" ដើម្បីជាមូលដ្ឋានក្នុងការរៀបចំសំនួរ និងចម្លើយសម្រាប់ការសិក្សា។ និយាយអំពី "ប្រព័ន្ធផ្លូវការ" គឺរួមបញ្ចូលទាំង ចៅក្រម ព្រះរាជអាជ្ញា និងនគរបាល។ ហើយ "ប្រព័ន្ធក្រៅផ្លូវការ" គឺរាប់បញ្ចូលទាំងយន្តការដោះស្រាយវិវាទក្រៅតុលាការ អាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរ ជនជាតិដើមភាគតិច (ចាស់ទុំ)។ ទ្រឹស្តីក្នុងន័យ

ទូលាយនេះ បែរជានាំឱ្យមានការភាន់ច្រលំ និងមានការយល់ច្រលំជាច្រើន [៦៤]។ ក្រុមការងារសិក្សាស្រាវជ្រាវយើងខ្ញុំ មិនលើកទឹកចិត្តឱ្យមានការបែងចែកបែបនេះសម្រាប់ការសិក្សាផ្សេងៗទៀតនៅពេលអនាគតឡើយ។ ឧទាហរណ៍ នគរបាលបានជួយដល់ភាគីវិវាទសម្រុះសម្រួលក្នុងរឿងព្រហ្មទណ្ឌជាច្រើន ដែលតាមច្បាប់ការសម្រុះសម្រួល ទាំងនេះគឺត្រូវហាមឃាត់ដាច់ខាត តែការអនុវត្តរបស់នគរបាលក្នុងន័យនេះ គឺមានន័យថា "ក្រៅផ្លូវការ"។ ដូចនេះ ការដែលប្រជាពលរដ្ឋប្ដឹងទៅនគរបាល មិនមែនសុទ្ធតែមានន័យថាប្ដឹងទៅ "ស្ថាប័នយុត្តិធម៌ផ្លូវការ" ឡើយ ដោយយើងពិចារណាអំពីការយល់ឃើញរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានថា "ក្រៅផ្លូវការ"។

ខ. ការសិក្សាបានកំណត់ចំណាត់ថ្នាក់ជនជាតិដើមភាគតិច និងជនជាតិភាគតិចឬអន្តោប្រវេសន៍ ជាក្រុមតែមួយ។ តែយើងមិនលើកទឹកចិត្តឱ្យធ្វើដូចនេះ សម្រាប់ការសិក្សាផ្សេងៗទៀតឡើយ ព្រោះជនជាតិដើមភាគតិចជាទូទៅ គេមានអាជ្ញាធររបស់ពួកគេ និងមាននីតិវិធីក្នុងការដោះស្រាយវិវាទផ្ទាល់ សម្រាប់សហគមន៍របស់ពួកគេ ហើយមានដែនដីកំណត់មួយជាក់លាក់។ តែផ្ទុយទៅវិញអ្វីៗទាំងនេះពុំមានទេសម្រាប់ជនជាតិភាគតិច (ដូចជា វៀតណាម ចិន ចាម។ល។) ពួកគេពុំមានអាជ្ញាធរផ្ទាល់ខ្លួនរបស់ពួកគេទេ តែជនជាតិដើមភាគតិចមាន ដូចនេះ ហើយពួកគេប្រហែលជាមានទស្សនៈឬការយល់ឃើញ និងអនុសាសន៍ខុសប្លែកពីគ្នាទាក់ទិននឹងយន្តការដោះស្រាយវិវាទនៅមូលដ្ឋាន។ ឧទាហរណ៍មួយផ្សេងៗទៀតគឺពាក់ព័ន្ធនឹង "ច្បាប់ជនជាតិដើមភាគតិច" ដែលតែងមានការយល់ច្រលំគ្នាជាមួយនឹង "សិទ្ធិរបស់ជនជាតិភាគតិចឬអន្តោប្រវេសន៍"។ ជនជាតិភាគតិចមានសិទ្ធិជាក់លាក់មួយចំនួនដូចជាការប្រើប្រាស់ភាសា និងវប្បធម៌ តែពួកគេពុំមានសិទ្ធិសមូហភាពទៅលើដីរួម ឬអាជ្ញាធរប្រពៃណីឡើយ (រីឯជនជាតិដើមភាគតិចមានសិទ្ធិទាំងនេះ)។

គ. យើងខ្ញុំក៏មិនលើកទឹកចិត្តឱ្យដាក់បញ្ចូលគ្នា រវាងប្រភេទស្ថាប័នដោះស្រាយវិវាទក្រៅតុលាការ ដែលបង្កើតឡើងដោយច្បាប់ (ដូចជាគណៈកម្មការសុរិយោដី ឬក្រុមប្រឹក្សាអាជ្ញាកណ្ដាល) ជាមួយគ្នានឹងអាជ្ញាធរមូលដ្ឋានដែរ។ ព្រោះស្ថាប័នទាំងពីរនេះខុសគ្នា ក្នុងន័យការទទួលស្គាល់ដោយច្បាប់សកម្មភាព ប្រភេទរឿងក្ដីដែលស្ថាប័ននីមួយៗត្រូវដោះស្រាយ និងលទ្ធផលដែលទទួលបាន។

ឃ. នៅក្នុងការធ្វើការស្ទាបស្ទង់មតិ យើងខ្ញុំលើកទឹកចិត្តឱ្យបញ្ចូលសំនួរមានលក្ខណៈទូលាយទាក់ទងនឹង "បញ្ហាចម្បងៗដែលពួកគេប្រឈម" ហើយមិនត្រូវផ្ដោតតែទៅលើ "វិវាទ" ឬ "ជម្លោះ" នោះទេ។ ភាគច្រើននៃការស្ទាបស្ទង់មតិសម្រាប់ការសិក្សាក្នុងវិស័យនេះ ច្រើនតែផ្ដោតទៅលើវិវាទដែលកើតមានរវាងប្រជាពលរដ្ឋ ដែលនាំឱ្យមានការចន្លោះប្រហោងយ៉ាងខ្លាំងអំពីអ្វីដែលជាតម្រូវការយុត្តិធម៌ក្នុងសង្គម ដូចជាអំពើពុករលួយ ឬការរំលោភសិទ្ធិបុគ្គល ឬសិទ្ធិសង្គម ឬសក្ដានុពល នៃតម្រូវការយុត្តិធម៌។ នៅក្នុងការសិក្សានេះ សំនួរដែលមានលក្ខណៈទូលាយត្រូវបានបញ្ចូល ហើយការបញ្ចូលនូវសំនួរទូលាយបែបនេះ អាចឱ្យមានការយល់កាន់តែប្រសើរឡើងអំពីតម្រូវការរបស់សង្គម (ភាពក្រីក្រ អំពើពុករលួយ ។ល។) ទោះជាយ៉ាងនេះក្ដី នៅក្នុងការស្ទង់មតិ មានតែស្ត្រីដែលមានបញ្ហាប្រឈមពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារទេ ដែលត្រូវបានសាកសួរ។ តែសំនួរនោះមិនបានបញ្ចូលជាសក្ដានុពលភាព នៃបញ្ហាសម្រាប់ក្រុមគោលដៅផ្សេងៗទៀតឡើយ។ យោងតាមសិក្ខាសាលា និងប្រភពដទៃៗទៀតបញ្ជាក់ថា អំពើហិង្សាក្នុងគ្រួសារត្រូវបានគេចាត់ទុកថាជាបញ្ហាមួយក្នុងចំណោមបញ្ហាដ៏ធ្ងន់ធ្ងរជាងគេនៅក្នុងប្រទេសជាមួយនិងបញ្ហាដីធ្លី។

---

៦៤ ការបែងចែកបែបនេះ ក៏បានប្រើប្រាស់ផងដែរនៅក្នុងឯកសារ "UNDP Asia Pacific, 2005" តែក្រុមការងារសិក្សាស្រាវជ្រាវយើងខ្ញុំ មិនលើកចិត្តឱ្យប្រើការបែងចែកបែបនេះឡើយ ព្រោះអាចមានការយល់ច្រលំច្រើន។

ង. ចាំបាច់ត្រូវមានការសិក្សាស្រាវជ្រាវជាបឋម ដោយផ្តោតសំខាន់លើក្រុមគោលដៅ មុននឹងចាប់ផ្តើមធ្វើការស្ទាបស្ទង់មតិណាមួយ ដើម្បីផ្ទៀងផ្ទាត់រាល់ការសន្និដ្ឋានទាំងឡាយតាមរយៈសំនួរ ដែលប្រើប្រាស់នៅក្នុងការស្ទាបស្ទង់មតិ (ឧទាហរណ៍ សាកសួរអំពីប្រភេទនៃប្រព័ន្ធយុត្តិធម៌ផ្លូវការ និងក្រៅផ្លូវការជាដើម)។

បទសម្ភាសន៍

កិច្ចសម្ភាសន៍ជាចំហជាច្រើនត្រូវបានធ្វើឡើងក្នុងគោលបំណង ដើម្បីទទួលបានព័ត៌មានចាំបាច់ពីអាជ្ញាធរមូលដ្ឋាន (ឃុំ/ភូមិ/សហគមន៍ជនជាតិដើមភាគតិច) អ្នកដឹកនាំអង្គការនៅមូលដ្ឋាន ស្ត្រី មន្ត្រីរាជការ (ចៅក្រម ព្រះរាជអាជ្ញា មេធាវី នគរបាល) មន្ត្រីទទួលបន្ទុកដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងអាជ្ញាកណ្តាល ព្រមទាំងភាគីដែលពាក់ព័ន្ធក្នុងរឿងក្តីនៅតុលាការ នៅក្រៅប្រព័ន្ធតុលាការ នៅអាជ្ញាធរមូលដ្ឋាន និងនៅប្រព័ន្ធដោះស្រាយវិវាទរបស់ជនជាតិដើមភាគតិច។ យើងក៏បានសម្ភាសជាមួយតំណាងអង្គការក្រៅរដ្ឋាភិបាល អ្នកស្រាវជ្រាវ អ្នកមានប្រយោជន៍ពាក់ព័ន្ធ អ្នកផ្តល់ជំនួយ និងអ្នកពាក់ព័ន្ធដទៃៗទៀត។ ភាគច្រើននៃការធ្វើសម្ភាសន៍ នេះត្រូវបានថតទុក និងសរសេរកំណត់ហេតុនៃបទសម្ភាសន៍ជាលាយលក្ខណ៍អក្សរទាំងភាសាអង់គ្លេសនិងខ្មែរ។ កិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងនៅខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ មណ្ឌលគិរី សៀមរាប កំពង់ធំ បន្ទាយមានជ័យ ឧត្តរមានជ័យ រតនគិរី និងភ្នំពេញ[៦៥] ។

បមពិសោធន៍ទទួលបាន:

- យើងចាំបាច់ត្រូវធ្វើបទសម្ភាសន៍ឱ្យបានកាន់តែច្រើនជាមួយស្ត្រី និងជនជាតិដើមភាគតិច។

ការចុះទស្សនកិច្ចសិក្សា និងករណីសិក្សា

ទោះបីការសិក្សានេះមិនមែនជាជាតិពន្ធុសាស្ត្រដោយខ្លួនឯងក៏ដោយ តែវាបានផ្អែកលើគោលការណ៍ មួយចំនួនស្តីពីជាតិពន្ធុសាស្ត្រ។ ការសិក្សានេះគឺរួមទាំងការចុះស្រាវជ្រាវនៅខេត្តចំនួន ៨ ក្នុងកម្រិតស៊ីជម្រៅខុសៗគ្នា។ ទស្សនកិច្ចសិក្សាដែលធ្វើនៅក្រៅក្រុងភ្នំពេញ មានរយៈពេលពីមួយសប្តាហ៍ទៅដល់ស្ទើរតែមួយខែ។ ការស្នាក់នៅ និងប្រមូលព័ត៌មានរយៈពេលយូរធ្វើនៅខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ មណ្ឌលគិរី និងសៀមរាប។ ការស្នាក់នៅរយៈពេលខ្លី ដោយមិនបានធ្វើការស្ទង់មតិធ្វើឡើងនៅខេត្ត កំពង់ធំ បន្ទាយមានជ័យ ឧត្តរមានជ័យ និងរតនគិរី។ ការប្រមូលទិន្នន័យ និងការសម្ភាសន៍ខ្លះ ក៏ត្រូវបានធ្វើផងដែរនៅភ្នំពេញ។ ការចុះទស្សនកិច្ចសិក្សារួមមាន: ក- ការចុះទៅដល់ភូមិនិងឃុំ ខ- កិច្ចសម្ភាសន៍ជាមួយតុលាការ មន្ត្រីរដ្ឋាភិបាល និងមន្ត្រីទទួលបន្ទុកដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ អាជ្ញាធរមូលដ្ឋាន និងចាស់ទុំ គូភាគីវិវាទ មេធាវី និងអង្គការក្រៅរដ្ឋាភិបាល គ- ការសង្កេតមើលការសម្រុះសម្រួល ឬការជម្រះរឿងក្តី និង ឃ- ការប្រមូលនូវឯកសារគ្រប់ប្រភេទ ដូចជារបាយការណ៍របស់តុលាការ ដំណើរការសម្រុះសម្រួល និងកិច្ចសន្យាព្រមព្រៀងជាដើម។ យើងបានប្រមូលសៀវភៅរបស់ ក្រុមប្រឹក្សាឃុំមួយចំនួនដែលបានកត់ត្រាពាក្យបណ្តឹង កំណត់ហេតុសម្រុះសម្រួល និងកិច្ចសន្យាព្រមព្រៀងរវាងគូភាគី។ រឿងក្តីដែលយើងបានសង្កេតបានជួយយើងឱ្យមានគំនិតពីដំណើរការពេលវេលា អាកប្បកិរិយារបស់គូភាគី និងលទ្ធផលនៃការដោះស្រាយ។ យើងមិនបានសង្កេតរឿងក្តីច្រើនទេ ហើយក៏មិនបានធ្វើសម្ភាសន៍តាមដានបន្តទៅលើការអនុវត្តដំណោះស្រាយ ឬកិច្ចសន្យាដែលភាគីបានព្រមព្រៀងនោះដែរ។ តែទោះជាយ៉ាងនេះក្តី ការសង្កេតដោយផ្ទាល់នូវរឿងក្តីមួយចំនួន ការសម្ភាសន៍ផ្សេងៗ និងការសិក្សាលើកិច្ចសន្យាព្រមព្រៀងគ្នាបានផ្តល់ នូវព័ត៌មានផ្ទាល់ដល់យើងពីការដោះស្រាយវិវាទនៅមូលដ្ឋាន។

៦៥ សូមមើលតារាងអ្នកដែលក្រុមការងារបានសម្ភាសក្នុងឧបសម្ព័ន្ធទី ៣ ។

បទពិសោធន៍ទទួលបាន:

ក. ការសិក្សានេះ បានបញ្ជាក់គាំទ្រពីសារៈសំខាន់នៃគោលការណ៍ជាតិពន្ធ ដែលត្រូវយកមកអនុវត្ត។

ខ. ចាំបាច់ត្រូវប្រើពេលឱ្យបានវែងជាងនេះនៅក្នុងវិស័យនីមួយៗ ដើម្បីតាមដានពី : ១). ដំណើរវិវឌ្ឍន៍នៃវិវាទនៅមូលដ្ឋានរហូតដល់ចុងបញ្ចប់នៃវិវាទ ២). វិវាទដែលមានរយៈពេលវែងទាក់ទិន នឹងវិវាទដីធ្លីធំៗ និងវិវាទការងារ ក៏ដូចជាអំពើហិង្សាក្នុងគ្រួសារ ៣). ការដោះស្រាយ និងទស្សនៈ អំពីអំពើពុករលួយដែលមាននៅក្នុងជីវិតរស់នៅជាប្រចាំ និងអំពើពុករលួយទ្រង់ទ្រាយធំ និង ៤). ទស្សនៈអំពីការរំលោភសិទ្ធិមនុស្ស ជាពិសេសទាក់ទងនឹងសិទ្ធិសង្គម ដូចជាខ្វះសេវាអប់រំ និង សុខាភិបាល ដោយហេតុផលនៃអំពើពុករលួយ។

គ. យើងមិនបានសង្កេតមើលដំណើរការដោះស្រាយវិវាទ ដែលធ្វើឡើងដោយនគរបាលឡើយ តែវាជាការមួយល្អប្រសើរណាស់បើសិនជាអាចធ្វើទៅបាន។

ឃ. ជាការមួយប្រពៃ និងមានសារៈសំខាន់ណាស់បើអាចប្រៀបធៀប "រឿងក្តីដែលបានចុះបញ្ជី" ជាមួយនឹង "រឿងក្តីទាំងឡាយដែលមិនបានចុះបញ្ជី" នៅពេលដោះស្រាយដោយអាជ្ញាធរមូលដ្ឋាន។

ង. ជាការមួយមានប្រយោជន៍ច្រើន បើសិនជាមានការសិក្សាស្រាវជ្រាវមួយអំពីជាតិពន្ធ ដើម្បីគ្របដណ្តប់លើៈជនជាតិដើមភាគតិចដោយស៊ីជម្រៅ ប្រជាពលរដ្ឋនៅទីប្រជុំជន បញ្ហាបងធំនៅក្នុងសង្គម និងបញ្ហារបស់ជនជាតិភាគតិច (ជាពិសេសជនជាតិវៀតណាម និងជនជាតិភាគតិចដទៃៗទៀត)។

សិក្ខាសាលាពិគ្រោះយោបល់

ការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ចំនួន ៣ នៅថ្នាក់មូលដ្ឋាន និងចំនួន ១ នៅថ្នាក់ជាតិបានក្លាយជាផ្នែកមួយចម្បងនៃវិធីសាស្ត្រស្រាវជ្រាវ។ សិក្ខាសាលាថ្នាក់ជាតិបានជួយឱ្យយើងអាចចងក្រងនូវព័ត៌មាន ដែលទទួលបាននៅឯសិក្ខាសាលានៅមូលដ្ឋាន និងធ្វើឱ្យក្លាយទៅជា "ទស្សនៈថ្នាក់ជាតិ" លើបញ្ហានានាដែលបានរកឃើញតាមរយៈការសិក្សានេះ។ សិក្ខាសាលាថ្នាក់ជាតិក៏អាចអនុញ្ញាតឱ្យយើងបានពិភាក្សាពីសំណូមពរ ដ៏ទូលំទូលាយដែលបានលើកឡើងជាអនុសាសន៍នៅថ្នាក់មូលដ្ឋាន។ សរុបទៅមានប្រជាពលរដ្ឋប្រហែល ៤០០នាក់ ដែលបានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់នេះ។ សិក្ខាសាលាមានអត្ថប្រយោជន៍សម្រាប់ : ក- ទទួលព័ត៌មានពីអ្នកចូលរួម ខ- ផ្តល់ឱ្យពួកគេនូវព័ត៌មាន និងផ្តល់អំណាចឱ្យពួកគេដើម្បីចូលរួមក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌បច្ចុប្បន្ន និង គ- ពិភាក្សា និងធ្វើសំណូមពរ និងអនុសាសន៍។

បទពិសោធន៍ទទួលបាន:

ក. ចាំបាច់ត្រូវមានសិក្ខាសាលាដំបូង នៅថ្នាក់មូលដ្ឋានជាមួយនឹងក្រុមគោលដៅប្រហាក់ប្រហែលគ្នា ដូចជាស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច។ល។ ដោយប្រើប្រាស់ភាសារបស់ពួកគេ ហើយបន្ទាប់មកទើបធ្វើសិក្ខាសាលាដោយមានការចូលរួមរបស់អាជ្ញាធរ។

ខ. វត្តមានរបស់អាជ្ញាធរនៅក្នុងសិក្ខាសាលាក្រោម "ជំហរអព្យាក្រឹត" រៀបចំដោយអង្គការសហប្រជាជាតិ ដើម្បីអនុញ្ញាតឱ្យមានឱកាសសម្រាប់ប្រជាពលរដ្ឋ អាចចោទសួរដល់អាជ្ញាធរទាំងនោះដោយផ្ទាល់ ដោយហេតុថាប្រជាពលរដ្ឋមានឱកាសតិច ឬស្ទើរតែគ្មានឱកាសដើម្បីធ្វើដូច្នោះ។ ប្រជាពលរដ្ឋអាចឆ្លៀតយកឱកាស ដែលមានវត្តមានអាជ្ញាធរនេះ ដើម្បីស្វែងយល់អំពីការធ្វើសេចក្តីសម្រេច លើករណីជាក់លាក់ណាមួយ ក៏ដូចជាបញ្ញត្តិច្បាប់នានា។ ការអនុវត្តលទ្ធិប្រជាធិបតេយ្យនេះ បង្ហាញអំពីសារៈសំខាន់នៃការរៀបចំឱ្យមានគោលការណ៍កាន់តែវែងឆ្ងាយ និងមានជាស្ថាប័នសម្រាប់ឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋជាមួយអាជ្ញាធរ ដើម្បីធានា

នូវសិទ្ធិទទួលបានយុត្តិធម៌ និងដោះស្រាយបញ្ហាផ្សេងៗ។ វេទិកាបែបនេះក៏ជាឱកាសមួយសម្រាប់ពលរដ្ឋ ដើម្បីទាមទារឱ្យមានគណនេយ្យភាពពីអាជ្ញាធរ។ នេះក៏ជាឱកាសដើម្បីសហការគ្នាដោះស្រាយបញ្ហានៅមូលដ្ឋាន និងបង្កើននូវតម្លាភាពក្នុងវិស័យរដ្ឋបាលសាធារណៈ។

គ. សិក្ខាសាលាទាំងឡាយបញ្ជាក់យ៉ាងច្បាស់ អំពីសារៈសំខាន់ក្នុងការផ្ដល់ព័ត៌មាននានា ទាក់ទងនឹងសិទ្ធិមនុស្សចំពោះអ្នកចូលរួមក្នុងសិក្ខាសាលា ដើម្បីឱ្យពួកគេអាចកសាងបទពិសោធន៍របស់គេ និងលើកជាសំណូមពរឱ្យកាន់តែប្រសើរ។ យើងមិនត្រូវរៀបចំសិក្ខាសាលា ដើម្បីគ្រាន់តែប្រមូលយកព័ត៌មានពីក្រុមគោលដៅដោយចាត់ទុកពួកគេជា "កម្មវត្ថុ" នៃការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះទេ គឺយើងត្រូវចាត់ទុកពួកគេថាជា "ប្រធាន" នៃការសិក្សាស្រាវជ្រាវ ដោយអនុញ្ញាតឱ្យ ពួកគេអាចចូលរួមក្នុងដំណើរការពិគ្រោះយោបល់ផងដែរ។

ឃ. រៀបចំឱ្យមានឯកសារ និងឧបករណ៍សម្រាប់ប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ជាពិសេស ត្រូវមានឧបករណ៍ដែលអាចមើលឃើញនិងងាយយល់សម្រាប់អ្នកមិនចេះអក្សរមួយចំនួនដូចជាមនុស្សចាស់ៗ និងស្ត្រី ។ល។

## ការកែសម្រួល និងធ្វើសុពលភាព

មានយន្តការច្បាស់លាស់នៃការធ្វើឱ្យមានសុពលភាព លើរបាយការណ៍នៅក្នុងដំណាក់កាលផ្សេងៗនៃការសិក្សាស្រាវជ្រាវនេះ។ ឧទាហរណ៍ ការវាយតម្លៃនិងការកែសម្រួលនៃការសិក្សាស្រាវជ្រាវ ត្រូវបានធ្វើឡើងដោយមានការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយស្ថាប័នដៃគូនិងអ្នកពាក់ព័ន្ធ។ យន្តការធ្វើឱ្យមានសុពលភាពបានធ្វើឡើងជាច្រើនលើកក្នុងដំណើរការសិក្សាស្រាវជ្រាវ ដូចជា : ក- ក្រោយការបង្ហាញគម្រោងនៃសិក្សានៅក្នុងខែមិថុនា ឆ្នាំ២០០៤ (សម្រាប់ផ្ទៃក្នុង) ខ- ក្រោយសិក្ខាសាលានីមួយៗ និងទស្សនកិច្ចនៅមូលដ្ឋាន (ខែវិច្ឆិកា-ធ្នូ ឆ្នាំ ២០០៤) គ- នៅចុងវគ្គទីមួយនៃការចុះស្រាវជ្រាវនៅខែធ្នូ ២០០៤ (មានការចូលរួមជាមួយអ្នកពាក់ព័ន្ធ) ឃ- នៅចុងបញ្ចប់នៃការចងក្រងឯកសារ និងសេចក្ដីព្រាងដំបូងនៃលទ្ធផលនៃការសិក្សាក្នុងខែមេសា ឆ្នាំ២០០៥ (សម្រាប់ផ្ទៃក្នុង) និងខែឧសភា ២០០៥ (ជាមួយដៃគូ) ង- និងដំណើរការសរសេររបាយការណ៍ទាំងមូលជាមួយស្ថាប័នដៃគូ (ខែឧសភា-មិថុនា ២០០៥) ហើយ ច- នៅចុងបញ្ចប់នៃការស្រាវជ្រាវ ក្នុងខែមិថុនា ២០០៥ (ជាមួយអ្នកពាក់ព័ន្ធ និងអ្នកចូលរួមសិក្ខាសាលា)។ ក្រោយដំណើរការនៃការធ្វើឱ្យមានសុពលភាពនីមួយៗ តែងមានការកែសម្រួលឡើងវិញ ដើម្បីបញ្ចូលលទ្ធផលបានមកពីដំណើរការធ្វើសុពលភាព។

## បទពិសោធន៍ទទួលបាន:

ក. ការផ្ដល់សុពលភាពមានសារៈសំខាន់ណាស់ ដោយហេតុថា មានអ្នកចូលរួមជាច្រើនបានចាប់អារម្មណ៍ និងបញ្ចេញនូវទស្សនៈរបស់ពួកគេ ដើម្បីរួមចំណែកកែលំអរបាយការណ៍ និងលទ្ធផលដែលរកឃើញ។

ខ. វានឹងអាចមានប្រយោជន៍កាន់តែច្រើន និងមានសារៈសំខាន់ បើសិនជាយើងអាចរៀបចំឱ្យមានការធ្វើសុពលភាពពីថ្នាក់មូលដ្ឋានផងដែរនោះ។

| | |
|---|---|
| **៤.១. គម្រោងសិក្សាស្រាវជ្រាវជាទូទៅ** | ក. គ្របដណ្តប់ទូលំទូលាយ : រាប់ចាប់ពីតម្រូវការយុត្តិធម៌របស់សង្គម រហូតដល់ ការផ្តល់សេវាយុត្តិធម៌<br>ខ. ការសិក្សាស្រាវជ្រាវនេះមានលក្ខណៈទូលាយ តែផ្តោតសំខាន់ទៅលើ អ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច ។<br>គ. ផ្តោតសំខាន់ទៅលើបញ្ហា និងសំណូមពរនាពេលបច្ចុប្បន្ន ។<br>ឃ. ប្រើវិធីសាស្ត្រសិក្សាស្រាវជ្រាវដោយមានការចូលរួម |
| **៤.២. វិធីសាស្ត្រ** ផ្អែកលើទិន្នន័យ និងការសិក្សាវិភាគ | ក. វិភាគ និង សិក្សាឯកសារដែលមានស្រាប់ ។<br>ខ. ស្ទង់មតិ : នៅខេត្តចំនួន ៤ គឺខេត្តកំពង់ឆ្នាំង ខេត្តមណ្ឌលគិរី ខេត្តកំពង់ស្ពឺ និងខេត្តសៀមរាប ដែលការស្ទង់មតិនេះ ធ្វើឡើងដោយ Indochina Research Ltd.<br>គ. ការសម្ភាសន៍ដោយជ្រើសរើស នៅខេត្តចំនួន ៨ រួមទាំងក្រុងភ្នំពេញ ។<br>ឃ. ទស្សនកិច្ចសិក្សា និងករណីសិក្សានៅខេត្តចំនួន ៨ ។ ការធ្វើទស្សនកិច្ចសិក្សានៅតាមខេត្តនានា មានរយៈពេលពី ១សប្តាហ៍ ដល់ ជិត១ ខែ ។ (ក) ខេត្តដែលក្រុមការងារស្នាក់នៅយូរ និងធ្វើស្ទង់មតិៈ ខេត្តកំពង់ឆ្នាំង ខេត្តមណ្ឌលគិរី ខេត្តកំពង់ស្ពឺ ខេត្តសៀមរាប (ខ) ខេត្តដែលក្រុមការងារបានធ្វើទស្សនកិច្ចរយៈពេលខ្លី : ខេត្តរតនគិរី ខេត្តកំពង់ធំ ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ និង (គ) ការសង្កេតមើលដំណើរការសម្រុះសម្រួល និងដោះស្រាយវិវាទ ការធ្វើសម្ភាសន៍ និងរៀបចំសិក្ខាសាលា ក៏ដូចជាប្រមូលទិន្នន័យនៅក្រុងភ្នំពេញ ។<br>ង. សិក្ខាសាលាពិគ្រោះយោបល់ : សិក្ខាសាលាចំនួន ៣ ត្រូវបានធ្វើឡើង នៅមូលដ្ឋាន នៅខេត្តចំនួនបី គឺខេត្តកំពង់ឆ្នាំង ខេត្តមណ្ឌលគិរី និងខេត្តកំពង់ស្ពឺ ។ បន្ទាប់មកវេទិកាជាតិមួយត្រូវបានធ្វើឡើងនៅថ្នាក់ជាតិក្រុងភ្នំពេញ ។ |
| **៤.៣. ធ្វើសុពលភាព និង ការផ្តល់យោបល់របស់អ្នកពាក់ព័ន្ធ** | ក. ធ្វើសុពលភាពជាមួយដៃគូ អ្នកពាក់ព័ន្ធ និងក្រុមគោលដៅ<br>ខ. ធ្វើការពិនិត្យសារឡើងវិញ<br>គ. ធ្វើការកែសម្រួល |

# ៣. ទិន្នន័យដែលបានប្រើប្រាស់

## ៣.១. ប្រភពទិន្នន័យនៃសកម្មភាពសិក្សាស្រាវជ្រាវ

គម្រោងការស្រាវជ្រាវ (គម្រោងនៃសិក្សា ឧបករណ៍ និងសេចក្តីណែនាំសម្រាប់ទស្សនកិច្ចសិក្សានៅមូលដ្ឋាន ការស្ទង់មតិ និងសិក្ខាសាលា) ដំណើរការដេញថ្លៃ ដើម្បីជ្រើសរើសស្ថាប័នទទួលបន្ទុកស្ទង់មតិ និងការជ្រើសរើសបុគ្គលិក ត្រូវបានធ្វើឡើងពី ខែឧសភា ដល់ខែសីហា ឆ្នាំ២០០៤ ។

សកម្មភាពភាគច្រើននៃគម្រោងស្រាវជ្រាវត្រូវបានធ្វើឡើងចាប់ពីខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០០៤ រួមទាំងការសិក្សាឯកសារដែលមានស្រាប់ ការស្ទង់មតិនៅខេត្តចំនួន៤ ទស្សនកិច្ចសិក្សាការសម្ភាសន៍ និងសិក្ខាសាលានៅខេត្ត ៣ និងវេទិកាថ្នាក់ជាតិ ១។

របាយការណ៍ដំបូងត្រូវបានព្រាងឡើងនៅពាក់កណ្តាលខែមករា ឆ្នាំ ២០០៥ និងបានកែសម្រួលឡើងវិញ ក្នុងខែមេសា ២០០៥។ រាល់ទិន្នន័យប្រមូលបានត្រូវបានចងក្រងចាប់ពីខែមករា ដល់ខែមិនា ឆ្នាំ ២០០៥ ដោយក្រុមអ្នកស្រាវជ្រាវ។ ក្នុងរយៈពេលនេះក៏មានការសង្កេតមើលដំណើរការដោះស្រាយវិវាទមួយចំនួនផងដែរ។

ទស្សនកិច្ចសិក្សានៅមូលដ្ឋាន និងការសង្កេតមួយចំនួន ត្រូវបានបញ្ចប់សព្វគ្រប់ក្នុងរយៈពេលពីខែ មេសា ដល់ខែមិថុនា ឆ្នាំ ២០០៥។ ក្នុងកំឡុងពេលនេះរបាយការណ៍បញ្ចប់ ត្រូវបានចាប់ផ្តើមសរសេរដោយមានការ ពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធដែលជាដៃគូ។ បន្ទាប់មកមានកិច្ចប្រជុំផ្តល់សុពលភាពមួយជាមួយដៃគូអ្នកពាក់ព័ន្ធនានា និងមានការកែសម្រួលរបាយការណ៍ឡើងវិញជាមួយស្ថាប័នជាដៃគូ។

**តារាងកំណត់ពេលវេលា និងដំណាក់កាលនៃការសិក្សា**

| ដំណាក់កាល | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| **I. រៀបចំគម្រោងនៃសិក្សាស្រាវជ្រាវ និងការរៀបចំ** | ឧសភា-សីហា ២០០៤ | - ល័ក្ខខ័ណ្ឌការងារ (TOR)<br>- សិក្សាឯកសារដែលមានស្រាប់<br>- រៀបចំគម្រោង និង ឯកសារ<br>- ជ្រើសរើសទីប្រឹក្សា (ដំណើរការជ្រើសរើស)<br>- ដេញថ្លៃសម្រាប់ការស្ទង់មតិ |
| **II. ចុះសិក្សានៅមូលដ្ឋានជំហានដំបូង** | កញ្ញា-តុលា ២០០៤ | - បញ្ចប់ការសិក្សាឯកសារដែលមានស្រាប់<br>- ទស្សនកិច្ចសិក្សា ស្រាវជ្រាវនៅខេត្តចំនួន ៣<br>- រៀបចំគម្រោងសម្រាប់ធ្វើការស្ទង់មតិ |
| **III. ទស្សនកិច្ចសិក្សា ចុះស្ទង់មតិ និង សិក្ខាសាលាពិគ្រោះយោបល់** | វិច្ឆិកា-ធ្នូ ២០០៤ | - ទស្សនកិច្ចសិក្សាស្រាវជ្រាវនៅខេត្តចំនួន ៤<br>- ចុះសិក្សានៅខេត្តផ្សេងៗទៀត<br>- រៀបចំសិក្ខាសាលានៅមូលដ្ឋានចំនួន ៣<br>- វេទិកាជាតិ ១ លើក<br>- ចុះស្ទង់មតិនៅខេត្ត ចំនួន ៤<br>- រៀបចំរបាយការណ៍បឋម |
| **IV. ចងក្រងទិន្នន័យ** | មករា-មីនា ២០០៥ | - សង្កេតមើលការដោះស្រាយវិវាទ<br>- សរសេររបាយការណ៍បឋម<br>- រៀបចំរបាយការណ៍សិក្ខាសាលានៅមូលដ្ឋាន និងវេទិកាជាតិ<br>- បកប្រែឯកសារដែលទទួលបានពីមូលដ្ឋាន<br>- ស្រង់ និងសរសេរកំណត់ហេតុកិច្ចសម្ភាសន៍ជាពីរភាសាខ្មែរ និងអង់គ្លេស។ |

| | | |
|---|---|---|
| v. **សរសេររបាយការណ៍បញ្ចប់** | មេសា-កក្កដា ២០០៥ | - បញ្ចប់ការប្រមូលទិន្នន័យ និង ការសម្ភាសន៍<br>- ទស្សនកិច្ចសិក្សាដើម្បីប្រមូលព័ត៌មានបន្ថែមទាក់ទងនឹងជនជាតិដើមភាគតិច<br>- ចងក្រងទិន្នន័យ<br>- សរសេរសេចក្តីព្រាងរបាយការណ៍បញ្ចប់<br>- កែសម្រួលរបាយការណ៍ជាមួយដៃគូ<br>- ធ្វើសុពលភាពរបាយការណ៍ជាមួយអ្នកពាក់ព័ន្ធ<br>- របាយការណ៍បញ្ចប់ចុងក្រោយ |

## ៣.២. ធនធានមនុស្ស

តារាងសង្ខេបពីធនធានមនុស្ស និងអ្នកពាក់ព័ន្ធរួមចំណែក

**ក្រុមការងារមកពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)**

| បុគ្គលិក UNDP | អ្នកទទួលបន្ទុក | រយៈពេល |
|---|---|---|
| បុគ្គលិក UNDP | - លោកស្រី បៀត ត្រាំងមែន ប្រធានផ្នែកអភិបាលកិច្ច<br>- លោកស្រី សារ៉ា ហ្វ៊េរ មន្ត្រីសិទ្ធិមនុស្ស ជាអ្នកទទួលបន្ទុកលើគម្រោងនេះ<br>- លោក សុខ ណារីន , នាយកកម្មវិធី | |
| បុគ្គលិកជួយគាំទ្រ UNDP | - បុគ្គលិក UNDP មកពីផ្នែកសេវាកម្ម ហិរញ្ញវត្ថុ ទំនាក់ទំនង និងដឹកជញ្ជូន | អចិន្ត្រៃយ៍ |
| **ក្រុមសិក្សាស្រាវជ្រាវ UNDP** | | |
| ទីប្រឹក្សាអន្តរជាតិ និងជាអ្នកដឹកនាំការសិក្សា | លោកស្រី រ៉ាកែល រីគូយែន ហ្វាចាដូ | ឧសភា ២០០៤ - កក្កដា ២០០៥ (១៦៨ ថ្ងៃធ្វើការងារ) |
| ទីប្រឹក្សាជាតិ | លោក គង់ រ៉ាឌី | កញ្ញា ២០០៤ - កក្កដា ២០០៥ (១១ ខែធ្វើការងារ) |
| អ្នកបកប្រែ និងជាជំនួយការលើការសិក្សាស្រាវជ្រាវ | លោក ផន ស៊ីន | វិច្ឆិកា ២០០៤ - កក្កដា ២០០៥ (៩ ខែធ្វើការងារ) |

| | | |
|---|---|---|
| ជំនួយការលើការសិក្សាស្រាវជ្រាវ សម្រាប់សិក្ខាសាលា នៅមូលដ្ឋានចំនួន ៣ នាក់ | - លោកស្រី អ៊ួច បូ ខេត្តកំពង់ស្ពឺ<br>- លោកស្រី ពុច ធាវី ខេត្តកំពង់ឆ្នាំង<br>- លោក ឯម វ៉ាសនា ខេត្តមណ្ឌលគិរី | តុលា – ធ្នូ ២០០៤<br>(១៥ ថ្ងៃធ្វើការងារ) |
| អ្នកបើកបរ | លោក ដា វ៉ាសេង | ជួយគាំទ្រគម្រោងសិក្សាជាប្រចាំ |
| ទីប្រឹក្សាប្រចាំការិយាល័យក្នុងតំបន់នៅក្រុងបាងកក | កញ្ញា បាស្ទីយ៉ាត អាផាណា | ជួយគាំទ្រដល់សិក្ខាសាលាថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ |

ស្ថាប័នជាដៃគូ

| ស្ថាប័នជាដៃគូ | ការចូលរួម |
|---|---|
| **ក្រសួងយុត្តិធម៌** | **ដៃគូគម្រោង**<br>ចូលរួមក្នុងសិក្ខាសាលាថ្នាក់មូលដ្ឋានម្តង និងជាដៃគូសហការរៀបចំវេទិកាជាតិ បន្ថែមចំណែកក្នុងដំណើរការធ្វើរបាយការណ៍បញ្ចប់<br>- ឯ.ឧ. ទៅ កាស៊ី រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ |
| **អង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌** | **ដៃគូគម្រោង**<br>**សហការរៀបចំសិក្ខាសាលានៅថ្នាក់មូលដ្ឋាន និងវេទិកាជាតិ**<br>មានអ្នកជំនាញ ១០ រូប មកចូលរួមសិក្ខាសាលាធ្វើជាអ្នកសម្រុះសម្រួល និងជាវាគ្មិនបន្ថែមចំណែកក្នុងដំណើរការធ្វើរបាយការណ៍បញ្ចប់<br>**សមាជិក បានចូលរួមក្នុងសិក្ខាសាលាថ្នាក់មូលដ្ឋាន និងវេទិកាជាតិមាន :**<br>- ឯ.ឧ. សួង លាង ហៃ អនុប្រធានអង្គភាពគ្រប់គ្រងគម្រោង<br>- លោក. ប៉ែន ប៊ុនណា អនុប្រធានអង្គភាពគ្រប់គ្រងគម្រោង<br>- លោក បួន សុមុន្នី<br>- លោក ជឹង ផេងស្រួយ<br>- លោក ឆុង ហួត<br>- លោក គង់ ផល្លៈ<br>- កញ្ញា ហួង សុកុល<br>- លោក ឆៃ លី<br>- លោក ឃ្លោក ដារ៉ា<br>- លោក កួយ សៅ |

| ស្ថាប័នផ្សេងៗទៀត | ការចូលរួម |
|---|---|
| **Indochina Research Ltd (IRL)** | IRL បានធ្វើការសិក្សាស្ទង់មតិ នៅខេត្តចំនួន ៤ ខេត្ត<br>- Stefano Magistretti, IRL<br>- Ingrid Fitzgerald, នាយកគម្រោង , IRL<br>បុគ្គលិក និងក្រុមសិក្សាស្រាវជ្រាវ អង្គការ UNDP បានតាមដានត្រួតពិនិត្យមើលការសិក្សានេះ |
| អង្គការអ្នកសម្រប សម្រួលសិក្ខាសាលា | - លោក ប៉ែន ស៊ី អង្គការ វីជីខ្សែន ខេត្តមណ្ឌលគិរី<br>- លោក អាន គិន សមាគមអាដហុក ខេត្តកំពង់ស្ពឺ |
| អាជ្ញាធរមូលដ្ឋាន ចៅក្រម មន្ត្រីរដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាល | រវាង ចៅក្រម ព្រះរាជអាជ្ញា អភិបាលខេត្ត អភិបាលស្រុក ក្រុមប្រឹក្សាឃុំ ប្រធានភូមិ មន្ត្រីគណៈកម្មការសុរិយោដី អ្នកសម្រុះសម្រួល អាជ្ញាកណ្តាល និងអង្គការក្រៅរដ្ឋាភិបាល បានធ្វើសហប្រតិបត្តិការជាមួយគ្នា ហើយនិងចូលរួមក្នុងសិក្ខាសាលាថ្នាក់មូលដ្ឋាន និងសកម្មភាពសិក្សាស្រាវជ្រាវផ្សេងៗទៀត ។ |
| អង្គការជាតិ និងអន្តរជាតិ | អង្គការជាច្រើនបានសហការ និងរួមចំណែកតាមបែបផ្សេងៗគ្នាក្នុងការរៀបចំវេទិកាជាតិ និងគម្រោងសិក្សាស្រាវជ្រាវនេះជាទូទៅ ។ |

## ៣.៣. សកម្មភាព និងលទ្ធផលជាចម្បងៗ

| សកម្មភាព | លទ្ធផល | អ្នកទទួលបន្ទុក | កាលបរិច្ឆេទ |
|---|---|---|---|
| **ការរៀបចំ គម្រោងនៃការសិក្សា** | | | |
| សរសេរលក្ខខណ្ឌការងារ (TOR) | | - បុគ្គលិក UNDP | |
| សិក្សាឯកសារមានស្រាប់ កំណត់កាលវិភាគ គម្រោងឧបករណ៍ត្រូវប្រើប្រាស់សេចក្តីណែនាំអំពីការសិក្សា | ១. គម្រោងនៃការសិក្សា (២ ច្បាប់)<br>២. ក្របខ័ណ្ឌច្បាប់<br>៣. ឧបករណ៍ ឯកសារសម្រាប់ទស្សនកិច្ចសិក្សា វិភាគ និងការស្ទង់មតិ<br>៤. សេចក្តីណែនាំអំពីសិក្ខាសាលា | - ទីប្រឹក្សាអន្តរជាតិ | ឧសភា-មិថុនា ២០០៤ |
| **សិក្សាឯកសារ ដែលមានស្រាប់** | | | |

| | | | |
|---|---|---|---|
| សិក្សាឯកសារដែលមានស្រាប់ជាជំនួយបន្ថែម | ១. សិក្សាពីក្របខ័ណ្ឌច្បាប់ដែលមានស្រាប់<br>២. សិក្សាប្រមូលទិន្នន័យទូទៅរបស់កម្ពុជា<br>៣. តារាងស្តីពីរចនាសម្ព័ន្ធតុលាការ គណៈកម្មការសុរិយោដី និងក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ ។ | ទីប្រឹក្សាជាតិ | កញ្ញា ២០០៤ |
| **ការស្ទាបស្ទង់មតិ** | | | |
| ដំណើរការជ្រើសរើស | សរសេរលក្ខខណ្ឌការងារ | បុគ្គលិក UNDP | កក្កដា ២០០៤ |
| ដំណាក់កាលរៀបចំគម្រោងនៃការសិក្សាស្រាវជ្រាវ | រៀបចំតារាងសំណួរសម្រាប់ក្រុមគោលដៅ ចំនួន៥ :<br>១. មន្ត្រី ឬ អាជ្ញាធរ<br>២. មន្ត្រីបម្រើការងារក្នុងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) និង អ្នកប្រើប្រាស់ ADR<br>៣. អាជ្ញាធរមូលដ្ឋាន<br>៤. ស្ត្រី<br>៥. ជនជាតិភាគតិច | - IRL<br>- យោបល់ពីបុគ្គលិក UNDP និងក្រុមសិក្សាស្រាវជ្រាវ | សីហា - តុលា ២០០៤ |
| ទស្សនកិច្ចសិក្សា | ចុះស្ទង់មតិនៅខេត្តចំនួន៤ : កំពង់ឆ្នាំង មណ្ឌលគិរី កំពង់ស្ពឺ និងរតនៈគិរី | IRL | វិច្ឆិកា - ធ្នូ ២០០៤ |
| របាយការណ៍បឋម | បង្ហាញនៅក្នុងវេទិកាជាតិ ដោយមានការ បញ្ចាំងស្លាយ (Power Point) | IRL | ធ្នូ ២០០៤ |
| របាយការណ៍បញ្ចប់ | - ជាភាសាអង់គ្លេស<br>- ជាភាសាខ្មែរ | IRL | មេសា ២០០៥<br>ឧសភា ២០០៥ |
| **ធ្វើទស្សនកិច្ចសិក្សា និងការពិសោធន៍** | | | |
| ទស្សនកិច្ចសិក្សា និងរៀបចំ សិក្ខាសាលានៅបីខេត្តផ្សេងៗ ពីគ្នា | របាយការណ៍ទស្សនកិច្ចសិក្សា ៣ ច្បាប់<br>- របាយការណ៍ខេត្តកំពង់ឆ្នាំង<br>- របាយការណ៍ខេត្តមណ្ឌលគិរី<br>- របាយការណ៍ខេត្តកំពង់ស្ពឺ<br>សម្ភាសជាមួយអាជ្ញាធរ និងអង្គការនានាប្រមាណជាង ៥០ នាក់ | ទីប្រឹក្សាជាតិ និងជំនួយការការសិក្សាស្រាវជ្រាវនៅតាមខេត្ត | តុលា - វិច្ឆិកា ២០០៤ |

| | | | |
|---|---|---|---|
| ទស្សនកិច្ចសិក្សាបន្ថែមនៅខេត្តដទៃទៀត ព្រមទាំងចុះសង្កេតមើល និងដកពិសោធន៍ការដោះស្រាយវិវាទនៅមូលដ្ឋាន | - ទស្សនកិច្ចសិក្សានៅខេត្តកំពង់ឆ្នាំង ខេត្តមណ្ឌលគិរី និងខេត្តកំពង់ស្ពឺ<br>- ទស្សនកិច្ចសិក្សានៅខេត្តសៀមរាប<br>- ទស្សនកិច្ចសិក្សានៅខេត្តកំពង់ធំ<br>- ដើម្បីស្វែងយល់អំពីសម្រុះសម្រួល វិវាទនៅថ្នាក់ឃុំ ដែលគាំទ្រដោយមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ។<br>- ថតចម្លងនូវសៀវភៅឯកសារទិន្នន័យ ស្តីពីកំណត់ហេតុ និងកិច្ចព្រមព្រៀងរវាងភាគីវិវាទនៅថ្នាក់ភូមិ ឃុំ និងស្រុក | ក្រុមសិក្សាស្រាវជ្រាវ | វិច្ឆិកា-ធ្នូ ២០០៤ |
| ករណីសិក្សាពិនិត្យមើលការដោះស្រាយវិវាទជាក់ស្តែងនៅខេត្តចំនួន ៥ | - ទស្សនកិច្ចសិក្សានៅគម្រោងរបស់អង្គការព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ នៅខេត្តបន្ទាយមានជ័យ និងឧត្តរមានជ័យ<br>- របាយការស្តីពីការអង្កេតមើលរឿងក្តីចំនួន ៧ នៅខេត្តចំនួន៥: កំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ បន្ទាយមានជ័យ និងឧត្តរមានជ័យ និងភ្នំពេញ | ទីប្រឹក្សាជាតិ និងជំនួយការការសិក្សាស្រាវជ្រាវ ព្រមទាំងសមាជិកអង្គភាពគ្រប់គ្រងគម្រោង | មករា -មីនា ២០០៥ |
| ទស្សនកិច្ចសិក្សាបន្ថែមដើម្បីមើលពីស្ថានភាព និងបញ្ហាជាក់ស្តែងរបស់ជនជាតិដើមភាគតិច | - ទស្សនកិច្ចសិក្សាផ្ទាល់នៅសហគមន៍ បងប្អូនជនជាតិដើមភាគតិច ADR និងតុលាការ ក្នុងខេត្តរតនៈគិរី | ក្រុមសិក្សាស្រាវជ្រាវ និងសមាជិកអង្គភាពគ្រប់គ្រងគម្រោង | ឧសភា ២០០៥ |
| **បទសម្ភាសន៍** | | | |
| បទសម្ភាសន៍ជាលម្អិត | សម្ភាសនៅខេត្តចំនួន ៨<br>សម្ភាសជាមួយអាជ្ញាធរគ្រប់ថ្នាក់ និងតំណាងអង្គការគ្រប់ស្រទាប់ប្រមាណជា ១៥០ នាក់ ។ | ក្រុមសិក្សាស្រាវជ្រាវ និងអ្នកបកប្រែ | កញ្ញា ២០០៤ ដល់ ឧសភា ២០០៥ |
| **សិក្ខាសាលា និងការពិគ្រោះយោបល់** | | | |
| ថ្នាក់មូលដ្ឋាន ៣ នៅ<br>- កំពង់ឆ្នាំង<br>-មណ្ឌលគិរី<br>-កំពង់ស្ពឺ | ឯកសារដែលបានចែកជូនដល់សមាជិក សមាជិកានៃអង្គសិក្ខាសាលា មាន :<br>- របៀបវារៈ<br>- គំរបទំព័រមុខ និងមាតិកាឯកសារ<br>- សេចក្តីណែនាំសម្រាប់ក្រុមពិភាក្សា<br>- សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល | ក្រុមសិក្សាស្រាវជ្រាវ ព្រមទាំង សមាជិកអង្គភាពគ្រប់គ្រងគម្រោង និងក្រសួងយុត្តិធម៌ | ថ្ងៃ ១០-២២ ខែធ្នូ ២០០៤ |

| | | | |
|---|---|---|---|
| វេទិកាជាតិ ១<br>ធ្វើឡើងនៅ ភ្នំពេញ | - ឯកសារទាក់ទងនឹង៥ប្រធានបទ (៥)<br>- បទបង្ហាញជាស្លាយ (៥)<br>- តារាងចុះឈ្មោះ (២ ទម្រង់)<br>- បទឧទ្ទេសនាម<br>- ឯកសារសម្រាប់ពិភាក្សាជាសង្ខេប អំពីការសិក្សាស្រាវជ្រាវសមាជិកសមាជិកាទាំងអស់ចំនួន ៣៨០ នាក់ | ក្រុមសិក្សាស្រាវជ្រាវ ព្រមទាំង បុគ្គលិក UNDP សមាជិក CLJR ក្រសួងយុត្តិធម៌ និង អ្នកពាក់ព័ន្ធ | ទី ១៦-១៧ ខែធ្នូ ២០០៤ |
| **ចងក្រងទិន្នន័យ** | | | |
| សិក្ខាសាលា | សេចក្តីណែនាំសម្រាប់ការចងក្រងឯកសារ និងលទ្ធផលសិក្ខាសាលា និងវេទិកាជាតិ | ទីប្រឹក្សាអន្តរជាតិ | វិច្ឆិកា ២០០៤ |
| | សង្ខេបលទ្ធផលទទួលបានពីសិក្ខាសាលាថ្នាក់មូលដ្ឋានទាំងបីខេត្ត | ក្រុមសិក្សាស្រាវជ្រាវ | ធ្នូ ២០០៤ |
| | ចងក្រងឯកសារសិក្ខាសាលាថ្នាក់មូលដ្ឋាន និងវេទិកាជាតិជាភាសាខ្មែរ និងបកប្រែជាភាសាអង់គ្លេស | ក្រុមសិក្សាស្រាវជ្រាវ និង អ្នកបកប្រែ | មករា ២០០៥ |
| បកប្រែឯកសារ | បកប្រែឯកសារចំនួន ៧០ ច្បាប់ប្រមូលបានពីខេត្តនានា (ទាក់ទងនឹងពាក្យបណ្តឹង របាយការណ៍តុលាការ និងកំណត់ហេតុសម្រុះសម្រួល) ពីភាសាខ្មែរទៅជាភាសាអង់គ្លេស | អ្នកបកប្រែ/ជំនួយការការសិក្សាស្រាវជ្រាវ | មករា -មីនា ២០០៥ |
| ចម្លង / វាយ កំណត់ហេតុបទសម្ភាសន៍ | បទសម្ភាសន៍ចំនួន ៣១ លើក (ជាមួយអ្នកត្រូវសម្ភាសចំនួន ៧០នាក់) ត្រូវបានចងក្រង និងសរសេរទាំងស្រុងជាភាសាខ្មែរ និងអង់គ្លេស | អ្នកបកប្រែ/ជំនួយការការសិក្សាស្រាវជ្រាវ | មករា-មីនា ២០០៥ |
| ចងក្រង និង រៀបជាប្រព័ន្ធ នូវសម្រង់ឯកសារស្តីពីការដោះស្រាយ វិវាទ | ចងក្រង និងបែងចែករឿងក្តីនៅក្នុង សៀវភៅចុះបញ្ជីរឿងក្តីរបស់ឃុំ តាមប្រភេទនៃសាច់រឿង ដោយគិតជាភាគរយនៃរឿងក្តីផ្សេងៗនៅក្នុងឆ្នាំ ក៏ដូចឯកសារពាក្យបណ្តឹង និងកំណត់ហេតុសម្រុះសម្រួលដទៃៗទៀត | ទីប្រឹក្សាជាតិ និង អ្នកបកប្រែ/ជំនួយការការសិក្សាស្រាវជ្រាវ | មេសា ២០០៥ |
| សម្រង់ទិន្នន័យស្ថិតិ និងសិក្សាពីច្បាប់ដែលពាក់ព័ន្ធ | - ស្ថិតិតុលាការ និងអ្នកជាប់ពន្ធនាគារ<br>- ស្ថិតិរបស់គណៈកម្មការសុរិយោដី<br>- ស្ថិតិរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ<br>- សិក្សាពីបទបញ្ញត្តិច្បាប់ពាក់ព័ន្ធ | ទីប្រឹក្សាជាតិ | មេសា-ឧសភា ២០០៥ |

| | | | |
|---|---|---|---|
| សម្រង់ទិន្នន័យទូទៅរបស់កម្ពុជា | - ទិន្នន័យទូទៅស្តីពីភាពក្រីក្រ ស្ថានភាពស្ត្រី និងជនជាតិដើមភាគតិចនៅកម្ពុជា | ទីប្រឹក្សាជាតិ និងអ្នកបកប្រែ/ជំនួយការការសិក្សាស្រាវជ្រាវ | មេសា-ឧសភា ២០០៥ |
| **សរសេររបាយការណ៍បញ្ចប់** | | | |
| របាយការណ៍បឋម | - សេចក្តីព្រាងរបាយការណ៍បឋមលើកទី១<br>- សេចក្តីព្រាងរបាយការណ៍បឋមលើកទី២ | ទីប្រឹក្សាអន្តរជាតិ | ធ្នូ ២០០៤<br>មករា ២០០៥ |
| កែសម្រួលរបាយការណ៍បឋម | កែសម្រួលរបាយការណ៍បឋម | ក្រុមសិក្សាស្រាវជ្រាវ | មេសា ២០០៥ |
| សរសេររបាយការណ៍បញ្ចប់ | - រៀបចំប្លង់សម្រាប់របាយការណ៍បញ្ចប់<br>- សេចក្តីព្រាងជំពូកនីមួយៗ របាយការណ៍បញ្ចប់ | ក្រុមសិក្សាស្រាវជ្រាវ | មេសា-មិថុនា ២០០៥ |
| កែសម្រួលរបាយការណ៍បញ្ចប់ជាមួយដៃគូរដ្ឋាភិបាល | កែសម្រួលរបាយការណ៍បឋម និងកែសម្រួលជំពូកនីមួយៗនៃរបាយការណ៍បញ្ចប់ជាមួយដៃគូ | - UNDP<br>- ក្រសួងយុត្តិធម៌<br>- សមាជិកអង្គភាពគ្រប់គ្រងគម្រោងនៃ CIJR/ប្រព័ន្ធយុត្តិធម៌ | មេសា -មិថុនា ២០០៥ |
| សុពលភាពរបាយការណ៍បញ្ចប់ | កិច្ចប្រជុំដើម្បីធ្វើសុពលភាពរបាយការណ៍បញ្ចប់ | អ្នកពាក់ព័ន្ធ | មិថុនា ២០០៥ |
| របាយការណ៍បញ្ចប់ចុងក្រោយ | - កែសម្រួលរបាយការណ៍បញ្ចប់<br>- បោះពុម្ព និងប្រគល់របាយការណ៍បញ្ចប់ | - UNDP និងក្រុមសិក្សាស្រាវជ្រាវ | កក្កដា ២០០៥ |
| **សកម្មភាពផ្សេងៗទៀត** | | | |
| - ការងាររដ្ឋបាល<br>- ចូលរួមប្រជុំ ឬ សិក្ខាសាលា | កែសម្រួលរបាយការណ៍ចំនួន ៧ដង<br>របាយការណ៍រដ្ឋបាលចំនួន ៥<br>ចែកចាយឯកសារ<br>ចូលរួមប្រជុំ និងសិក្ខាសាលា | - ទីប្រឹក្សាអន្តរជាតិ<br>- ក្រុមសិក្សាស្រាវជ្រាវ | មិថុនា ២០០៤<br>មិថុនា ២០០៥ |

ទិន្នន័យរួមនៃសិក្ខាសាលានៅថ្នាក់មូលដ្ឋាន និងវេទិកាជាតិ

| សិក្ខាសាលា - ទីតាំង | កាលបរិច្ឆេទ | ប្រុស | ស្រី | សរុប |
|---|---|---|---|---|
| ខេត្តកំពង់ឆ្នាំង | ១០-១១ វិច្ឆិកា ឆ្នាំ ២០០៤ | ៣៤ | ១៦ | ៥០ |
| ខេត្តមណ្ឌលគិរី | ១៦-១៧ វិច្ឆិកា ឆ្នាំ ២០០៤ | ៤៨ | ១៩ | ៦៧ |
| ខេត្តកំពង់ស្ពឺ | ២២-២៣ វិច្ឆិកា ឆ្នាំ ២០០៤ | ៤១ | ២៤ | ៦៥ |
| *អ្នករៀបចំសិក្ខាសាលានៅថ្នាក់មូលដ្ឋាន* | | ១៥ | ៥ | ២០ |
| វេទិកាជាតិ-ភ្នំពេញ | ១៦-១៧ ធ្នូ ឆ្នាំ ២០០៤ | ១៤២ | ៣៦ | ១៧៨ |
| **សរុប** | | **២៨០** | **១០០** | **៣៨០** |
| ប្រជុំផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍បញ្ចប់ - ភ្នំពេញ | ២៣ មិថុនា ឆ្នាំ ២០០៥ | | | **១៣៥** |
| **សរុបទាំងអស់** | | | | **៥១៥** [៦៦] |

## ៤. ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះរាប់បញ្ចូលទាំងព័ត៌មានទាំងឡាយ ដែលប្រមូលបានផ្ទាល់ពីទស្សនកិច្ចសិក្សានៅខេត្តចំនួន ៨ នៃព្រះរាជាណាចក្រកម្ពុជា ដូច្នេះការសិក្សានេះមិនមានបំណងឆ្លុះបញ្ចាំងអំពីស្ថានភាពជាក់ស្តែងនៅទូទាំងព្រះរាជាណាចក្រកម្ពុជានោះទេ។ ព័ត៌មានខ្លះគ្របដណ្តប់ស្ថានភាពទូទាំងប្រទេស ដូចជាព័ត៌មានស្តីពី ស្ថិតិតុលាការ អយ្យការ គណៈកម្មការសុរិយោដី និងក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារជាដើម។ ចំពោះព័ត៌មានទាក់ទងនឹងក្រុមប្រឹក្សាឃុំ ប្រធានភូមិ គឺសំដៅតែទៅលើក្រុមប្រឹក្សាឃុំ ឬប្រធានភូមិ ទាំងឡាយណាដែលក្រុមការងារបានចុះទៅសម្ភាស ឬបានចុះទៅដល់ប៉ុណ្ណោះ។ អ្វីដែលរបាយការណ៍សិក្សានេះឆ្លុះបញ្ចាំងសំខាន់នោះ គឺទាក់ទងនឹងអ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិចដែលរស់នៅជនបទដាច់ស្រយាល។ ការសិក្សានេះ មិនបានរាប់បញ្ចូលដំណើរការដោះស្រាយវិវាទ នៅក្នុងទីក្រុងឡើយ។

ការសិក្សាស្រាវជ្រាវនេះប្រើប្រាស់ទ្រឹស្តីជាតិពន្ធុសាស្ត្រ តែវាខ្លួនឯងមិនមែនជាជាតិពន្ធុសាស្ត្រឡើយ។ ការធ្វើទស្សនកិច្ចសិក្សា និងការប្រើប្រាស់ឧបករណ៍ផ្សេងៗគ្នាក្នុងការសិក្សា បានឆ្លុះបញ្ចាំងអំពីកម្រិតនៃបរិមាណ និងភាពស៊ីជម្រៅខុសគ្នាដែរ។ ការស្ទង់មតិត្រូវបានធ្វើឡើងនៅខេត្តចំនួន ៤ ។ សិក្ខាសាលាថ្នាក់មូលដ្ឋានត្រូវបាន រៀបចំឡើងនៅខេត្តចំនួន ៣ បន្ទាប់មកមានវេទិកាជាតិមួយ ត្រូវបានធ្វើឡើងនៅរាជធានីភ្នំពេញ។ ក្រុមការងារបានប្រើពេល ៣ សប្តាហ៍ក្នុងការធ្វើទស្សនកិច្ចសិក្សានៅក្នុងខេត្តនីមួយៗនៃខេត្តទាំងបី។ រីឯនៅខេត្ត ៣ ផ្សេងទៀត ក្រុមការងារបានចំណាយពេលអស់តែ ១ សប្តាហ៍ប៉ុណ្ណោះ។ លើសពីនេះទៀត ក្រុមការងារក៏បានធ្វើទស្សនកិច្ចសិក្សារយៈពេលខ្លីចំនួន ៤ ថ្ងៃ ទៅកាន់ខេត្តចំនួន ២ ទៀត។ ការសិក្សាវិភាគ

---

៦៦ ចំនួនអ្នកចូលរួមទាំងអស់ (ទាំងសិក្ខាសាលានៅមូលដ្ឋាន និងថ្នាក់ជាតិ) គឺមានចំនួន ៤០១ នាក់។ ក្នុងចំណោមអ្នកទាំងនោះ មានអ្នកខ្លះ បានចូលរួមច្រើនជាងមួយលើក ដែលនាំឱ្យចំនួនសរុបទាំងអស់អាចដល់ ៥១៥ នាក់។ សូមមើលឧបសម្ព័ន្ធទី៤: តារាងអ្នកចូលរួមសិក្ខាសាលានានា។

លើករណីរឿងក្តី និងការសង្កេតមើល ដំណើរការដោះស្រាយវិវាទត្រូវបានធ្វើឡើងនៅខេត្តចំនួន ៧។ ក្រុមការងារសិក្សាស្រាវជ្រាវ និងសមាជិកខ្លះមកពីអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ បានចុះទៅសង្កេតមើលដំណើរការដោះស្រាយវិវាទដែលធ្វើឡើងដោយអាជ្ញាធរនិងស្ថាប័នផ្សេងៗ ( ក្រុមប្រឹក្សាឃុំ និងគណៈកម្មការដោះស្រាយវិវាទនានានៅថ្នាក់ឃុំ ដោយគណៈកម្មការសុរិយោដី ដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ និងដោយតុលាការទាំងរឿងក្តីរដ្ឋប្បវេណី និងព្រហ្មទណ្ឌ) និងគ្រប់លំដាប់ថ្នាក់ (ពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ) តែករណីទាំងនេះគ្រាន់តែជាឧទាហរណ៍តូចខ្លះៗ សម្រាប់ជាគំនិតដល់យើងស្តីពីការដោះស្រាយទំនាស់ ដែលបានអនុវត្តជាក់ស្តែងតែប៉ុណ្ណោះ។ តែយើងខ្ញុំមិនមានឱកាសសង្កេតមើលដំណើរការសម្រុះសម្រួលរឿងក្តី ឱ្យបានច្រើននៅអាជ្ញាធរ ឬស្ថាប័នថ្នាក់ដូចៗគ្នាដើម្បីប្រៀបធៀបឡើយ។ ហើយយើងខ្ញុំក៏មិនបានសង្កេតមើលដំណើរការសម្រុះសម្រួលនៅចំពោះមុខនគរបាល និងអភិបាលស្រុកដែរ។ ក្រុមការងារសិក្សាស្រាវជ្រាវបានប្រមូល និងចងក្រងទិន្នន័យរឿងក្តី ដែលបានចុះបញ្ជីក្នុងសៀវភៅកំណត់ហេតុរឿងក្តីនៅថ្នាក់ឃុំនៃខេត្តចំនួន ៤។ ដូច្នេះការបញ្ចេញមតិយោបល់របស់យើងខ្ញុំ ទាក់ទងនឹងដំណើរការសម្រុះសម្រួលវិវាទនានា ឆ្លុះបញ្ចាំងតែទៅលើការអនុវត្តដែលបានសង្កេតមើល និងកស្តុតាងដែលប្រមូលបានភាគច្រើនបំផុត ពីឃុំទាំងនោះតែប៉ុណ្ណោះ។ ក្រុមការងារយើងខ្ញុំបានដឹងដែរថា ឯកសារស្តីពីដំណើរការសម្រុះសម្រួល ដែលប្រមូលបានមកនេះគ្រាន់តែឆ្លុះបញ្ចាំងនូវរឿងក្តីមួយចំនួន ហើយគ្រាន់តែបង្ហាញនូវផ្នែកខ្លះនៃការពិតតែប៉ុណ្ណោះ។ ទស្សនកិច្ចសិក្សានិងការសម្ភាសន៍ត្រូវបានធ្វើឡើងដោយស៊ីជម្រៅនៅខេត្តចំនួន ៨។ ទស្សនកិច្ចសិក្សានេះបានបូកបញ្ចូលទាំងការធ្វើសម្ភាសន៍ជាមួយចៅក្រម ព្រះរាជអាជ្ញា ប្រធានពន្ធនាគារ អភិបាលស្រុក អភិបាលខេត្ត មន្ត្រីបម្រើការងារក្នុងគណៈកម្មការសុរិយោដី នគរបាលថ្នាក់ឃុំ នគរបាលថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងជាមួយសហគមន៍ និងអាជ្ញាធរជនជាតិដើមភាគតិចផងដែរ។ លើសពីនេះទៀត ក្រុមការងារក៏បានសម្ភាសផងដែរជាមួយប្រជាពលរដ្ឋដែលធ្លាប់ប្រើប្រាស់ប្រព័ន្ធនានាដើម្បីដោះស្រាយវិវាទ ដូចជា អ្នកជាប់ពន្ធនាគារ សកម្មជននិងមេធាវីអង្គការក្រៅរដ្ឋាភិបាល និងជនរងគ្រោះជាដើម។ ប៉ុន្តែក្រុមការងារសិក្សាស្រាវជ្រាវមិនបានសង្កេតមើលដំណើរការធ្វើការងារប្រចាំថ្ងៃរបស់អាជ្ញាធរ ឬស្ថាប័នទាំងនោះឡើយ។

វិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងការសិក្សានេះ អាចឱ្យយើងដឹងថាតើអ្វីខ្លះ ដែលនាំឱ្យមានតម្រូវការយុត្តិធម៌នៅក្នុងសង្គមបន្ថែមលើវិវាទ ឬជម្លោះជាក់ស្តែងដែលប្រជាពលរដ្ឋប្រឈមរាល់ថ្ងៃ។ នេះគឺជាកត្តាមួយដ៏សំខាន់។ ទោះជាយ៉ាងនេះក្តី ការសិក្សារយៈពេលវែងពិតជាមានប្រយោជន៍ច្រើន ដើម្បីវិភាគពីយុត្តិកម្មតាមផ្លូវសីលធម៌ និងតម្លៃវប្បធម៌ ទាក់ទិននឹងកិច្ចការយុត្តិធម៌នៅក្នុងចំណោមក្រុមគោលដៅដូចជា ( ស្ត្រី/បុរស មនុស្សពេញវ័យ/យុវជន ។ល។) ជាតិសាសន៍ និងសាសនាផ្សេងៗគ្នា។ ដើម្បីធ្វើដូចនោះ គឺទាមទារឱ្យមានការសិក្សាស៊ីជម្រៅពីបញ្ហាភាសានិងវប្បធម៌ ដើម្បីឱ្យយល់តម្លៃវប្បធម៌ និងយុត្តិកម្មខាងផ្លូវសីលធម៌ ដែលជាសក្តានុពលនៃការតវ៉ារបស់ក្រុមគោលដៅ។ ការសិក្សាបែបនេះក៏ចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃការអន្តរាគមន៍រយៈពេលវែង នៅលើការពិភាក្សាគ្នាជាអន្តរវប្បធម៌ទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ អំពើពុករលួយ ហិង្សាបង្កដោយក្រុមបងធំ និងបញ្ហាដទៃៗទៀត។

ទាក់ទងនឹងសហគមន៍ជនជាតិដើមភាគតិច ការសិក្សានេះបានជ្រើសរើសយកខេត្ត ដែលមានជនជាតិដើមភាគតិចច្រើនជាងគេ នៅព្រះរាជាណាចក្រកម្ពុជា គឺខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី ដើម្បីធ្វើទស្សនកិច្ចសិក្សាស្វែងយល់ តែក្នុងចំណោមខេត្តដែលមានជនជាតិដើមភាគតិចនេះ មានតែខេត្តមួយប៉ុណ្ណោះ ( មណ្ឌលគិរី) ដែលយើងខ្ញុំបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់នៅថ្នាក់មូលដ្ឋាន។ នៅខេត្តមួយផ្សេងទៀត ក្រុមការងារបានសម្ភាសជាមួយសហគមន៍ជនជាតិដើមភាគតិច ដែលបានរងការរំលោភបំពានយកដីធ្លីពីអ្នកខាងក្រៅ ព្រមទាំងសម្ភាសជាមួយអាជ្ញាធរថ្នាក់ខេត្តនានាផងដែរ។ នៅក្នុងខេត្តទាំងពីរនេះ

ក្រុមការងារបានសម្ភាសស៊ីជម្រៅជាមួយអាជ្ញាធរ និងសមាជិកសហគមន៍ជនជាតិដើមភាគតិច ដែលធ្លាប់ជាភាគីប្រើប្រាស់យន្តការដោះស្រាយវិវាទ។ ទោះយ៉ាងនេះក្តី យើងពុំមានឱកាសដើម្បីសង្កេតមើលដំណើរការសម្រុះសម្រួលវិវាទនៅក្នុងខេត្តទាំងពីរនេះទេ។ IRL បានធ្វើការស្ទង់មតិនៅខេត្តមណ្ឌលគីរី ដែលនៅទីនោះ IRL បានសម្ភាសជាមួយជនជាតិដើមភាគតិច ក៏ដូចជាសមាជិកជនជាតិភាគតិច (ជាពិសេសវៀតណាម) ដូចនេះហើយលទ្ធផលទទួលបាន គឺសំដៅលើក្រុមទាំងពីរនេះផងដែរ។ ទាក់ទងនឹងជនជាតិដើមភាគតិច ក្រុមការងារយើងខ្ញុំបានមានឱកាសចូលរួមសិក្ខាសាលាមួយ រៀបចំដោយអង្គការ ILO ដែលក្នុងនោះជនជាតិដើមភាគតិច បានលើកឡើងនូវតម្រូវការរបស់ពួកគេ (សិក្ខាសាលាពិគ្រោះយោបល់រៀបចំដោយ ILO នៅថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០០៥ និងសិក្ខាសាលាស្តីពីសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍ជនជាតិដើមភាគតិច នៅថ្ងៃទី១០-១១ ខែកក្កដា ឆ្នាំ២០០៥) តែយើងគិតថាការសិក្សានៅពេលខាងមុខដ៏សំខាន់ ត្រូវតែធ្វើឡើង ដោយរួមបញ្ចូលនូវការស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រស្តីពីច្បាប់សម្រាប់ជនជាតិដើមភាគតិច និងជាដំណើរការពិគ្រោះយោបល់ ដើម្បីស្វែងរកវិធីសាស្ត្រល្អសម្រាប់រៀបចំបទបញ្ញត្តិ អំពីយន្តការដោះស្រាយវិវាទនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ឱ្យទៅជាប្រព័ន្ធយុត្តិធម៌ របស់ជាតិ ។

ចំពោះបញ្ហាស្ត្រីវិញ ពួកគេក៏ត្រូវបានអញ្ជើញឱ្យចូលរួម ក្នុងសិក្ខាសាលាពិគ្រោះយោបល់ផងដែរ ហើយពួកគេបានលើកឡើងនូវបញ្ហាជាក់ស្តែងទាំងឡាយ ដែលពួកគេជួបប្រទះ។ ស្ត្រីក៏ជាក្រុមគោលដៅក្នុងការស្ទង់មតិ ដែលធ្វើឡើងដោយ IRL ដែរ។ យើងខ្ញុំក៏បានសម្ភាសជាមួយអង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការងារពាក់ព័ន្ធនឹងសិទ្ធិស្ត្រីដែរ។ ការសិក្សាស្រាវជ្រាវនេះភាគច្រើនសំដៅលើស្ថានភាពស្ត្រីនៅជនបទ មិននៅទីក្រុងទេ។

សំណូមពរនិងអនុសាសន៍ជាច្រើន ដែលបានលើកឡើងទៅក្នុងរបាយការណ៍សិក្សាស្រាវជ្រាវនេះ ឆ្លុះបញ្ចាំងនូវរាល់សំណូមពរ និងអនុសាសន៍ទាំងឡាយ ដែលបានលើកឡើងនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ និងសិក្ខាសាលាធ្វើសុពលភាពជាមួយដៃគូ អ្នកពាក់ព័ន្ធ និងអ្នកដែលក្រុមការងារបានសម្ភាសជាមួយ។ ជាសរុបគឺមានតំណាងប្រជាពលរដ្ឋមកពីខេត្តក្រុងចំនួន ១១ (ក្នុងចំណោមខេត្តក្រុងទាំង ២៤) បានចូលរួមនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ និងសិក្ខាសាលាផ្តល់សុពលភាពលើរបាយការណ៍នេះ។